# វេស្សន្តរជាតក



នេះកាលសក្កទេវរាជទ្រង់កាឡាខ្លួនជាព្រាហ្មណ៍
មកបំពេញទានបារមីថ្វាយព្រះវេស្សន្តរ

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**ភុល ផេង**

**ព.ស. ២៥៦៣**

# **វេស្សន្តរជាតកពិស្តារ**

## **អធិបតីក្នុងការរៀបរៀង**
## **បណ្ឌិត កុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោក* **លឹម ឈឿម**

*លោក* **ដុង សុភឿន**

*លោក* **ឌិញ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គឹមឈយន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហាន សុខេមន្ទ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាម៉ៀន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សារេន** *សមាជិក*

*សាស្ត្រាចារ្យ* **ឱត ឧន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **យឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ត** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*លោក* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ្ញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គឹមឈន់** *សមាជិក*

**សូមថ្វាយព្រះរាជកុសល**
**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**
**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**
**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

***បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***ទេសន្តរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីត: ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,
ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**កុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***វេស្សន្តរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយ ព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធ*

គ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុង អនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយអភិបាលថែរក្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ទ្រង់មានព្រះរាជ-សុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្ម យឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជ-ហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "***វេស្សន្តរជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុង លោកសូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្តេច**

*សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវីរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**គុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## បុព្វកថា

រឿងវេស្សន្តរនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធោវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលី ដូច្នេះជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ម្យ៉ាងវិញទៀតប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក **ឈឹម ស៊ុម** កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយឃើញថា មានសេចក្តីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ជួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្ទែង ចាត់ចែង រៀបចំបកប្រែ និង រៀបរៀងវេស្សន្តរជាតកនេះ

ម្តងទៀត ឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជាភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួនណាត ជោតញ្ញាណោ ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសាដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្តាំផ្គង់ខ្លះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើនដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅវេស្សន្តរ

*ជាតកពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត សូមឲ្យលោកអ្នកមានគុណទាំងនោះ បានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្តីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**គុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី១

### ពរ ១០ ប្រការរបស់ព្រះឥន្ទ្រ

ញាតិវង្សានុវង្សមិនថ្វាយបង្គំព្រះតថាគត.................................១

ព្រះពុទ្ធបិតាក្រាបទូលភាពអស្ចារ្យ..........................................៤

ស្តេចសញ្ជ័យ..............................................................................៧

## ជំពូកទី២

### សម្រស់ព្រៃហិមពាន្ត

ស្តេចសញ្ជ័យនិងព្រះនាងផុស្សតី..........................................១៨

កំណើតព្រះមហាសត្តនិងទេវបុត្រ៦០០០០អង្គ.....................១៩

មូលហេតុនាំឲ្យដាក់នាមវេស្សន្តរ..........................................២១

វេស្សន្តរគិតឲ្យអជ្ឈត្តិកទាន.................................................២៤

ដែនកាលិង្គៈរាំងស្ងួត..........................................................២៨

ព្រះវេស្សន្តរប្រទានដំរីមង្គល..............................................៣១

អ្នកនគរប្តឹងព្រះវេស្សន្តរ....................................................៣៥

ព្រះវេស្សន្តរផ្តាំនាងមទ្រី......................................................៤៧

ព្រះនាងមទ្រីសូមរួមដំណើរទៅព្រៃ.......................................៤៩

## ជំពូកទី៣

### ទានកណ្ឌវណ្ណនា

ផុស្សតីទេវីលួងលោមរាជបុត្រនិងសុណិសា..........................៥៥

ព្រះវេស្សន្តរឲ្យសត្តសតកមហាទាន.......................................៦៤

ព្រះបាទស្រីសញ្ជ័យអង្វរព្រះសុណិសា................................៧៣

ព្រះវេស្សន្តរចាកចេញពីរាជវាំង............................................៨០

## ជំពូកទី៤

### វនប្បវេសនកណ្ឌវណ្ណនា

ព្រះវេស្សន្តរយាងចូលព្រៃ ..................................................៨៦

ស្ដេចមាតុលនគរអញ្ជើញព្រះវេស្សន្តរឲ្យសោយរាជ្យ...........៨៨

ស្ដេចចេតៈបង្ហាញផ្លូវ.........................................................៩៥

ចេតបុត្រថ្នាំព្រៃ...................................................................៩៧

វិស្សកម្មទេវបុត្រនិម្មិតបណ្ណសាលា......................................៩៨

ក្សត្រិយ៍ទាំង ៤ សាងផ្នួស......................................................៩៩

ព្រះវេស្សន្តរនិងព្រះនាងមទ្រីសូមពរពីគ្នា...........................១០១

## ជំពូកទី៥

### ជូជកបព្វវណ្ណនា

តាជូជកកាច់បំណុលយកកូនក្រមុំ.....................................១០៣

ពួកស្ត្រីជេរប្រទេចនាងអមិត្តតាបនា...................................១០៨

នាងអមិត្តតាបនាជំរុញតាជូជករកខ្ញុំកំដរ............................១០៦

ឆ្កែដេញខាំតាជូជក..........................................................១១២

តាជូជកកុហកចេតបុត្រថាខ្លួនជារាជទូត............................១១៥

## ជំពូកទី៦

### ចូឡវនវណ្ណនា

ចេតបុត្តពណ៌នាសម្រស់ភ្នំគន្ធមាទន៍.................................១១៩

សម្រស់ធម្មជាតិក្បែរអាស្រម.............................................១២២

## ជំពូកទី៧

### មហាវនវណ្ណនា

ជូជកជួបអច្ចុតឥសី..........................................................១៣១

សោកណាភាពស្រះបោក្ខរណី........................................១៣៣

សោកណាភាពស្រះមុចលិន្ទ............................................១៣៦

## ជំពូកទី៨

### ការកបព្វវណ្ណនា

ព្រះនាងមទ្រីយល់សុបិនអាក្រក់.......................................១៤៤

តាជូជកបដិសេធសេចក្ដីស្នើរបស់ព្រះវេស្សន្តរ...................១៤៨

ជាលីនិងក្រឹស្នារត់ពួន......................................................១៥៥

ព្រះវេស្សន្តរកាត់ថ្លៃកូនដូចកាត់ថ្លៃគោ...............................១៥៨

ជាលីកុមារថាយក្សនិម្មិតខ្លួនជាព្រាហ្មណ៍.........................១៦១

ព្រះវេស្សន្តរញ័រខ្លួនដូចព្រះចន្ទក្នុងមាត់រាហូ......................១៦៦

ព្រះវេស្សន្តរវិះតែប្រហារជីវិតតាជូជក ..............................១៦៧

នាងក្រឹស្នាបួងសួងទេវតា...................................................១៧០

## ជំពូកទី៩

### មទ្ទីបព្វវណ្ណនា

ទេវតាប្រជុំការពារព្រះនាងមទ្រី........................................១៧៨

ព្រះនាងមទ្រីអង្វរសត្វទាំង ៣ ..........................................១៧៥

ព្រះនាងមទ្រីពិលាប........................................................១៧៩

ព្រះវេស្សន្តរធ្វើលេសមិនឆ្លើយ..........................................១៨៣

ព្រះនាងមទ្រីរត់រកបុត្រ....................................................១៨៥

ព្រះនាងមទ្រីសន្ទប់ទៀបបាទមូលព្រះវេស្សន្តរ..................១៩០

ព្រះវេស្សន្តររើតទ្រូងព្រះនាងមទ្រី........................................១៩២

## ជំពូកទី១០

### សក្កបព្វវណ្ណនា

សក្កទេវរាជប្លែងភេទជាព្រាហ្មណ៍.....................................១៩៧

ព្រះវេស្សន្តរប្រទានកុមារទាំងពីរឱ្យទៅជូជកព្រាហ្មណ៍..................២០០

## ជំពូកទី១១

### មហារាជបព្វវណ្ណនា

តាជូជកវង្វេងផ្លូវ............................................................២០៩

ស្តេចសញ្ជ័យលោះព្រះរាជនត្តា.......................................២១៣

ជាលីស្នើសូមព្រះអយ្យកោ...............................................២១៧

## ជំពូកទី១២

### ឆខត្តិយកម្មវណ្ណនា

ជំនួបរបស់ក្សត្រិយ៍ ៦ អង្គ.................................................២២៦

សក្កទេវរាជប្រោសក្សត្រិយ៍ទាំង ៦ អង្គ..............................២៣៥

## ជំពូកទី១៣

### នគរកណ្ឌវណ្ណនា

ព្រះវេស្សន្តរយាងចូលនគរវិញ ........................................២៣៧

ព្រះនាងមទ្រីជូនពរដល់រាជបុត្ររាជធីតា ..........................២៤០

តង្វាយថ្វាយព្រះនាងមទ្រី..................................................២៤១

ព្រះបាទសញ្ជ័យត្រាច់ប្រពាតព្រៃ......................................២៤៣

ព្រះវេស្សន្តរច្យុតទៅកើតនៅឋានតុសិត.............................២៤៥

សាស្តាប្រជុំជាតក.......................................................២៤៧

# ជំពូកទី ១
## ពរ ១០ ប្រការរបស់ព្រះឥន្ទ្រ

### និទានខាងដើម

ធម្មទេសនា ដែលមានពាក្យផ្ដើមថា "ផុស្សតី វរវណ្ណាភេ" ជាដើមនេះ គឺព្រះបរមសាស្ដាចារ្យបានសម្ដែងប្រារព្ធទៅនឹងភ្លៀងបោក្ខរព័ស[1] គ្រាកាលព្រះអង្គគង់នៅក្នុងវត្តនិគ្រោធារាម ក្បែរក្រុងកបិលពស្ដុ ។

មានដំណើររឿងតំណាលថា បន្ទាប់ពីព្រះអង្គសម្ដែងព្រះធម្មចក្កប្បវត្តនសូត្ររួចហើយ ព្រះសាស្ដាបានយាងតាមលំដាប់លំដោយទៅគង់នៅក្រុងរាជគ្រឹះ[2] អស់មួយហេមន្តរដូវ រួចក៏ស្ដេចយាងចេញពីក្រុងរាជគ្រឹះនោះ ឆ្ពោះទៅកាន់ក្រុងកបិលពស្ដុ[3] មួយអន្ទើដោយព្រះខីណា-

[1] (ន.) (បោក-ខៈរ៉ៈ ព័រ) (បោក្ខរ "ឈូក" + វស្ស "ភ្លៀង" > បោក្ខរវស្ស; បុក្ខរ + វស៌) ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក ។ ភ្លៀងនេះ បើអ្នកណាចង់ឲ្យទទឹកក៏ទទឹក, អ្នកដែលមិនចង់ឲ្យទទឹកទេ ភ្លៀងនោះក៏ពុំទទឹកឡើយ គឺគ្រាន់តែធ្លាក់មកត្រូវប៉ុន្តែរអិលជ្រុះដូចជាទឹកធ្លាក់លើស្លឹកឈូក, ហៅថា បោក្ខរព័ស ឬភ្លៀងបោក្ខរព័រ្ស ។

[2] ឈ្មោះរាជធានីមួយរបស់ដែនមគធៈក្នុងសម័យបុរាណ ។

[3] ឈ្មោះក្រុងកំណើតនៃព្រះសក្យមុនី ក្នុងដែនឥណ្ឌា ។

ស្រព[៤] ២០.០០០ អង្គជាបរិវារ ដោយមានព្រះឧទាយិត្ថេរជាមគ្គុទ្ទេសក៍ដំផ្ទើម ។ នេះជាពុទ្ធដំណើរទៅកាន់មាតុប្រទេស[៥]ជាលើកទី ១ របស់ព្រះសម្ពុទ្ធ បន្ទាប់ពីគ្រាដែលព្រះអង្គចេញសាងព្រះផ្នួសមក ។

គ្រានោះ សក្យរាជទាំងឡាយ គិតជំនុំគ្នាថាពួកព្រះអង្គប្រាកដជានឹងបានឃើញព្រះរាជបុត្រច្បងនៃព្រះញាតិរបស់ពួកព្រះអង្គ ហើយក៏បានប្រឹក្សាគ្នារកមើលអារាមណាមួយសក្តិសម[៦]សម្រាប់ថ្វាយព្រះមានព្រះភាគ ក៏កត់សម្គាល់ឃើញអារាមឈ្មោះសក្កនិគ្រោធថាជាទីរីករាយ ហើយបានរៀបចំចាត់ចែងសព្វគ្រប់ ត្រៀមថ្វាយព្រះមានព្រះភាគ ។ ក្នុងកិច្ចស្វាគមន៍ចំពោះការយាងមកនៃព្រះពុទ្ធអង្គ សក្យរាជទាំង - ឡាយ ឈរកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម រង់ចាំទទួលព្រះមានព្រះភាគ ប៉ុន្តែពួកព្រះអង្គអឹមអៀម[៧]ក្នុងការគោរព ម៉្លោះហើយ

---

[៤] ព្រះអរហន្តអ្នកអស់អាសវៈ គឺកិលេសជាគ្រឿងត្រាំក្នុងសន្តាន ។

[៥] ប្រទេសកំណើត, ស្រុកកំណើត ។

[៦] សមដោយអំណាច ។

[៧] ដែលចេះតែស្ងៀមក្រអឹមអៀនប្រៀន, មិនសូវស្ដីនិយាយ ឬដែលច្រើនតែនិយាយរហ៊ឹម ស្ទើរមិនហើបមាត់ ដោយសេចក្ដីអៀនច្រើន ។

យុវនយុវតី[8]ក្រុងដែលស្លៀកពាក់និងស្អិតស្អាងស្អាតបាត ពួកទ្រង់បាន បញ្ជូនឲ្យទៅទទួលមុន, បន្ទាប់មក ពួកទ្រង់បញ្ជូនពួករាជកុមារានិង រាជកុមារី រីឯពួកព្រះអង្គវិញ បានឈរតាមចន្លោះកន្ទុកកន្ទៀតកៀន កំបាំងក្នុងចំណោមរាជកុមារទាំងនោះ លើកគ្រឿងក្រអូប ផ្កាកម្រង និងម្សៅជាដើមបូជាព្រះសាស្ដា ហើយបានយាងព្រះមានព្រះភាគ ទៅ គង់នៅឯនិគ្រោធារាម[9] មួយអន្លើដោយព្រះខីណាស្រព ២០.០០០ អង្គ

[8] បុរសកំលោះនិងស្ត្រីក្រមុំ ។

[9] ក្នុងអដ្ឋកថាធម្មបទបញ្ជាក់ថា ៖ តថាគតោ ហិ មាតិបក្ខតោ អសីតិយា, បិតិបក្ខតោ អសីតិយាតិ ទ្វេអសីតិញាតិកុលសហស្សេហិ ការិតេ និគ្រោធមហាវិហារេ ឯកមេវ វស្សាវាសំ វសិ, អនាថបិណ្ឌិកេន ការិតេ ជេតវនមហាវិហារេ ឯកូនវីសតិវស្សានិ, វិសាខាយ សត្តវីសតិកោដិធនបរិច្ចាគេន ការិតេ បុព្វារាមេ ឆព្វស្សានិ ទ្វិន្នំ កុលានំ គុណមហត្តតំ បដិច្ច សាវត្ថិំ និស្សាយ បញ្ចវីសតិ វស្សានិ វស្សាវាសំ វសិ។ ព្រះតថាគតគង់ក្នុងមហាវិហារឈ្មោះនិគ្រោធដែលសាង ឡើងដោយព្រះញាតិវង្ស ១៦.០០០ ត្រកូល គឺខាងព្រះមាតា ៨.០០០, ខាងព្រះបិតា ៨.០០០ អស់តែ ១ វស្សាគត់ ។ ទ្រង់គង់ចាំវស្សាអស់ ១៩ វស្សា ក្នុងមហាវិហារជេតពនដែលសាងដោយអនាថបិណ្ឌិក (អស់តម្លៃ ៥៤ កោដិ) និងគង់នៅអស់ ៦ វស្សា ក្នុងបុព្វារាមដែលសាងដោយវិសាខា អស់តម្លៃ ២៧ កោដិ ។ សរុបមក ព្រះតថាគត គង់នៅក្បែរក្រុងសាវត្ថី អស់ ២៥ វស្សា ដោយសារត្រកូលទាំង ២ នោះមានគុណធំ ។

ជាបរិវារ ។ កាលព្រះមានព្រះភាគកំពុងគង់លើពុទ្ធាសនៈ[១០]ក្នុងអារាម
នោះ សក្យរាជទាំងឡាយកើតមានះរឹងត្អឹង មិនថ្វាយបង្គំព្រះអង្គទេ
ដោយប្រកាន់ថា "សិទ្ធត្ថ[១១]រាជកុមារនេះ មានវ័យក្មេងជាងពួកយើង
សិទ្ធត្ថនេះជាប្អូន ជាក្មួយ ជាបុត្រ ជាចៅរបស់យើង" ។ ដូច្នេះហើយ
បានជាសក្យរាជទាំងឡាយ បានត្រឹមតែប្រើពួករាជកុមារនិងពួករាជ
កុមារិកាឲ្យឱនកាយថ្វាយបង្គំព្រះមានព្រះភាគប៉ុណ្ណោះ ចំណែកខាង
ពួកព្រះអង្គវិញ គង់លាក់ខ្លួននៅពីក្រោយពួករាជកុមារទាំងឡាយនោះ
ធ្វើព្រងើយ ។

**ព្រះពុទ្ធបិតាក្រាបទូលនាពអស្ចារ្យ**

កាលដែលសក្យរាជទាំងឡាយ អង្គុយមិនថ្វាយបង្គំយ៉ាងនេះ,
ព្រះមានព្រះភាគ បានប្រមើលមើលនូវអធ្យាស្រ័យរបស់ពួកព្រះអង្គ
ហើយទ្រង់មានព្រះតម្រិះថា "ញាតិទាំងឡាយមិនថ្វាយបង្គំតថាគតទេ
ល្អើយចុះ អញតថាគតនឹងធ្វើឲ្យពួកព្រះអង្គថ្វាយបង្គំឥឡូវនេះ" ទ្រង់

---

[១០] អាសនៈដែលក្រាលថ្វាយព្រះពុទ្ធអង្គ ។

[១១] ព្រះនាមដើមរបស់ព្រះសក្យមុនីគោតម ដែលពួកព្រាហ្មណ៍បានថ្វាយក្នុងថ្ងៃតាំង
ព្រះនាម មានន័យថា អ្នកញ៉ាំងប្រយោជន៍ឬបំណងឲ្យសម្រេច ឬថាអ្នកសម្រេច
ប្រយោជន៍តាមបំណង ។

មានព្រះតម្រិះដូច្នេះហើយ ទ្រង់បានចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញចាកឈាននោះហើយ ទ្រង់ហោះទៅឰដ៏អាកាស ហាក់ដូចជាព្រះអង្គរោយលម្អងធូលីជាប់នឹងព្រះបាទាឲ្យធ្លាក់ចុះលើព្រះសីសៈរបស់ព្រះញាតិវង្សានុវង្ស, ព្រះអង្គបានធ្វើនូវបាដិហារ្យស្រដៀងគ្នានឹងយមកប្បាដិហារ្យ ដែលទ្រង់បានធ្វើទៀបគល់នៃកណ្ឌម្ពព្រឹក្ស ។ គ្រានោះ ព្រះរាជាសុទ្ធោទនៈ ពុទ្ធបិតា ឃើញភាពអស្ចារ្យដូច្នោះ ទ្រង់បានក្រាបទូលព្រះមានព្រះភាគថា ៖

"បពិត្រព្រះអង្គដ៏ចម្រើន, កាលនៅថ្ងៃកំណើតព្រះអង្គ គេបានបង្អោនព្រះកាយព្រះអង្គឲ្យថ្វាយបង្គំកាឡទេវិលតាបស ប៉ុន្តែព្រះបាទាព្រះអង្គ បែរជាអណ្តែតទៅប្រតិស្ឋាន[១២]លើក្បាល របស់តាបសនោះទៅវិញ ។ ទូលបង្គំបានឃើញដូច្នោះ ក៏ថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។ នេះជាបឋមវន្ទនា របស់ទូលបង្គំ ។ ក្រោយមកទៀត ក្នុងថ្ងៃពិធីច្រត់ព្រះនង្គ័ល គេទុកព្រះអង្គឲ្យប្រថាប់គង់លើគ្រែស្រីសយនា ក្រោមម្លប់ដើមព្រីង ទូលបង្គំបានទតឃើញស្រមោលដើមព្រីងនោះមិនជ្រេរទៅខាងណាសោះ ដូច្នេះទូល

[១២] តាំងនៅ, តម្កល់ ។

បង្គំ បានថ្វាយបង្គំនូវព្រះបាទារបស់ព្រះអង្គម្តងទៀត ។ នេះ ជាទុតិយវន្ទនា របស់ទូលបង្គំ ។ សូម្បីឥឡូវនេះ ក៏ទូលបង្គំបាន ឃើញនូវបាដិហារ្យដែលមិនធ្លាប់បានឃើញពីមុនមក ទូលបង្គំ សូមថ្វាយបង្គំ នូវព្រះបាទារបស់ព្រះអង្គ ។ នេះ ជាតតិយវន្ទនា របស់ទូលបង្គំ" ។

នាកាលសុទ្ធោទនមហារាជឱនកាយថ្វាយបង្គំព្រះមានព្រះភាគ ពុំ មានសក្យរាជអង្គណាមួយ ទប់ជំហរខ្លួនបានឡើយ មួយអង្គ ៗ បាន ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ឥតសេសសល់មួយអង្គណាឡើយ ។ នេះបញ្ជាក់ឲ្យឃើញថា ព្រះមានព្រះភាគធ្វើឲ្យញាតិទាំងឡាយ ថ្វាយបង្គំ រួចទ្រង់ចុះពីអាកាស ប្រថាប់គង់លើពុទ្ធាសនៈដ៏បវរដែលគេ ក្រាលថ្វាយ ។ នាកាលព្រះមានព្រះភាគប្រថាប់គង់ ញាតិវង្សានុវង្ស ជួបជុំគ្នាមូលមីរដេរដាស ហើយពួកគេអង្គុយដោយមានចិត្តមូលស្ងួង។ គ្រានោះ ពពកឡើងអព្ទ[១៣] ផងឹតដាសជិតភ្នែក ហើយបង្អុរភ្លៀងបោក្ខរ-ព័ស់ចុះយ៉ាងខ្លាំង ។ ភ្លៀងនេះ មានសូរផ្គរលាន់ ធ្លាក់ចុះក្រោមជាទឹក មានពណ៌ក្រហម ។ ជនទាំងឡាយណាដែលចង់ទទឹក ជនទាំងនោះក៏

[១៣] ពពកខាប់ឬក្រាស់ ។

ទទឹកសើម ។ ជនទាំងឡាយដែលមិនចង់ទទឹក ភ្លៀងក៏ពុំធ្លាក់ត្រូវសូម្បី តែមួយដំណក់ជាប់សរីរៈខ្លួនឡើយ ។ ឃើញដូច្នោះ ពួកគេមានសេចក្ដីស្ញប់ស្ញែងក្នុងចិត្ត ។

រីឯភិក្ខុទាំងឡាយ សន្ទនាគ្នាថា ៖

"អស្ចារ្យអ្វីម៉្លេះទេ ! ចម្លែកអ្វីម៉្លេះទេ ! ពុទ្ធានុភាពខ្លាំងអ្វីម៉្លេះទេ !

ត្រង់ដែលភ្លៀងបោក្ខរព័ស៌បែបនេះ បង្អុរចុះក្នុងញាតិសមាគម" ។

ព្រះសាស្ដាសណ្ដាប់ដូច្នោះហើយ ទ្រង់បានត្រាស់ថា ៖

"ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែឥឡូវនេះទេ សូម្បីពីអតីតជាតិ ក៏មហាមេឃធ្លាប់បង្អុរចុះ នូវភ្លៀងបោក្ខរព័ស៌ ក្នុងសមាគមញាតិរបស់អញតថាគតផងដែរ"

## ស្ដេចសញ្ជ័យ

កាលដែលត្រូវភិក្ខុទាំងនោះអារាធនាហើយ ព្រះសាស្ដាបាននាំអតីតនិទានមកតំណាលដូចតទៅនេះ ៖

ក្នុងអតីតកាល មានព្រះរាជាមួយអង្គ ព្រះនាមថា សិវិមហារាជ ទ្រង់គ្រប់គ្រងរាជាណាចក្រ ក្នុងជេតុត្តរនគរ ក្នុងដែនសិវិ ។ ព្រះអង្គមានរាជបុត្រមួយអង្គ ព្រះនាមថា **សញ្ជ័យ** ។ កាលដែលព្រះកុមារសញ្ជ័យចម្រើនវ័យវឌ្ឍនាការឡើង ព្រះបាទសិវិមហារាជ បាននាំនូវ

រាជកញ្ញានាមផុស្សតី ដែលជារាជធីតានៅដែនមទ្ទៈ មករៀបចំផ្សំផ្គុំឲ្យធ្វើជាអគ្គមហេសីរបស់សញ្ជ័យកុមារ រួចទ្រង់ធ្វើការដាក់រាជ្យ ថ្វាយដល់ព្រះរាជបុត្រគ្រប់គ្រងស្នង ។ មានដំណើររឿងក្នុងអតីតជាតិ របស់ព្រះនាងផុស្សតីទេវី ដូចតទៅនេះ ៖

ក្នុងកប្បទី ៩១ រាប់ពីភទ្ទកប្បនេះទៅ មានព្រះសាស្តាមួយអង្គព្រះនាមថា **វិបស្សី** ទ្រង់កើតឡើងក្នុងលោក ។ កាលដែលព្រះសាស្តាអង្គនោះ កំពុងគង់នៅក្នុងព្រៃមិគទាយវ័នជាទីដ៏ក្សេម ជិតក្រុងពន្ធុមតី ស្តេចមួយអង្គ បានបញ្ជូនសុវណ្ណមាលាតម្លៃ ១០០.០០០ កហាបណៈ ព្រមទាំងខ្លឹមចន្ទន៍ល្អ ៗ ទៅថ្វាយព្រះមហាក្សត្រ **ពន្ធុមៈ** ។ ស្តេចពន្ធុមអង្គនោះ មានព្រះរាជធីតា ២ ព្រះអង្គ ។ ស្តេចអង្គនោះ មានបំណងថ្វាយនូវបណ្ណាការនោះដល់ពួកនាង ដូច្នេះ ទ្រង់បានថ្វាយខ្លឹមចន្ទន៍ដល់ព្រះរាជធីតាច្បង ថ្វាយនូវសុវណ្ណមាលា ដល់ព្រះរាជធីតាប្អូន ។ រាជធីតាទាំងពីរនោះ គិតគ្នាថា ៖

"យើងនឹងមិនប្រដាប់នូវគ្រឿងបណ្ណាការនេះ លើខ្លួនប្រាណរបស់ខ្លួនទេ យើងនឹងបូជាព្រះសាស្តាវិញ"

ពួកនាងបានក្រាបទូលព្រះរាជាថា ៖

"បពិត្រព្រះបិតា ពួកខ្ញុំម្ចាស់នឹងបូជាព្រះទសពល ដោយខ្លឹម
ចន្ទន៍ដ៏ល្អនេះផង ដោយសុវណ្ណមាលានេះផង" ។

ទ្រង់សណ្ដាប់ដូច្នោះ ព្រះរាជាទ្រង់យល់ព្រមតាមសេចក្ដីស្នើនោះ ។ រាជធីតាច្បង បានឲ្យជាងធ្វើលម្អិតខ្លឹមចន្ទន៍ដ៏សុខុម រួចច្រកបំពេញក្នុងក្លងមាស ។ ចំណែកឯប្អូនពៅបានឲ្យជាងធ្វើសុវណ្ណមាលានោះជាឧរច្ឆទមាលា ច្រកបំពេញក្នុងក្លង[14]មាសដែរ ។ រាជធីតាទាំងពីរ បានប្រើឲ្យគេជួយកាន់ទៅមិគទាយវិហារ ។ ធីតាច្បង បូជានូវសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះទសពលដោយលម្អិតខ្លឹមចន្ទន៍ និងរោយរាយនូវលម្អិតដែលសេសសល់ក្នុងគន្ធកុដិ បានតាំងនូវសេចក្ដីប្រាថ្នាថា ៖

"បពិត្រព្រះអង្គដ៏ចម្រើន ដល់ទៅអនាគតជាតិ ខ្ញុំម្ចាស់សូមធ្វើជា
ព្រះមាតារបស់ព្រះពុទ្ធជាម្ចាស់ដូចជាព្រះអង្គ" ។

រីឯរាជធីតាពៅបានបូជាដោយឧរច្ឆទៈដែលធ្វើពីសុវណ្ណមាលានូវសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះតថាគត ហើយបានតាំងនូវសេចក្ដីប្រាថ្នាថា ៖

[14] បំពង់មានគ្របខ្ទីជាងក្លាក់ ធ្វើដោយក្រឡឹង ឬដោយដំ ដោយសិត ។

"បពិត្រព្រះអង្គដ៏ចម្រើន សូមកុំឲ្យគ្រឿងប្រដាប់នេះប្រាសអំពីខ្លួនប្រាណរបស់ខ្ញុំម្ចាស់ ដរាបដល់ខ្ញុំម្ចាស់សម្រេចព្រះអរហត្តផល" ។

ព្រះសាស្តា ទ្រង់បានធ្វើនូវអនុមោទនា ដល់ពួកនាង ។

រាជធីតាទាំងពីរ បិតនៅរហូតអស់ជន្មាយុ ហើយបានកើតនៅទេវលោក ។ បណ្តាជនទាំងពីរនោះ បងស្រីបានអន្ទោលពីទេវលោកកាន់មនុស្សលោក ពីមនុស្សលោកកាន់ទេវលោក ដល់មកខាងចុងកប្បទី ៩១ នេះ ក្នុងសម័យព្រះពុទ្ធបរមគ្រូនៃយើងកើតឡើង ព្រះនាងបានយោនយកកំណើតជាពុទ្ធមាតា ព្រះនាមថា **មហាមាយាទេវី** ។ រីឯប្អូនស្រី ក៏អន្ទោលវិលវល់ដូចគ្នាយ៉ាងនោះដែរ ដល់មកសម័យព្រះទសពលកស្សប ព្រះនាងបានកើតជារាជធីតា របស់ព្រះមហាក្សត្រនាមថាកិកិ ។ ព្រះនាងកាលនៅជាកុមារិកា អ្នកផងតែងហៅថា **ឧរច្ឆទា** ព្រោះនាងកើតមកដោយមានទ្រូងតុបតែងល្អដោយឧរច្ឆទមាលា ប្រៀបដូចជារូបគំនូរវិចិត្រយ៉ាងល្អល្អះ ។ ក្នុងកាលជន្មាយុ ១៦ ឆ្នាំ ព្រះនាងបានស្តាប់ភត្តានុមោទនា របស់ព្រះសាស្តា ហើយក៏តាំងស៊ប់ក្នុងសោតាបត្តិផល ។ គ្រាក្រោយមក ក្នុងថ្ងៃដែលព្រះបិតាស្តាប់នូវភត្តានុមោទនា

សម្រេចសោតាបត្តិផល ព្រះនាងក៏សម្រេចព្រះអរហត្តផលជាមួយគ្នា នោះ រូបចេញសាងផ្នួស ហើយបរិនិព្វាន ។ ព្រះរាជាកិកិ[១៥] បានរាជធីតា ៧ អង្គផ្សេងទៀត ។

តាសំ នាមានិ –

"សមណី សមណគុត្តា ច, ភិក្ខុនី ភិក្ខុទាយិកា;
ធម្មា ចេវ សុធម្មា ច, សង្ឃទាសី ច សត្តមី"តិ ។

តា ឥមស្មិំ ពុទ្ធុប្បាទេ –

"ខេមា ឧប្បលវណ្ណា ច, បដាចារា ច គោតមី;
ធម្មទិន្នា មហាមាយា, វិសាខា ចាបិ សត្តមី"តិ ។

ឈ្មោះរបស់ពួកនាងគឺ ៖

សមណី ១, សមណគុត្តា ១, ភិក្ខុនី ១, ភិក្ខុទាយិកា ១, ធម្មា ១, សុធម្មា ១, សង្ឃទាសី ១, ជាគម្រប់ ៧ ។

ក្នុងពុទ្ធុប្បាទនេះ ពួកនាងទាំង ៧ នោះ បានមកជា ៖

---

[១៥] ព្រះនាមព្រះរាជាមួយអង្គក្នុងសម័យព្រះពុទ្ធកស្សប ។

ខេមា ១, ឧប្បលវណ្ណា ១, បដាចារា ១, គោតមី ១, ធម្មទិន្នា ១, មហាមាយា ១, វិសាខា ១, ជាគម្រប់ ៧ ។

បណ្ដារាជធីតាទាំង ៧ អង្គនោះ ផុស្សតី ឈ្មោះថាសុធម្មា ព្រះនាងបានធ្វើបុណ្យទាំងឡាយ មានការឲ្យទានជាដើម បានកើតជាកុមារិកាផុស្សតី ព្រោះព្រះនាងកើតមកមានសរីរៈហាក់ដូចជាប្រោះព្រំដោយរសខ្លឹមចន្ទន៍ក្រហម ដោយសារផលនៃការបូជាលម្អិតខ្លឹមចន្ទន៍ដែលខ្លួនធ្វើហើយចំពោះព្រះវិបស្សីសម្មាសម្ពុទ្ធ ។ កាលអន្ទោលទៅមកក្នុងទេវលោកនិងមនុស្សលោក ក្រោយមក ព្រះនាងកើតជាអគ្គមហេសី របស់សក្កទេវរាជ ។ ព្រះនាងឋិតនៅទេវលោកនោះ រហូតដល់កាលកំណត់អាយុរបស់ទេវតា ។ នាកាលបុព្វនិមិត្តទាំង ៥ ប្រការកើតឡើងដល់ព្រះនាង សក្កទេវរាជ បានដឹងថានាងត្រូវអស់អាយុ ក៏នាំនាងទៅកាន់ឧទ្យាននន្ទនវ័ន ទាំងយសបរិវារដ៏ធំ ហើយព្រះអង្គគង់ចុងគ្រែសយនា ត្រាស់នឹងព្រះនាងកំពុងគង់នៅលើផ្ទៃគ្រែសយនាដ៏វិចិត្រ ក្នុងឧទ្យាននោះ យ៉ាងនេះថា ៖

"ហៃផុស្សតីសម្ងាញ់ ! យើងនឹង ថ្វាយពរ ១០ ប្រការ ដល់នាង, នាងចូរយកពរទាំងនោះចុះ" ។

កាលពោលដូច្នេះហើយ ទ្រង់បានពោលនូវគាថាទី ១ ក្នុងមហាវេស្សន្តរជាតកនេះ ដែលប្រដាប់ដោយគាថា ១.០០០ ដូច្នេះថា ៖

"ហៃផុស្សតីមហេសី ដ៏មានសម្បុរភ្លឺថ្លាប្រសើរ ទាំងមានអវយវៈដ៏ល្អឧត្តម, ចូរនាងទទួលពរ ១០ ប្រការលើផែនដី តាមសេចក្តីពេញចិត្តរបស់នាង" ។

ព្រះនាងផុស្សតីមិនដឹងថាខ្លួនត្រូវច្យុត[១៦] ក៏បានទូលតបថា ៖

"បពិត្រទេវរាជ ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំព្រះអង្គ ទូលសួរថាតើខ្ញុំម្ចាស់បានធ្វើអ្វីខុសឆ្គងក្នុងសម្នាក់ព្រះអង្គ ទើបបានជាព្រះអង្គញ៉ាំងខ្ញុំម្ចាស់ឲ្យច្យុតឃ្លាតចាកព្រះរាជដំណាក់ដ៏គួរឲ្យរីករាយដូចជាឈើត្រូវខ្យល់បក់រំលើងដូច្នេះ ?" ។

គ្រានោះ សក្កទេវរាជជ្រាបថាមហេសីធ្វេសប្រហែស ទ្រង់តបថា ៖

"ហៃមហេសីអូន នាងពុំបានធ្វើអំពើគ្គាំគ្គងអ្វីទេ ទាំងមិនមែនជាទីសម្អប់នៃយើងដែរ ប៉ុន្តែឥឡូវនេះនាងអស់បុណ្យហើយ ដូច្នេះហើយ បានជាយើងប្រាប់នាងយ៉ាងនេះ ។ ហៃមហេសីសម្លាញ់

[១៦] ស្លាប់, អស់អាយុ ។

*នាងនៅកៀកជិតមរណៈ[១៧]ណាស់ នាងមុខតែព្រាត់ប្រាសអំពីយើងពុំខាន ទាន់ពេលយើងប្រទានពរ ១០ ប្រការឲ្យ ចូរនាងផាប់ទទួលយកចុះ” ។*

*ផុស្សតី ឮពាក្យរបស់សក្កៈហើយ ជ្រាបនូវសេចក្តីស្លាប់របស់ខ្លួន ដោយមិនត្រូវសង្ស័យ ក៏ក្រាបទូលទទួលនូវពរថា ៖*

“វរំ ចេ មេ អទោ សក្ក, សព្វភូតានមិស្សរ;
សិវិរាជស្ស ភទ្ទន្តេ, តត្ថ អស្សំ និវេសនេ។

នីលនេត្តា នីលភមុ, នីលក្ខី ច យថា មិគី;
ផុស្សតី នាម នាមេន, តត្ថបស្សំ បុរិន្ទទ។

បុត្តំ លភេថ វរទំ, យាចយោគំ អមច្ឆរឹ;
បូជិតំ បដិរាជូហិ, កិត្តិមន្តំ យសស្សិនំ។

គព្ភំ មេ ធារយន្តិយា, មជ្ឈិមង្គំ អនុន្នតំ;
កុច្ឆិ អនុន្នតោ អស្ស, ចាបំវ លិខិតំ សមំ។

---

*[១៧] សេចក្តីស្លាប់ ។*

ជនា មេ នប្បបទេយ្យុំ, បលិតា ន សន្តុ វាសរ;
កាយេ រជោ ន លិម្បេថ, វជ្ឈញ្ចាបិ បមោចយេ។

មយូរកោញ្ចាភិរុទេ, នារិវរគណាយុតេ;
ខុជ្ជចេលាបកាកិណ្ណេ, សូតមាគធវណ្ណិតេ។

ចិត្រគ្គឡេរុឃុសិតេ, សុរាមំសបពោធនេ;
សិវិរាជស្ស ភទ្ទន្តេ, តត្ថស្សំ មហេសី បិយា”។

*“បពិត្រទេវរាជដ៏ចម្រើន ជាឥស្សរៈលើពួកទេវតាទាំងអស់, ថាបើព្រះអង្គសព្វព្រះហឫទ័យប្រទានពរដល់ខ្ញុំម្ចាស់ហើយ ខ្ញុំម្ចាស់សូមទទួលយកពរ ១០ ប្រការនោះចុះគឺ ៖*

*ទី ១ សូមឲ្យខ្ញុំម្ចាស់កើតក្នុងព្រះរាជនិវេសន៍នៃព្រះបាទសិវិ*

*ទី ២ សូមឲ្យខ្ញុំម្ចាស់មាននេត្រាខ្មៅ ដូចជាភ្នែកកូនម្រឹគញី*

*ទី ៣ សូមឲ្យខ្ញុំម្ចាស់មានចិញ្ចើមខ្មៅ*

*ទី ៤ សូមឲ្យខ្ញុំម្ចាស់មានឈ្មោះថា **ផុស្សតី** ដូចដើម*

*ទី ៥ សូមឲ្យខ្ញុំម្ចាស់បានបុត្រល្អ ចូលចិត្តឲ្យទាន ជាអ្នកគួរដល់ស្ទូម មិនមានសេចក្ដីកំណាញ់ ជាបុគ្គលដែលព្រះរាជានៃ*

ប្រទេសដទៃគោរពបូជា និងអ្នកមានកេរ្តិ៍ឈ្មោះយសសក្តិ

ទី ៦ សូមឲ្យខ្ញុំម្ចាស់កុំមានពោះប៉ោង នៅពេលទ្រង់គភ៌ ឲ្យនៅស្មើ ដូចជាដងធ្នូដែលគេសិត ។

ទី ៧ សូមឲ្យខ្ញុំម្ចាស់កុំមានដោះយារវែង

ទី ៨ សូមឲ្យខ្ញុំម្ចាស់កុំមានសក់ស្កូវ

ទី ៩ សូមឲ្យខ្ញុំម្ចាស់កុំជាប់ធូលី[១៨]លើកាយ

ទី ១០ សូមឲ្យខ្ញុំម្ចាស់បានដោះលែងចោរ ទោះពួកគេមានកំហុសគួរសម្លាប់ក៏ដោយ

បពិត្រទេវរាជដ៏ចម្រើន កាលខ្ញុំម្ចាស់បានជាអគ្គមហេសីនៃព្រះបាទសិវិហើយ សូមឲ្យបានជាទីស្រឡាញ់នៃព្រះអង្គ ក្នុងព្រះរាជនិវេសន៍នោះ ដែលជាទីកងរំពងដោយសំឡេងក្ងោកនិងក្រៀល[១៩] សម្បូរពួកនារីដ៏ប្រសើរ ដេរដាសដោយមនុស្សគមនិងមនុស្សតឿ

[១៨] ផង់, លម្អង, ល្អង ។

[១៩] សត្វស្លាបមួយប្រភេទ សម្បុរប្រផេះចំពុះវែង, កវែង, ជើងវែង, ខ្ពស់ជង្គ្រោង, មានសម្រែកឮខ្លាំង ។

ជាព្រះរាជនិវេសន៍ដែលពួកអ្នកសូទ្រ:[20] និងពួកអ្នកមគធ: តែង

ស្ញើចសរសើរ ជាដំណាក់គឹកកងដោយសំឡេងនៃសន្ទះទ្វារបង្អួច

ដ៏វិចិត្រ និងជាទីមានពួកជនជាស់គ្នាផឹកសុរាបរិភោគសាច់" ។

សក្កទេវរាជ ត្រាស់ថា ៖

"ហៃផុស្សតីជានារីមានអវយវៈដ៏ឧត្តមទាំងអស់, ពរ ១០ ប្រការ

ដែលយើងនឹងប្រទានដល់នាង នាងប្រាកដជាបានពរទាំងអស់

នោះ ក្នុងដែននៃព្រះបាទសិវិមិនខាន" ។

ត្រាស់ដូច្នេះហើយ សក្កទេវរាជមានព្រះហឫទ័យត្រេកអររីករាយយ៉ាង

ខ្លាំង បានប្រទានពរទាំង ១០ ដល់ព្រះនាងផុស្សតីថា ៖

"ម្នាលផុស្សតីមហេសីសម្លាញ់ ពរទាំង ១០ នោះ ចូរសម្រេច

ដល់នាង" ។

ទសវរកថា ចប់ ។

[20] អ្នកកើតក្នុងវណ្ណៈទី ៤ ។

# ជំពូកទី ២
# សម្រស់ព្រៃហិមពាន្ត

## ស្ដេចសញ្ជ័យនិងព្រះនាងផុស្សតី

តាមប្រការដូចពោលមកនេះ ព្រះនាងផុស្សតីបានទទួលពរ រួចក៏ច្យុតចាកទីនោះ កើតក្នុងផ្ទៃរបស់អគ្គមហេសី នៃព្រះបាទមទ្ទរាជ ។ កាលកំពុងតែប្រសូតចាកផ្ទៃ ទារិកាកើតមកសរីរៈហាក់ដូចជាប្រោះព្រំដោយលម្អិតខ្លឹមចន្ទន៍ហ្មត់ខែ ម៉្លោះហើយ ក្នុងថ្ងៃដាក់ឈ្មោះ ព្រះមាតាបិតា បានដាក់ឈ្មោះឲ្យនាងថា "ផុស្សតី" ។ ផុស្សតី ចម្រើនដោយបរិវារជាច្រើន លុះដល់អាយុ ១៦ ឆ្នាំ នាងមានរូបរាងផូរផង់ស្រលូតស្រឡះ រលីងរលង់ ស្រស់បំព្រង់លើសស្រីនានា ។ គ្រានោះសិវិមហារាជ បានផ្សំផ្គុំនាងនឹងរាជបុត្រសញ្ជ័យកុមារ ហើយឲ្យមន្ត្រីទាំងឡាយលើកស្វេតច្ឆត្រថ្វាយព្រះរាជបុត្រ ឡើងគ្រងរាជ្យស្នង រួចតែងតាំងផុស្សតី ក្នុងតំណែងជាអគ្គមហេសីច្បង លើអស់ស្រីស្នំចំនួន ១៦.០០០នាក់ ក្នុងនគរជេតុត្តរ ។

## កំណើតព្រះមហាសត្តនិងទេវបុត្រ ៦០.០០០ អង្គ

ព្រះនាងផុស្សតី បានជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ព្រះបាទសញ្ជ័យ ។ គ្រានោះ សក្កទេវរាជ ប្រមើលមើលព្រះនាងទៅឃើញថា "បណ្ដាពរទាំងឡាយ ដែលអញឲ្យដល់ផុស្សតី ពរ ៩ សម្រេចហើយ" រួចទ្រង់ព្រះតម្រិះថា "ពរគឺបុត្រមួយទេ ដែលមិនទាន់សម្រេច អញនឹងញ៉ាំងពរនោះឲ្យសម្រេច" ។ គាប់ចួនសម័យនោះ ព្រះមហាសត្តកំពុងរស់នៅ ក្នុងតាវត្តិង្សទេវលោក ទាំងព្រះជន្មរបស់ព្រះអង្គក៏ត្រូវអស់ផងដែរ ។ ដឹងដូច្នោះ សក្កៈក៏ទៅកាន់សម្នាក់របស់ព្រះអង្គ ពោលថា ៖

"បពិត្រព្រះអង្គនិរទុក្ខ គួរណាស់តែព្រះអង្គទៅកាន់មនុស្សលោក គួរណាស់តែព្រះអង្គ ចាប់បដិសន្ធិក្នុងផ្ទៃរបស់អគ្គមហេសី នៃព្រះបាទសិវិរាជ ក្នុងទីនោះ" ។

ស្របពេលនោះដែរ មានទេវបុត្រផ្សេង ៗ ដែលត្រូវច្យុតដំណាលនឹងព្រះមហាសត្ត ចំនួន ៦០.០០០ អង្គ សក្កទេវរាជក៏ទៅទទួលសេចក្ដីប្ដេជ្ញារបស់ពួកគេ រួចទ្រង់យាងមកលំនៅឋាននៃខ្លួនវិញ ។

រីឯព្រះមហាសត្ត ច្យុតចាកទេវលោកនោះហើយ ទ្រង់បានយោនយកកំណើត ក្នុងទីនោះមែន ។ សូម្បីទេវបុត្រផ្សេង ៗ ក៏អន្ទោលចាប់កំណើត ក្នុងផ្ទះទាំងឡាយ របស់ពួកមន្ត្រី ៦.០០០ នាក់ដែរ ។ នា

កាលព្រះមហាសត្វ នៅក្នុងផ្ទៃ ព្រះនាងផុស្សតី កើតរោគចាញ់គភ៌ នឹក ភ្នកចង់ឲ្យគេសាងសាលាធទាន ក្នុងទី ៦ កន្លែង គឺនៅត្រង់ទ្វារនគរ ៤ កន្លែង កណ្តាលនគរ ១ កន្លែង ត្រង់ទ្វារព្រះរាជនិវេសន៍ ១ កន្លែង ហើយនឹងចំណាយព្រះរាជទ្រព្យ ៦០០.០០០ កហាបណៈ រៀងរាល់ថ្ងៃ ធ្វើមហាទាន ។

ព្រះរាជា លុះទ្រង់បានសណ្តាប់ នូវអាការរោគចាញ់គភ៌ របស់ ព្រះនាង ព្រះអង្គឲ្យគេទៅអញ្ជើញព្រាហ្មណ៍ទាយនិមិត្តជាច្រើនរូប មកសាកសួរ ។ ពួកព្រាហ្មណ៍ទាយនិមិត្ត បានក្រាបទូលថា

"បពិត្រមហារាជ សត្វអ្នកត្រេកអរក្នុងទាន បានកើតហើយក្នុងផ្ទៃ

របស់ព្រះទេវី គេនឹងមិនចេះឆ្អែតស្កប់ស្កល់ក្នុងការឲ្យទានទេ" ។ ទ្រង់សណ្តាប់ដូច្នោះ ព្រះរាជាមានព្រះរាជហឫទ័យត្រេកអរជាពន់ ពេក បានចេញរាជបញ្ជាឲ្យជាងសាងសង់នូវសាលាធទាន រួចទ្រង់ បានឲ្យគេចាត់តាំងព្រះរាជអំណោយ តាមប្រការដូចដែលបានពោល រួចហើយ ។ តាំងអំពីថ្ងៃចាប់បដិសន្ធិរបស់ព្រះពោធិសត្វមក ព្រះរាជា តែងតែមានលាភតង្វាយដែលគេយកមកថ្វាយច្រើន ប្រមាណថា ប៉ុណ្ណោះប៉ុណ្ណោះពុំបានសោះ ។ ដោយអានុភាពនៃបុណ្យ របស់ព្រះ

មហាសត្តនោះ ស្តេចទូទាំងជម្ពូទ្វីប បានបញ្ជូននូវគ្រឿងបណ្ណាការមកថ្វាយ ។ កាលព្រះនាងផុស្សតីទេវីទ្រង់គភ៌ ដោយមានបរិវារជាច្រើន ព្រះនាងមានបំណងចង់ទតទេសភាពទីក្រុង ក្នុងពេលគភ៌កំពុងតែគ្រប់ទសមាស[២១]។ ព្រះនាងបានក្រាបទូលព្រះរាជាសុំសេចក្តីអនុញ្ញាត ។ ព្រះរាជាបានឲ្យគេតុបតែងទីក្រុងស្រស់ស្អាតបីដូចទេវនគរ ហើយលើកព្រះនាងដាក់លើរថដ៏បវរ រួចបរប្រទក្សិណព្រះនគរ ។ កាលរថមកដល់ទីកណ្តាលវិថីរបស់ពួកឈ្មួញ ខ្យល់កម្មជ្ជវាតរបស់ព្រះនាងបានកក្រើក ។ គ្រានោះ មន្ត្រីទាំងឡាយ បានរាយការណ៍ ចំពោះព្រះមហាក្សត្រ ។ ព្រះរាជាឮដូច្នោះហើយ ទ្រង់ឲ្យគេធ្វើបន្ទប់ប្រសូតបុត្រថ្វាយព្រះនាង លើមហាវិថីរបស់ពួកឈ្មួញនោះឯង រួចអញ្ជើញព្រះនាងឲ្យចូលទៅស្នាក់នៅ ។ ព្រះនាង បានប្រសូតបុត្រនៅទីនោះ ។

**មូលហេតុនាំឲ្យដាក់នាមវេស្សន្តរ**

កាលព្រះមហាសត្តប្រសូតចាកផ្ទៃម្តាយ ព្រះអង្គមានខ្លួនបរិសុទ្ធបើកនូវព្រះនេត្រទាំងគូចេញមក ។ លុះប្រសូតផុតមកភ្លាម ព្រះអង្គបានលាដៃទៅរកព្រះមាតា និយាយថា ៖

[២១] ទស (១០) + មាស (ខែ) = ១០ ខែ ។

"បពិត្រព្រះមាតា ទូលបង្គំនឹង ឲ្យទាន តើព្រះមាតាមានទ្រព្យ
អ្វីទេ" ។

គ្រានោះ ព្រះមាតារបស់ព្រះអង្គ ដាក់ថង់ទ្រព្យ ១.០០០ កហាបណៈ លើដៃលារបស់ព្រះមហាសត្វ ដោយនិយាយថា

"ហៃបា ! អ្នកចូរឲ្យទាន តាមអធ្យាស្រ័យចុះ" ។

**កំណត់សម្គាល់**

ពិតណាស់ កំណើតព្រះមហាសត្វនិយាយជាមួយនឹងម្ដាយ ក្នុងពេលប្រសូតមកភ្លាម មាន ៣ អត្តភាព គឺ

១- អត្តភាពជាព្រះមហោសថ

១- អត្តភាពជាព្រះវេស្សន្តរ

១- អត្តភាពជាព្រះសិទ្ធត្ថនៅជាតិចុងក្រោយ ។

បន្ទាប់មក ក្នុងថ្ងៃតាំងនាមរបស់ព្រះអង្គ ព្រះមាតាបិតាបានដាក់ឈ្មោះឲ្យថា **វេស្សន្តរ** ព្រោះព្រះអង្គកើតនៅលើវិថីរបស់ពួកឈ្មួញ ដែលមិនមែននាមជាប់មកពីមាតានិងបិតាទេ ។

ក្នុងថ្ងៃកំណើតរបស់ព្រះមហាសត្វ មានមេដំរីមួយត្រាច់ចរតាមអាកាស បណ្តើរកូនដំរីខ្ចីនសសុទ្ធដែលគេសន្មតថាជាអភិមង្គលមកដាក់ក្នុងកន្លែងដំរីមង្គល ហើយវាចៀសចេញទៅ ។ ពួកគេបានដាក់ឈ្មោះឲ្យកូនដំរីនោះថា បច្ច័យ ព្រោះកើតមកមានព្រះមហាសត្វជាបច្ច័យ ។ ក្នុងថ្ងៃនោះដែរ កុមារ ៦០.០០០ នាក់ បានប្រសូតក្នុងផ្ទះនៃពួកមន្ត្រីទាំងឡាយ ។ ព្រះរាជា បានរៀបស្ត្រីខ្ពស់ពេកជាដើម សម្រាប់ព្រះមហាសត្វ ហើយព្រះអង្គបានឲ្យគេជ្រើសតាំងស្ត្រីដែលមានដោះមិនយារ និងមានទឹកដោះផ្អែម ចំនួន ៦៤ នាក់ ធ្វើជាមេដោះរបស់ព្រះមហាសត្វ, និងទ្រង់ឲ្យគេចាត់តាំងស្ត្រីមេដោះមួយ ៗ សម្រាប់ទារក ៦០.០០០ នាក់ ដែលកើតដំណាលគ្នានឹងព្រះអង្គផងដែរ ។ ព្រះមហាសត្វ បានធំធាត់ឡើងដោយមានបរិវារជាច្រើន ជាមួយនឹងពួកក្មេង ៦០.០០០ នាក់ ។ គ្រានោះ ព្រះរាជាបានឲ្យជាងធ្វើគ្រឿងប្រដាប់សម្រាប់កុមារ ដែលមានតម្លៃ ១០០.០០០ កហាបណៈ ថ្វាយដល់ព្រះមហាសត្វ ។ ក្នុងកាលព្រះអង្គអាយុ ៤ ឬ ៥ ឆ្នាំ ស្រាប់តែព្រះមហាសត្វដោះគ្រឿងប្រដាប់នោះ ឲ្យដល់ពួកមេដោះ ទ្រង់មិនយកគ្រឿងប្រដាប់នោះវិញទេ បើទុកណាជាពួកមេដោះថ្វាយវិញក៏ដោយ ។ ពួកមេដោះបានថ្វាយដំណឹង ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់សណ្តាប់សេចក្តីនោះ

ហើយ ត្រាស់ថា "អ្វីដែលបុត្រយើងឲ្យ ចូរជាការឲ្យដ៏ប្រសើរ" រួចទ្រង់ចាត់ឲ្យជាងធ្វើគ្រឿងប្រដាប់មួយផ្សេងទៀត ។ ព្រះកុមារបានឲ្យនូវគ្រឿងប្រដាប់នោះទៀត ។ សរុបសេចក្តីមកថា កាលព្រះកុមារនៅក្មេង ព្រះអង្គបានឲ្យនូវគ្រឿងប្រដាប់ ដល់ពួកមេដោះ អស់ ៩ លើក ។

## វេស្សន្តរគិតឲ្យអជ្ឈត្តិកទាន

ក្នុងកាលអាយុ ៨ ឆ្នាំ ព្រះមហាសត្តនៅលើប្រាសាទដ៏បវរ គង់លើគ្រែសយនា បានគិតដូច្នេះថា ៖

"អាត្មាអញកំពុងតែឲ្យពាហិរកទានតែម៉្យាងទេតើ, ពាហិរកទាននោះ ពុំញុំាងអាត្មាអញឲ្យត្រេកអរជាពន់ពេកសោះ អាត្មាអញមានបំណងចង់ឲ្យអជ្ឈត្តិកទាន ប្រសិនបើនរណាមួយគប្បីសុំនូវក្បាល ចំពោះអាត្មាអញ អាត្មាគប្បីកាត់ក្បាលឲ្យដល់អ្នកនោះ ។ បើនរណាមួយ គប្បីសុំបេះដូង ចំពោះអាត្មាអញ អាត្មាអញគប្បីរូងទ្រូងយកបេះដូងចេញមកឲ្យដល់អ្នកនោះ ។ ប្រសិនបើនរណាមួយ គប្បីសុំនូវភ្នែកទាំងគូ អញគប្បីឆ្កៀលនូវភ្នែកទាំងគូឲ្យដល់អ្នកនោះ ។ ប្រសិនបើនរណាគប្បីសុំនូវសាច់នៃសរីរៈ អាត្មាអញ

គប្បីចៀរសាច់អំពីសរីរៈទាំងមូលឲ្យដល់អ្នកនោះ ។ ប្រសិនបើនរណាមួយ គប្បីសុំនូវឈាម ចំពោះអាត្មាអញ អាត្មាអញគប្បីយកឈាមឲ្យដល់អ្នកនោះ ។ ម្យ៉ាងវិញទៀត ថាបើនរណាមួយគប្បីនិយាយថា "នៃវេស្សន្តរ ឯងចូរធ្វើជាទាសៈរបស់យើង ដូច្នេះ អាត្មាអញគប្បីលំអោនខ្លួនចំពោះអ្នកនោះ សុខចិត្តឲ្យខ្លួនធ្វើជាទាសៈ" ។

កាលដែលព្រះកុមារវេស្សន្តរកំពុងតែ គិតយ៉ាងនេះ មហាប្រឹថពីដែលមានកម្រាស់ ២០០.០០០ យោជន៍ និង ៤ នហុត បានរញ្ជួយលាន់ស្នូរដូចជាដំរីចុះប្រេង ។ ស្ដេចភ្នំសិនេរុ បានទន់ទោរដូចវល្លិ៍ពេលភ្លើងឈមមុខមកចំជេតុត្តរនគរ ។ ភ្លៀងលាន់ផ្គរ បានបង្អុរចុះមួយរំពេចលាយដោយសំឡេងប្រឹថពី បណ្ដាលឲ្យកើតសូរគួរឲ្យស្រៀវសាច់ស្ញើបចិត្ត ។ ឯផ្លេកបន្ទោរក៏ឆ្លៀលឆ្វាត់ខុសកាល ។ ផ្ទៃសាគរ កគ្រើករំពើកភ្ញូកភ្ញឹក ។ សក្កទេវរាជទះដៃ ។ មហាព្រហ្ម ថ្វាយពរសព្ទសាធុការ ។ តាំងពីផែនដី រហូតដល់ព្រហ្មលោក មានការកើតកោលាហលតែមួយដំណាលគ្នា ។

ព្រោះហេតុនោះ ក៏មានពុទ្ធដីកាបញ្ជាក់ផងដែរថា ៖

"យទាហំ ទារកោ ហោមិ, ជាតិយា អដ្ឋវស្សិកោ;
តទា និសជ្ជ បាសាទេ, ទានំ ទាតុំ វិចិន្តយិំ។

ហទយំ ទទេយ្យំ ចក្ខុំ, មំសម្បិ រុធិរម្បិ ច;
ទទេយ្យំ កាយំ សាវេត្វា, យទិ កោចិ យាចយេ មមំ។
សភាវំ ចិន្តយន្តស្ស, អកម្បិតមសណ្ឋិតំ;
អកម្បិ តត្ថ បថវី, សិនេរុវនវដំសកា" ។

*"កាលដែលតថាគតនៅក្មេងតូច ទើបនឹងមានអាយុ ៨ ឆ្នាំអំពីកំណើត តថាគតបានអង្គុយលើប្រាសាទ រិះគិតនឹងឲ្យទានថា បើមានស្មូមណាមួយ មកបន្លឺវាចាសូមអាត្មាអញ ។ គួរឲ្យបេះដូងគួរឲ្យភ្នែក គួរឲ្យសាច់ គួរឲ្យឈាម គួរឲ្យរាងកាយ ដល់ស្មូមនោះឯង ។ កាលតថាគតនោះ កំពុងគិតសភាវធម៌ដែលមិនកម្រើក*

មិនតាំងនៅក្នុងកាលនោះ ប្រើចពីមានភ្នំសិនេរុ និងព្រៃជាគ្រឿង
ប្រដាប់អំពីខាងលើក៏ញាប់ញ័រ" ។

ក្នុងកាលជន្មាយុ ១៦ វស្សា ព្រះពោធិសត្វបានរៀនចេះចប់គ្រប់មុខវិជ្ជាសិល្ប៍ទាំងអស់ ។ គ្រានោះ ព្រះបិតារបស់ព្រះអង្គ មានបំណងថ្វាយរាជ្យ បានប្រឹក្សាជាមួយនឹងមាតា ហើយបាននាំរាជកញ្ញាឈ្មោះមទ្រី ជាធីតារបស់ព្រះមាតុលា អំពីមទ្ទរាជត្រកូល មកផ្សំផ្គុំជាអគ្គមហេសីច្បង របស់ព្រះវេស្សន្តរ ធំលើសអស់ស្រីស្នំ ១៦.០០០ នាក់ រួចអភិសេកព្រះមហាសត្ត ក្នុងរាជសម្បត្តិ ។ ព្រះមហាសត្ត តាំងពីកាលឋិតនៅក្នុងរាជ្យមក ព្រះអង្គតែងចំណាយនូវព្រះរាជទ្រព្យ ៦០០.០០០ កហាបណៈ ជារៀងរាល់ថ្ងៃ ធ្វើជាមហាទាន ។ គ្រាក្រោយមក ព្រះនាងមទ្រីទេវី បានប្រសូតរាជបុត្រមួយអង្គ។ ជនទាំងឡាយ បានទទួលរាជបុត្រនោះ ដោយស្បៃមាស ហេតុនោះ ពួកគេបានតាំងនាមព្រះរាជបុត្រអង្គនោះថា ជាលីកុមារ ។ ក្នុងកាលជាលីកុមារចេះដើរ ព្រះនាងមទ្រីទេវី បានសម្រាលព្រះរាជធីតាមួយអង្គទៀត ។ ជនទាំងឡាយបានទទួលនូវរាជធីតាអង្គនោះ ដោយស្បៃកខ្មៅ ហេតុនោះ ពួកគេបានតាំង

នាមឲ្យនាងថា **កណ្ហាជិនា** ។ ព្រះមហាសត្វ តែងជិះលើ-កនៃដំរីដែលគេតុបតែង បរមើលសាលាទានទាំង ៦ កន្លែង ក្នុង ១ ខែ ៦ ដង ។

**ដែនកាលិង្គៈរាំងស្ងួត**

គ្រានោះ នៅឯដែនកាលិង្គៈមានគ្រោះរាំងស្ងួត សន្ទូងទាំងឡាយមិនបរិបូណ៌ ភ័យធំអំពីការឃ្លាន បានប្រព្រឹត្តទៅដល់ពពួកមនុស្ស ។ រីឯមនុស្សទាំងឡាយ កាលមិនអាចចិញ្ចឹមជីវិតបាន ក៏ប្រព្រឹត្តនូវអំពើចោរកម្ម ។ អ្នកជនបទទាំងឡាយ កាលបើត្រូវទុក្ខបៀតបៀន បានមកប្រជុំគ្នាត្រង់ព្រះលានហ្លួង តិះដៀលនូវព្រះមហាក្សត្រស្ដេចផែនដី ។ ព្រះរាជា លុះទ្រង់ព្រះសណ្ដាប់នូវពាក្យនោះ ទ្រង់ត្រាស់សួរអំពីមូលហេតុ ។ អ្នកជនបទទាំងឡាយ ក៏បានក្រាបទូលឲ្យទ្រង់ជ្រាបនូវសេចក្ដីនោះ ។ ព្រះរាជា បានបញ្ជូនឲ្យពួកគេត្រឡប់ទៅវិញ ដោយសន្យាថា "នែ៎អ្នកទាំងឡាយ ប្រពៃណាស់ យើងនឹងញ៉ាំងភ្លៀងឲ្យធ្លាក់" រួចទ្រង់ផ្ដើមសមាទានសីល ៥ និងនៅចាំឧបោសថសីល ។ បើទោះជាយ៉ាងនេះក៏ដោយ ក៏ទ្រង់ពុំអាចញ៉ាំងភ្លៀងឲ្យធ្លាក់បាន ។ ស្ដេចអង្គនោះបានកោះហៅអ្នកនគរទាំងឡាយឲ្យមកប្រជុំគ្នា រួចទ្រង់មានព្រះតម្រាស់សួរថា ៖

"ហៃអ្នកទាំងឡាយ យើង បើទោះបីបានសមាទានសីល ៥ និង រក្សាសីលឧបោសថ អស់ ១ សប្តាហ៍ហើយក៏ដោយ ក៏នៅតែពុំ អាចញុំាងភ្លៀងឲ្យបង្អុរចុះបាន តើយើងត្រូវធ្វើដូចម្តេចវិញ?"។

អ្នកក្រុងក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះអង្គពុំអាចញុំាងភ្លៀងឲ្យ បង្អុរចុះបានទេ សូមព្រះអង្គធ្វើដូច្នេះវិញចុះ ពួកទូលបង្គំបានឮ ដំណឹងថា នៅឯជេតុត្តរនគរឯណោះ មានរាជបុត្ររបស់ព្រះ បាទសញ្ជ័យមួយអង្គ ព្រះនាមថា **វេស្សន្តរ** រាជបុត្រនោះត្រេកអរ ក្នុងការឲ្យទានណាស់ ។ ព្រះអង្គមានដំរីមង្គល សម្បុរសសុទ្ធ បើ គេនាំទៅតំបន់ជនបទណា ៗ ក៏តែងមានភ្លៀងបង្អុរចុះនៅតំបន់ ជនបទនោះ ៗ ។ ដូច្នេះ គួរតែព្រះសម្មតិទេព បញ្ជូនព្រាហ្មណ៍ ទាំងឡាយឲ្យទៅសុំដំរីពីរាជបុត្រវេស្សន្តរនោះមក ប្រញាប់ចេញ ព្រះរាជបញ្ជាទៅ ក្រាបទូល" ។

ព្រះរាជា យល់ស្របតាមយោបល់អ្នកនគរ ទ្រង់កោះហៅប្រជុំ ពួកព្រាហ្មណ៍ ជ្រើសយកតែ ៨ នាក់ក្នុងនោះ ចំពោះតែព្រាហ្មណ៍ណា ដែលពូកែខាងវោហារពណ៌នាគុណ រួចទ្រង់ថ្វាយស្បៀងដល់ពួកគេ បង្គាប់ថា "អញ្ជើញទៅចុះ! អ្នកទាំងឡាយ សុំដំរីនឹងវេស្សន្តរបាន

ហើយ ចូរនាំដំរីមក" ។ ព្រាហ្មណ៍ទាំងឡាយ កាលដែលធ្វើដំណើរទៅកាន់ជេតុត្តរនគរ តាមលំដាប់លំដោយ ពួកគេបានបរិភោគបាយក្នុងរោងទាន រួចនាំគ្នាលាបស្រឡាបសរីរៈខ្លួនដោយអាចម៍ដី ដែលពោរពាសដោយល្អងធូលីប៉ងសូមនូវដំរីនឹងព្រះមហាក្សត្រ ។ លុះដល់កាលនៃព្រះមហាក្សត្រ ស្ដេចយាងមកកាន់រោងទាន ពួកគេបានមកកាន់ទ្វារនៅទិសខាងកើត ។ រីឯព្រះរាជា ទ្រង់ព្រះតម្រិះថា "អញនឹងគន់មើលនូវរោងទាន រួចទ្រង់ស្រង់ទឹកពេលព្រលឹម សោយនូវក្រយាស្ងោយមានរសឆ្ងាញ់ផ្សេង ៗ តុបតែងខ្លួនប្រាណ ហើយឡើងជិះលើ-កនៃដំរីដែលគេតុបតែងស្រេច យាងទៅទ្វារទិសខាងកើត ។ ព្រាហ្មណ៍ទាំងឡាយ មិនបានឱកាសក្នុងទីនោះសោះ ក៏នាំគ្នាទៅទ្វារខាងត្បូង ឈរលើទីទួលមួយកន្ទែង ។ ក្នុងកាលព្រះរាជាគន់មើលរោងទាននៅទិសខាងកើតរួច ស្ដេចយាងមកកាន់ទ្វារខាងត្បូង ព្រាហ្មណ៍ទាំងនោះបានលាដៃ នាំគ្នាពោល ៣ ដងថា ៖

"ជយោ ព្រះវេស្សន្តរ ៗ" ។

**ព្រះវេស្សន្តរប្រទានដំរីមង្គល**

ព្រះមហាសត្វ ទតមើលព្រាហ្មណ៍ទាំងនោះ ហើយបញ្ជាដំរីឲ្យទៅកាន់កន្លែងឈររបស់ពួកគេ ទ្រង់គង់នៅលើ-កនៃដំរីនៅឡើយ បានត្រាស់ថា ៖

"បរូឡ្ហកច្ឆនខលោមា, បង្កទន្តា រជស្សិរា;
បគ្គយ្ហ ទក្ខិណំ ពាហុំ, កិំ មំ យាចន្តិ ព្រាហ្មណា"។

"ពួកព្រាហ្មណ៍មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ផ្គងដើមដៃខាងស្តាំ តើសូមអ្វីនឹងអញ" ។

ព្រាហ្មណ៍ទាំងឡាយ បានក្រាបទូលថា ៖

"រតនំ ទេវ យាចាម, សិវីនំ រដ្ឋវឌ្ឍនំ
ទទាហិ បវរំ នាគំ, ឦសាទន្តំ ឧរូឡ្ហវំ"។

"បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំសូមក្រាបបង្គំសុំនូវដំរីកែវដែលជាសត្វញ៉ាំងដែននៃពួកអ្នកសិវិរាស្ត្រឲ្យចម្រើន, សូមព្រះ

អង្គ ទ្រង់ព្រះរាជទានដំរីដ៏ប្រសើរ ដែលមានភក្ដ-ធំទន្ទាំ[២២] អាច
ញុំាញីសត្រូវបាន ក្រាបទូល" ។

ព្រដូច្នោះហើយ ព្រះមហាសត្តមានព្រះតម្រិះថា "អាត្មាអញមាន
បំណងឲ្យនូវអជ្ឈត្តិកទាន មានក្បាលជាដើម ប៉ុន្តែពួកព្រាហ្មណ៍នេះ
សូមអញ ត្រឹមតែពាហិរកទានប៉ុណ្ណោះ អញត្រូវតែបំពេញបំណង
របស់ពួកគេ" គិតដូច្នេះរួច ទ្រង់នៅលើ-កនៃដំរីត្រាស់ដូច្នេះ ៖

"ព្រាហ្មណ៍ទាំងឡាយ សុំដំរីណានឹងអញ ទោះជាដំរីចុះប្រេង ជា
កុញ្ជរជាតិ មានភក្ដដ៏ល្អ ជាដំរីដ៏ប្រសើរ គួរជារាជពាហនៈ អញ
នឹងឲ្យដំរីនោះ អញមិនញាប់ញ័រឡើយ" ។

លុះប្ដេជ្ញាដូច្នេះហើយព្រះរាជាដែលជាអ្នកញុំាងពួកអ្នកសិវិរាស្ត្រ
ឲ្យចម្រើន ទ្រង់មានព្រះហឫទ័យប្រាថ្នាយ៉ាងលើសលុបក្នុងការបរិច្ចាគ
ទ្រង់ចុះចាកកនៃដំរី ធ្វើប្រទក្សិណ ៣ ជុំ ដើម្បីគន់មើល នូវកន្លែងពុំ
បានតុបតែងរបស់ដំរី ហើយទ្រង់រកពុំឃើញ នូវកន្លែងដែលគេមិនបាន
ប្រដាប់សោះ រួចទ្រង់ចាប់កុណ្ឌីមាសដែលពេញដោយទឹកក្រអូប

[២២] ដែលមានលំនាំរាងធំទ្រទ្រូយ, រំពើន ។

លាយដោយផ្កាម្ទិះ ត្រាស់ថា "អ្នកទាំងឡាយ ចូរមកណោះ" ទ្រង់ចាប់ប្រមោយដំរីដែលប្រៀបដូចផ្លូងប្រាក់វិចិត្រ ដាក់ទៅលើដៃនៃព្រាហ្មណ៍ទាំងនោះ ហើយទ្រង់ច្រូចទឹក ប្រទានដំរីដែលប្រដាប់តុបតែង ហើយធ្វើជាទានដល់ពួកព្រាហ្មណ៍ ។

និយាយពីគ្រឿងអលង្ការ នៅត្រង់ជើងទាំង ៤ របស់ដំរី មាន តម្លៃ ៤០០.០០០ កហាបណៈ ។ សំពត់កម្ពលខាងក្រោមពោះថ្លៃ ១០០.០០០ កហាបណៈ ។ ស្បៃកែវមុក្តា ស្បៃកែវមណី ស្បៃមាស ដែលនៅលើខ្នងទាំង ៣ នេះ ថ្លៃ ៣០០.០០០ កហាបណៈ ។ គ្រឿង អលង្ការត្រង់ត្រចៀកសងខាង ថ្លៃ ២០០.០០០ កហាបណៈ ។ កម្រាល សំពត់កម្ពលលើខ្នង ថ្លៃ ១០០.០០០ កហាបណៈ ។ គ្រឿងអលង្ការនៃ កូបដំរី ថ្លៃ ១០០.០០០ កហាបណៈ ។ រយាងទាំង ៣ ថ្លៃ ៣០០.០០០ កហាបណៈ។ គ្រឿងអលង្ការលើត្រចៀក ថ្លៃ ២០០.០០០ កហាបណៈ។ គ្រឿងអលង្ការ នៃភ្លុកទាំងពីរ ថ្លៃ ២០០.០០០ កហាបណៈ ។ គ្រឿងអលង្ការការពារ សុវត្ថិភាពប្រមោយ ថ្លៃ ១០០.០០០ កហាបណៈ ។ គ្រឿងអលង្ការត្រង់ កន្ទុយ ថ្លៃ ១០០.០០០ កហាបណៈ ។ ខ្សែបង្ហោង ថ្លៃ ១០០.០០០ កហាបណៈ ។ ស្នូកចំណី ថ្លៃ ១០០.០០០ កហាបណៈ ។ គ្រឿងប្រដាប់ដែលនៅលើកាយ លើកលែងតែកណ្ឌៈកាត់ថ្លៃមិនបាន

ចេញ មានតម្លៃ ២២០០.០០០ កហាបណៈ ។ សរុបមក ទ្រព្យប៉ុណ្ណេះ ថ្លៃ ២៤០០.០០០ កហាបណៈ ។ ឯកណ្ឌៈដែលកាត់ថ្លៃមិនបាន មាន ៧ គឺ កែវមណីលើដុំឆត្រ១ ចូឡាមណី ១ មុក្តាហារមណី ១ កង្វេរមណី ១ មុក្តាហារមណីដែលរុំកដំរី ១ កែវមណីលើក្បូបដំរី ១ រួមជាមួយនឹង ដំរីដែលកាត់ថ្លៃមិនបាន ១ រួម ទាំង ៧ នេះ គឺព្រះវេស្សន្តរបានប្រទានដល់ព្រាហ្មណ៍ទាំងឡាយនោះ អស់ឥតមានសេសសល់ ។ ជាមួយគ្នានោះដែរ ព្រះវេស្សន្តរ បានប្រទានអ្នកបម្រើដំរី ៥០០ ត្រកូល ជាមួយនឹងអ្នកបរដំរីនិងអ្នកគ្រប់គ្រងដំរីជាច្រើននាក់ទៀត ។ ដំណាលគ្នានឹងការប្រទានរបស់ព្រះអង្គហ្នឹងឯង ការរញ្ជួយផែនដី ការកើតហេតុគួរខ្លាច គួរព្រឺរោម ក៏មានឡើងក្នុងកាលនោះ តាមន័យដូចពោលខាងដើម ។ បន្ទាប់ពីព្រះរាជា ទ្រង់ប្រទានដំរីដ៏ប្រសើរ ដែលជាដំរីញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ផែនដីក៏កម្រើកញាប់ញ័រ ការកើតហេតុគួរខ្លាចគួរព្រឺរោម ក៏មាន អ្នកនគរក៏ជ្រួលជ្រើម អ្នកបុរីក៏ជ្រួលច្របល់ ទាំងសំឡេង ក៏គឹកកងរំពងខ្លាំង ។

បានឮថា ព្រាហ្មណ៍ទាំងឡាយ បានដំរីនៅទ្វារខាងត្បូង នាំគ្នាជិះលើខ្នងដំរី មានមហាជនជាបរិវារបរទៅតាមកណ្តាលនគរ ។ មហាជនឃើញពួកគេ ក៏ស្រែកសួរថា ៖

"នែព្រាហ្មណ៍អើយ ពួកឯងកំពុងជិះដំរីយើង តើពួកឯងបានដំរីអំពីណា ?" ។

ពួកព្រាហ្មណ៍ឆ្លើយថា ៖

"ព្រះបាទវេស្សន្តរ ទ្រង់ប្រទានឲ្យពួកយើងហើយ តើពួកឯងជានរណា ?" ។

ពួកព្រាហ្មណ៍ទាំងនោះ ឌឺដាក់មហាជនដោយក្បាច់ដៃជាដើម កាត់តាមកណ្តាលនគរ ចេញទៅតាមទ្វារខាងជើង ។ អ្នកនគរក្រោធខឹងចំពោះ ព្រះពោធិសត្វ ដោយសារការពង្វក់ចិត្តរបស់ទេវតា ពួកគេប្រជុំគ្នានៅត្រង់ទ្វារព្រះបរមរាជវាំង ស្រែកតិះដៀលយ៉ាងខ្លាំង ៗ ។ គ្រានោះ សំឡេងយ៉ាងខ្លាំងពន្លឹក ជាសំឡេងគួរខ្លាច ក៏ប្រព្រឹត្តទៅក្នុងនគរនោះ ក្នុងកាលនោះ អ្នកនគរក៏ជ្រួលជ្រើម ។

**អ្នកនគរប្ដឹងព្រះវេស្សន្តរ**

កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ជាដំរីញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន គ្រានោះ សំឡេងយ៉ាងខ្លាំងពន្លឹក គួរខ្លាច ប្រព្រឹត្តទៅ

ក្នុងនគរនោះ ។ គ្រានោះ ដោយទានរបស់ព្រះវេស្សន្តរ ពួកជនអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្រ ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកទាហានដំរី ទាហានសេះ ទាហានរថ និងពលថ្មើរជើង អ្នកនិគមទាំងអស់ និងពួកអ្នកសិវិរាស្រ្ត ក៏មកប្រជុំគ្នា ពួកជនទាំងនោះ បានឃើញដំរីដែលពួកព្រាហ្មណ៍កំពុងនាំទៅ ក៏ក្រាបទូលចំពោះព្រះរាជា ទ្រង់ព្រះនាមសញ្ជ័យថា ៖

“វិធមំ ទេវ តេ រដ្ឋំ, បុត្តោ វេស្សន្តរោ តវ;
កថំ នោ ហត្ថិនំ ទជ្ជា, នាគំ រដ្ឋស្ស បូជិតំ។

កថំ នោ កុញ្ជរំ ទជ្ជា, ឦសាទន្តំ ឧរូឡ្ហវំ;
ខេត្តញ្ញុំ សព្វយុទ្ធានំ, សព្វសេតំ គជុត្តមំ។

បណ្ឌុកម្ពលសញ្ឆន្នំ, បភិន្នំ សត្តុមទ្ទនំ;
ទន្តឹ សវាលពីជនឹ, សេតំ កេលាសសាទិសំ។

សសេតច្ឆត្តំ សឧបាធេយ្យំ, សាថព្វនំ សហត្ថិបំ;
អគ្គយានំ រាជវាហឹ, ព្រាហ្មណានំ អទា គជំ”។

"បពិត្រព្រះសម្មតិទេព ដែនរបស់ព្រះអង្គសាបសូន្យហើយ ដោយសារព្រះវេស្សន្តរជាព្រះរាជបុត្ររបស់ព្រះអង្គ ។ ព្រះរាជបុត្ររបស់ព្រះអង្គ ម្ដេចក៏ប្រទានដំរីដ៏ប្រសើរឧត្តម ដែលអ្នកដែនបូជាជាដំរីកុញ្ជរ មានភ្លុក-ងទន្ទាំ អាចញាំញីសត្រូវបាន ជាសត្វស្គាល់ខេត្តចម្បាំងទាំងអស់របស់យើងអ៊ីចឹង ? ។ ដំរីយើងនោះមានខ្លួនពាសដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេង ញាំញីសត្រូវបាន មានភ្លុកដ៏ល្អ ប្រកបដោយសៃ ជាដំរី-ស ប្រហែលនឹងភ្នំកៃលាស ។ ព្រះរាជបុត្ររបស់ព្រះអង្គ បានប្រទានដំរីជារាជពាហនៈ ជាយានដ៏ប្រសើរ ព្រមទាំងស្វេតច្ឆត្រ ព្រមទាំងកម្រាលសម្រាប់ក្រាលលើខ្នង ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សាដំរីទៅឲ្យជាទានដល់ពួកព្រាហ្មណ៍ហើយ ព្រះអង្គ" ។

លុះពោលយ៉ាងនេះហើយ ពួកគេបានពោលបន្ថែមថា ៖

"អន្នំ បានញ្ច យោ ទជ្ជា, វត្ថសេនាសនានិ ច;
ឯតំ ខោ ទានំ បតិរូបំ, ឯតំ ខោ ព្រាហ្មណារហំ ។
អយំ តេ វំសរាជា នោ, សិវីនំ រដ្ឋវឌ្ឍនោ;
កថំ វេស្សន្តរោ បុត្តោ, គជំ ភាជេតិ សញ្ចយ ។

សចេ ត្វំ ន ករិស្សសិ, សិវីនំ វចនំ ឥធំ;
មញ្ញេ តំ សហ បុត្តេន, សិវី ហត្ថេ ករិស្សរេ"។

"ព្រះរាជបុត្ររបស់ព្រះអង្គនោះ បើឲ្យត្រឹមតែបាយទឹក សំពត់ និងសេនាសនៈ នោះមិនជាថ្វីទេ ព្រោះថា វត្ថុនោះឯងជារបស់គួរដល់ទាន គួរដល់ព្រាហ្មណ៍ ។ បពិត្រព្រះបាទសញ្ជ័យ ព្រះវេស្សន្តរ ជាបុត្ររបស់ព្រះអង្គនេះ ជាព្រះឱរសកើតក្នុងវង្សរបស់ព្រះអង្គ ជាអ្នកញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ម្ដេចក៏ប្រទានដំរីទៅឲ្យព្រាហ្មណ៍ ។ ថាបើព្រះអង្គមិនធ្វើតាមសម្ដីរបស់ពួកអ្នកដែនសិវិនេះទេ ប្រាកដជាពួកអ្នកសិវិរាស្ត្រ ធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្រឲ្យឋិតនៅក្នុងកណ្ដាប់ដៃមិនខាន" ។

ឮដូច្នោះ ព្រះបាទសញ្ជ័យសម្គាល់ថា "ពួកនេះចង់ឲ្យអញសម្លាប់បុត្រវេស្សន្តរទេតើ" រួចទ្រង់តបទៅថា ៖

"កាមំ ជនបទោ មាសិ, រដ្ឋញ្ចាបិ វិនស្សតុ;
នាហំ សិវីនំ វចនា, រាជបុត្តំ អទូសកំ;
បព្វាជេយ្យំ សកា រដ្ឋា, បុត្តោ ហិ មម ឱរសោ។

កាមំ ជនបទោ មាសិ, រដ្ឋញ្ចាបិ វិនស្សតុ;
នាហំ សិវីនំ វចនា, រាជបុត្តំ អទូសកំ;
បព្វាជេយ្យំ សកា រដ្ឋា, បុត្តោ ហិ មម អត្រជោ។
ន ចាហំ តស្មឹ ទុព្ភេយ្យំ, អរិយសីលវតោ ហិ សោ;
អសិលោកោបិ មេ អស្ស, ចាបញ្ច បសវេ ពហុំ;
កថំ វេស្សន្តរំ បុត្តំ, សត្ថេន ឃាតយាមសេ”។

*“ជនបទសាបសូន្យ សាបសូន្យទៅចុះ, ដែនហិនហោច ក៏ហិនហោចទៅចុះ, យើងនឹងមិនបណ្តេញរាជបុត្រអ្នកមិនប្រទូស្តឲ្យចេញចាកដែន តាមសម្តីរបស់ពួកអ្នកសិវិរាស្ត្រទេ ដ្បិតរាជបុត្រនេះ ពិតជាកើតអំពីទ្រូងរបស់យើង ។ ជនបទសាបសូន្យទៅចុះ ទាំងដែនក៏ហិនហោចទៅចុះ យើងនឹងមិនបណ្តេញរាជបុត្រអ្នកមិនប្រទូស្តឲ្យចេញចាកដែនរបស់ខ្លួន តាមសម្តីរបស់ពួកអ្នកសិវិរាស្ត្រទេ ដ្បិតកូនប្រុសនេះ ពិតជាកើតអំពីខ្លួនរបស់យើង ។ មួយទៀត យើងមិនគួរប្រទូស្តចំពោះបុត្រយើងនោះទេ ព្រោះថាបុត្រយើងនោះជាអ្នកមានសីលនិងវត្តដ៏ប្រសើរ តំណិះដំណៀល*

នឹងមានដល់យើងផង យើងត្រូវទទួលរងបាបច្រើនផង តើយើងនឹងពិឃាតវេស្សន្តរជាបុត្រដោយគ្រឿងសស្ត្រាវុធដូចម្ដេចបាន" ។

ពួកអ្នកដែនសិវិ ឮដូច្នោះ ក៏បានទូលតបថា ៖

"មា នំ ទណ្ឌេន សត្ថេន,     န ហិ សោ ពន្ធនារហោ;
បព្វាជេហិ ច នំ រដ្ឋា,     វង្កេ វសតុ បព្វតេ" ។

"សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រនោះ ដោយដំបង ឬគ្រឿងសស្ត្រាវុធឡើយ ព្រោះព្រះរាជបុត្រនោះ មិនគួរដល់ចំណងទេ ព្រះអង្គគ្រាន់តែបណ្ដេញព្រះរាជបុត្រនោះ ចេញអំពីដែនទៅសមល្មមណាស់ទៅហើយ ឲ្យព្រះរាជបុត្រនោះទៅគង់នៅឯភ្នំគិរីវង្កតបុះ" ។

ព្រះរាជា ត្រាស់ថា ៖

"ឯសោ ចេ សិវីនំ ឆន្ទោ, ឆន្ទំ ន បនុទាមសេ;
ឥមំ សោ វសតុ រត្តិំ, កាមេ ច បរិភុញ្ជតុ ។
តតោ រត្យា វិវសានេ, សុរិយស្សុគ្គមនំ បតិ;

សមគ្គា សិវយោ ហុត្វា, រដ្ឋា បព្វាជយន្តុ នំ"។

"ថាបើពួកអ្នកដែនសិវិ មានបំណងបែបនេះទៅហើយ យើងក៏មិនអាចទប់បំណងនេះបានដែរ តែយើងសុំអនុញ្ញាតឲ្យកូនយើងនៅបរិភោគកាមបានមួយរាត្រីនេះសិន គ្រាន់នឹងបានគេផ្តល់ជំបូន្មានអប់រំកូនប្រពន្ធ ដូច្នេះសូមអ្នកទាំងឡាយផ្តល់ឱកាសឲ្យកូនយើងតែមួយរាត្រី ។ ដល់រាត្រីកាលមួយនេះអស់ហើយ ព្រះអាទិត្យផ្តើមរះឡើង សូមឲ្យពួកអ្នកសិវិរាស្ត្រព្រមព្រៀងគ្នាបំបរបង់កូនរបស់យើងចេញអំពីដែនចុះ" ។

ពួកអ្នកនគរ បានយល់ស្រប នូវពាក្យរបស់ព្រះរាជាថា "ត្រឹមតែមួយរាត្រី ឲ្យនៅបាន" ។ គ្រានោះ ព្រះរាជាបានបញ្ជូនពួកគេទៅហើយ ហៅបម្រើម្នាក់ឲ្យយករាជសារទៅកាន់សម្នាក់របស់រាជបុត្រជាប្រញាប់ ។ អាមាត្យបម្រើនោះ លុះព្រះបាទសិវិទ្រង់បញ្ជូនទៅ ក៏ប្រញាប់ប្រញាល់ងូតទឹកកក់ក្បាល ពាក់គ្រឿងប្រដាប់ដៃស្លៀកសំពត់ល្អ ប្រោះព្រំដោយខ្លឹមចន្ទន៍ ពាក់កុណ្ឌលកែវមណី ចូលទៅកាន់ព្រះរាជនិវេសន៍នៃព្រះបាទវេស្សន្តរដែលជាបុរីរម្យ ។ អាមាត្យនោះបានឃើញព្រះរាជកុមារវេស្សន្តរ កំពុងរីករាយក្នុងបុរីរបស់ព្រះអង្គនោះ

ដ៏កុះករដោយពួកអាមាត្យ ដូចព្រះវាសវៈរបស់ទេវតាជាន់ត្រៃត្រិង្ស ។ អាមាត្យនោះ ប្រញាប់ប្រញាល់ទៅក្នុងរាជបុរីនោះហើយ ក្រាបទូលព្រះបាទវេស្សន្តរថា ៖

"បពិត្រព្រះអង្គដ៏ប្រសើរលើរថ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលអំពីសេចក្តីទុក្ខដែលនឹងកើតឡើងដល់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងទូលព្រះបង្គំជាខ្ញុំឡើយ"

និយាយប៉ុណ្ណោះ អាមាត្យនោះថ្វាយបង្គំយំទួញក្រាបបង្គំទូលថា ៖

"បពិត្រមហារាជ ព្រះអង្គតែងនាំមកនូវរសជាទីប្រាថ្នាគ្រប់យ៉ាងមកចិញ្ចឹមទូលព្រះបង្គំជាខ្ញុំ ទូលបង្គំជាខ្ញុំនឹងក្រាបទូលសេចក្តីទុក្ខដែលនឹងកើតមានដល់ព្រះអង្គ សូមព្រះករុណាថ្លៃវិសេសឲ្យទូលព្រះបង្គំដកដង្ហើមស្រួល ក្នុងការពិតទូលនោះផង ក្រាបទូល ។ បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្ត្រ, ពួកអ្នកនិគម, ពួកអ្នកមានកេរ្តិ៍ឈ្មោះ, ពួករាជបុត្រ, ពួកអ្នកជំនួញ, និងពួកព្រាហ្មណ៍, ជួបជុំគ្នាខឹងសម្បានឹងព្រះអង្គខ្លាំងណាស់ ។ ពួកទ័ពដំរី ទ័ពសេះ ទ័ពរថ និងទ័ពថ្មើរជើង ព្រមទាំងអ្នកនិគមទាំងអស់ និងពួកអ្នកសិវិរាស្ត្របានមកជួបជុំគ្នា រង់ចាំតែរាត្រីនេះកន្លងទៅ ព្រះអាទិត្យរះឡើង

ពួកគេនឹងព្រមព្រៀងគ្នាបណ្តេញព្រះអង្គចាកដែនពុំខានឡើយ ក្រាបទូល" ។

ព្រះមហាសត្វ ពោលថា ៖

"ព្រោះហេតុដូចម្តេច បានជាពួកអ្នកសិវិរាស្ត្រខឹងនឹងយើង ដ្បិតយើងរកមិនឃើញកំហុសខ្លួនអ្វីសោះ ? ម្នាលអាមាត្យ អ្នកចូរប្រាប់យើងមកថាតើគេចង់បណ្តេញយើង ព្រោះហេតុអ្វី ?" ។

អាមាត្យពោលថា ៖

"ពួកអ្នកមានកេរ្តិ៍ឈ្មោះ, ពួករាជបុត្រ, ពួកអ្នកជំនួញ, ពួកព្រាហ្មណ៍, ពួកទាហានដំរី, ទាហានសេះ, ពលរថ, និងពលថ្មើរជើង កំពុងតែខឹងនឹងព្រះអង្គសម្បើម[២៣]ណាស់ ព្រោះតែព្រះអង្គបានប្រទានដំរីទៅគេ ហេតុនោះបានជាគេរកបណ្តេញព្រះអង្គ ក្រាបទូល" ។

ឮដូច្នោះ ព្រះមហាសត្វបានពោលតបទាំងមានសោមនស្ស ៖

"យើងចង់ឲ្យបេះដូងឬភ្នែកជាទានទៀតផង ចុះទម្រាំទ្រព្យជាខាងក្រៅ ដូចជាប្រាក់ មាស កែវមុក្តា កែវពិទូរ្យ និងកែវមណី តើយើងនឹងខ្លាចឲ្យទានដូចម្តេច ? បើយើងបានឃើញស្មូមមកសុំ

---

[២៣] ដែលគួរស្ញើម, គួរកោត, គួរស្ញប់ស្ញែង ។

ដៃស្តាំឬដៃឆ្វេងយើង យើងមុខតែឲ្យដោយមិនញាប់ញ័រចិត្តទេ ព្រោះថា ចិត្តរបស់យើងតែងរីករាយក្នុងការឲ្យទាន ។ ពួកអ្នកសិវិរាស្ត្រទាំងអស់នោះ ចង់បណ្តេញយើងក្តី ចង់សម្លាប់យើងក្តី ក៏យើងមិនងាកវេពីការឲ្យទានទេ អ្នកដែនទាំងអស់នោះ ចង់កាត់យើងជាប្រាំពីរកំណាត់ក៏ដោយចុះ" ។

ឮដូច្នោះ អាមាត្យបានពោលនូវសារមួយផ្សេង មិនមែនព្រះរាជាឲ្យ មិនមែនអ្នកនគរឲ្យ គឺគេពោលតាមមតិរបស់ខ្លួនតែប៉ុណ្ណោះ ៖

"ពួកអ្នកសិវិរាស្ត្រ និងពួកអ្នកនិគម ប្រជុំគ្នានិយាយអំពីព្រះអង្គយ៉ាងនេះថា ពួកអ្នកទោសត្រូវនិរទេស តែងទៅតាមឆ្នេរទន្លេកោន្តិមារាណា ព្រះបាទវេស្សន្តរដែលមានវត្តល្អ ចូរយាងសំដៅទៅកាន់ភ្នំអារញ្ញរា តាមឆ្នេរទន្លេកោន្តិមារានោះចុះ" ។

បានឮថា អាមាត្យនោះ ត្រូវទេវតាជ្រែក ទើបបាននិយាយនូវពាក្យនេះឡើង ។

ឮដូច្នោះ ព្រះពោធិសត្វបាននិយាយថា ៖

"ប្រពៃណាស់ យើងនឹងទៅតាមផ្លូវ ដែលអ្នកទោសទាំងឡាយបានដើរទៅ ពិតណាស់ អ្នកនគរទាំងឡាយនិរទេសខ្ញុំ មិនមែន

ដោយទោសដទៃទេ គឺពួកគេនិរទេសខ្ញុំព្រោះតែខ្ញុំបានធ្វើទានដំរី បើទោះជាយ៉ាងនេះក៏ដោយ ខ្ញុំនឹងឲ្យសត្តសតកមហាទាន សូមឲ្យអ្នកនគរទាំងឡាយ ផ្តល់ឱកាសឲ្យខ្ញុំបានធ្វើទានមួយថ្ងៃទៀតសិន ដល់ថ្ងៃស្អែក ខ្ញុំនឹងឲ្យទាន ដល់ថ្ងៃខានស្អែកខ្ញុំនឹងចេញចាកព្រះនគរ"

រួចព្រះអង្គបន្តពោលថា ៖

"ពួកជនអ្នកប្រទូស[២៤] តែងទៅតាមផ្លូវណា យើងនឹងទៅតាមផ្លូវនោះ តែសូមឲ្យអ្នកទាំងឡាយ អត់ទោសដល់យើងបានមួយយប់មួយថ្ងៃ ចាំយើងឲ្យទានសិន" ។

ព្រះដូច្នោះ អាមាត្យក្រាបទូលថា ៖

"ព្រះករុណាថ្លៃវិសេស ទូលបង្គំនឹងប្រាប់ពួកអ្នកនគរ"

និយាយដូច្នេះរួច អាមាត្យនោះក៏បានចៀសចេញទៅ ។

ក្រោយពីបញ្ជូនអាមាត្យនោះទៅ ព្រះមហាសត្តបានប្រើឲ្យគេទៅហៅមហាសេនគុត្តឲ្យមកចូលគាល់ទ្រង់ រួចទ្រង់បង្គាប់ឲ្យជួយចាត់ចែងសត្តសតកមហាទានដូច្នេះ ៖

---

[២៤] បៀតបៀន, រករឿងរកហេតុធ្វើឲ្យអាក្រក់, ឲ្យវិនាស ។

"នៃអ្នក ក្នុងថ្ងៃស្អែក ខ្ញុំនឹងឲ្យមហាទាន ឈ្មោះថា សត្តសតកៈ គឺដំរី ៧០០, សេះ ៧០០, រថ ៧០០, ស្ត្រី ៧០០, មេដោះ ៧០០, ទាសៈ ៧០០, ទាសី ៧០០ សូមអ្នកជួយចាត់ចែងរបស់អស់ទាំងនេះឲ្យផង សូម្បីបាយនិងទឹកជាដើម មានប្រការផ្សេង ៗ ក៏សូមជួយចាត់ចែងរបស់ទាំងអស់ដែលគួរឲ្យដោយហោចទៅ សូម្បីតែស្រា ក៏ចូរអ្នកជួយចាត់តាំងផង" ។

## ព្រះវេស្សន្តរផ្តាំនាងមទ្រី

ចាត់ដូច្នេះរួច ព្រះមហាសត្វបានបញ្ជូនអាមាត្យទាំងឡាយឲ្យទៅអស់ នៅសល់តែទ្រង់មួយអង្គឯង ស្តេចក៏យាងទៅរាជដំណាក់របស់ព្រះនាងមទ្រី គង់ប្រថាប់លើគ្រែសយនា ហើយបានចរចាជាមួយនឹងព្រះនាងមទ្រីទេវី ដែលមានអវយវៈដ៏ល្អទាំងអស់នោះថា ៖

"ទ្រព្យស្រូវណាមួយ ដែលយើងឲ្យដល់នាង នៅមានក្តី ប្រាក់ មាស, កែវមុក្តា, កែវពិទូរ្យ[២៥] ណា ដ៏ច្រើនក្តី ទ្រព្យណាជារបស់ព្រះបិតានាងក្តី នាងគប្បីកប់ទ្រព្យទាំងអស់នោះទុកចុះ" ។

រាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈល្អទាំងអស់ គិតថា វេស្សន្តរស្វាមីរបស់អញ អស់កាលប៉ុណ្ណោះហើយ មិនដែលប្រាប់ ឲ្យអញកប់ទ្រព្យសោះ ចម្លែកអ្វីតែឥឡូវនេះ ទ្រង់ប្រាប់ តើត្រូវកប់ទុកនៅទីណា អញនឹងសួរព្រះអង្គមើល គិតដូច្នេះរួច ព្រះនាងបានក្រាបបង្គំទូលសួរព្រះរាជានោះថា ៖

"បពិត្រព្រះទេវៈ តើខ្ញុំម្ចាស់នឹងកប់ទុកក្នុងទីណា ? សូមព្រះអង្គប្រាប់ខ្ញុំម្ចាស់ផង ព្រះអង្គ" ។

---

[២៥] ពេជ្រភ្នែកឆ្មា ។

ព្រះវេស្សន្តរ បានឆ្លើយថា ៖

"ម្នាលមទ្រីមហេសីមាសបង នាងគួរឲ្យទានចំពោះអ្នកមានសីលទាំងឡាយ តាមសមគួរ ព្រោះថាទីពឹងរបស់សព្វសត្វទាំងឡាយក្រៅអំពី ទាននេះ មិនមានទេ ។ ពិតណាស់ មិនមានទីពឹងដែលល្អលើសជាងទានឡើយ"។

"ចាស" ព្រះនាងមទ្រីទេវី ទទួលស្តាប់ពាក្យរបស់ព្រះមហាសត្ត ។

គ្រានោះ ព្រះវេស្សន្តរបានឲ្យដំបូន្មានបន្ថែម ដល់ព្រះនាងថា ៖

"ម្នាលនាងមទ្រី នាងត្រូវមានមេត្តាចំពោះបុត្រ ព្រះមាតាក្មេក និងព្រះបិតាក្មេក មួយទៀត បើមានបុរសណាសក្តិសមនឹងធ្វើជាស្វាមីនាង នាងចូរបម្រើអ្នកនោះ ដោយគោរពចុះ ។ បើគ្មានបុរសណាសក្តិសមនឹងធ្វើជាស្វាមីនាងទេ នាងចូរស្វែងរកស្វាមីដទៃទៀតចុះ កាលណាបើនាងព្រាត់ប្រាសពីយើងទៅ សូមនាងកុំលំបាក ព្រោះព្រាត់ប្រាសយើងឡើយ" ។

គ្រានោះ ព្រះនាងមទ្រីគិតថា ហេតុម្តេចព្រះវេស្សន្តរនោះ និយាយនឹងនាង នូវពាក្យបែបនេះ ក៏មានព្រះសវនីយ៍សួរព្រះវេស្សន្តរថា ៖

"បពិត្រព្រះសម្មតិទេព ព្រោះហេតុអ្វី ព្រះអង្គត្រាស់ព្រះរាជឱង្ការមិនគប្បីយ៉ាងនេះ?"

ព្រះមហាសត្វ ឆ្លើយថា ៖

"ហៃមហេសីសម្លាញ់ ពួកអ្នកសិវិរាស្ត្រក្រោធខឹងនឹងបង ពួកគេនិរទេសបងឲ្យចេញចាកដែន ព្រោះតែបងបានឲ្យដំរីទៅជាទានថ្ងៃស្អែក បងនឹងឲ្យសត្តសតកមហាទាន លុះចូលដល់ថ្ងៃទី ៣ បងនឹងចេញចាកព្រះនគរ"

និយាយដូច្នេះហើយ ព្រះវេស្សន្តរបន្តប្រាប់នាងមទ្រីថា ៖

"ព្រោះបងនឹងទៅកាន់ព្រៃដែលសម្បូរដោយម្រឹគកាចសាហាវដូច្នេះ ទើបបងគិតថា ជីវិតរស់នៅក្នុងព្រៃម្នាក់ឯង មិនដឹងជារស់ឬស្លាប់យ៉ាងណាទេ" ។

**ព្រះនាងមទ្រីសូមរួមដំណើរនៅព្រៃ**

ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី មានអវយវៈល្អទាំងអស់ នាងបានក្រាបទូលព្រះបាទវេស្សន្តរនោះថា ៖

"ថ្វីក៏ព្រះអង្គមានព្រះបន្ទូលដែលពុំធ្លាប់មាន? ព្រះអង្គមានព្រះបន្ទូលអាក្រក់អ្វីម្ល៉េះ ក្រាបទូល? ។ បពិត្រមហារាជ ដំណើរនោះមិនត្រូវតាមធម៌ទេ ដ្បិតព្រះអង្គទ្រង់ស្តេចយាងទៅតែមួយអង្គ

ឯង បពិត្រក្សត្រិយ៍ ព្រះអង្គស្តេចយាងទៅតាមផ្លូវណា ខ្ញុំម្ចាស់នឹងទៅតាមផ្លូវនោះដែរ ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី សេចក្តីរស់នៅតែព្រាត់ប្រាសចាកព្រះអង្គក្តី សេចក្តីស្លាប់នោះឯង ប្រសើរជាង, ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គ មិនប្រសើរទេ ។ ខ្ញុំម្ចាស់នឹងដុតភ្លើងឲ្យឆេះសន្ធោសន្ធៅ ហើយលោតចូលទៅក្នុងភ្លើនោះឲ្យស្លាប់ ប្រសើរជាង, ខ្ញុំម្ចាស់រស់នៅ តែព្រាត់ប្រាសចាកព្រះអង្គ មិនប្រសើរទេ ។ មេដំរីតែងដើរតាមដំរីឈ្មោលដែលមានភ្លុកល្អ ក្នុងព្រៃ ទោះបីត្រាច់ទៅក្នុងជ្រោះ ជ្រលង ភ្នំស្មើខ្លះ មិនស្មើខ្លះក៏ដោយ យ៉ាងណាមិញ ។ ខ្ញុំម្ចាស់នឹងនាំបុត្រទាំងឡាយ ដើរតាមក្រោយព្រះអង្គយ៉ាងនោះដែរ ខ្ញុំម្ចាស់ជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយងាយ មិនមែនជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយក្រទេ" ។

លុះពោលយ៉ាងនេះហើយ ព្រះនាងមទ្រីនោះ បាននិយាយសរសើរនូវតំបន់ព្រៃហិមពាន្ត ហាក់ដូចជាធ្លាប់ឃើញម្តងទៀតថា ៖

"កាលព្រះអង្គបានទតឃើញកុមារទាំងនេះ ដែលមានសំឡេងពីរោះ និយាយសម្តីជាទីស្រឡាញ់ អង្គុយក្បែរគុម្ពឈើ ព្រះអង្គ

នឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះអង្គបានទតឃើញកុមារទាំង នេះ មានសំឡេងពីរោះ និយាយសម្តីជាទីស្រឡាញ់ កំពុងលេង ក្បែរគុម្ពឈើ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះអង្គ បានទត ឃើញកុមារទាំងនេះ មានសំឡេងពីរោះ និយាយពាក្យ ជាទីស្រឡាញ់ក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរលឹករាជ សម្បត្តិ ។ កាលព្រះអង្គទតឃើញកុមារទាំងនេះ មានសំឡេង ពីរោះ និយាយសម្តីជាទីស្រឡាញ់ កំពុងលេងក្បែរអាស្រមជាទី ត្រេកអរ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះអង្គទត ឃើញកុមារទាំងនេះ ពាក់កម្រងផ្កា មានខ្លួនប្រដាប់ ក្នុងអាស្រម ជារមណីយដ្ឋាន ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះ អង្គទតឃើញកុមារទាំងនេះ ពាក់កម្រងផ្កា មានខ្លួនប្រដាប់កំពុង លេងក្បែរអាស្រម ដែលជាទីត្រេកអរ ព្រះអង្គនឹងមិនរលឹករាជ សម្បត្តិ ។ កាលណាព្រះអង្គទតឃើញកុមារពាក់កម្រងផ្កា កំពុង រាំក្នុងអាស្រមជារមណីយដ្ឋាន ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ឡើយ ។ កាលណាព្រះអង្គទតឃើញកុមារពាក់កម្រងផ្កា កំពុង រាំលេងក្នុងអាស្រមជាទីត្រេកអរ នឹងមិនរលឹករាជសម្បត្តិ ។ កាល ណាព្រះអង្គទតឃើញដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ

ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញ ដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ ត្រាច់ទៅមករាល់ល្ងាចរាល់ព្រឹក ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ កាលដើរទៅខាង មុខនៃហ្វូងដំរីញីនិងហ្វូងដំរីឈ្មោល ហើយបន្លឺ-កោញ្ចនាទ ព្រះអង្គ បានទ្រង់ព្រះសណ្ដាប់ដំរីបន្លឺកោញ្ចនាទនោះហើយ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដងព្រៃសងខាង ផ្លូវជាទីឲ្យសេចក្ដីប្រាថ្នាក្នុងព្រៃ ដំដេរដាសដោយម្រឹគសាហាវ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គទតឃើញម្រឹគជាបញ្ចមាលិនី ដើរមកនឹងឃើញពួកកិន្នរដែលលំពុងរាំក្នុងវេលាល្ងាច ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គឮស្នូរសំឡេងគឹកកងនៃទន្លេ កំពុងហូរទៅផងឮចម្រៀងនៃពួកកិន្នរផង ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គឮស្នូរសំឡេងគឹកកងនៃសត្វមៀម ដែលត្រាច់ក្នុងញកនៃភ្នំ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គឮស្នូរសំឡេង គឹកនៃម្រឹគសាហាវក្នុងព្រៃ គឺរាជសីហ៍ ខ្លាធំ

រមាស គោព្រៃ នឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទត ឃើញក្ងោកឈ្មោល ដែលមានពួកក្ងោកញីចោមរោមជាសត្វដេរដាសដោយសំណុំកន្ទុយ ទំលើ កំពូលភ្នំ កំពុងពេនពង់ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះអង្គ ទតឃើញក្ងោក ឈ្មោល ដែលមានក្ងោកញីចោមរោមជាអណ្ដាជាតិមានភ្នែកដ៏វិចិត្រ កំពុងពេនពង់ ព្រះអង្គនឹងមិនរលឹករាជសម្បត្តិ ។

កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានក្ងោកញីចោមរោម ជាសត្វមានផ្នត់កខៀវ មានកំប៉ោយ កំពុងពេនពង់ នឹងមិនរលឹករាជសម្បត្តិ ។ កាលព្រះអង្គទតឃើញដើមឈើទាំងឡាយ មានផ្ការីកក្នុងហេមន្តរដូវ ផ្សព្វផ្សាយដោយក្លិនក្រអូប នឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញផែនដី មានស្មៅខៀវខ្ចី ក្នុងខែខាងក្នុងហេមន្តរដូវ ដ៏ដេរដាសដោយមេភ្លៀង នឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយ ដែលមានផ្ការីករាយស្គុះស្គាយ ក្នុងហេមន្តរដូវផង ដើមខ្ទឹងគង់ និងឈើដែលមានត្រួយ មានស្លឹកក្រហមផង ដើមលោទនិងដើមឈូកមានផ្ការីក ផ្សព្វផ្សាយក្លិនក្រអូបផង នឹងមិនរលឹករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញព្រៃ មានផ្កា

រីកក្នុងខែ ខាងក្នុងហេមន្តរដូវផង ឈូកទាំងឡាយមានផ្កាជ្រុះហើយផង នឹងមិនរលឹករាជសម្បត្តិ” ។

សរុបមកថា ព្រះនាងមទ្រី បាននិយាយសរសើរព្រៃហិមពាន្ត ដោយពាក្យប្រមាណប៉ុណ្ណោះ ហាក់ដូចជាព្រះនាងធ្លាប់បានរស់នៅក្នុងព្រៃហិមពាន្ត ។

សេចក្តីពណ៌នាអំពីព្រៃហិមពាន្ត ចប់ ។

# ជំពូកទី ៣
# ទានកណ្ឌវណ្ណនា

## ផុស្សតីទេវីលួងលោមរាជបុត្រនិងសុណិសា

ចំណែកឯព្រះនាងផុស្សតីទេវី គិតថា ដំណឹងដ៏ក្តៅផ្សាបានទៅដល់កូនរបស់នាងហើយ តើកូននាងនឹងធ្វើដូចម្តេច នាងនឹងទៅដឹងពីស្ថានការណ៍នោះ ។ គិតដូច្នេះហើយ ព្រះនាងផុស្សតីទេវីឡើងជិះយានជំនិះជាកំបាំង ទៅឈរទៀបទ្វារបន្ទប់ ស្តាប់នូវការចរចា របស់កូនបង្កើតនិងកូនប្រសាស្រី ហើយព្រះនាងក៏យំទួញខ្សឹកខ្សួលទ្រង់ព្រះកន្សែង មុខគួរអាណោចអាធម្មថា ៖

"ឱ ! អាត្មាអញគួរតែបរិភោគថ្នាំពិស ឬអាត្មាអញលោតទម្លាក់ខ្លួន ក្នុងជ្រោះ ពុំនោះទេ ចងកនឹងខ្សែឲ្យស្លាប់ប្រសើរជាង ។ ម្តេចឡើយ ក៏ពួកអ្នកសិវិរាស្ត្របណ្តេញបាវេស្សន្តរជាកូនអញដែលជាអ្នកមិនប្រទូស្ត ។ ម្តេចឡើយ ក៏ពួកអ្នកសិវិរាស្ត្រ បណ្តេញបាវេស្សន្តរជាកូនអញ ដែលជាអ្នកចេះចប់ត្រៃវេទ[២៦] ជាម្ចាស់ទានជាអ្នកគួរដល់ស្នូម ឥតមានសេចក្តីកំណាញ់ ជាអ្នកមិនប្រទូស្ត ។

[២៦] ការរួបរួមឬប្រជុំនៃវេទ ៣ ។

ម្តេចឡើយ ក៏ពួកអ្នកសិវិរាស្ត្របណ្តេញបាវេស្សន្តរជាកូនអញ ដែលពួកព្រះរាជាប្រទេសដទៃបូជា មានកិត្តិយស ជាអ្នកមិនប្រទូស្ត ។ ម្តេចឡើយ ក៏ពួកអ្នកសិវិរាស្ត្របណ្តេញបាវេស្សន្តរជាកូនអញ ដែលជាបុគ្គលចិញ្ចឹមមាតានិងបិតា ជាអ្នកគោរពចំពោះបុគ្គលជាធំក្នុងត្រកូល ជាអ្នកមិនប្រទូស្ត ។ ម្តេចឡើយ ក៏ពួកអ្នកសិវិរាស្ត្រ បណ្តេញបាវេស្សន្តរជាកូនអញ ដែលជាអ្នកមានប្រយោជន៍ដល់ព្រះរាជា មានប្រយោជន៍ដល់ទេវតា មានប្រយោជន៍ដល់ពួកញាតិនិងសម្លាញ់ មានប្រយោជន៍ដល់អ្នកដែនទាំងអស់ ជាអ្នកមិនប្រទូស្ត" ។

លុះខ្សឹកខ្សួលមុខគួរអាណោចអាធម្មដូច្នេះ ព្រះនាងបានលួងលោមរាជបុត្រនិងរាជសុណិសា ហើយនាំទៅកាន់សម្នាក់របស់ព្រះរាជា បានក្រាបទូលថា ៖

"ដែនរបស់ព្រះអង្គមុខជានឹងសាធារណៈដល់ជនទាំងឡាយ ដូចផ្ទិតឃ្មុំដែលមេឃ្មុំហើរចោល ពុំនោះ ដូចផ្លែស្វាយដែលជ្រុះលើផែនដី ព្រោះពួកអ្នកសិវិរាស្ត្របណ្តេញវេស្សន្តរជាអ្នកមិនប្រទូស្ត ។ ព្រះអង្គ ដែលពួកអាមាត្យបោះបង់ហើយ ជាព្រះ

រាជាម្នាក់ឯង រមែងនឿយព្រួយ ដូចហង្សដែលអស់ស្លាបលើ
ភក់ដែលគ្មានទឹក ។ បពិត្រមហារាជ ព្រោះហេតុនោះ បានជា
ខ្ញុំម្ចាស់ក្រាបទូលព្រះអង្គ កុំឲ្យប្រយោជន៍កន្លង ផុតព្រះអង្គ
ឡើយ សូមព្រះអង្គកុំបំបរបង់វេស្សន្តរ ដែលជាអ្នកមិនប្រទូស្ត
នោះ តាមសម្ដីពួកអ្នកសិវិរាស្ត្រឡើយ" ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវសម្ដីនោះហើយ ទ្រង់តបថា ៖

"យើងបណ្ដេញបាវេស្សន្តរ ដែលជាទង់ជ័យនៃពួកសិវិរាស្ត្រ
ឈ្មោះថាធ្វើសេចក្ដីគោរពចំពោះបវេណីធម៌ ទុកជាបាវេស្សន្តរ
ជាទីស្រឡាញ់ដ៏លើសជាងជីវិតរបស់យើងក៏ដោយ ក៏យើងនៅ
តែបណ្ដេញបាវេស្សន្តរ ដែលជាកូនរបស់យើងមិនខាន" ។

ផុស្សតីទេវី ព្រះវរជននីនោះ បានខ្សឹកខ្សួលទួញថា ៖

"ក្នុងកាលមុន ចុងទង់ជ័យទាំងឡាយដូចជាផ្កាកណិការ[២៧]រីក រមែង
ទៅតាមបាវេស្សន្តរ ក្នុងកាលចេញទៅកាន់ឧទ្យានជាដើម តែក្នុង

---

[២៧] ឈ្មោះឈើផ្កាមួយប្រភេទមានផ្កាពណ៌សផង លឿងផង និងពណ៌មាសផង មាន
ក្លិនក្រអូប ។ ផ្កានេះមានតំណាលច្រើនក្នុងព្រះពុទ្ធសាសនា ។ ផ្កាកណិការ កាល
ចាប់ក្រពុំរីករហូតដល់ផ្កាចាស់ រមែងរក្សានូវភាពស្រស់ជានិច្ច គឺមិនរោយឬចាស់
តាមសភាពនៃអាយុឡើយ ជាពិសេសការរក្សាបាននូវពណ៌មាស យ៉ាងឆ្អិនឆ្អៅ គួរជា

ថ្ងៃនេះ បាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុន ចុង ទង់ជ័យទាំងឡាយដូចជាព្រៃផ្កាកណិកា រមែងទៅតាមបាវេស្សន្ត ក្នុងកាលទៅកាន់ឧទ្យានជាដើម តែក្នុងថ្ងៃនេះ បាវេស្សន្តរនោះ នឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុន ពលទាំងឡាយដូចជាដើម កណិការីក រមែងទៅតាមបាវេស្សន្តរ ក្នុងកាលទៅកាន់ឧទ្យាន ជាដើម តែក្នុងថ្ងៃនេះ បាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុង កាលមុន ពលទាំងឡាយ ដូចជាព្រៃផ្កាកណិការ រមែងទៅតាម បាវេស្សន្តរ ក្នុងកាលទៅកាន់ឧទ្យាជាដើម តែក្នុងថ្ងៃនេះ បា វេស្សន្តរនោះ នឹងទៅតែម្នាក់ឯង ។ ពួកសេនាស្លៀកសំពត់កម្ពល

ទីរីកពាយចិត្ត ។ < កនិដ្ឋ + ករ៑-ធា. + ណ-ប ។ វិ. អគន្ធបុប្ផតាយ អត្តានំ កណិដ្ឋំ ករោតីតិ > កណិការោ, ដ្ឋលោបោ ។ ផ្កាកណិការ គឺផ្កាមានសណ្ឋានតូចទាំងឥតមានក្លិន, លុប ដ្ឋ ចេញ ។ តត្ថ កណិការន្តិ សកលបត្តបលាសានំ បរិភដ្ឋ បាតេត្វា បុប្ផគហណសមយេ កណិកាពន្ធោ ហុត្វា ។ កណិការា ច បុប្ផិតា ។ កណិកា-រាតិ វល្ចេកណិការា រុក្ខកណិការា ។ ពាក្យថា កណិការ គឺជាតួផ្កាមួយប្រភេទសណ្ឋានជាចង្កោមទម្លាក់ត្របកស្លឹកទាំងអស់រីកធាងជុំវិញ នៅរដូវផ្ការីក ។ កណិការ ហៅតួដើមផង ហៅតួផ្កាផង ។ នៅក្នុងអដ្ឋកថា បោរាណាចារ្យ លោកសរសេរមិនឲ្យច្រឡំគ្នាទេ កាលណាចង់និយាយថា ផ្កា លោកសរសេរ កណិការបុប្ផ, កាលណាចង់និយាយថាដើម លោកសរសេរ កណិការរុក្ខ ។

មានពណ៌លឿង ដែលកើតក្នុងដែនគន្ធារៈ[២៨] មានរស្មីដូចជាសម្បុរមេភ្លៀង រមែងទៅតាមបាវេស្សន្តរ ក្នុងកាលទៅកាន់ឧទ្យានជាដើម តែក្នុងថ្ងៃនេះ បាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុន បាវេស្សន្តរតែងទៅដោយដំរី ដោយសល្លៀង[២៩] និងរថ តែក្នុងថ្ងៃនេះ បាវេស្សន្តរនោះ នឹងដើរទៅដូចម្ដេចបាន ? ។ បាវេស្សន្តរដែលមានអវយវៈលាបដោយខ្លឹមចន្ទន៍ ធ្លាប់ភ្ញាក់រលឹកដោយរបាំងនិងចម្រៀង ស្លៀកដណ្ដប់ស្បែកខ្លាទាំងក្រចកគ្រោតគ្រាតផង រែកអម្រែកទម្ងន់មួយខារិ[៣០] ផង ដូចម្ដេចកើត ? ។ ព្រោះហេតុដូចម្ដេច ក៏ជនទាំងឡាយមិននាំសំពត់កាសាវៈផង ស្បែកខ្លាផង ដើម្បីបាវេស្សន្តរ កាលចូលទៅក្នុងព្រៃធំ ? ព្រោះហេតុអ្វីក៏ជនទាំងឡាយ មិនត្បាញសំពត់សម្បកឈើថ្វាយ ? ។ ពួកជនជារាជបព្វជិត នឹងស្លៀកសំពត់សម្បកឈើ ដូចម្ដេចកើត ? នាងមទ្រី នឹងស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំង ដូចម្ដេចកើត ? ។ នាងមទ្រីធ្លាប់តែស្លៀកសំពត់ ដែលកើតក្នុងដែនកាសីផង សំពត់

---

[២៨] ឈ្មោះដែនមួយក្នុងប្រទេសឥណ្ឌា ។

[២៩] ( ន. ) [សៈ--] ( ស. ) គ្រែស្នែងលាត (វ. ស.) : *ស្ដេចគង់លើព្រះសល្លៀង ។*

[៣០] អម្រែកប្រមាណ ៤ មាណិកា ។

ដែលកើតក្នុងដែនខេមៈផង និងដែនកោទុម្ពរៈផង ឥឡូវនេះមក ស្លៀកសំពត់ដែលក្រងដោយស្បូវក្លាំង តើនឹងធ្វើអ្វីកើត ? ។ នាងមទ្រីនោះមានអវយវៈគួរសរសើរ ធ្លាប់ទៅដោយវយ្ហ[៣១] ព្រះសាលៀង និងរថ ថ្ងៃនេះ នឹងដើរដោយជើងតាមផ្លូវ ដូចម្ដេចបាន ? ។ នាងមទ្រីណាមានផ្ទៃដៃដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់បិតនៅក្នុងសេចក្ដីសុខ ថ្ងៃនេះ នាងមទ្រីមានអវយវៈគួរសរសើរនោះ នឹងដើរដោយជើងតាមផ្លូវ ដូចម្ដេចបាន ? ។ នាងមទ្រី មានផ្ទៃជើងដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់បិតនៅក្នុងសេចក្ដីសុខ មានអវយវៈគួរសរសើរ តែងពាក់ស្បែកជើងមាស ហើយដើរទៅ ថ្ងៃនេះ នឹងដើរដោយជើងទៅតាមផ្លូវ ដូចម្ដេចបាន ? ។ នាងមទ្រីតែងពាក់កម្រងផ្កា ដើរទៅមុខនៃស្ត្រី ១.០០០ ថ្ងៃនេះ នឹងដើរទៅព្រៃតែម្នាក់ឯង ដូចម្ដេចបាន ? ។ នាងមទ្រីដែលនៅក្នុងបុរី គ្រាន់តែបាន

[៣១] (ន.) (ស.) (វយ្ហ អ. ថ. វ៉ៃ) យានមួយប្រភេទ មានគ្រែ, ដងស្នែង, ដំបូល សម្រាប់ឥស្សរជនថ្នាក់ខ្ពស់ជិះ មានមនុស្សសែង : *គង់លើ-វ, ជិះវ* (មានប្រើច្រើនតែក្នុងសម័យពីដើម); *វ. ស. ព្រះវ វ ធម្មតា*; (*ព្រះសិវិកា ឬ ព្រះទីន័ងសិវិកា វមានក្បាច់រចនាវិចិត្រ*) ។

ឮសំឡេងចចក[៣២]លូរៀយ ៗ រមែងតក់ស្លុត ថ្ងៃនេះ នាងមទ្រីមានអវយវៈគួរសរសើរនោះ ជាស្ត្រីរន្ធត់ នឹងទៅព្រៃដូចម្ដេចបាន ? ។ នាងមទ្រី គ្រាន់តែបានឮសំឡេងមៀម[៣៣]ជាកោសិយគោត្រ កាលស្រែកបន្ទឺ ក៏ខ្លាចរន្ធត់ដូចមេមត[៣៤]ដែលខ្មោចចូល ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះ ជាស្ត្រីមានសេចក្ដីរន្ធត់ នឹងដើរទៅព្រៃដូចម្ដេចបាន ? ។ ខ្ញុំម្ចាស់លុះមកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងធេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចមេបក្សីដែលបាត់កូនឃើញតែសម្បុកសូន្យទទេដូច្នោះ ។ កាលខ្ញុំម្ចាស់មិនបានឃើញកូនទាំងពីរហើយ មុខជានឹងស្គមស្លេកស្លាំង ដូចជាមេបក្សីដែលបាត់កូន ឃើញតែសម្បុកសូន្យទទេ ដូច្នោះ ។ កាលខ្ញុំម្ចាស់មិនឃើញកូនទាំងពីរជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាម

---

[៣២] (ន.) ឈ្មោះសត្វជើង ៤ សន្ដានឆ្កែព្រៃ ។

[៣៣] ពាក្យនេះ មានន័យ ២ យ៉ាងគឺ (កិ.) ប៉ិចជាពន្លក ឬជាត្រួយ ។ (ន.) ឈ្មោះសត្វស្លាបរត្តិចរមួយប្រភេទ ពួកទីទុយ តែមាឌតូចជាង, ក្បាលនិងភ្នែកធំមិនសមនឹងរូប ។

[៣៤] (ន.) ខ្មោចអារក្ស; ស្រីរូបអារក្ស : បន់មេមត់, រៀបទ្រនីបជូនមេមត់ ។ (ពាក្យ មត់ ទំនងជាក្លាយមកពី បា. មត "ដែលស្លាប់ហើយឬមនុស្សដែលស្លាប់ហើយ (ខ្មោច)" មេមត គឺមេខ្មោច ?) ។ ឈ្មោះស្រុកមួយក្នុងខេត្រកំពង់ចាមប៉ែកខាងកើត ប្រទល់គ្នានឹងខេត្រពេងជំរី ។

ទីនោះ ៗ ដូចជាមេបក្សីដែលបាត់កូនឃើញ តែសម្បុកសូន្យទទេ ដូច្នោះ ។ ខ្ញុំម្ចាស់លុះមកកាន់បុរីនេះសូន្យទទេហើយ នឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចមេអក[៣៥]ដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ កាលខ្ញុំម្ចាស់ មិនឃើញកូនទាំងពីរជាទីស្រឡាញ់ហើយ មុខជានឹងស្គមស្លេកស្លាំង ដូចជាមេអក

---

[៣៥] ពាក្យនេះមានន័យជា កិ.១ ជា នាម ២, ដូច (កិ.) ចាប់ចំណីអាហារក្រៀម, ផង់ ឬភេសជ្ជៈស្ងួតផង់ជាដើម ពេញទូកដៃ ហាមាត់ជំងើយពម : អកប្រអួល, អកអំបុក, អកថ្នាំផង់ ។ (ន.) អណ្ដូបាតកសត្តមួយប្រភេទ សម្បុរខ្លួនខ្មៅស្រអាប់ មាឱជំកន្ទុលបន្តិចជាផ្កុកខ្មៅ, ឆាបចាប់មច្ឆជាតិជាចំណី; កាលណាព្រាត់គូឬព្រាត់កូន ស្រែកយំគ្រលួចសង្រេងសង្រែហើរឆ្មៀលឆ្ងាត់ខ្ពស់ ៗ ទាប ៗ ប្រះប្រាណ គួរឲ្យស្រងេះស្រងោចអាណោចអាធម្ម (ហៅ អក តាមសូរវាយំ) ។ គេតែងនិយាយប្រៀបថា កើតទុក្ខធំយំបោកខ្លួន ឬយំប្រះប្រាណដូចជាអក ។ (ព. កា.) : សត្វអកជាសត្វមានចិត្តស្មោះ អាឡោះអាល័យហួសទំនង នៅពេលដែលព្រាត់បាត់គូគ្រង ទោះព្រាត់រំលងកាលយូរថ្ងៃ ។ ស្រែកយំរង្គំមិនសូវស្រាក ក្រៀមក្រំលំបាកពន់ពេកក្រៃ ជួនកាលបោកខ្លួនឲ្យក្សិណក្សយសង្រេងសង្រែដល់ស្គាំងស្គម ។ មនុស្សខ្លះកើតទុក្ខដូចជាអក ច្រើនខកខូចចិត្តដល់ខ្លួនទ្រម ទោះគេពន្យល់ក៏ពុំព្រម រញមត្រាតែមានជំងឺ ។ (ន.) ប្រដាប់ធ្វើដោយលោហជាតិផ្សេង ៗ ឬធ្វើដោយប្រាក់, មាសជាដើមមានរាងច្រឡោឬមានសណ្ឋានដូចបំពង់តូច មានមេមានគម្រប សម្រាប់ដាក់កំបោរបៀកម្លូ : កំបោរកន្ទះអក, អកកំបោរលង់ហិន, អកកំបោរប្រាក់ ។

ដែលបាត់កូន ឃើញតែសម្បុកសូន្យទទេ ដូច្នោះ ។ កាលខ្ញុំម្ចាស់មិនឃើញកូនទាំងពីរជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាមទីនោះ ៗ ដូចជាមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេ ដូច្នោះ ។ ខ្ញុំម្ចាស់មកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដោយពិត ដូចជាមេចាក្រពាកដែលសំកុកលើកក់មិនមានទឹក ។ ខ្ញុំម្ចាស់នោះមិនឃើញកូនទាំងពីរ ជាទីស្រឡាញ់ហើយ មុខជានឹងស្គមស្ទេកស្ទាំងដោយពិត ដូចជាមេចាក្រពាក[៣៦] ដែលសំកុកនៅលើកក់មិនមានទឹក ។ កាលខ្ញុំម្ចាស់មិនឃើញកូនទាំងពីរ ជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាមទីនោះ ៗ ដោយពិត ដូចជាមេចាក្រពាកដែលនៅលើកក់មិនមានទឹក ។ កាលបើខ្ញុំម្ចាស់យំរៀបរាប់យ៉ាងនេះហើយ ព្រះអង្គនៅតែបណ្តេញរាជបុត្រនោះ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ខ្ញុំម្ចាស់ទំនងជានឹងលះបង់ជីវិតមិនខាន" ។

សិរិកញ្ញាទាំងឡាយ របស់ព្រះបាទសញ្ជ័យទាំងអស់ លុះឮនូវសូរសំឡេងខ្សឹកខ្សួល របស់ព្រះទេវី ពួកនាងក៏មកជួបជុំគ្នា ហើយយំ

---

[៣៦] សត្វប្រវឹក, ព្រវែក ។

កន្ទក់កន្ទេញ ។ ដូចគ្នានេះដែរសូម្បីពួកសិរិកញ្ញាក្នុងដំណាក់របស់ព្រះមហាសត្វ លុះឮសំឡេងខ្សឹកខ្សួល របស់ពួកគេហើយ ពួកនាងក៏យំកន្ទក់ន្ទេញយ៉ាងអ៊ីចឹងដែរ ។ កូននិងប្រពន្ធទាំងឡាយ ក៏ដួលដេកក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ដូចដើមឈើ ដែលត្រូវខ្យល់បក់បោកខ្ទេចខ្ទី ។ ពួកស្រីស្នំ ពួករាជកុមារពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដើម ដែកន្ទក់កន្ទេញ ក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដើមដែកន្ទក់កន្ទេញក្នុងព្រះរាជនិវេសន៍របស់ព្រះបាទវេស្សន្តរ ។ សរុបសេចក្ដីមកថា ទោះនរណាមួយក៏ដោយ ក្នុងរាជត្រកូលទាំងឡាយពុំអាចទប់ជំហរខ្លួនបានឡើយ ពួកគេសោតសឹងតែដួលបម្រះនទៀលខ្សឹកខ្សួល ហាក់ដូចជាពោងត្រូវសន្ទុះខ្យល់ផាត់បំបើុងខ្ទេចខ្ទី ។

## ព្រះវេស្សន្តរឲ្យសត្តសតកមហាទាន

រាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង គ្រានោះ ព្រះបាទវេស្សន្តរស្ដេចចូលទៅដើម្បីឲ្យទាន មានព្រះរាជបញ្ជាថា អ្នកទាំងឡាយ ចូរឲ្យសំពត់ដល់ពួកជនដែលត្រូវការសំពត់ ឲ្យសុរាដល់ពួកអ្នកលេង ឲ្យភោជនដល់ពួកអ្នកត្រូវការដោយភោជន ចូរឲ្យដោយប្រពៃ

ចុះ ។ អ្នកទាំងឡាយ កុំបៀតបៀនពួកវណិព្វក: ដែលមកក្នុងទីនេះ តិចតួចឡើយ អ្នកទាំងឡាយ ចូរញ៉ាំងពួកវណិព្វក:ឲ្យស្កប់ស្កល់ដោយបាយនិងទឹក ពួកវណិព្វក:ដែលយើងបានឲ្យរួចហើយ ចូរទៅចុះ ។ លំដាប់នោះ ស្រាប់តែសំឡេងគ្រលួច យ៉ាងពន្លឹក ប្រព្រឹត្តទៅក្នុងព្រះនគរនោះថា ពួកអ្នកសិវិរាស្ត្របាន បណ្តេញព្រះអង្គ ព្រោះតែឲ្យទានឥឡូវនេះ ព្រះអង្គឲ្យទានទៀតហើយ ។ កាលមហារាជព្រះអង្គញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យាងចេញទៅ វណិព្វក:[៣៧] ទាំងនោះក៏ដួលចុះ ដូចជាបុគ្គលស្រវឹង ឬដូចជាបុគ្គលនឿយហត់ខ្លាំង ដោយពាក្យថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្រ បានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចគេកាត់ផ្តាច់ដើមឈើជាឈើឲ្យផ្លែផ្សេង ៗ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របាន បណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យ ចេញចាកដែន ដូចជាគេកាត់ចោល នូវដើមឈើជាឈើទ្រទ្រង់ផ្លែផ្សេង ៗ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្រ បាន

[៣៧] ស្នូមអ្នកពោលពណ៌នាសរសើរគុណរបស់អ្នកឲ្យ ឬសរសើរផលទានជាមុនរួចទើបសុំទាន ឬក៏ពោលសរសើ, ពោលឲ្យពរជាមុន ក្នុងកាលដែលគេឲ្យទានមកខ្លួនរួចហើយ ។

បណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើ ជាឈើឲ្យសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្រ បានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើ ជាឈើនាំមកនូវរសជាទីប្រាថ្នាគ្រប់យ៉ាង ។ ពួកជនណាដែលចាស់ក្តី ពួកជនណា ដែលនៅក្មេងក្តី ពួកជនណាដែលមានវ័យកណ្តាលក្តី ជនទាំងនោះ កាលដែលមហារាជព្រះអង្គញុំាងដែនរបស់ពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាងចេញទៅ ក៏ផ្គងដៃកន្ទក់កន្ទេញ ។ កាលមហារាជព្រះអង្គ ញុំាងដែនអ្នកសិវិឲ្យចម្រើន ទ្រង់យាងចេញទៅ ពួកពេទ្យចាប់ខ្មោច ពួកអ្នករក្សាស្រីស្នំ និងពួកស្រីស្នំរបស់ព្រះរាជា ក៏ផ្គងដើមដៃកន្ទក់កន្ទេញ ។ កាលមហារាជ ព្រះអង្គញុំាងអ្នកដែនសិវិឲ្យចម្រើន ទ្រង់យាងចេញទៅ ពួកស្ត្រីដែលនៅក្នុងព្រះនគរនោះ ក៏កន្ទក់កន្ទេញ ។ ពួកព្រាហ្មណ៍សមណៈ និងវណិព្វកៈដទៃ ៗ ផ្គងដើមដៃកន្ទក់កន្ទេញថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា នេះមិនមែនជាធម៌ទេ ។ ដូចយ៉ាងព្រះបាទវេស្សន្តរ កាលបូជាក្នុងបុរីរបស់ព្រះអង្គ ទ្រង់យាងចេញចាកដែនរបស់ព្រះអង្គ ព្រោះហេតុតែសម្តីរបស់ពួកអ្នក

សិរីរាស្ត្រ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទានដំរីមាតង្គៈ៧០០ ដែល ស្អិតស្អាងដោយគ្រឿង អលង្ការទាំងពួង មានខ្សែដង្គន់មាស មាន គ្រឿងប្រដាប់ក្បាលជាវិការៈនៃមាស ដែលពួកហ្មដំរីមានលំពែងស្នែង ក្របីនិងកង្វេរក្នុងដៃឡើងជិះហើយ ក៏យាងចេញទៅចាកដែនរបស់ ព្រះអង្គ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទានសេះអាជានេយ្យ ៧០០ ជា សេះសិន្ធពដោយជាតិ ជាពាហនៈមានសន្ទុះលឿន ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ដែលពួកអ្នកជិះសេះ កាន់ស៊ែនិងធ្នូ ឡើងជិះហើយ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទ វេស្សន្តរនុ៎ះ បានប្រទានរថ ៧០០ ដែល ប្រដាប់ហើយ មានទង់លើក ឡើងហើយ បិទបាំងដោយស្បែកខ្លាដំបង និងស្បែកខ្លាធំ ស្អិងស្អាង ដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយ សារថីមានធ្នូក្នុងដៃ និង ពាក់អាវក្រោះឡើងជិះហើយ ក៏យាងចេញចាក ដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទានស្រ្តី ៧០០ បិត នៅលើរថមួយម្នាក់ ៗ ដែលស្អិតស្អាងហើយ ប្រដាប់ដោយខ្សែជាវិការ នៃមាសឆ្តោរ មាន គ្រឿងប្រដាប់លឿង មានសម្លៀកបំពាក់លឿង ស្អិតស្អាងដោយគ្រឿង អាភរណៈលឿង មានថ្ពាល់និងភ្នែកដ៏ល្អញញឹម ហើយទើបនិយាយ ជាស្រ្តីមានត្រគាកល្អ មានចង្កេះដ៏រៀវស្ដួច ក៏យាងចេញចាកដែន

របស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទាន មេគោ ៧០០ ព្រម ទាំងភាជន៍មាសសម្រាប់ត្រងទឹកដោះទាំងអស់ ហើយយាងចេញចាក ដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរនុ៎ះ បាន ប្រទានខ្ញុំស្រី ៧០០ ខ្ញុំប្រុស ៧០០ ហើយយាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទ វេស្សន្តរនុ៎ះ បានប្រទានដំរី សេះ រថ និងនាងនារីដែល ប្រដាប់ហើយ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ កាលដែលព្រះបាទវេស្សន្តរ ប្រទានមហាទាន ការស្ញប់ស្ញែង ការព្រឺរោមក៏កើតមាន ក្នុងកាលនោះ ផែនដី ក៏ញាប់ញ័រ ។ ព្រះរាជាដែលមហាជនកំពុងផ្គងអញ្ជលី ទ្រង់ យាងចេញចាកដែនរបស់ព្រះអង្គ ដោយហេតុណា ហេតុនោះ ជាការ គួរស្ញប់ស្ញែង គួរព្រឺរោម កើតមានក្នុងកាលនោះ ។

ព្រះវេស្សន្តរ បានឲ្យសត្តសតកមហាទាន គឺ ដំរីបិទបាំងដោយ គ្រោះការពារព្រឹល មានទង់មាស មានអលង្ការមាស ចំនួន៧០០, និង សេះមានសភាពដូច្នោះ ចំនួន ៧០០, រទេះពាសជុំវិញដោយស្បែកតោ ជាដើម វិចិត្រដោយរតនៈនានា មានទង់មាស ចំនួន ៧០០, ស្ត្រីខត្តិយ កញ្ញាជាដើម មានរូបស្រស់សោភា ប្រដាប់ដោយអលង្ការគ្រប់មុខ ចំនួន ៧០០, ទាសៈដែលមានការអប់រំល្អ ហ្វឹកហាត់ល្អ ចំនួន ៧០០,

ទាសី មានសភាពយ៉ាងនោះដែរ ចំនួន ៧០០, មេគោធំលើគោឧសភដ៏បវរ ដែលដាក់កន្ទុះរួចជាស្រេច ចំនួន ៧០០, ហើយនិងបាយទឹកច្រើនឥតប្រមាណបាន ។ កាលព្រះវេស្សន្តរនោះ កំពុងតែឲ្យនូវទានយ៉ាងនេះ ពួកអ្នកជេតុត្តរនគរ ខត្តិយៈ ព្រាហ្មណ៍ វេស្សៈ និងសុទ្រៈជាដើម បានខ្សឹកខ្សួលថា ៖

"បពិត្រព្រះវេស្សន្តរជាអម្ចាស់ជីវិតតម្កល់ត្បូង ពួកអ្នកសិវិរាស្ត្រកំពុងតែបណ្តេញព្រះអង្គ ដ្បិតតែព្រះអង្គឲ្យទាន បីក៏ព្រះអង្គនៅតែឲ្យទានទៀតអ៊ីចឹង ?" ។

ចំណែកឯអ្នកទទួលព្រះរាជអំណោយទាំងឡាយ លុះយកនូវអំណោយហើយ ក៏ឮនូវដំណឹងភ្លាម ៗនោះថា ព្រះបាទវេស្សន្តរនឹងចូលទៅព្រៃ ទុកឲ្យពួកគេនៅអនាថា ពីឥឡូវនេះទៅ តើពួកគេនឹងទៅកាន់សម្នាក់របស់អ្នកណា ។ ពួកគេហាក់ដូចជាមនុស្សកំបុតជើង នាំគ្នាដួលបម្រះត្រឡប់ត្រឡិន ស្រែកខ្សឹកខ្សួលខ្លាំង ៗ ។ ពួកវណិព្វកៈទាំងនោះ ដួលចុះដូចបុគ្គលស្រវឹង ឬ ដូចបុគ្គលនឿយហត់ខ្លាំង" ។

គ្រានោះឯង ទេវតាទាំងឡាយ បាននាំគ្នាធ្វើសេចក្តីពយការណ៍ដល់ព្រះមហាក្សត្រស្តេចផែនដី លើផ្ទៃជម្ពូទ្វីបថា "ព្រះបាទវេស្សន្តរកំពុងតែឲ្យនូវមហាទាន" ។ ដោយហេតុនោះ ក្សត្រិយ៍ទាំងឡាយនោះ

បានមកដោយអានុភាពរបស់ទេវតា យកអំណោយបវរកញ្ញាចៀសទៅ
កាន់ប្រទេសរៀង ៗខ្លួន ។ កាលព្រះវេស្សន្តរនោះ ឲ្យនូវមហាទានរួច
ព្រះអង្គបានផ្គងនូវអញ្ជលី នមស្ការនូវទានរបស់ខ្លួន រួចផ្គងអញ្ជលី
តាំងប្រាថ្នាថា ទាននេះចូរជាបច្ច័យនាំខ្ញុំឲ្យសម្រេចសព្វញ្ញុតញ្ញាណ។
រំពេចនោះ ស្រាប់តែសំឡេងគួរឲ្យខ្លាច ក៏កើតមានឡើង ប្រឹថពីបាន
រញ្ជួយមួយរំពេច និងគ្មាននរណាមួយឃាត់ព្រះអង្គឡើយ ។

ប្រការមួយវិញទៀត កាលព្រះវេស្សន្តរ កំពុងតែឲ្យនូវទាន
វេលាល្ងាច ក៏ឈានមកដល់ ។ ព្រះអង្គបានទៅកាន់និវេសន៍របស់ខ្លួន
គិតថា "អញនឹងថ្វាយបង្គំម្តាយឪពុក ដល់ថ្ងៃស្អែកឡើង នឹងចេញទៅ
តែម្តង" ។ គិតរួច ព្រះអង្គឡើងរទេះដ៏វិចិត្រស្អាត ទៅកាន់ដំណាក់នៃ
ព្រះមាតាបិតា ។ រីឯព្រះនាងមទ្រីទេវី ក៏គិតដែរថា ព្រះនាងនឹងទៅជា
មួយនឹងព្រះស្វាមី នឹងស្នើសូមឲ្យព្រះមាតាបិតាអនុញ្ញាត ។ គិតរួចព្រះ
នាងក៏ចេញដំណើរទៅមួយនឹងព្រះស្វាមីនោះដែរ ។ ព្រះមហាសត្ត
ថ្វាយបង្គំព្រះបិតាហើយ ព្រះអង្គបានក្រាបបង្គំទូលនូវដំណើរទៅ
របស់ខ្លួនដល់រាជាព្រះនាមសញ្ជ័យជាធម្មិករាជដ៏ប្រសើរថា ៖

"បពិត្រព្រះទេវៈ ព្រះអង្គទ្រង់បណ្តេញទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងទៅឯវង្កបព៌ត ។ បពិត្រមហារាជ សត្វទាំងឡាយណាមួយកើតហើយក្តី ទាំងសត្វទាំងឡាយណានឹងកើតក្តី ពួកសត្វដែលកំពុងកើតក្តី សត្វទាំងនោះសុទ្ធតែមិនឆ្អែតដោយកាមទាំងអស់ រមែងទៅកាន់ទីរបស់យមៈ[៣៨] ។ ទូលព្រះបង្គំជាខ្ញុំនោះកាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថាបៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំ កាលចេញចាកដែនរបស់ខ្លួន ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្ត្រ ទូលព្រះបង្គំក៏នឹងរងទុក្ខក្នុងព្រៃដែលច្របូកច្របល់ដោយម្រឹគសាហាវ ដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើបុណ្យទាំងឡាយ ឯព្រះអង្គលិចក្នុងភក់គឺកាមចុះ" ។

ព្រះមហាសត្វ បានពោលជាមួយនឹងព្រះបិតា ដោយពាក្យទាំងនេះដូច្នេះហើយ ព្រះអង្គក៏ទៅកាន់សម្នាក់ព្រះវររាជមាតា ក្រាបបង្គំទូលស្នើសុំទ្រង់អនុញ្ញាតនូវផ្នួស ដោយពោលយ៉ាងនេះថា ៖

[៣៨] សេចក្តីស្លាប់ ។

"បពិត្រព្រះមាតា សូមទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំគាប់ចិត្តនឹងបព្វជ្ជា ទូលព្រះបង្គំជាខ្ញុំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថា បៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំ កាលចេញចាកដែនរបស់ខ្លួន ព្រោះហេតុតែសម្ដីរបស់ពួកអ្នកសិវិរាស្ត្រ ទូលព្រះបង្គំជាខ្ញុំ នឹងសោយទុក្ខក្នុងព្រៃ ដែលច្របូកច្របល់ដោយម្រឹគសាហាវ ដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំ តែងធ្វើបុណ្យទាំងឡាយនឹងទៅឯគិរីវង្កត" ។

ផុស្សតីទេវី ព្រះដូច្នោះហើយ បានពោលតបថា ៖

"ម្នាលកូន យើងអនុញ្ញាតអ្នកហើយ បព្វជ្ជាចូរសម្រេចដល់អ្នកចុះ តែនាងមទ្រីកល្យាណីនេះ នាងមានត្រគាកដ៏ល្អ មានចង្កេះរៀវ ចូរនៅជាមួយនឹងកូនទាំងពីរចុះ នាងនឹងធ្វើអ្វីក្នុងព្រៃ" ។

វេស្សន្តរ ពោលថា ៖

"សូម្បីតែទាសីដែលប្រាថ្នានឹងទៅ ទូលព្រះបង្គំជាខ្ញុំ ក៏មិនអាចនាំទៅកាន់ព្រៃទេ ប្រសិនបើនាងមទ្រីចង់ ចូរទៅតាមចុះ បើមិនចង់ ចូរនៅចុះ" ។

**ព្រះបាទស្រីសញ្ជ័យអង្វរព្រះសុណិសា**

គ្រានោះ ព្រះរាជាឮនូវសម្តីរបស់បុត្រ ទ្រង់ក៏យាងទៅអង្វរព្រះរាជសុណិសាថា ៖

"ម្នាលនាងមានរាងកាយប្រោះព្រំដោយខ្លឹមចន្ទន៍ នាងកុំស្លៀកដណ្តប់សំពត់ឲ្យប្រឡាក់ក្អែលឡើយ ។ នាងធ្លាប់ស្លៀកដណ្តប់សំពត់អ្នកដែនកាសី ហើយត្រឡប់ជាស្លៀកដណ្តប់សំពត់ដែលក្រងដោយស្បូវភ្លាំងវិញ ការនៅក្នុងព្រៃ តែងនាំមកនូវសេចក្តីទុក្ខ ម្នាលនាងមានលក្ខណ៍ នាងកុំទៅឡើយ" ។

ព្រះរាជបុត្រីព្រះនាមមទ្រី មានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះបិតាក្មេកថា ៖

"ខ្ញុំម្ចាស់ បើព្រាត់ប្រាសពីព្រះវេស្សន្តរជាស្វាមីរបស់ខ្ញុំម្ចាស់ហើយ ខ្ញុំម្ចាស់មិនចង់បានសេចក្តីសុខទេ" ។

មហារាជជាអ្នកញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន មានព្រះបន្ទូលនឹងនាងមទ្រីនោះថា ៖

"ម្នាលនាងមទ្រី បើដូច្នោះ នាងចូរស្តាប់នូវសេចក្តីអន្តរាយទាំងឡាយ ដែលនាងអត់ទ្រាំបានដោយក្រ ក្នុងព្រៃចុះ ។ កណ្តូបរបោម មូស និងឃ្មុំដ៏ច្រើន សត្វទាំងនោះ គប្បីបៀតបៀននាង

ក្នុងព្រៃនោះ ការបៀតបៀននោះ មុខជានាំមកនូវទុក្ខយ៉ាងខ្លាំង ដល់នាង ។ នាងចូរមើលពួកសត្វដទៃ ដែលគួរឲ្យតក់ស្លុតដែល អាស្រ័យនៅនឹងទន្លេ គឺពស់ថ្លាន់ ពស់ទាំងនោះមិនមានពិសទេ តែមានកម្លាំងច្រើន ។ ពស់ថ្លាន់ទាំងនោះតែងយកក្អែនរឹតមនុស្ស ឬម្រឹគដែលមកជិតវា ហើយនាំមកកាន់អំណាចខ្លួន ។ ខ្លាឃ្មុំដទៃ ទៀត មានសម្បុរខ្មៅ រោមរឹង ជាម្រឹគឲ្យទុក្ខ បុរសដែលខ្លាទាំង នោះឃើញហើយ រត់ឡើងដើមឈើ ក៏មិនរួច ។ ក្របីជាសត្វ ប្រហារ តែងវ័ធនឹងស្នែងមានចុងដ៏មុត តែងត្រាច់ទៅមកក្នុងព្រៃ នោះ ជិតទន្លេឈ្មោះសោតុម្ពរា ។ ម្នាលនាងមទ្រី នាងដូចជាមេ គោដែលមានចិត្តជាប់នឹងកូន ឃើញគោឈ្មោលកំពុងទៅតាម ហ្វូងម្រឹគក្នុងព្រៃ នឹងធ្វើដូចម្តេច ? ។ ម្នាលនាងមទ្រី ភ័យធំមុខជា នឹងមានដល់នាង ដែលជាស្ត្រីមិនដឹងទីខេត្ត ព្រោះឃើញស្វាទាំង ឡាយដ៏ពន្លឹក ដែលផ្ទុំគ្នាក្បែរផ្លូវ ដែលទៅមកបានដោយក្រ ។ ម្នាលនាងមទ្រី ក្នុងបុរី នាងគ្រាន់តែឮសូរសំឡេងចចក រមែងតក់ ស្លុតរឿយ ៗ ដល់ទៅគិរីវង្កត តើនឹងធ្វើដូចម្តេច ? ។ កាលដែល ពួកបក្សីប្រជុំគ្នា ក្នុងវេលាដែលព្រះអាទិត្យឋិតនៅត្រង់កណ្តាល

ថ្ងៃត្រង់ ព្រៃធំក៏លាន់ឮសំឡេងគឹកកង ចុះនាងចង់ទៅក្នុងព្រៃធំនោះធ្វើអ្វី ?”

ព្រះរាជបុត្រីព្រះនាមមទ្រី មានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះរាជបិតាក្មេកនោះថា ៖

“ព្រះអង្គទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់ នូវភ័យដែលមានចំពោះមុខទាំងឡាយណា ក្នុងព្រៃ ឯខ្ញុំម្ចាស់អាចទទួលអត់ទ្រាំភ័យ ដែលមានចំពោះមុខទាំងអស់នោះបាន បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ខ្ញុំម្ចាស់នឹងយកទ្រូងរុលវែកដើមអំពៅព្រៃ ស្បូវភ្លាំង ស្មៅសសិត ស្មៅរណ្ដាស ស្មៅយាប្លង់និងស្មៅដំណេកទន្សាយ ដើរមុខព្រះវេស្សន្តរជាប្ដីខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងនាំព្រះកស្ដាទៅមិនឲ្យលំបាក ។ កុមារីរមែងបានប្ដីដោយការប្រព្រឹត្តវត្តដ៏ច្រើន គឺដោយការបិទពោះ (បន្ថយអាហារឲ្យពោះតូច) ដោយការដំចង្កេះ ដោយឈើមានសណ្ឋានដូចចង្កាគោ និងការរឹតចង្កេះខ្លួនដោយឈ្នួត ធ្វើឲ្យចង្កេះរៀវ ដោយការបម្រើភ្លើង (អាំងភ្លើង) និងដោយការដុសលាងសម្អាតដោយទឹក ។ ភាពជាស្ត្រីមេម៉ាយ រមែងក្ដៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀត បុរសមិនគួរ

បរិភោគរបស់សំណល់ អំពីស្ត្រីមេម៉ាយនោះ បុរសណា សូម្បីមានជាតិទាប បុរសនោះក៏ចាប់ដៃទង់ទាញស្ត្រីមេម៉ាយនោះ ដែលមិនប្រាថ្នាផង ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយ ក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ បុរសតែងឲ្យសេចក្តីទុក្ខយ៉ាងច្រើនលើសលុប ដោយការចាប់សក់កញ្ឆក់ឡើង ដោយការផ្តួលលើផែនដី ហើយក៏មិនដើរចេញទៅណា នៅឈរមើលព្រងើយ ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅមិនខានឡើយ ។ ពួកបុរសដែលមានសម្បុរ-ស ជាអ្នកត្រូវការនឹងស្ត្រីមេម៉ាយ ប្រកាន់ខ្លួនថា មានលម្អដ៏ប្រសើរ បានឲ្យទ្រព្យបន្តិចបន្តួច ហើយទង់ទាញស្ត្រីមេម៉ាយដែលមិនត្រូវការនឹងខ្លួន ដូចក្អែកដែលឆាបមៀមដូច្នោះ ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀត ស្ត្រីមេម៉ាយ កាលនៅក្នុងត្រកូលញាតិដ៏ស្តុកស្តម្ភ រុងរឿងដោយភាជន៍មាស ក៏នៅតែបានពាក្យតិះដៀលអំពីបងប្អូនប្រុស និងពួកស្ត្រីជាសម្លាញ់ពុំខាន

ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គ
ដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ទន្លេដែលគ្មានទឹក
ហៅថាទន្លេស្រាត ដែនដែលគ្មានព្រះរាជា ហៅថា ដែនស្រាត
ចំណែកស្ត្រី បើទុកជាមានបងប្អូនប្រុស ដល់ ១០ នាក់ ក៏ហៅថា
ស្ត្រីស្រាត ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក
បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។
ទង់ជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង
ព្រះរាជា ជាគ្រឿងប្រាកដរបស់ដែន ភស្តាជាគ្រឿង ប្រាកដរបស់
ស្ត្រី ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះ
អង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ស្ត្រីណាដែល
មានកេរ្តិ៍ឈ្មោះ កាលស្វាមីទ័លក្រ ក៏ជាស្ត្រីទ័លក្រជាមួយ កាល
ស្វាមីស្តុកស្តម្ភ ក៏ជាស្ត្រីស្តុកស្តម្ភជាមួយ ពួកទេវតារមែងសរសើរ
ស្ត្រីនោះឯង ព្រោះថា ស្ត្រីនោះធ្វើអំពើដែលគេធ្វើបានដោយក្រ ។
ខ្ញុំម្ចាស់ នឹងស្លៀកសំពត់កាសាយៈ ហើយដើរតាមប្តីសព្វ ៗ កាល
ភាពជាស្ត្រីមេម៉ាយ ទោះបីមានផែនដីមិនបែក បានជាធំលើផែន
ដីទាំងមូល ក៏នៅតែក្តៅក្រហាយដែរ ។ ម្យ៉ាងទៀត ខ្ញុំម្ចាស់បើ
ប្រាសព្រាត់ព្រះវេស្សន្តរជាប្តី ហើយមិនចង់បានផែនដី ដែលមាន

សមុទ្រពទ្ធជុំវិញ ទ្រទ្រង់ទ្រព្យដ៏ច្រើន ជាផែនដីបរិបូណ៌ដោយ
រតនៈផ្សេង ៗ ទេ ។ ពួកស្ត្រីណា ជាស្ត្រីរីងរូសយ៉ាងក្រៃលែង
កាលដែលស្វាមីដល់នូវសេចក្តីទុក្ខហើយ ប្រាថ្នាសេចក្តីសុខដល់
ខ្លួនតែម្យ៉ាង ហឫទ័យរបស់ស្ត្រីទាំងនោះ នឹងទៅជាដូចម្តេចហ្ន៎ ។
កាលបើមហារាជដែលញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់
ចេញទៅហើយ ខ្ញុំម្ចាស់នឹងទៅតាមមហារាជនោះ ព្រោះថា ព្រះ
អង្គជាអ្នកឲ្យវត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ខ្ញុំម្ចាស់" ។

ព្រះបាទសញ្ជ័យមហារាជ មានព្រះរាជឱង្ការនឹងព្រះនាងមទ្រី ដែល
មានអវយវៈទាំងអស់ដ៏ល្អនោះថា ៖

"ម្នាលនាងមានលក្ខណ៍ នាងចូរទុកកូនតូចទាំងពីររបស់នាង គឺ
បាជាលីនិងនាងកណ្ហាជិនានេះហើយទៅចុះ យើងនឹងចិញ្ចឹមកូន
តូចទាំងនោះ" ។

ព្រះរាជបុត្រីព្រះនាមមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អ បានក្រាប
ទូលព្រះរាជានោះវិញថា ៖

"បពិត្រព្រះទេវៈ កូនតូចទាំងពីរគឺបាជាលី និងនាងកណ្ហាជិនា ជា
ទីស្រឡាញ់របស់ខ្ញុំម្ចាស់ កូនតូចទាំងពីរនោះ នឹងញ៉ាំងហឫទ័យ

នៃយើងខ្ញុំដែលមិនទាន់ប្រាសចាកសេចក្តីសោក ឲ្យត្រេកអរក្នុងព្រៃនោះបាន" ។

ព្រះបាទសញ្ជយមហារាជ ទ្រង់ញ៉ាំងពួកអ្នកសិរិវាស្រ្តឲ្យចម្រើន មានព្រះបន្ទូលនឹងព្រះនាងមទ្រីនោះថា ៖

"ក្មេងទាំងពីរ ធ្លាប់បរិភោគបាយអង្ករសាលីលាយដោយសាច់ ដ៏ស្អាត នឹងបរិភោគផ្លែឈើដូចម្តេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់បរិភោគ ភោជនក្នុងភាជន៍មាស ដែលមានទម្ងន់ ១០០ បល្ល:[៣៩] មានស្នាមចម្លាក់ ១០០ នឹងបរិភោគភោជនដែលដាក់ក្នុងស្លឹកឈើដូចម្តេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់ស្លៀកដណ្តប់សំពត់ អ្នកដែនកាសីផង សំពត់ខោមៈផង សំពត់កោទុម្ពរៈផង នឹងស្លៀកដណ្តប់សំពត់ដែលក្រងដោយស្បូវភ្លាំងដូចម្តេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់ទៅដោយរ ដោយគ្រែស្នែង ដោយរថ នឹងដើរទៅដោយជើងដូចម្តេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់ដេកក្នុងផ្ទះមានកំពូល មានសន្ទះទ្វារនិងបង្អួចដ៏ជិតស្និទ្ធ ខ្យល់ចេញចូលមិនបាន នឹងដេកទៀបគល់ឈើដូចម្តេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់ដេកលើបល្ល័ង្ក

---

៣៩ ឈ្មោះមាត្រាសម្រាប់ថ្លឹង, វាស់, វាល់" ទម្ងន់១០ធរណៈត្រូវជាមួយបល្ល:។

លើកម្រាលពោមវែងនិងលើកម្រាលដ៏វិចិត្រ នឹងដេកលើកម្រាលស្មៅដូចម្ដេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់លាបស្រឡាបដោយគ្រឿងក្រអូប គឺខ្លឹមក្រឹស្នា ខ្លឹមចន្ទន៍ នឹងស្មៀកដណ្ដប់សំពត់ប្រឡាក់ក្អែលដូចម្ដេចកើត ? ។ ក្មេងទាំងពីរ ធ្លាប់បិតនៅក្នុងសេចក្ដីសុខ មានអវយវៈគេតែងបក់ដោយផ្ចិតពោមចាមរី និងសំណុំកន្ទុយក្ងោក នឹងត្រូវល្បោមមូសប៉ះពាល់ដូចម្ដេចកើត" ។

## ព្រះវេស្សន្តរចាកចេញពីរាជវាំង

កាលដែលជនទាំងនោះ កំពុងជជែកគ្នាទៅវិញទៅមកយ៉ាងនេះស្រាប់តែរាត្រីភ្លឺច្បាស់ ព្រះអរុណោទ័យរះឡើង ។ អាមាត្យទាំងឡាយបាននាំមកនូវរថវិចិត្ររចនាល្អល្អះ ទឹមដោយសេះសិន្ធព ៤ មកបញ្ឈរទៀបព្រះរាជទ្វារ រង់ចាំព្រះមហាសត្ត ។ រីឯព្រះនាងមទ្រី ថ្វាយបង្គំព្រះមាតាក្មេកឪពុកក្មេក ក្រាបទូលថា ៖

"បពិត្រព្រះទេវៈ ព្រះអង្គកុំទ្រង់ព្រះកន្សែងឡើយ សូមព្រះអង្គកុំមានព្រះហឫទ័យអាក់អន់ឡើយ ខ្ញុំម្ចាស់ទាំងពីរនាក់នឹងរស់នៅយ៉ាងណា ក្មេងទាំងពីរនាក់ ក៏រស់នៅយ៉ាងនោះដែរ"

ពោលហើយ ព្រះនាងលាស្ត្រីផ្សេង ៗ នាំកូនទាំងពីរទៅឈរចាំនៅឯរថ មុនព្រះបាទវេស្សន្តរ ។

លំដាប់នោះ ក្នុងកាលព្រះនាងមទ្រីឡើងរថឈរនៅរង់ចាំ ព្រះវេស្សន្តរជាក្សត្រទ្រង់បានឲ្យទាន ហើយក៏ថ្វាយបង្គំព្រះបិតានិងព្រះមាតា ធ្វើប្រទក្សិណព្រះបិតានិងព្រះមាតានោះ ។ ព្រះវេស្សន្តរឡើងកាន់រថដែលទឹមដោយសេះ ៤ មានសន្ទុះដ៏លឿន នាំបុត្រាបុត្រីនិងព្រះជាយាស្ដេចទៅកាន់គិរីវង្កត ។ លំដាប់នោះ ពពួកជនជាច្រើនឈរមូលមីរដេរដាស អើតមើលព្រះបាទវេស្សន្តរ, ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរទ្រង់ក៏បររថសំដៅទៅរកទីដែលមានជនច្រើនកុះករន៉ុះ ហើយត្រាស់ថា ៖

"យើងសូមលាអ្នករាល់គ្នាទៅហើយ សូមឲ្យពួកញាតិកុំមានជំងឺតម្កាត់ឡើយ ចូររស់នៅឲ្យបានសុខ កុំបីមានទុក្ខបុកម្នេញឡើយ" ។

ព្រះមហាសត្វ លាមហាជនយ៉ាងនេះ ទ្រង់ចេញទៅទាំងផ្ដល់ដំបូន្មានដល់ពួកគេផងដែរថា ៖

"ចូរអ្នកទាំងឡាយ កុំធ្វេសប្រហែស ចូរធ្វើបុណ្យទាំងឡាយ មានទានជាដើម" ។

កាលព្រះអង្គកំពុងតែចេញដំណើរទៅ ព្រះមាតារបស់ទ្រង់ បានបញ្ជូននូវរទេះផ្ទុកពេញរតនៈ ៧ ប្រការ ព្រមទាំងអាភរណៈជាច្រើន តាមខាងទាំងពីរ ដោយផ្ដាំថា ៖

"ចូរឲ្យកូនរបស់ខ្ញុំដែលមានអាធ្យាស្រ័យក្នុងទាន បន្តឲ្យទានទៀតចុះ" ។

ព្រះបាទវេស្សន្តរ ដោះគ្រឿងអាភរណៈដែលពាក់ជាប់កាយខ្លួនប្រទានដល់ពួកស្មូមដែលមកដល់ អស់វារៈ ១៨ ដង រួចទ្រង់ប្រទានសព្វវត្ថុដែលសេសសល់ ។ ព្រះអង្គចេញផុតអំពីនគរ ទ្រង់មានបំណងងាកមើលក្រោយ ។ រំពេចនោះ ដោយអាស្រ័យហឫទ័យរបស់ព្រះអង្គមហាប្រឹថពីក្នុងទីមួយរទេះ បានបែកបង្វិលដូចមាស៊ីនផលិតភាជន៍តម្រង់រទេះឲ្យមានមុខឈមឆ្ពោះទៅចំនគរ ។ ព្រះអង្គបាន បោលខ្សែនេត្រា គន់មើលទៅលំនៅឋានរបស់ព្រះមាតាបិតា ។ ដោយហេតុនោះផែនដីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។

លុះគន់មើលដោយព្រះអង្គឯងហើយ ព្រះបាទវេស្សន្តរប្រាប់នាងមទ្រីឲ្យសម្លឹងមើលផងដែរ ៖

"នែអូនមទ្រី អូនចូរគន់មើលចុះ នុ៎ះហ្ន៎និវេសន៍របស់ព្រះបាទសិវិដ៏ប្រសើរ នុ៎ះរាំងរបស់យើងដែលព្រះបិតាប្រទានឲ្យ មើលទៅជាទីគួរត្រេកអរណាស់" ។

លំដាប់នោះ ព្រះមហាសត្តបានប្រាប់ឲ្យពួកអាមាត្យដែលកើតដំណាល ចំនួន៦០.០០០នាក់ និងជនផ្សេង ៗ ទៀត ឲ្យនាំគ្នាត្រឡប់វិញ រួចទ្រង់បររថទៅ និងប្រាប់ព្រះនាងមទ្រីថា ៖

"នែអូនសម្លាញ់ អូនឃ្មាំមើលផង ក្រែងលោស្នូមយាចកមកតាមក្រោយ" ។

ព្រះនាងមទ្រីក៏អង្គុយសម្ងឹងមើលទៅក្រោយ ។

គ្រានោះ ព្រាហ្មណ៍ ៤ នាក់ ដែលទៅពុំទាន់សត្តសតកមហាទានរបស់ព្រះបាទវេស្សន្តរ ពួកគេបានមកកាន់នគរ សួរថាតើព្រះបាទវេស្សន្តរនៅឯណា កាលបើឮគេប្រាប់ថាព្រះបាទវេស្សន្តរ ឲ្យទានរួចចេញទៅបាត់ហើយ ពួកគេសួរទៀតថា តើទ្រង់ចេញទៅយកអ្វីទៅខ្លះជាមួយ កាលបើឮគេប្រាប់ថាទ្រង់ទៅដោយរទេះទេ ពួកគេក៏នាំគ្នាស្រូតដំណើរយ៉ាងរួសរាន់ពេញទំហឹង តាមទៅ ដើម្បីសូមសេះទាំងឡាយនឹងព្រះអង្គ ។

ព្រះនាងមទ្រី លោតែក្រឡេកឃើញពួកព្រាហ្មណ៍នោះ កំពុងដើរស្រូតមកយ៉ាងញាប់ជើងស្មេញ ក៏ក្រាបទូលដល់ព្រះស្វាមីថា ៖

"ពួកស្មូមកំពុងមក ព្រះសម្មតិទេព" ។

ព្រះមហាសត្វ សំចតរទេះចាំ ។ ពួកគេមកដល់ ក្រាបទូលសូមសេះទាំងឡាយ ។ ព្រះមហាសត្វ បានប្រទានសេះទាំងឡាយដល់ពួកគេ ។

នាកាលសេះទាំងឡាយ ត្រូវបានប្រទាន នឹមរទេះឋិតនៅទ្រឹងលើអាកាស រំពេចនោះ កាលបើព្រាហ្មណ៍ទាំងនោះ គ្រាន់តែចេញផុតទៅ មានទេវបុត្រ ៤ អង្គ បានប្លែងភេទជារមាំងមកចូលក្រោមនឹមនាំរទេះទៅ ។ ព្រះមហាសត្វ ដឹងអានុភាពទេវបុត្ររបស់ពួកគេ បានត្រាស់ថា ៖

"នែមទ្រី នាងចូរគន់មើលចុះ ម្រឹគទាំងឡាយមានភេទជារមាំង

នាំយើងទៅ ដូចសេះដែលគេហ្វឹកល្អហើយ មានរូបល្អដ៏វិចិត្រ" ។

កាលព្រះអង្គកំពុងទៅយ៉ាងនេះ ស្រាប់តែមានព្រាហ្មណ៍ម្នាក់ផ្សេងទៀតជាទី ៥ មកក្នុងព្រៃនោះសូមរទេះ ។ ព្រះបាទវេស្សន្តរក៏ប្រទានរថដល់ព្រាហ្មណ៍នោះ ព្រះហឫទ័យរបស់ព្រះអង្គ មិនបានរួញរាឡើយ ។ ទ្រង់បានឲ្យព្រះទេវី បុត្រា បុត្រីរបស់ព្រះអង្គចុះពីរថនោះ

រួចប្រទានអស្សរថដល់ព្រាហ្មណ៍ អ្នកស្វែងរកទ្រព្យ ។ នាកាលរទេះ
ត្រូវបានប្រទាន ពួកទេវបុត្របានអន្តរធានបាត់ទៅ ។

តាំងពីគ្រានោះមក ជនទាំងអស់នោះ ក្លាយជាថ្មើរជើង ។ ពេល
នោះ ព្រះមហាសត្តប្រាប់នាងមទ្រីថា ៖

"នៃមទ្រី នាងចូរពកណ្ហាចុះ ដ្បិតកណ្ហានុ៎ះជាកូនប្អូននៅតូច
ស្រាល បងនឹងពជាលី ដ្បិតជាលីនោះជាកូនបងធ្ងន់ជាងប្អូន" ។

លុះនិយាយយ៉ាងនេះហើយ ព្រះរាជាទ្រង់ពជាលីកុមារ ចំណែក
ព្រះរាជបុត្រី ទ្រង់ពនាងកណ្ហាជិនា ទ្រង់យាងទៅ មានព្រះបន្ទូលព្រះ
វាចាជាទីស្រឡាញ់ សំណេះសំណាលគ្នាទៅវិញទៅមក ។

ទានកណ្ឌវណ្ណនា ចប់ ។

# ជំពូកទី ៤

## វនបវេសនកណ្ឌវណ្ណនា

### ព្រះវេស្សន្តរយាងចូលព្រៃ

*ជនទាំងនោះ កាលបើជួបមនុស្សទាំងឡាយដែលដើរមកតាមផ្លូវ ក៏តែងតែសួរថា ៖*

*"តើភ្នំគិរីវង្កត នៅឯណា ?" ។*

*"នៅឆ្ងាយ" មនុស្សទាំងឡាយប្រាប់ ។*

*ក្សត្រទាំងនោះ មានព្រះបន្ទូលសំណេះសំណាលថា ប្រសិនបើពួកមនុស្សណាមួយ មកជួបក្នុងផ្លូវជាលំដាប់ យើងនឹងសួររកផ្លូវនឹងមនុស្សទាំងនោះថា វង្កតបព៌តនៅក្នុងទីណា ។ មនុស្សទាំងនោះបានឃើញយើងក្នុងទីនោះហើយ សមជាទួញយំ មុខគួរឲ្យអាណោចអាធម្ម មនុស្សទាំងនោះ ក៏ប្រាប់សេចក្ដីទុក្ខថា វង្កតបព៌តនៅក្នុងទីឆ្ងាយ ។*

*នៅសងខាងផ្លូវ មានដើមឈើដែលទ្រទ្រង់ផ្លែផ្សេង ៗ ទារកទាំងពីរក្រឡេកតែឃើញ ក៏នាំគ្នាកន្ទក់កន្ទេញទារបរិភោគ ។ ដោយអានុភាពនៃព្រះមហាសត្ត ដើមឈើដែលទ្រទ្រង់ផ្លែ ក៏ឱនទោរទន់មកជិតមួយ*

ដំហោងដៃ[៤០] ។ លំដាប់នោះ ពួកគេបានបេះផ្លែឈើតូចធំទុំល្អ ៗ ឲ្យដល់ក្មេង ។ ព្រះនាងមទ្រី ឃើញហេតុដូច្នោះហើយ បានប្រកាសនូវសេចក្តីអស្ចារ្យ ចម្លែកគួឲ្យព្រឺរោម ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ៖

"ឱហ្ន៎ នេះគួរអស្ចារ្យណាស់ ចម្លែកណាស់ គួរឲ្យព្រឺរោមក្នុងលោក ! ដើមឈើទាំងឡាយស្រាប់តែទោរចុះមកឯង ដោយតេជានុភាពនៃព្រះបាទវេស្សន្តរ" ។

ពីជេតុត្តរនគរទៅចម្ងាយ ៥ យោជន៍ ដល់ភ្នំមួយឈ្មោះថា សុវណ្ណគិរីតាល, ពីសុវណ្ណគិរីទៅ ៥ យោជន៍ទៀត ដល់ស្ទឹងមួយឈ្មោះថា កោន្តិមារា, ពីកោន្តិមារាទៅ ៥ យោជន៍ទៀត ដល់ភ្នំមួយឈ្មោះថា អញ្ជរគិរី, ពីអញ្ជរគិរីទៅ ៥ យោជន៍ទៀត ដល់ស្រុកមួយឈ្មោះថាទុន្និវិដ្ឋព្រាហ្មណៈ, ពីទុន្និវិដ្ឋព្រាហ្មណៈទៅចម្ងាយ ១០ យោជន៍ ទើបដល់មាតុលនគរ ។ សរុបមកថា ផ្លូវនោះ មានចម្ងាយ ៣០ យោជន៍ រាប់អំពីជេតុត្តរនគរទៅ ។ ទេវតាបានបំប្រួញផ្លូវនោះ ទើបពួកគេបានធ្វើដំណើរដល់មាតុលនគរ ដោយចំណាយពេលត្រឹមតែមួយថ្ងៃគត់ ។

[៤០] រយៈទីដែលអាចឈោងដៃទៅដល់, ចន្លោះដែលអាចលូកឈោងដៃចាប់បាន ។

ជនទាំងនោះ ចេញអំពីជេតុត្តរនគរក្នុងពេលបាយព្រឹក ទៅដល់មាតុលនគរ ក្នុងដែនចេតៈដែលស្តុកស្តម្ភជំទូលាយ មានសាច់សុរានិងទឹកច្រើន ក្នុងពេលល្ងាច ។

## ស្តេចមាតុលនគរអញ្ជើញព្រះវេស្សន្តរឲ្យសោយរាជ្យ

ក្នុងសម័យនោះ ក្សត្រិយ៍ចំនួន ៦០.០០០ អង្គ រស់នៅក្នុងមាតុលនគរ ។ ព្រះមហាសត្វ មិនចូលទៅខាងក្នុងនគរទេ ព្រះអង្គបានអង្គុយនៅក្នុងសាលាមួយខ្នង ទៀបទ្វារព្រះនគរហ្នឹងឯង ។ គ្រានោះ ព្រះនាងមទ្រី បានជូតល្អងធូលីចេញពីព្រះបាទា របស់ព្រះពោធិសត្វ ហើយប្រាប់ព្រះបាទា ។ ព្រះនាងមានព្រះតម្រិះថា "អញនឹងឲ្យគេដឹងថាព្រះបាទវេស្សន្តរយាងមក" ដូច្នេះ ព្រះនាងចេញពីសាលាមកឈរនៅត្រង់ទ្វារសាលា ល្មមស្វាមីចោលដាក់ភ្នែកមកឃើញ ។ ពួកស្ត្រីដែលចូលចេញនគរ លោតែបានឃើញព្រះនាង ក៏នាំគ្នាចោមរោមមើលចរចាថា ៖

"ឱហ្ន៎ ព្រះនាងម្ចាស់ជាសុខុមាលជាតិ ស្ដេចសញ្ចារ[៤១]មកដោយព្រះបាទទទេ ។ សម្ដេចព្រះមទ្រីនោះ ធ្លាប់ស្ដេចទៅដោយវ គ្រែស្នែងមាស និងរថ តែក្នុងថ្ងៃនេះស្ដេចទៅក្នុងព្រៃដោយព្រះបាទទទេ" ។

មហាជន បានឃើញព្រះនាងមទ្រីផង ព្រះបាទវេស្សន្តរផង កូនទាំងពីរផង ដែលមកដោយដំណើរអនាថា ពួកគេក៏នាំគ្នាទៅក្រាបទូលដល់ព្រះមហាក្សត្ររបស់ពួកគេ ។ ស្ដេចទាំង ៦០.០០០ អង្គ យំខ្សឹកខ្សួល នាំគ្នាយាងមកកាន់សម្នាក់របស់ព្រះបាទវេស្សន្តរ ទ្រង់ព្រះកន្សែងថា ៖

"បពិត្រព្រះទេវៈ ព្រះអង្គសុខស្រួលទេឬ? បពិត្រព្រះទេវៈព្រះអង្គ មិនមានជំងឺតម្កាត់ទេឬ? ។ ព្រះបិតារបស់ព្រះអង្គ មិនមានរោគទេឬ? ពួកអ្នកសិវិរាស្ត្រមិនមានជំងឺតម្កាត់ទេឬ? បពិត្រមហារាជ ទៅណាទៅពួកពលរបស់ព្រះអង្គ? ទៅណាទៅរថមណ្ឌលរបស់ព្រះអង្គ? ។ ព្រះអង្គទ្រង់ស្ដេចមកកាន់ផ្លូវឆ្ងាយ

[៤១] (ន.) ការត្រាច់ទៅតាមច្រករហក ឬផ្លូវតូចចង្អៀត ។ (កិ.) ដើរត្រាច់ចរ, ដើរប្ញើកចុះប្ញើកឡើង, ដើរស្វែងរកប្រយោជន៍ស្វាត់ ៗ ។

មិនមានសេះ មិនមានរថ ពួកបច្ចាមិត្រគ្របសង្កត់ព្រះអង្គឬ ទើប ស្ដេចយាងមកកាន់ទិសនេះ ?" ។

គ្រានោះ ព្រះមហាសត្វប្រាប់មូលហេតុមករបស់ខ្លួន ដល់ពួកក្សត្រិយ៍ទាំងនោះថា ៖

"ម្នាលសម្លាញ់ទាំងឡាយ យើងមានសេចក្ដីសុខស្រួលទេ ម្នាលសម្លាញ់ទាំងឡាយ យើងមិនមានជំងឺតម្កាត់ទេ ព្រះបិតារបស់យើងក៏មិនមានរោគទេ ទាំងពួកអ្នកសិវិរាស្ត្រ ក៏មិនមានជំងឺតម្កាត់ដែរ ។ យើងបានឲ្យដំរី មានភ្លុកងទន្ទាំ អាចពុះពារសត្រូវស្គាល់ខែត្រនៃចម្បាំងគ្រប់យ៉ាង ជាដំរីដ៏ឧត្តមសសុទ្ធ បិទបាំងដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេងអាចញាំញីសត្រូវបាន មានភ្លុកល្អគ្របដោយស៊ែ ជាដំរីសប្រហែលនឹងភ្នំកៃលាស[៤២] ។ ខ្ញុំបានឲ្យដំរីនោះព្រមទាំងស្វេតច្ឆត្រ ព្រមទាំងកម្រាល លើខ្នងដ៏ល្អ ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សា ជាយានដ៏ប្រសើរ ជារាជពាហនៈ ដល់ពួកព្រាហ្មណ៍ ។ ព្រោះដំណើរនោះហើយ បានជាពួកអ្នកសិវិរាស្ត្រខឹងនឹងខ្ញុំ ទាំងព្រះបិតា ក៏មានព្រះហឫទ័យអាក់

[៤២] ឈ្មោះភ្នំវិសេសមួយក្នុងពួកភ្នំហិមាល័យ ។

អន់នឹងខ្ញុំ ព្រះរាជាទ្រង់ដេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្លាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរដឹងឱកាសជាទីនៅក្នុងព្រៃសម្រាប់ពួកយើង" ។

ស្ដេចចេតៈទាំងនោះ ពោលថា ៖

"បពិត្រមហារាជ ព្រះអង្គទ្រង់យាងមកស្រួលហើយ ព្រះអង្គមិនមែនយាងមកដោយអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់ស្ដេចមកដល់ហើយ សូមព្រះអង្គមានព្រះបន្ទូលប្រាប់របស់ដែលមានក្នុងទីនេះ បពិត្រមហារាជ សូមព្រះអង្គទ្រង់សោយអន្ទក់ ក្រអៅឈូកទឹក ឃ្មុំ សាច់និងបាយនៃអង្ករស្រូវសាលី[៤៣]ដ៏ស្អាត ដ្បិតព្រះអង្គយាងមកហើយ ទុកជាភ្ញៀវរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ" ។

ព្រះបាទវេស្សន្តរ តបថា ៖

"វត្ថុណាដែលអ្នកទាំងអស់ធ្វើឲ្យជារបស់មានតម្លៃ បានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំក៏បានទទួលហើយ តែថាព្រះរាជាទ្រង់បណ្ដេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្លាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងឱកាសជាទីនៅក្នុងព្រៃសម្រាប់យើង" ។

---

[៤៣] ស្រូវខ្សាយ ។

ស្តេចចេតៈទាំងឡាយ តបថា ៖

"បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គស្តេចគង់នៅក្នុងដែនឈ្មោះចេតៈនេះសិនចុះ ទម្រាំពួកព្រះរាជាចេតៈ នឹងទៅកាន់សម្នាក់ព្រះរាជបិតា ដើម្បីទូលអង្វរ ។ ពួកព្រះរាជាចេតៈត្រេកអរបានទីពឹងហើយ ហែហមចោមរោមព្រះអង្គទៅ ដើម្បីញ៉ាំងមហារាជ ដែលញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ឲ្យលើកទោសចោល បពិត្រក្សត្រ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ" ។

ព្រះបាទវេស្សន្តរ តបថា ៖

"អ្នកទាំងឡាយកុំពេញចិត្តនឹងការទៅកាន់សម្នាក់ព្រះរាជា ដើម្បីទូលអង្វរមហារាជ ឲ្យលើកទោសចោល ព្រោះព្រះរាជាមិនជាធំក្នុងការនោះទេ ។ ព្រោះថាពួកអ្នកសិវិរាស្ត្រណា ជានាយពលក្តី ជាអ្នកនិគមក្តី សុទ្ធតែជាអ្នកខឹង ពួកអ្នកសិវិរាស្ត្រនោះ ចង់បណ្តេញទាំងព្រះរាជា ព្រោះហេតុតែយើងផង" ។

ស្តេចចេតៈទាំងឡាយ ពោលថា ៖

"បពិត្រព្រះអង្គអ្នកញ៉ាំងដែនឲ្យចម្រើន បើដំណើរហ្នឹងមានក្នុងដែននុ៎ះមែន សូមព្រះអង្គសោយរាជ្យក្នុងដែននេះចុះ នឹងមាន

ព្រះរាជាចេតនគរជាបរិវារ ។ ដែននេះសោត ក៏ជាដែនស្តុកស្តម្ភ ទូលាយ ជនបទក៏ស្តុកស្តម្ភធំ បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់ធ្វើសេចក្តីពេញព្រះទ័យ ដើម្បីនឹងគ្រប់គ្រងរាជ្យ" ។

ព្រះបាទវេស្សន្តរ តបថា ៖

"យើងត្រូវគេបណ្តេញអំពីដែនហើយ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីពេញចិត្ត ដើម្បីនឹងគ្រប់គ្រងរាជ្យទេ ម្នាលពួកចេតបុត្រ អ្នកចូរស្តាប់ខ្ញុំ ។ បើពួកព្រះរាជាចេតៈអភិសេកយើងដែលត្រូវគេបណ្តេញចាកដែនក្នុងរាជ្យហើយ ពួកអ្នកសិវិរាស្ត្រណាជានាយពលក្តី ជាអ្នកនិគមក្តី ពួកអ្នកសិវិរាស្ត្រនោះ មិនត្រេកអរទេ ។ ទាំងមិនមានសេចក្តីស្មោះស្មគ្រនឹងអ្នកទាំងឡាយ ព្រោះហេតុតែខ្ញុំដោយពិត ខ្ញុំមិនគាប់ចិត្តនឹងការប្រកួតប្រកាន់ទាស់ទែង ជាមួយនឹងពួកអ្នកសិវិរាស្ត្រ ។ តទៅ នឹងកើតមានការប្រកួតប្រកាន់ដ៏ពន្លឹក ការវាយដំគ្នាយ៉ាងសម្បើមនឹងមានមិនខាន ជនជាច្រើនគប្បីបៀតបៀនគ្នា ព្រោះហេតុតែខ្ញុំម្នាក់ឯង ។ វត្ថុណាដែលអ្នកទាំងអស់គ្នាធ្វើឲ្យជារបស់មានតម្លៃ បានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំបានទទួលហើយ ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅក្នុ

វង្កត ម្នាលសម្លាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរជួយបង្ហាញ ឱកាសជាទីនៅក្នុងព្រៃសម្រាប់យើង" ។

ព្រះមហាសត្ត មិនប្រាថ្នានូវរាជសម្បត្តិយ៉ាងនេះ បើទោះបីជាត្រូវស្តេចចេតៈទាំងឡាយ ទូលអង្វរដោយអនេកបរិយាយយ៉ាងណាក៏ដោយ ។ គ្រានោះ ស្តេចចេតៈទាំងឡាយ បានធ្វើសក្ការៈដ៏សម្បើមចំពោះព្រះអង្គ ។ បើទោះបីជាយ៉ាងនេះ ក៏ព្រះអង្គមិនប្រាថ្នាយាងចូលទៅកាន់ទីក្រុងរបស់ពួកគេទេ ។ លំដាប់នោះ ពួកស្តេចចេតៈ តុបតែងសាលានោះឯង ព័ទ្ធព័ទ្ធជុំវិញដោយរាំងនន រៀបតាំងគ្រែធំ ធ្វើការរក្សាយ៉ាងហ្មត់ចត់ នូវជនទាំង ៤ រូប ។ ព្រះបាទវេស្សន្តរ ទទួលការរក្សាយ៉ាងហ្មត់ចត់នោះ អំពីពួកគេ ត្រឹមតែមួយរាត្រី ទ្រង់ផ្ទំក្នុងសាលា លុះថ្ងៃបន្ទាប់ ព្រឹកព្រហាមឡើង ទ្រង់ស្រង់ទឹក សោយនូវព្រះក្រយាដែលមានរសឆ្ងាញ់ផ្សេង ៗ រួចទ្រង់បន្តដំណើរចេញទៅទៀត ដោយមានស្តេចចេតៈទាំងនោះហែហមទៅជាមួយផង ។

**ស្តេចចេតៈបង្ហាញផ្លូវ**

ក្សត្រិយ៍ទាំង ៦០.០០០ អង្គ បានជូនដំណើរព្រះបាទវេស្សន្តរនោះទៅ អស់ចម្ងាយផ្លូវ ១៥ យោជន៍ លុះទៅដល់ជិតទ្វារព្រៃ ពួកគេបានប្រាប់ផ្លូវខាងមុខចម្ងាយ ១៥ យោជន៍ទៀតថា ៖

"ពួករាជបព្វជិត ជាអ្នកឈ្លាស ជាអ្នកបូជាភ្លើង មានចិត្តតម្កល់មាំតែងគង់នៅក្នុងទីណា ពួកទូលព្រះបង្គំជាខ្ញុំ នឹងក្រាបទូលដល់ព្រះអង្គយ៉ាងនោះ បពិត្រមហារាជ ព្រះអង្គគង់នៅជាមួយនឹងព្រះរាជបុត្រ ព្រមទាំងព្រះអគ្គជាយា ក្បែរភ្នំណា ភ្នំនោះហៅថា ភ្នំគន្ធមាទន៍ ជាវិការៈនៃថ្មសុទ្ធ" ។

ពួកព្រះរាជាចេតៈ កាលយំមានមុខជោកដោយទឹកភ្នែក ក៏ក្រាបទូលព្រះបាទវេស្សន្តរនោះថា ៖

"បពិត្រមហារាជ សូមព្រះអង្គទ្រង់យាងទៅអំពីទីនេះ សំដៅត្រង់ទៅទិសខាងជើង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ព្រះអង្គនឹងទតឃើញភ្នំឈ្មោះវេបុល្លៈ ជាភ្នំដេរដាសដោយពួកឈើផ្សេង ៗ មានម្លប់ត្រជាក់ជាទីរីករាយចិត្ត។ បពិត្រព្រះអង្គដ៏ចម្រើន លុះព្រះអង្គច្លងផុតភ្នំនោះ នឹងបានឃើញស្ទឹងមួយ ជាទីហូរទៅនៃទឹក ឈ្មោះកេតុមតី ជាស្ទឹងជ្រៅ ហូរចេញអំពីផ្ទៃភ្នំ ដេរដាស

ដោយហ្វូងត្រីច្រើន មានកំពង់រាបស្មើល្អ មានទឹកច្រើន ព្រះអង្គ ស្រង់ផង សោយផង លួងលោមព្រះរាជបុត្ររបស់ព្រះអង្គ ក្នុង ស្ទឹងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន តទៅ ព្រះអង្គនឹងទតឃើញ ដើមជ្រៃ មានផ្លែផ្អែមដុះនៅលើកំពូលភ្នំជាទីត្រេកអរ មានម្លប់ ត្រជាក់ ជាទីរីករាយនៃចិត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់ នោះ ព្រះអង្គនឹងទតឃើញភ្នំមួយ ឈ្មោះនាលិក ជាវិការៈនៃថ្ម ដេរដាសដោយពួកសត្វស្លាបផ្សេង ៗ កុះករដោយពួកកិន្នរ ។ នៅ ភាគខាងជើងឆៀងខាងកើតនៃភ្នំនោះ មានស្រះឈ្មោះ មុចលិន្ទ សឹងដេរដាសដោយឈូកសផង ឧប្បលសផង ចង្កុលណីផង ។ ព្រះអង្គចូលទៅកាន់ព្រៃដូចផ្ទៃមេឃ មានស្មៅ ចិញ្ចៀនខៀវ ស្រស់ជានិច្ច ចូលទៅកាន់ដងព្រៃដេរដាសដោយ ឈើមានផ្កា និងឈើ មានផ្លែទាំងពីរ ដូចសីហៈប្រាថ្នាចំណី ។ ក្នុងព្រៃនោះ មានបក្សីជាច្រើន មានសម្បុរប្លែក ៗ គ្នា មានសំឡេងមូល មាន សំឡេងពីរោះ ស្រែកយំ ឆ្លងឆ្លើយគ្នាទៅមកលើដើម ឈើមាន ផ្ការីកតាមរដូវ ។ ព្រះអង្គទ្រង់ ស្តេចទៅកាន់ជង្ហុកភ្នំ និងកន្លែង កកើតនៃស្ទឹងទាំងឡាយ នឹងបានទតឃើញស្រះបោក្ខរណី ដេរ

ដាសដោយដើមកញ្ជើបាយដាចនិងដើមថ្ងាន់ ។ ជាស្រះដេរដាស ដោយហ្វូងត្រីដ៏ច្រើន មានកំពង់រាបស្មើល្អ មានទឹកច្រើន មាន សណ្ឋាន ៤ ជ្រុងស្មើ មានទឹកមានរសឆ្ងាញ់ មានក្លិនមិនគួរខ្ពើម ។ សូមព្រះអង្គទ្រង់សាងបណ្ណសាលា ត្រង់ទិសខាងជើង ឆៀងខាង កើតនៃស្រះបោក្ខរណីនោះ លុះទ្រង់បានសាងបណ្ណសាលាហើយ សូមទ្រង់ព្យាយាមត្រាច់ស្វែងរកផលាផលចិញ្ចឹមព្រះអង្គចុះ" ។

## ចេតបុត្រឆ្នាំព្រៃ

ស្តេចចេតៈទាំងឡាយនោះ បានប្រាប់ផ្លូវចម្ងាយ ១៥ យោជន៍ ដល់ព្រះបាទវេស្សន្តរ យ៉ាងនេះ រួចបានបញ្ជូនស្តេចវេស្សន្តរទៅ ។ ដើម្បីបន្ទោបង់ នូវសេចក្តីភ័យខ្លាចអំពីអន្តរាយ របស់ព្រះបាទវេស្សន្តរ ពួកទ្រង់មានព្រះចិន្តាថា ៖

"កុំឲ្យបច្ចាមិត្រណាមួយ បានឱកាសឡើយ"

ដូច្នេះ ពួកទ្រង់បានហៅចេតបុត្រម្នាក់ ដែលជាអ្នកក្លាហាន បានហ្វឹក ហាត់ល្អហើយ មកឲ្យចាត់តាំងការយាមរក្សាថា ៖

"ឯងចូរឃ្លាំមើល នូវមនុស្សទាំងឡាយ ទាំងអ្នកទៅ ទាំងអ្នកមក"

ដូច្នេះហើយ ពួកទ្រង់បាន វិលត្រឡប់ទៅរាជធានីរបស់ខ្លួនវិញ ។

## វិស្សកម្មទេវបុត្រនិម្មិតបណ្ណសាលា

ចំណែកព្រះបាទវេស្សន្តរ ព្រមទាំងកូនប្រពន្ធ បានទៅដល់ភ្នំគន្ធមាទន៍ ស្នាក់នៅទីនោះមួយថ្ងៃ ចេញពីទីនោះឆ្ពោះមុខទៅខាងជើង កាត់តាមជើងភ្នំវេបុល្ល: ដល់ស្ទឹងមួយឈ្មោះកេតុមតី ទ្រង់អង្គុយទៀបឆ្នេរ សោយនូវសាច់ដ៏ឆ្ងាញ់ដែលអ្នកព្រៃថ្វាយ រួចហូតស្នៀតសក់មាសប្រទានដល់គេ ទ្រង់ចុះងូតផឹកក្នុងស្ទឹងនោះ មានសេចក្ដីក្រវាល់ក្រវាយស្ងប់ហើយ ទ្រង់ឡើងពីស្ទឹង អង្គុយសម្រាកមួយស្របក់ទៀបគល់ដើមជ្រៃ ដែលដុះនៅលើកំពូលភ្នំសានុ ទ្រង់សោយផ្លែជ្រៃជាច្រើនផ្លែ រួចទ្រង់ក្រោកបន្តដំណើរបានទៅដល់ភ្នំមួយទៀតឈ្មោះថានាឡិក: ទ្រង់យាងឆ្ពៃលភ្នំនោះ បានដល់ស្រះមុចលិន្ទ ទ្រង់យាងឆ្ពៃលតាមឆ្នេរស្រះបានទៅដល់ជ្រុងខាងជើងឆៀងខាងកើត ហើយដើរចូលទៅកាន់ព្រៃស្រោង តាមផ្លូវចុះតែជើងម្នាង រំលងព្រៃនោះ បានដល់នូវស្រះបោក្ខរណីរាង៤ជ្រុង ខាងមុខនៃប្រភពស្ទឹង ដែលមានភ្នំពិបាកដើរ ។

ក្នុងខណ:នោះ សក្កទេវរាជបានរំពឹងមើល ក៏ដឹងថា "ព្រះមហាសត្តកំពុងយាងចូលទៅកាន់ព្រៃហិមពាន្ត" ទ្រង់ព្រះចិន្តាថា "ព្រះបាទវេស្សន្តរនោះគួរណាស់តែបានលំនៅឋាន" រួចទ្រង់ឲ្យហៅវិស្សកម្មទេវ

បុត្រ បញ្ជាថា "នែអ្នក អ្នកចូរទៅសាងអាស្រមបទ ក្នុងទីគួររីករាយនៃចិត្ត ក្នុងទឹកដីភ្នំវង្កត រួចហើយសឹមមកវិញចុះ" ។ វិស្សុកម្មទេវបុត្រទទួលតបថា "ព្រះករុណាថ្លៃវិសេស ព្រះទេវៈ" ហើយគេចុះចាកទេវលោក និម្មិតបណ្ណសាលាពីរខ្នង ទីចង្រ្កមពីរកន្លែង និងទីសម្រាកវេលាយប់មួយកន្លែង ទីសម្រាកវេលាថ្ងៃមួយកន្លែងទុកក្នុងទីនោះ ។ មិនតែប៉ុណ្ណោះទេ វិស្សុកម្មទេវបុត្របាននិម្មិតដើមឈើទាំងឡាយ ដែលទ្រទ្រង់ផ្លែផ្សេង ៗ និងព្រៃចេកជាច្រើនតំបន់ ទុកក្នុងទីចុងចង្រ្កមនិងក្នុងទីនេះផងនោះផង រួចត្រៀមបម្រុង នូវគ្រឿងបរិក្ខារបព្វជិតទាំងអស់ សរសេរអក្សរទុកថា ៖

"ជនទាំងឡាយណា ប្រាថ្នានឹងបួស សូមជនទាំងនោះយកបរិក្ខារទាំងនេះប្រើប្រាស់ចុះ" ។

វិស្សុកម្មទេវបុត្រ បានបណ្តេញអមនុស្សទាំងឡាយផង ម្រឹគនិងបក្សីទាំងឡាយ ដែលមានសំឡេងគួរខ្លាចផង ហើយទើបបានវិលត្រឡប់ទៅកាន់លំនៅឋានខ្លួនវិញ ។

## ក្សត្រិយ៍ទាំង ៤ សាងផ្នួស

ព្រះមហាសត្ត ឃើញផ្លូវចុះតែជើងមួយខាង ទ្រង់ព្រះតម្រិះថា "ប្រាកដជាមានលំនៅឋានរបស់បព្វជិត" ។ ព្រះអង្គបានទុកព្រះនាង

មទ្រី និងកូន ៗ ទៀបទ្វារអាស្រមបទ រួចទ្រង់យាងចូលទៅអាស្រមបទ សម្រឹងទៅចម្ងាក់អក្សរ ទ្រង់យល់ថាសក្កទេវរាជឃើញព្រះអង្គ ទ្រង់ចូលទៅបណ្ណសាលា ដោះព្រះខាន់និងធ្នូចេញ ដោះសម្លៀកបំពាក់ រួចទ្រង់ស្លៀកសំពត់សម្បកឈើពណ៌ក្រហម ពាក់ធៀងនូវស្បែកខ្លាឥត ក្រចកលើស្មា ចងជដាមណ្ឌល[៤៤] កាន់ភេទជាឥសី ច្រត់ឈើច្រត់ចេញពីបណ្ណសាលា រែកនូវអម្រែកគឺសម្បត្តិរបស់បព្វជិត បន្លឺនូវឧទានឡើងថា ៖

"សុខអ្វីម៉្លេះហ្ន៎ ! សុខអ្វីម៉្លេះហ្ន៎ ! ផ្នួសអញបានសាងហើយ" ។ ព្រះអង្គយាងឡើងទីចង្ក្រម ដើរទៅវិញទៅមករួចទ្រង់យាងទៅកាន់សម្នាក់របស់កូននិងប្រពន្ធ ដោយភាពស្ងប់ប្រាកដដូចព្រះបច្ចេកពុទ្ធ ។ រីឯព្រះនាងមទ្រី ក្រាបចុះទៀបព្រះបាទារបស់ព្រះមហាសត្វ ទួញយំ ហើយចូលទៅកាន់អាស្រមជាមួយនឹងព្រះអង្គដែរ ទៅកាន់បណ្ណសាលារបស់ខ្លួន កាន់ភេទជាឥសីដែរ ។ ក្រោយមក ជនទាំងពីរបាន បំបួសកូន ៗ ជាកុមារតាបស ។ ក្សត្រិយ៍ទាំង ៤ អង្គ បានរស់នៅក្នុងទឹកដីភ្នំវង្កត ។

---

[៤៤] ផ្នួងសក់មូល ។

## ព្រះវេស្សន្តរនិងព្រះនាងមទ្រីសូមពរពីគ្នា

គ្រានោះ ព្រះនាងមទ្រី ក្រាបទូលសូមពរនឹងព្រះមហាសត្វថា ៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គកុំទៅព្រៃដើម្បីផលាផលឡើយ ព្រះអង្គនៅទីនេះ មើលកូន ៗ ទុកឲ្យខ្ញុំទៅបេះផ្លែឈើតូចធំយកមកវិញ" ។

តាំងពីគ្រានោះមក ព្រះនាងមទ្រី តែងទៅបេះផ្លែឈើតូចធំអំពីព្រៃ មកទំនុកបម្រុងផ្គត់ផ្គង់ជនទាំង ៣ រូប ។ ចំណែកព្រះពោធិសត្វ ក៏សូមពរនឹងព្រះនាងមទ្រីផងដែរថា ៖

"នែមទ្រីសម្លាញ់អើយ ពួកយើងតាំងពីឥឡូវនេះទៅ ឈ្មោះថាជាបព្វជិតហើយ ធម្មតាស្ត្រីតែងជាមន្ទិលដល់ព្រហ្មចរិយៈ តាំងពីគ្រានេះទៅ នាងកុំមកកាន់សម្នាក់របស់ខ្ញុំ ក្នុងកាលខុសឡើយ" ។

"ព្រះករុណាថ្លៃវិសេស" ព្រះនាងមទ្រីតប ។

ដោយមេត្តានុភាពរបស់ព្រះមហាសត្វ សត្វតិរច្ឆានទាំងអស់ ក្នុងទី៣យោជន៍ជុំវិញ បានត្រឡប់នូវមេត្តាចិត្តចំពោះគ្នានឹងគ្នា ។ ចំណែកព្រះនាងមទ្រីទេវី ក្រោកក្នុងពេលព្រលឹម ដងទឹកផឹកទឹកប្រើប្រាស់មកតម្កល់ទុក យកទឹកលុបមុខ និងឈើស្ទន់មកថ្វាយព្រះស្វាមី បោសសម្អាតអាស្រមបទហើយ បានបីកូនទាំងពីរ យកទៅទុកក្នុងសម្នាក់

បិតា ហើយព្រះនាងមានដៃកាន់នូវកញ្ច្រែង ជ្រនីក និងតម្ពក់ ចូលទៅព្រៃបេះផ្លែឈើតូចធំ លុះបានពេញកញ្ច្រែង ក៏ដល់វេលាល្ងាច ព្រះនាងយាងពីព្រៃ ដាក់ផលាផលទុកនៅក្នុងបណ្ណសាលា ងូតទឹកជម្រះកាយរួចងូតទឹកឲ្យកូន ៗ ។ បន្ទាប់មក ជនទាំង ៤ នាក់ អង្គុយទៀបទ្វារបណ្ណសាលា បរិភោគផលាផល ។ តពីនោះ ព្រះនាងមទ្រី យកកូនចូលទៅបណ្ណសាលារបស់ខ្លួនវិញ ។ ជនទាំង ៤ រូប បានរស់នៅក្នុងទឹកដីភ្នំវង្កត តាមទំនងនេះ អស់រយៈពេល ៧ ខែ ។

វនប្បវេសនកណ្ឌវណ្ណនា ចប់ ។

# ជំពូកទី ៥
# ជូជកបព្វវណ្ណនា

## តាជូជកកាច់បំណុលយកកូនក្រមុំ

ក្នុងសម័យនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះថាជូជក មានប្រក្រតីនៅក្នុងស្រុកទុន្និវិដ្ឋព្រាហ្មណគ្រាម ក្នុងដែនកាលិង្គៈ[៤៥] ។ ព្រាហ្មណ៍នោះ គាត់ត្រាច់សូមបាយគេបរិភោគ ហើយសន្សំបាននូវប្រាក់ ១០០ កហាបណៈ យកទៅទុកផ្ញើក្នុងត្រកូលព្រាហ្មណ៍មួយហើយត្រាច់ស្វែងរកទ្រព្យទៀត ។ កាលគាត់ បាត់មុខយូរពេក ត្រកូលព្រាហ្មណ៍ទាំងឡាយ បានប្រើប្រាស់ចាយអស់នូវប្រាក់ ១០០ កហាបណៈនោះ លុះគ្រាក្រោយមក ព្រាហ្មណ៍ជូជកប្តឹងផ្តល់ឲ្យសង ត្រកូលនោះរកប្រាក់សងពុំបាន ក៏សម្រេចចិត្តប្រគល់កូនក្រមុំឈ្មោះអមិត្តតាបនាឲ្យដល់ព្រាហ្មណ៍ជូជក ទុកជាថ្នូរនឹងប្រាក់ ១០០ កហាបណៈ ។ ព្រាហ្មណ៍ជូជកនាំយកនាងអមិត្តតាបនាទៅរស់នៅឯស្រុកទុន្និវិដ្ឋព្រាហ្មណ៍ ដែនកាលិង្គៈ ។ អមិត្តតាបនា តែងបម្រើតាព្រាហ្មណ៍ជូជក ដោយសេចក្តីគោរព ។ គ្រានោះ ព្រាហ្មណ៍ក្មេង ៗ ឯទៀត កាលបើបានឃើញនូវ

[៤៥] ឈ្មោះដែនមួយក្នុងមជ្ឈិមប្រទេស ។

អាចារសម្បត្តិរបស់អមិត្តតាបនាហើយ ក៏នាំគ្នាគំរាមប្រពន្ធរៀង ៗ ខ្លួនថា ៖

"អមិត្តតាបនានេះ ផ្គត់ផ្គង់ល្អណាស់ ចំពោះព្រាហ្មណ៍ចាស់

ចុះពួក នាងធ្វេសប្រហែសអ្វីម៉្លេះចំពោះយើង ?" ។

## ពួកស្ត្រីជេរប្រទេចនាងអមិត្តតាបនា

ស្ត្រីទាំងឡាយនោះ គិតគ្នាថា "យើងនឹងបណ្ដេញអមិត្តតាបនានេះឲ្យចេញពីស្រុកនេះ" ដូច្នេះហើយ ពួកនាងមកជួបប្រជុំគ្នាក្នុងកំពង់ទឹកជាដើម ផ្អើលជ្រួលជ្រើមចោមរោម ជេរប្រទេចជេរប្រទេចផ្ដាសានូវនាងអមិត្តតាបនាថា ៖

"ម្ដាយនាងជាសត្រូវពិត ឪពុកនាងជាសត្រូវពិត បានជាឲ្យនាង

ដែលនៅកំពុងក្រមុំ យ៉ាងនេះដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិ

របស់នាង នាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាប្រយោជន៍ដល់នាង

ពិតហើយ បានជានាំគ្នាលើកនាងដែលនៅកំពុងក្រមុំយ៉ាងនេះ

ឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុង

ទីស្ងាត់ ជាការលាមករបស់នាងប្រាកដហើយ បានជានាំគ្នាលើក

នាង ដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិ

របស់នាង នាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាទីគាប់ចិត្តរបស់នាង ពិតហើយ បានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះ ឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងនៅទាំងមិនគាប់ចិត្តជាមួយនឹងប្តីចាស់ ដ្បិតនាងនៅក្នុងផ្ទះនៃប្តីចាស់បែបនេះ នាងស្លាប់ទៅប្រសើរជាងការរស់នៅ ។ នៃនាងមានលម្អយ៉ាងឆើត មាតាបិតារបស់នាង ជាក់ជារកប្តីដទៃឲ្យនាងមិនបាន បានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងបានធ្វើការបូជាមិនល្អក្នុង ថ្ងៃទី ៩ ទាំងមិនបាន ធ្វើការបូជាព្រះអគ្គី បានជាពួកញាតិនាំគ្នា លើកនាងដែលនៅក្រមុំយ៉ាងនេះ ឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាង ជាក់ជាជេរប្រទេចនូវពួកសមណៈ និងព្រាហ្មណ៍ មានព្រហ្មចរិយៈ ប្រព្រឹត្តទៅខាងមុខ ជាអ្នកមានសីលមានការចេះដឹងច្រើន ក្នុងលោក បានជានាងដែលនៅក្រមុំយ៉ាងនេះនៅក្នុងផ្ទះព្រាហ្មណ៍ចាស់។ ពស់ចឹក មិនទាន់ជាទុក្ខទេ ទាំងលំពែងមុត ក៏មិនទាន់ជាទុក្ខដែរ ត្រង់នាងឃើញប្តីចាស់នោះ ទើបជាទុក្ខ ទាំងជាគ្រឿងក្តៅក្រហាយ ។ ល្បែងមិនមានតម្រេក មិនមានការចរចាជាមួយនឹងប្តី ចាស់មិនមាន ទាំងការសើច ក៏មិនសមល្អ ។ កាលណា ប្តីក្មេងប្រពន្ធក្មេង ទៅប្រឹក្សាគ្នាក្នុងទីស្ងាត់កាលណោះ

សេចក្ដីសោកគ្រប់យ៉ាងណាមួយ ដែលអាស្រ័យនៅក្នុងហឫទ័យ

ក៏រមែងវិនាសបាត់ទៅ នាងក្មេងមានរូបល្អ រមែងជាទីប្រាថ្នានៃ

ពួកបុរសណាស់ ចូរនាងវិលទៅនៅឯត្រកូលញាតិវិញទៅ

ព្រាហ្មណ៍ចាស់នឹងធ្វើនាងឲ្យរីករាយ ដោយកាមគុណ ៥ ដូច

ម្ដេចកើត ?" ។

## នាងអមិត្តតាបនាជំរុញតាជូជករកេខ្ញុំកំដរ

នាងអមិត្តតាបនា បានការជេរប្រទេច អំពីពួកស្ត្រីទាំងនោះ កណ្ដៀត

ក្អមទឹកទៅផ្ទះវិញទាំងយំអណ្ដក់អណ្ដឹត កាលបើត្រូវព្រាហ្មណ៍សួរថា

"ព្រោះហេតុអ្វីនាងយំពោបណ្ដូលចិត្ត" នាងក៏ប្រាប់ដល់តាព្រាហ្មណ៍

នោះថា ៖

"នៃព្រាហ្មណ៍ ខ្ញុំមិនទៅដងទឹកស្ទឹងឲ្យអ្នកទេ នៃព្រាហ្មណ៍ ដ្បិត

ពួកស្រី ៗ ជេរប្រទេចខ្ញុំ ព្រោះតែអ្នកចាស់ តាំងពីឥឡូវនេះទៅ

ខ្ញុំលែងទៅដងទឹកឲ្យអ្នកហើយ" ។

ជូជក ពោលថា ៖

"នាងកុំធ្វើកិច្ចការឲ្យអញឡើយ នាងកុំដងទឹកមកឲ្យអញឡើយ អញនឹងដងទឹកខ្លួនឯង ម្នាលនាងដ៏ចម្រើន នាងកុំក្រេវក្រោធឡើយ" ។

អមិត្តតាបនា និយាយថា ៖

"ខ្ញុំមិនមែនកើតក្នុងត្រកូលស្រីអ្នកប្រើប្ដីនោះទេ អ្នកដងទឹកណា ខ្ញុំមិនត្រូវការទឹកនោះទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុស ឬខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំមិននៅក្នុងសម្នាក់អ្នកទេ" ។

ជូជក ពោលថា ៖

"ម្នាលព្រាហ្មណី ហេតុជាទីតាំងនៃសិល្បៈ[៤៦]ក្ដី ទ្រព្យក្ដី ស្រូវក្ដី របស់អញមិនមានទេ ។ តើអញនឹងនាំយកខ្ញុំប្រុសឬខ្ញុំស្រី មកឲ្យ

[៤៦] ជំនាញ, ការជាងផ្សេង ៗ, ហត្ថកម្មគ្រប់យ៉ាង; ចំណេះដែលត្រូវសិក្សា មានការជាងឈើ, ការឆ្លាក់គូរ, រៀបឥដ្ឋ, បូកបាយអ រហូតដល់ការបង្ហាត់សេះ, បង្ហាត់ដំរី; ចំណេះភ្លេងតន្ត្រី, ច្រៀង, រាំ ជាដើម ឬការប្រដាប់តាក់តែង, ការរចនាវិចិត្រផ្សេង ៗ (ហៅ សិប្បៈ ឬ សិល្បៈ ទាំងអស់) ។

នាងជំចម្រើនអំពីណាបាន ? អញនឹងបម្រើនាងជំចម្រើន នាងជំចម្រើន កុំក្រេវក្រោធឡើយ" ។

អមិត្តតាបនា និយាយថា ៖

"អ្នកចូរមក ខ្ញុំនឹងប្រាប់អ្នក តាមពាក្យដែលខ្ញុំឮមកថា ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរនោះ ស្តេចគង់នៅនាគិរីវង្កត ។ ម្នាលព្រាហ្មណ៍អ្នកចូរទៅសូមខ្ញុំប្រុសខ្ញុំស្រីនឹងព្រះបាទវេស្សន្តរនោះ ។ ក្សត្រនោះដែលអ្នកសូមហើយ មុខជាប្រទានខ្ញុំប្រុសខ្ញុំស្រីដល់អ្នកពុំខាន" ។

អមិត្តតាបនា បាននិយាយពាក្យនេះ ព្រោះនាងត្រូវទេវតាជ្រែកចូលក្នុងខ្លួន ។ ជូជក ពោលថា ៖

"អញចាស់ហើយ មានកម្លាំងថយ តើអញនឹងទៅដូចម្តេចបាន ? ទាំងផ្លូវក៏ឆ្ងាយលំបាកទៅណាស់ នាងជំចម្រើនកុំយំយែកឡើយ នាងជំចម្រើនកុំអាក់អន់ចិត្តឡើយ អញនឹងបម្រើនាងជំចម្រើន នាងជំចម្រើន កុំក្រេវក្រោធឡើយ" ។

អមិត្តតាបនា និយាយថា ៖

"ទាហានមិនទាន់ទៅធ្វើសង្គ្រាម មិនទាន់ច្បាំង ចាញ់មុនទៅហើយ ម្នាលព្រាហ្មណ៍ អ្នកមិនទាន់ទាំងទៅផង ចាញ់យ៉ាងនោះដែរ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុសខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ខ្ញុំនឹងធ្វើអំពើមិនគាប់ចិត្តដល់អ្នក អំពើនោះនឹងជាទុក្ខដល់អ្នកមិនខាន កាលណាអ្នកនឹងឃើញខ្ញុំ តាក់តែងខ្លួនត្រេកត្រអាលជាមួយនឹងពួកប្រុសឯទៀត ក្នុងថ្ងៃនក្ខត្តឫក្ស[៤៧] ក្នុងខាងដើមរដូវទាំងឡាយ ដំណើរនោះនឹងជាទុក្ខដល់អ្នក ក្នុងកាលនោះ ។ ម្នាលព្រាហ្មណ៍ កាលអ្នកជាបុគ្គលចាស់ទួញយំរៀបរាប់ ព្រោះតែមិនបានឃើញខ្ញុំ ខ្នងរឹតតែកោងទៅ សក់នឹងកាន់តែស្កូវច្រើនឡើង"។

---

[៤៧] (ន.) (សំ.),(បា.) (ន័ក-ខ័ត-ត: រឹក) (នក្សត្រ "ផ្កាយ" + ឫក្ស "ផ្កាយ"; នក្ខត្ត + ឥក្ក "ផ្កាយ + ផ្កាយ") ផ្កាយទាំងពួងទូទៅ ។ ពេលកំណត់ដោយផ្កាយដែលហោរគន់រកដើម្បីឲ្យដឹងថា គ្រោះកាចឬគ្រោះជា (តាមហោរាសាស្ត្រ) : ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តឫក្សដ៏ឧត្តម...។

ឮសម្តីនោះភ្លាម ព្រាហ្មណ៍ជូជក មានសេចក្តីភ័យខ្លាចភិតភ័យ លុះក្នុងអំណាចនាងព្រាហ្មណី ត្រូវកាមរាគៈគ្របសង្កត់ បានពោលនឹងនាងព្រាហ្មណីយ៉ាងនេះថា ៖

"ម្នាលនាងព្រាហ្មណី នាងចូរធ្វើទ្រាប[៤៨]ល្ងផង ទ្រាបលាជផង នំទឹកឃ្មុំដែលគេធ្វើល្អហើយផង កត្តុគឺសដូវ[៤៩]ផង ឲ្យជាស្បៀងដល់អញ ។ អញនឹងនាំកុមារជាខ្ញុំពីរនាក់ មានជាតិគោត្រ ត្រកូលនិងប្រទេស ដើម្បីនាង កុមារទាំងនោះនឹងបម្រើនាង ទាំងយប់ទាំងថ្ងៃ មិនខ្ជិលច្រអូសឡើយ" ។

---

[៤៨] (ន.) បង្អែមធ្វើដោយអង្ករដំណើប ឬល្ង ជាដើម លាយកូរនឹងទឹកស្ករស្អិត រួចយកមកសង្កត់ជាផែន ៗ : ទ្រាបលាជ, ទ្រាបល្ង, ទ្រាបបាយ ។ (កិ.) ផ្កាប់មុខគ្របសង្កត់ពីលើ ឬសង្កត់ដោយបាតដៃលើកឈ្នក់ ដាក់ផ្កាប់ទៅផ្ទាល់នឹងផ្ទៃភក់ក្នុងទឹក : ទ្រាបត្រី ។

[៤៩] (ន.) (បា.),(សំ.) (សៈ--) (សត្តុ; គត្តុ) អាហារធ្វើដោយប្រអួលផង់ឬម្សៅស្ងួតសម្រាប់ទុកបរិភោគបានយូរ; មាន ២ យ៉ាងគឺ សដូវដុំ ធ្វើឲ្យជាដុំៗ, សដូវផង់ ធ្វើឲ្យនៅផង់រាយៗ; ប្រើជាស្បៀងក្នុងវេលាដើរផ្លូវឆ្ងាយដាច់ស្រយាលឬប្រើក្នុងវេលារត់លួនគេចចៀសពីមុខទ័ព : សដូវខៅតាក សដូវនិងបាយក្រៀម ។

នាងអមិត្តតាបនានោះ បានចាត់ចែងស្បៀងយ៉ាងរួសរាន់ រួចជាស្រេចហើយ បានជម្រាបដល់ព្រាហ្មណ៍ជូជក ។

ព្រាហ្មណ៍នោះ ជួសជុលផ្ទះ ត្រង់កន្លែងណាដែលដាច់រហែកធ្លុះធ្លាយ ឲ្យជាប់មាំទាំ ធ្វើទ្វារបិទបើក ហើយទៅលីឧសជាច្រើនមកអំពីព្រៃ យកក្អមទៅដងទឹកចាក់ បំពេញពាងភាជន៍សព្វគ្រប់ក្នុងផ្ទះ រួចគាត់កាន់ភេទជាតាបសនៅក្នុងផ្ទះហ្នឹងឯង គាត់ផ្តល់ដំបូន្មានដល់នាងអមិត្តតាបនាថា ៖

ពីគ្រានេះទៅ   សូមស្រីនោមនៅ   កុំចេញខុសកាល
ចូររក្សាខ្លួន   កុំប្រហែសប្រាណ   ដរាបបងបាន
ផ្ទះវិញណាថ្ងៃ ។

ទូន្មានដូច្នេះហើយ គាត់ពាក់ស្បែកជើង ស្ពាយបង្វិចស្បៀងលើស្មា ធ្វើប្រទក្សិណ[៥០]នាងអមិត្តតាបនា មានភ្នែករលីងរលោងដោយទឹកភ្នែក

[៥០] (ន.) (សំ.),(បា.) (ប្រទ័ក-សិន) (បទក្ខិណា) ការសម្តែងសេចក្តីគោរពឬសេចក្តីស្រឡាញ់ដោយដើរព័ទ្ធជុំវិញបុគ្គលឬវត្ថុអ្វី ៗ ឲ្យបុគ្គលឬវត្ថុនោះនៅជាខាងស្តាំដៃ : ធ្វើប្រទក្សិណវិហារ ៣ ជុំ...។ ប្រើជា កិ. វិ. ក៏បាន : ដើរប្រទក្សិណ; កាលដែលជូជកគាត់រៀបនឹងចេញពីផ្ទះគាត់បានដើរប្រទក្សិណផ្ទះនិងនាងអមិតតាបនាបី ៗ ជុំហើយទើបគាត់ចេញទៅ... (ម. កណ្ឌជូជក) ។

ស្រែកយំសស្រាក់ បានសមាទានវត្ត ត្រាច់ទៅកាន់នគររបស់ពួកអ្នកសិវិរាស្ត្រ ជានគរធំទូលាយ ស្វែងរកខ្ញុំប្រុសខ្ញុំស្រី ។ កាលជូជកទៅដល់នគរនោះ សួរពួកជនដែលប្រជុំគ្នាថា "តើព្រះបាទវេស្សន្តរ ស្តេចគង់នៅទីណា ? យើងគប្បីស្គាល់ក្សត្រអង្គនោះក្នុងទីណា ?" ។ ពួកជនដែលមកប្រជុំគ្នាក្នុងទីនោះ ៗ បាននិយាយនឹងព្រាហ្មណ៍នោះថា "ម្នាល ព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅ ព្រោះអតិទានគេបំបរ បង់ចាកដែនរបស់ព្រះអង្គ ៗ ទៅគង់ឯគិរីវង្កត ។ ម្នាល ព្រាហ្មណ៍ក្សត្រ ត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅ ព្រោះអតិទាន ទ្រង់នាំព្រះឱរសនិងព្រះទេវីទៅគង់នៅឯគិរីវង្កតហើយ" ។ ពពួកជនមានដៃកាន់ដុំដីនិងដំបងជាដើម ដេញតាមព្រាហ្មណ៍ជូជក ដោយស្រែកយ៉ាងនេះថា ៖

> "អ្នកញ៉ាំងព្រះរាជារបស់យើងឲ្យវិនាសហើយ កោតតែហ៊ានមកទីនេះទៀត ចូរឈប់ទីនេះសិន" ។

**ឆ្កែដេញខាំតាជូជក**

តាព្រាហ្មណ៍នោះ ត្រូវទេវតាជ្រែកចូលខ្លួន ក៏រត់ប៉ះចំផ្លូវទៅកាន់ភ្នំវង្កតមែន ។ ជូជកនោះ ដែលនាងព្រាហ្មណីដាស់តឿនហើយ ជាបុគ្គលមាន

សេចក្តីជាប់ជំពាក់នឹងកាម រងទុក្ខក្នុងព្រៃដេរដាសដោយម្រឹគសាហាវ ជាទីដែលរមាសនិងខ្លាដំបងអាស្រ័យនៅហើយ ។ ព្រាហ្មណ៍ បានកាន់ដំបងមានសម្បុរដូចផ្លែញ្ញោ និងវែកសម្រាប់បូជាភ្លើង ព្រមទាំងកុណ្ឌី ចូលទៅកាន់ព្រៃធំ ដែលគាត់បានឮថាជាទីដែលព្រះវេស្សន្តរ ព្រះអង្គឲ្យសេចក្តីប្រាថ្នា គង់នៅ ។ ឆ្កែទាំងឡាយ បានចោមរោមគាត់ កំពុងចូលទៅកាន់ព្រៃធំនោះ គាត់វង្វេងផ្លូវ ស្រែកទ្រហោយំ ស្ទុះឃ្លាតទៅក្នុងទីឆ្ងាយអំពីផ្លូវ ដែលជាទីទៅកាន់គិរីវង្កត ។ លំដាប់នោះ ព្រាហ្មណ៍ដែលល្មោភក្នុងភោគៈ មិនសង្រួម ទៅវង្វេងនៅក្នុងផ្លូវដែលជាទីទៅកាន់គិរីវង្កត ត្រូវពួកឆ្កែទាំងឡាយចោមព័ទ្ធ ក៏ឡើងទៅអង្គុយនៅលើដើមឈើ ពោលថា ៖

"ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរ ដែលជារាជបុត្រដ៏ប្រសើរឈ្នះសេចក្តីកំណាញ់មិនចាលចាញ់ ជាអ្នកឲ្យសេចក្តីក្សេម ក្នុងកាលមានភ័យ ដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីពឹងនៃពួកស្មូមដូចជាផែនដី ជាទីពឹងនៃពួកសត្វ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចផែនដី ដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីទៅរបស់ពួកស្មូម ដូចជាសាគរជាទីទៅនៃផ្លូវទឹកទាំងឡាយ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាសមុទ្រ ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូច

ជាអន្លង់ទឹកមានកំពង់ល្អ ផ្ទាយផឹក មានទឹកត្រជាក់ជាទីមនោរម្យ ដេរដាសដោយផ្កាឈូកស ប្រកបដោយលម្អផ្កា ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមពោធិ៍បាយ ដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាក របស់បុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមជ្រៃដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមស្វាយ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមពាំងដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមឈើដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ ម្យ៉ាងទៀត បុគ្គលណានិយាយប្រាប់ថា ខ្ញុំឯងស្គាល់កន្លែងនៅនៃ

ព្រះបាទវេស្សន្តរដូច្នេះដល់ខ្ញុំ ដែលចូលមកក្នុងព្រៃធំ កំពុងយំ
រៀបរាប់យ៉ាងនេះ បុគ្គលនោះ ឈ្មោះថាញ៉ាំងសេចក្ដីត្រេកអរ
ខ្លាំងឲ្យកើត ដល់ខ្ញុំ ។ មួយទៀត បុគ្គលណានិយាយប្រាប់ថា
ខ្ញុំដឹងលំនៅនៃព្រះបាទវេស្សន្តរដូច្នេះ ដល់ខ្ញុំ ដែលចូលមកក្នុង
ព្រៃធំ កំពុងយំរៀបរាប់យ៉ាងនេះ បុគ្គលនោះ រមែងប្រទះបុណ្យ
ដ៏ច្រើន ព្រោះតែសម្ដីមួយម៉ាត់នោះឯង" ។

**តាជូជកភូតភរចេតបុត្រថាខ្លួនជារាជទូត**

ចេតបុត្តព្រានព្រៃ ដែលត្រូវពួកស្ដេចចេតៈចាត់តាំងឲ្យរក្សាការពារ បានដើរត្រាច់កន្លែងនេះកន្លែងនោះនៅក្នុងព្រៃ ស្រាប់តែឮសូរសំឡេងខ្សឹកខ្សួលនោះ របស់ព្រាហ្មណ៍ជូជក គេគិតថា "ព្រាហ្មណ៍នេះខ្សឹកខ្សួល ដើម្បីប្រយោជន៍ដឹងលំនៅឋាន របស់ព្រះបាទវេស្សន្តរ គាត់មិនមែនដោយធម្មតាទេ ប្រាកដជានឹងសូមព្រះនាងមទ្រីឬទារកទាំងពីរ អញនឹងសម្លាប់គាត់ចោលទីនេះចុះ" គិតហើយ ចេតបុត្តព្រានព្រៃដើរតម្រង់ទៅកាន់សម្នាក់ព្រាហ្មណ៍ជូជកលើកធ្នូយឹតគំរាមថា ៖

"នៃព្រាហ្មណ៍ ខ្ញុំនឹងមិនឲ្យជីវិតដល់អ្នកទេ ។ នៃព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ភ្ចាត់ទៅ ព្រោះអតិទាន ត្រូវគេបណ្ដេញចេញចាកដែនរបស់ព្រះអង្គ ទៅគង់ឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ភ្ចាត់ទៅ ព្រោះអតិទានទ្រង់នាំព្រះរាជ

បុត្រនិងព្រះទេវីទៅគង់ឯគិរីវង្កត ។ អ្នកជាបុគ្គលឥតប្រាជ្ញា មិន ខំប្រឹងធ្វើការងារ ចេញអំពីដែនចូលមកកាន់ព្រៃធំ ដើរស្វែងរក ព្រះរាជបុត្រ ដូចជាកុកស្វែងរកត្រីក្នុងទឹក ។ នែព្រាហ្មណ៍ យើង មុខជាមិនឲ្យជីវិត ដល់អ្នកនោះក្នុងទីនេះទេ ព្រោះថា ព្រួញនេះ ដែលយើងបាញ់សំដៅអ្នកហើយ មុខជាផឹកឈាមអ្នក ។ ម្នាល ព្រាហ្មណ៍ យើងមុខជានឹងកាត់ក្បាលអ្នក ពន្ទះកាត់យកបេះដូង ព្រមទាំងទង បូជាបន្ទសកុណយញ្ញ[៥១] ដោយសាច់របស់អ្នក ។ ម្នាលព្រាហ្មណ៍ យើងនឹងកាត់យកបេះដូងរបស់អ្នក រួចផ្តងការ បូជា ដោយសាច់ខ្លាញ់ខាប់ និងក្បាលរបស់អ្នក ។ ម្នាលព្រាហ្មណ៍ ការបូជានោះដោយសាច់របស់អ្នកនោះ ឈ្មោះថា យើងបូជាល្អ ហើយ មួយទៀត អ្នកនឹងនាំព្រះទេពីនិងព្រះរាជបុត្រាបុត្រីនៃ ព្រះរាជបុត្រមិនបានទេ” ។

ជូជកឮពាក្យគេ ស្ញែកមុខជ្សិតត្រូវមរណភ័យគំរាម ក៏កុហកថា ៖

---

[៥១] បូជាទេវតានៅតាមផ្លូវ ។

"នៃចេតបុត្ត អ្នកចូរស្ដាប់យើង ព្រាហ្មណទូតអ្នកមិនត្រូវសម្លាប់ទេ ព្រោះហេតុនោះឯង បានជាគេមិនសម្លាប់ទូត[៥២]នេះ ជាធម៌មានមកយូរយារណាស់ហើយ ពួកអ្នកសិវិរាស្ត្រទាំងអស់ បាត់ខឹងហើយ ព្រះបិតាចង់ជួបព្រះបាទវេស្សន្តរនោះ ទាំងព្រះមាតាព្រះអង្គក៏មានកម្លាំងថយ ពុំយូរឡើយ មុខជានឹងងងឹតព្រះនេត្រដោយទ្រង់ព្រះពិលាប ។ នៃចេតបុត្ត អ្នកចូរស្ដាប់ពាក្យយើង យើងជារាជទូតដែលក្សត្រទាំងនោះ បញ្ជូនមកហើយ យើងនឹងនាំទៅនូវព្រះរាជបុត្ត បើអ្នកដឹង អ្នកចូរប្រាប់យើង" ។

គ្រានោះ ចេតបុត្ត មានសោមនស្សដោយឮដំណឹងថាព្រាហ្មណ៍មកដើម្បីនាំព្រះបាទវេស្សន្តរត្រឡប់ទៅវិញ ដូច្នេះ គេបានចងហ្វូងឆ្កែទុកមួយកន្ទែង ប្រាប់ឲ្យព្រាហ្មណ៍ជូជកចុះ អញ្ជើញឲ្យគាត់អង្គុយលើកម្រាលមែកឈើ ជូនភោជនគាត់ពិសា ដោយពោលដូច្នេះថា ៖

[៥២] (គុ.), (ន.) (សំ.),(បា.) អ្នកដែលគេបញ្ជូន, ដែលគេប្រើទៅ; អ្នកនាំការ, នាំដំណឹងពីម្ខាងទៅម្ខាង ។ មន្ត្រីសក្តិធំដែលរាជការចាត់ទៅជាតំណាង ដើម្បីនៅនិយាយផ្ទាល់នឹងរដ្ឋបាលប្រទេសដទៃ (ម. ព. រាជទូត ផង) ។ (ឧ.) សូរលាន់ចេញពីអ្វីមួយដែលប៉ោង, ដែលខ្ទប់ មានកញ្ចែកប៉ាល់ ជាដើម ។ ទូតៗ

"នែព្រាហ្មណ៍ អ្នកជាទូតជាទីស្រឡាញ់នៃព្រះបាទវេស្សន្តរដែលជាទីស្រឡាញ់របស់យើង យើងខ្ញុំនឹងឲ្យភាជន៍ដ៏ពេញដោយទឹកផង តុម្ពា[៥៣]ទឹកឃ្មុំនេះផង ភ្ញៅម្រឹគដែលចម្អិនស្រេចផង ដល់អ្នកមួយទៀត ព្រះបាទវេស្សន្តរដែលជាអ្នកឲ្យវត្ថុជាទីប្រាថ្នា គង់នៅក្នុងប្រទេសណា យើងនឹងប្រាប់ប្រទេសនោះដល់អ្នក" ។

ជូជកបព្វវណ្ណនា ចប់ ។

---

[៥៣] (ន.) (សំ.),(បា.) (តុម) នាឡិ (រង្វាល់); ទីកោទឹក...។ ខ្មែរយើងប្រើចំពោះតែក្រឡតូចរាងត្រមៀចរាក់សម្រាប់ដាក់កំបោរបៀកម្ទូ : តុម្ពកំបោរ ។

# ជំពូកទី ៦
## ចូឡវនវណ្ណនា

### ចេតបុត្តពណ៌នាសម្រស់ភ្នំគន្ធមាទន៍

*ចេតបុត្ត បានអញ្ជើញព្រាហ្មណ៍ជូជកឲ្យពិសាភោជនយ៉ាងនេះហើយ ក៏បានវេចខ្ចប់តុម្ពទឹកឃ្មុំ និងបាយលាយដោយសាច់ម្រឹគធ្វិនស្រាប់ ជូនដល់ព្រាហ្មណ៍ ប្រយោជន៍ដើម្បីបានជាស្បៀងតាមផ្លូវ គេបានឈរលើកំណាត់ផ្លូវ លើកដៃខាងស្តាំចង្អុលប្រាប់ទីនៅ របស់ព្រះបាទវេស្សន្តរដូច្នេះថា ៖*

"ឯស សេលោ មហាព្រហ្មេ, បព្វតោ គន្ធមាទនោ;

យត្ថ វេស្សន្តរោ រាជា, សហ បុត្តេហិ សម្មតិ។

ធារេន្តោ ព្រាហ្មណវណ្ណំ, អាសទញ្ច មសំ ជដំ;

ចម្មវាសី ឆមា សេតិ, ជាតវេទំ នមស្សតិ។

ឯតេ នីលា បទិស្សន្តិ, នានាផលធរា ទុមា;

ឧគ្គតា អព្ភកូដាវ, នីលា អញ្ជនបព្វតា។

ធវស្សកណ្ណា ខទិរា, សាលា ផន្ទនមាលុវា;

សម្បវេធន្តិ វាតេន, សកឹំ បីតាវ មាណវា។

ឧបរិ ទុមបរិយាយេសុ, សង្គីតិយោវ សុយ្យរេ;

នជ្ជុហា កោកិលសង្ឃា, សម្បតន្តិ ទុមា ទុមំ។

អវ្ហយន្តេវ គច្ឆន្តំ, សាខាបត្តសមីរិតា;

រមយន្តេវ អាគន្តំ, មោទយន្តិ និវាសិនំ;

យត្ថ វេស្សន្តរោ រាជា, សហ បុត្តេហិ សម្មតិ។

ធារេន្តោ ព្រាហ្មណវណ្ណំ, អាសទញ្ច មសំ ជដំ;

ចម្មវាសី ឆមា សេតិ, ជាតវេទំ នមស្សតិ”។

"នៃមហាព្រាហ្មណ៍ នោះហ្ន៎ភ្នំគន្ធមាទន៍ ជាវិការៈនៃថ្ម ដែលព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយនឹងព្រះរាជបុត្រនិងព្រះទេពី ។ ព្រះរាជា ទ្រទ្រង់ភេទអ្នកបួសដ៏ប្រសើរផង មានតម្កក់[៥៤]និងវែកសម្រាប់បូជា ភ្លើង និងជដាផង ទ្រង់ស្លៀកដណ្ដប់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការនូវភ្លើង ។ ឈើទាំងឡាយនុ៎ះ ដ៏ខៀវ ទ្រទ្រង់ផ្លែផ្សេង ៗ ដ៏ខ្ពស់មានកំពូល ទើសមេឃ ដ៏ខៀវដូចភ្នំផ្កាអញ្ជ័ន[៥៥] ។ មានដើមត្របែកព្រៃ ដើមត្រចៀកប្រើស ដើមគគីរ ដើមរាំង ដើមពង្រ និងដើមជ្រៃ ទោរទន់ទោមក ដោយខ្យល់ ដូចជាមាណពទើបផឹកស្រាម្ដង ។ នៅខាងលើមែកឈើទាំងឡាយ ពួសួរសត្វដូចជាចម្រៀងទិព្វ ព្រោះមានហ្វូងប៉ោលតោកនិង តាវៅ ចុះទំពីឈើមួយទៅឈើមួយ ។ មែកឈើនិងស្លឹកឈើទាំងឡាយ ដែល

[៥៤] (ន.) ប្រដាប់ធ្វើដោយដែក ឬឈើ ឬស្សីជាដើម មានចុងរាងខ្វេរឬខុបសម្រាប់ថ្កក់ទាញអ្វីៗ : តម្កក់រនាស់ ។ (ធ្លាប់ប្រើជា ទំពក់ មកយូរហើយ ប៉ុន្តែដោយអនុលោមតាមពាក្យថា ថ្កក់ គួរប្រើជា តម្កក់ វិញ ទើបត្រឹមត្រូវតាមវេយ្យាករណ៍ខ្មែរ) ។

[៥៥] (ន.) (សំ.),(បា.) (អ័ញ-ជ័ន) (អញ្ជន "ការបន្តក់ទឹកថ្នាំ; ថ្នាំទឹកសម្រាប់បន្តក់; ថ្នាំបន្តក់ភ្នែក; ឈ្មោះឈើមួយប្រភេទ; ឈ្មោះវល្លិមួយប្រភេទ;...") ឈ្មោះវល្លិមួយប្រភេទដើមទន់ល្អូត ស្លឹកមូល ៗ ល្អិត ៗ ផ្កាមានព័ណ៌ផ្សេង ៗ ប៉ុន្តែក្នុងកម្ពុជរដ្ឋច្រើនតែព័ណ៌ខៀវស្រស់ : គេច្រើនដាំអញ្ជ័នឲ្យវារឡើងរបងភូមិ ឬឲ្យវារឡើងតោរណៈភូមិ ។

*ខ្យល់បក់ត្រូវហើយ ពុដូចជាហៅរកជនកំពុងដើរ ដូចជារីករាយនឹងជនដែលមកដល់ ត្រេកត្រអាលនឹងជនដែលនៅអាស្រ័យ ។ អ្នកនឹងចូលទៅក្នុងអាស្រម ដែលជាកន្លែងព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងឡាយ ស្តេចទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជា និងព្រះជដាទ្រង់ស្បៀកស្បែកខ្លា ផ្ទំលើផែនដី នមស្ការ[៥៦] ភ្លើង ។ កាលបើអ្នកបានទៅដល់អាស្រម ដែលព្រះបាទវេស្សន្តរគង់នៅហើយ អ្នកនឹងបានឃើញនូវសម្បត្តិ របស់អាស្រមបទដូច្នេះ" ។*

**សម្រស់ធម្មជាតិក្បែរអាស្រម**

*តពីនេះទៅ ចេតបុត្តព្រានព្រៃ បានពោលពណ៌នាអាស្រមបទ បន្ថែមទៀតថា ៖*

"អម្ពា កបិត្ថា បនសា, សាលា ជម្ពូ វិភីតកា;
ហរីតកី អាមលកា, អស្សត្ថា ពទរានិ ច ។

[៥៦] (ន.) (សំ.),(បា.) (នៈម៉ុស-ស្កា) (នមក្ការ) កិរិយាថ្វាយបង្គំ, ការបង្អោនកាយក្រាបប្រណិប័ត; គំនាប់ : សូមនមស្ការចំពោះព្រះរត្នត្រ័យ គឺព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ !

បារុតិម្ពរុក្ខា ចេត្ថ, និគ្រោធា ច កបិត្ថនា;
មធុមធុកា ថេវន្តិ, នីចេ បក្កា ចុទុម្ពរា។

បារេវតា ភវេយ្យា ច, មុទ្ទិកា ច មធុត្ថិកា;
មធុំ អនេលកំ តត្ថ, សកមាទាយ ភុញ្ជរេ។

អញ្ញេត្ថ បុប្ផិតា អម្ពា, អញ្ញេ តិដ្ឋន្តិ ទោវិលា;
អញ្ញេ អាមា ច បក្កា ច, ភេកវណ្ណា តទូភយំ។

អថេត្ថ ហេដ្ឋា បុរិសោ, អម្ពបក្កានិ គណ្ហតិ;
អាមានិ ចេវ បក្កានិ, វណ្ណគន្ធរសុត្តមេ។

អតេវ មេ អច្ឆរិយំ, ហីង្ការោ បដិភាតិ មំ;
ទេវានមិវ អាវាសោ, សោភតិ នន្ទនូបមោ។

វិភេទិកា នាឡិកេរា, ខជ្ជុរីនំ ព្រហាវនេ;
មាលាវ គន្ថិតា ឋន្តិ, ធជគ្គានេវ ទិស្សរេ;
នានាវណ្ណេហិ បុប្ផេហិ, នភំ តារាចិតាមិវ។

កុដជី កុដ្ឋតគរា, បាដលិយោ ច បុប្ផិតា;

បុន្នាគា គិរិបុន្នាគា, កោវិឡារា ច បុប្ផិតា។

ឧទ្ទាលកា សោមរុក្ខា, អគរុផល្លិយា ពហូ;
បុត្តជីវា ច កកុធា, អសនា ចេត្ថ បុប្ផិតា។

កុដជា សលឡា នីថា, កោសម្ពា លពុជា ធវា;
សាលា ច បុប្ផិតា តត្ថ, បលាលខលសន្និភា។

តស្សាវិទូរេ បោក្ខរណី, ភូមិភាគេ មនោរមេ;
បទុមុប្បលសញ្ឆន្នា, ទេវានមិវ នន្ទនេ។

អថេត្ថ បុប្ផរសមត្តា, កោកិលា មញ្ជុភាណិកា;
អភិនាទេន្តិ បវនំ, ឧតុសម្បុប្ផិតេ ទុមេ។

ភស្សន្តិ មករន្ទេហិ, បោក្ខរេ បោក្ខរេ មធូ;
អថេត្ថ វាតា វាយន្តិ, ទក្ខិណា អថ បច្ឆិមា;
បទុមកិញ្ជក្ខរេណូហិ, ឱកិណ្ណោ ហោតិ អស្សមោ។

ថូលា សិង្ឃាដកា ចេត្ថ, សំសាទិយា បសាទិយា;

មច្ឆកច្ឆបព្យាវិទ្ធា, ពហូ ចេត្ថ មុបយានកា;
មធុំ ភិសេហិ សវតិ, ខីរសប្បិ មុឡាលិភិ។

សុរភី តំ វនំ វាតិ, នានាគន្ធសមោទិតំ;
សម្មទ្ទតេវ គន្ធេន, បុប្ផសាខាហិ តំ វនំ;
ភមរា បុប្ផគន្ធេន, សមន្តា មភិនាទិតា។

អថេត្ថ សកុណា សន្តិ, នានាវណ្ណា ពហូ ទិជា;
មោទន្តិ សហ ភរិយាហិ, អញ្ញមញ្ញំ បកូជិនោ។

នន្ទិកា ជីវបុត្តា ច, ជីវបុត្តា បិយា ច នោ;
បិយា បុត្តា បិយា នន្ទា, ទិជា បោក្ខរណីឃរា។

មាលាវ គន្ថិតា ឋន្តិ, ធជគ្គានេវ ទិស្សរេ;
នានាវណ្ណេហិ បុប្ផេហិ, កុសលេហេវ សុគន្ថិតា;
យត្ថ វេស្សន្តរោ រាជា, សហ បុត្តេហិ សម្មតិ។

ធារេន្តោ ព្រាហ្មណាវណ្ណំ, អាសទញ្ច មសំ ជដំ;
ចម្មវាសី ឆមា សេតិ, ជាតវេទំ នមស្សតិ”។

"ក្នុងទីនុ៎ះមានដើមស្វាយ ខ្វិត ខ្នុរ រាំង ព្រីង សម៉ពិភេទក៍ សម៉ក្ទុក កន្ទួតព្រៃ ពោធិ ពុទ្រា ទន្ទាប់មាស ជ្រៃនិងក្រសាំង មាក់សាង មានផ្លែដ៏ផ្អែមរុងរឿង និងល្វាមានផ្លែទុំ ដើមទាប ៗ មានបេកអម្បូងក្ទុក បេកអម្បូងស្នែង និងចន្ទន៍ មានផ្លែផ្អែមដូចទឹកឃ្មុំ គេតែងយកឃ្មុំឥត មេក្នុងទីនោះមកជារបស់ខ្លួនហើយបរិភោគ ។ ក្នុងទីនុ៎ះ មានស្វាយខ្វះ កំពុងផ្កា ស្វាយទើបជាក្បាលរុយ ស្វាយខ្វះមានផ្លែខ្ចីនិងទុំ ផ្លែទាំងពីរ បែបនោះមានសម្បុរដូចខ្នងកញ្ចាញ់ចេក ។ ក្នុងទីនុ៎ះ បុរសឈរខាងក្រោម បេះផ្លែស្វាយទុំទាំងឡាយ ស្វាយទាំងឡាយទាំងខ្ចីទាំងទុំ មានសម្បុរ ក្លិន និងរសដ៏ឧត្តម ។ ខ្ញុំតែងមានសេចក្តីអស្ចារ្យក្រៃពេក ទាំងការលាន់ឮជាហឹង ៗ ក៏ប្រាកដដល់ខ្ញុំ ប្រទេសនោះ ឧបមាដោយនន្ទនវ័ន ល្អដូចជាទីនៅរបស់ពួកទេវតា ។ ត្នោតដូងដុះចម្រុះគ្នា ក្នុងព្រៃលម៉ើដ៏ធំ ផ្កាទាំងឡាយ ដូចជាកម្រងដែលគេក្រងហើយ ឬប្រាកដដូចជាជាយទង់ជ័យ ។ ខ្វែងគង់ តុម្ពកោដ្ឋ គុម្ពក្រីស្នា ច្រនៀង បុន្នាគ

តូច បុន្នាគ[៥៧]ធំ និងរលួស មានផ្កាពណ៌ផ្សេង ៗ រីកស្គុះស្គាយដូចផ្កាយដែល ភ្លឺព្រោងព្រាត ឮដ៏អាកាស ។ រាជព្រឹក្ស ខ្នុញ កំញានរាក់ខ្មៅ ជ្រៃធំ ទន្ទានិងផ្ចង់ជាច្រើន បញ្ចេញផ្កាក្នុងទីនោះ ។ ខ្ទិងគង់ ស្រល់ ស្មោល សង្ស័រ ខ្នុរសម្ង ត្របែកព្រៃនិងរាំងជ្រុះផ្កាក្នុងទីនោះ ដូចជាលានចំបើង ។ ក្នុងភូមិភាគជាទីមនោរម្យ ជិតអាស្រមនោះ មានស្រះបោក្ខរណីដេរដាសដោយផ្កាឈូក និងផ្កាព្រលិតដូចជាក្នុងនន្ទនវ័នរបស់ពួកទេវតា ។ មួយទៀត ពួកតាវៅ[៥៨]ដែលស្រវឹងដោយរសផ្កា យំពីរោះនៅ លើឈើដែលមានផ្ការីកតាមរដូវញុាំងព្រៃនោះឲ្យលាន់ឮគឹកកង ។ លម្អងដែលរោយរាយ ចេញអំពីកេសរ ដែលមាននៅគ្រប់ស្លឹក ឈូក មានរសផ្អែម បើខ្យល់បក់ផាត់មក ក្នុងទីអាស្រមនុ៎ះ អំពីទិសខាងត្បូង និងខាងលិច ។

---

[៥៧] ន.) (សំ.),(បា.) (បុន្នាគ) ឈ្មោះឈើមួយប្រភេទ ស្លឹកស្រដៀងនឹងរំដួល ផ្កាស្រដៀងនឹងផ្កាសុរភីតែធំៗ ជាង មានក្លិនក្រអូបល្អ, ដើមប្រើការធ្វើជាគ្រឿងផ្ទះរាយរងក៏បាន : ដើមបុសនាគ (ពាក្យថា បុន្នាគ ជា សំ. បា. ពិត តែខ្មែរយើងមិនសូវហៅ) ។

[៥៨] (ន.) (--វៅ) ឈ្មោះសត្វស្លាបមួយប្រភេទមានសម្បុរខ្មៅ មាឧតូចជាងក្អែក យំឮសូរ តាវៅ ៗ ។

អាស្រមក៏ដេរដាសដោយលម្អង់កេសរផ្កាឈូកក្នុងស្រះបោក្ខរណី
នុំះ មានផ្លែក្រចាប់ដ៏ថ្លោស ៗ និងស្រូវសាលីជ្រុះរុះរោយរាយលើ
ផែនដី ។ មួយទៀត មានត្រីអណ្ដើក និងក្ដាមច្រើនបែប ហែប
ហែលទៅមកក្នុងស្រះនោះ រសដែលហូរចេញអំពីក្រអៅឈូក
មាន ឱជាដូចទឹកឃ្មុំ និងរសដែលហូរចេញអំពីមើមឈូក មាន
ឱជាដូចទឹក ដោះស្រស់និងទឹកដោះថ្លា ព្រៃនោះមានក្លិនក្រអូប
ផ្សេង ៗ ផ្សព្វផ្សាយ ក្លិនឈ្ងុយឈ្ងប់ ។ ព្រៃនោះ ដូចជាញុំាងជន
ដែលមកដល់ឲ្យរីករាយ ដោយក្លិន ដោយផ្កា និងមែកឈើ កន្ទង់
ទាំងឡាយ ក៏ញុំាងព្រៃឲ្យគឹក កងដោយជុំវិញ ព្រោះតែក្លិនផ្កា ។
មិនតែប៉ុណ្ណោះសោត មានសត្វបក្សី ទ្វិជាតិជាច្រើន មានសម្បុរ
ផ្សេង ៗ គ្នា ត្រេកត្រអាលជាមួយនឹងមេ យំរកគ្នាទៅវិញទៅមក
ក្នុងស្រះនោះ ។ ពួកបក្សីដែលនៅក្នុងស្រះបោក្ខរណី គឺសត្វ
នន្ទិកា១ សត្វជីវបុត្តា១ សត្វជីវបុត្តាបិយាចនោ១ សត្វ បិយាបុត្តា
បិយានន្ទា១ ។ ផ្កាទាំងឡាយ ដូចជាកម្រងផ្កាដែលគេក្រង ហើយ
ប្រាកដដូចជាជាយទង់ជ័យ ពុំនោះដូចជាកម្រងផ្កាដែលមាលា
ការដ៏ឈ្លាសក្រងយ៉ាងល្អ ដោយផ្កាមានពណ៌ផ្សេង ៗ ។ ក្នុងទី

ដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ជាមួយនឹងព្រះរាជបុត្របុត្រី
ព្រះអង្គទ្រង់ ភេទជាអ្នកបួសដ៏ប្រសើរ មានតម្លក់ និងវែកសម្រាប់
បូជាភ្លើងផង និងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទំនៅលើផែនដី
នមស្ការភ្លើង" ។

លំនៅឋានរបស់ព្រះបាទវេស្សន្តរ ត្រូវចេតបុត្តព្រានព្រៃពណ៌នា យ៉ាងនេះហើយ ជូជកត្រេកអររំភើប ធ្វើបដិសណ្ឋារៈតបថា ៖

"ឥទញ្ច មេ សត្តុភត្តំ, មធុនា បដិសំយុតំ;
មធុបិណ្ឌិកា ច សុកតាយោ, សត្តុភត្តំ ទទាមិ តេ"។

"ភត្តគឺសដូវនេះ ដែលយើងលាយហើយដោយទឹកឃ្មុំ យើងនឹងឲ្យទឹកឃ្មុំដែលយើងធ្វើល្អហើយផងនិងភត្តគឺសដូវផង ដល់អ្នក"។

ព្ទដូឈ្មោះ ចេតបុត្តតបថា ៖

"តុយ្ហេវ សម្ពលំ ហោតុ, នាហំ ឥច្ឆាមិ សម្ពលំ;
ឥតោបិ ព្រហ្មេ គណ្ហាហិ, គច្ឆ ព្រហ្មេ យថាសុខំ។
អយំ ឯកបទី ឯតិ, ឧជុំ គច្ឆតិ អស្សមំ;
ឥសីបិ អច្ចុតោ តត្ថ, បង្កទន្តោ រជស្សិរោ;
ធារេន្តោ ព្រាហ្មណវណ្ណំ, អាសទញ្ច មសំ ជដំ។
ចម្មវាសី ឆមា សេតិ, ជាតវេទំ នមស្សតិ;

តំ ត្វំ កន្ទាន បុច្ឆស្សុ, សោ តេ មគ្គំ បវក្ខតិ”។

“ស្បៀងចូរនៅជារបស់អ្នកឯងចុះយើងមិនត្រូវការស្បៀងទេ នែព្រាហ្មណ៍ អ្នកចូរយកស្បៀងអំពីនេះទៅ នែព្រាហ្មណ៍ អ្នកចូរទៅតាមស្រួលចុះ ។ ផ្លូវនេះជាផ្លូវល្មមដើរចុះបុគ្គលម្នាក់ ត្រង់ទៅកាន់អាស្រម ក្នុងអាស្រមនោះ មានឥសីឈ្មោះអច្ចុតៈមានធ្មេញប្រកបដោយមន្ទិល មានសរីរៈប្រឡាក់ដោយធូលី ទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរផង តម្ពក់ផង វែកសម្រាប់បូជាភ្លើងផង ជដាផង ។ ឥសីឈ្មោះអច្ចុតៈនោះ ជាអ្នកស្លៀកស្បែកខ្លាដេកនៅលើកម្រាលស្លឹកឈើលើផែនដី នមស្ការភ្លើង អ្នកចូរទៅសួរលោកចុះ លោកនឹងប្រាប់ផ្លូវដល់អ្នកពុំខាន” ។

ជូជកព្រាហ្មណ៍ លុះបានឮពាក្យនេះហើយ ក៏មានចិត្តរីករាយ ធ្វើនូវប្រទក្សិណចេតបុត្តព្រានព្រៃ រួចដើរតម្រង់ទៅកាន់អច្ចុតឫសី ។

ចូឡវនវណ្ណនា ចប់ ។

# ជំពូកទី ៧
# មហាវនវណ្ណនា

## ជូជកជួបអច្ចុតឥសី

កាលជូជកព្រាហ្មណ៍នោះ ដើរទៅជួបឥសីឈ្មោះអច្ចុតៈ លុះឃើញឥសីនោះហើយ ក៏សំណេះសំណាលជាមួយនឹងឥសីថា ៖

"លោកដ៏ចម្រើន សុខសប្បាយទេឬ? លោកដ៏ចម្រើន មិនមានរោគាពាធទេឬ? តើលោកចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ? មើមឈើនិងផ្លែឈើមានច្រើនដែរឬ? ។ ពួករបោម មូស ពស់ មានតិចទេឬ? ក្នុងព្រៃដេរដាសដោយម្រឹគសាហាវ មិនមានការបៀតបៀនទេឬ?" ។

អច្ចុតឥសី តបថា ៖

"ម្នាលព្រាហ្មណ៍អាត្មាសុខសប្បាយទេ អាត្មាមិនមានរោគាពាធទេ មួយទៀត អាត្មាចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេ ទាំងមើមឈើផ្លែឈើ ក៏មានច្រើនដែរ ។ មួយវិញទៀត ពួករបោម មូស ពស់ មានតិចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនមានការបៀតបៀនអាត្មាទេ ។ អាត្មានៅក្នុងអាស្រមនេះ អស់

ប្រជុំនៃឆ្នាំជាច្រើន អាត្មាមិនដែលស្គាល់អាពាធមិនជាទីត្រេកអរនៃចិត្តកើតហើយទេ ។ នៃមហាព្រាហ្មណ៍ អ្នកមកល្អហើយ អ្នកមិនមែនមកអាក្រក់ទេ ម្នាលព្រាហ្មណ៍ដ៏ចម្រើន អ្នកអញ្ជើញចូលមកខាងក្នុង អ្នកចូរលាងជើងទាំងឡាយរបស់អ្នកចុះ ។ នៃព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែមាក់សាង ផ្លែមាក់ដោក មានរសឆ្ងាញ់ពីសា ដូចជាទឹកឃ្មុំ ។ ទាំងទឹកត្រជាក់នេះ អាត្មាបានដងមកអំពីជ្រោះភ្នំ នៃមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនោះចុះ ប្រសិនបើអ្នកត្រូវការ" ។

ជូជក ពោលតបថា ៖

"វត្ថុដែលលោកបានឲ្យ ខ្ញុំបានទទួលយកហើយ ដែលលោកបានធ្វើឲ្យជាជំនូនដល់ខ្ញុំទាំងអស់ ខ្ញុំមកនេះដើម្បីចង់ជួបនឹងព្រះរាជបុត្របង្កើត របស់ព្រះបាទសញ្ជ័យ ដែលពួកអ្នកសិវិរាស្ត្របំបរបង់ហើយនោះ ប្រសិនបើលោកជ្រាប សូមប្រាប់ខ្ញុំផង" ។

តាបស តបថា ៖

"អ្នកមិនមែនមកគាល់ព្រះបាទសិវិដើម្បីបុណ្យទេ អ្នកទំនងជាចង់បានព្រះទេពីរបស់ព្រះរាជា ដែលជាស្ត្រីប្រតិបត្តិក្នុងកស្តាទេ

ដឹង ។ អ្នកទំនងជាចង់បានកុមារីឈ្មោះកណ្ហាជិនាធ្វើជាទាសីនិង កុមារឈ្មោះ ជាលីធ្វើជាទាសៈ ឬក៏អ្នកមកដើម្បីនាំយកជនទាំង ៣ នាក់ គឺមាតានិង បុត្រីបុត្រាទៅអំពីព្រៃ នៃព្រាហ្មណ៍ ឯព្រះ បាទវេស្សន្តរនោះ មិនមានភោគៈ មិនមានទ្រព្យ មិនមានធញ្ញ- ជាតទេ ។ ព្រះរាជបុត្ររស់នៅទុគ៌តណាស់ តើអ្នកនឹងទៅកាន់ សម្នាក់ព្រះអង្គធ្វើអ្វី?" ។

ជូជកព្រូជូច្នោះ ពោលតបថា ៖

"ខ្ញុំមិនមានសភាពជាអ្នកខឹងនឹងលោកទេខ្ញុំមិនមែនមកដើម្បីសូម ទេ កាលជួបប្រទះនឹងពួកលោកដ៏ប្រសើរ ជាការល្អ ការនៅរួមនាំ មក នូវសេចក្ដីសុខសព្វ ៗ កាល ។ ព្រះបាទសិវិដែលពួកអ្នក សិវិរាស្ត្របំបរបង់ហើយ ខ្ញុំមិនដែលបានឃើញ បានជាខ្ញុំមក គាល់ព្រះអង្គ ប្រសិនបើលោកជ្រាប សូមប្រាប់ខ្ញុំផង" ។

**សោភណភាពស្រះបោក្ខរណី**

អច្ចុតតសី ព្រូពាក្យរបស់ជូជកនោះ ក៏ជឿនិយាយថា ៖

"មិនអីទេ ខ្ញុំនឹងប្រាប់អ្នកថ្ងៃស្អែក ចូរអ្នកនៅទីនេះមួយថ្ងៃនេះសិន ប៉ុះ"

រួចគាត់អញ្ជើញជូជកឲ្យឆ្អែតស្កប់ស្កល់ ដោយផ្លែឈើតូចធំ ។ ដល់ថ្ងៃបន្ទាប់ គាត់បង្ហាញផ្លូវ លាដៃស្ដាំចង្អុលប្រាប់ដូច្នេះថា ៖

"នែមហាព្រាហ្មណ៍ នុ៎ះភ្នំគន្ធមាទន៍ ជាវិការៈនៃថ្មដែលព្រះបាទវេស្សន្តរស្ដេចគង់នៅ ជាមួយនឹងព្រះរាជបុត្រនិងព្រះទេពី ។ ព្រះរាជាទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរមានតម្លក់និងវែកសម្រាប់បូជាភ្លើង សក់កណ្ដាញ់ ស្លៀកដណ្ដប់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។ ពួកឈើដែលមើលទៅឃើញនុ៎ះ ជាឈើមានពណ៌ខៀវ ទ្រង់ទ្រង់ផ្លែផ្សេង ៗ ខ្ពស់មានចុងស្មើនឹងពពក មានពណ៌ខៀវដូចភ្នំផ្កាអញ្ជ័ន គឺដើម ត្របែកព្រៃ ត្របៀកប្រើស គគីរ រាំងភ្នំ ពង្រនិងជ្រៃ ញ័រទ្រេតទ្រោត ដោលខ្យល់ ដូចពួកមាណពទើបផឹកស្រាម្ដង ។ សំឡេងរបស់ពួកសត្វស្វាបផ្សេង ៗ លើមែកឈើទាំងឡាយលាន់ឮដូចចម្រៀងទិព្វ ពួកសត្វ ប៉ោលតោក សត្វតាវៅ នាំគ្នាហើរឆ្លៀលឆ្វាត់ អំពីដើមឈើមួយទៅ កាន់ដើមឈើមួយ ។ អស់ទាំងមែកឈើមានស្លឹក ដែលត្រូវខ្យល់បក់មក ក៏ហាក់ដូចជាដង្ហោយហៅជនដែលកំពុងដើរ ដូចជាត្រេកអរនឹងជនដែលមកដល់ រីករាយនឹងជនដែលនៅអាស្រ័យ ។ អ្នកនឹងឃើញ

នូវសម្បត្តិនៃអាស្រមបទ ក្នុងអាស្រមដែលព្រះបាទវេស្សន្តរស្ដេចគង់នៅ ជាមួយនឹងព្រះរាជបុត្រនិងព្រះទេពី ព្រះអង្គបានទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរ មានតម្លក់និងរែកសម្រាប់បូជាភ្លើង និងសក់កណ្ដាញ់ស្បៀក ដណ្ដប់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។ មានផ្កាទន្ទា[៥៩]ជ្រុះពោយរាយ ដេរដាសលើភូមិភាគ ជាទីត្រេកអរនៃចិត្ត ទាំងផ្ទៃផែនដីក៏មាន ពណ៌ខៀវស្រងាត់ដោយស្មៅចិញ្ចៀន ឥតមានធូលីហុយក្នុងទីនោះឡើយ ។ ទាំងស្មៅសោតក៏មានពណ៌ដូចជាផ្ឋតកនៃក្ងោក មានឧបមាស្មើដោយសម្ផស្សនៃសំឡី មិនហួសអំពី ៤ ធ្នាប់ដោយជុំវិញ ។ មានស្វាយព្រីង ក្វិដ្ឋ ល្វា មានផ្លែទុំក្នុងទីទាប ព្រៃនោះសម្រាប់ញ៉ាំងតម្រេកឲ្យចម្រើន ដោយពួកឈើសម្រាប់បរិភោគ ។ ទឹកស្អាត មានក្លិនក្រអូប មានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពៃទូរ្យ កុះករដោយហ្វូងត្រី រមែងហូរទៅក្នុងព្រៃនោះ ។ ក្នុងទីជិតនៃអាស្រមបទនោះ មានស្រះបោក្ខរណី ដ៏ដេរដាសដោយឈូកនិងឧប្បលក្នុងភូមិភាគជាទីត្រេកអរនៃចិត្តដូចជាក្នុងនន្ទនវ័ននៃពួកទេវតា ។

[៥៩] (ន.) ឈ្មោះឈើមួយប្រភេទ ពួកថ្វាន់ ច្រើនដុះតែនៅព្រៃរនាម ឬនៅមាត់បឹង, ស្ទឹង, ព្រែក...។

ម្នាលព្រាហ្មណ៍ ក្នុងស្រះនោះ សឹងធ្ចូកធ្ចាស់ដោយឧប្បលជាត៣ នេះគឺឧប្បលខៀវ ឧប្បលស និងឧប្បល[៦០]ក្រហម" ។

**សោភណភាពស្រះមុចលិន្ទ**

*លុះពណ៌នាស្រះបោក្ខរណីជ្រុង ៤ យ៉ាងនេះហើយ អច្ចុតឥសី បាន ពោលពណ៌នាស្រះមុចលិន្ទតទៅទៀតថា ៖*

"ក្នុងស្រះនោះ សដូចជាសំពត់សម្បកឈើ ស្រះនោះឈ្មោះថា មុចលិន្ទស្រះ ដេរដាសដោយព្រលិត និងស្គន់ទាំងឡាយផង ដោយត្រកួនទាំងឡាយផង ។ មួយទៀត ពួកផ្កាឈូកក្នុងស្រះ នោះ រីកស្គុះស្គាយ ឃើញហាក់ដូចជាគ្មានទីបំផុត ខ្លះក៏រីកក្នុង គិម្ហរដូវ ខ្លះក៏រីកក្នុងហេមន្តរដូវ បិតនៅក្នុងទឹកត្រឹមជង្គង់ ។ ផ្ទៃ ទឹកនោះសឹងវិចិត្រល្អ ដ៏ដេរដាសដោយផ្កា មានក្លិនក្រអូបឈ្ងុយ ឈ្ងប់បក់ផ្សាយទៅ ពួកមេឃ្មុំនិងកន្ធង់ ទ្រហឹងអឺងកងជុំវិញ

---

[៦០] (ន.) (សំ.),(បា.) (អ៊ុត-ត្បល់ ត. ទ. ស្រ. អ៊ុត-ត្បុល) បទុមជាតិ; ព្រលិត; លំចង់ : ក្នុងស្រះស្រីនោះមានកុមុទឧត្បលចង្កុលណី... ។ ឧប្បលក្រហម រត្តុប្បស ។ ឧប្បល ខៀវ នីលុប្បល ។ ឧប្បលស សេតុប្បល ។ អ. ថ. អ៊ុត-ត្ប៉ៈ ល័ៈ ឬ អ៊ុប-ប៉ៈល័ៈ, ដូចជា ឧត្បលបត្រ ឬ ឧប្បលបត្ត (--បាត់) ស្លឹកឧត្បល ។ ឧត្បលវ័ន ឬ ឧប្បល-- ព្រៃឧត្បល ។ ឧត្បលស្រស់ ត្រពាំងមានឧត្បល ។ល។ ឧប្បល

ព្រោះក្លិនផ្កា ។ ម្នាលព្រាហ្មណ៍ មួយទៀត មានពួកដើមឈើ គឺក្តម្ព ប្រនៀង និងរលួសផ្អុង មានផ្ការីកស្គុះស្គាយ ដុះក្បែរមាត់ទឹកមុចលិន្ទស្រះនុ៎ះ ។ មានទាំងដើមព្រូស ជន្ទូស ស្វាត ខ្ទឹង មានផ្ការីក អមសងខាងមុចលិន្ទស្រះ ។ មានពួកជីរខ្មៅ ជីរ-ស ឈូកត្រាញ់ គណ្ឋី-ស គណ្ឋីខ្មៅ ផ្នង់ បញ្ចេញផ្កា ក្បែរមុចលិន្ទស្រះនុ៎ះ មានក្លិនក្រអូបបក់ផ្សាយទៅ ។ មានពួកដើមសុក្រំ ដកពរ ពពូល ថ្ម ម្រុំ មានផ្ការីក ពួកដើមកេតកៈ កណិការ ច្បាទេសមានផ្ការីក ។ ពួកថ្វាន់ស ថ្វាន់ខ្មៅ ជន្ទាត់ដៃ មានផ្ការីក មានត្រួយរីកល្អ ដុះនៅប្រាលរន្ទាលដូចជាផ្កាចារ ។ ពួកដើមសត្បាស សត្បាខ្មៅ ដើមចេកមាស ដើមដកគាំ ព្រៃនោះរុងរឿង ដោយផ្កាទឹក ដោះខ្វានិងគន្ធាផង ដោយផ្កាផ្នង់ និងទន្ធាផង។ ដើមដកខិម រកា អំពៅ ព្រៃអង្គាសដី ក្រឹស្នា គ្រញូង កោដ្ឋស កោដ្ឋខ្មៅ មានផ្ការីក ។ ព្រឹក្សាទាំងនោះ ទោះខ្ទី សឹងមានដើមដ៏ត្រង់ មានផ្ការីក ក្បែរមុចលិន្ទស្រះនុ៎ះ ដុះនៅទាំងសងខាងអាស្រម ព័ន្ធព័ទ្ធជុំវិញរោងភ្លើង ។ មួយទៀត មានទាំងស្ទឹកគ្រៃ សណ្តែកបាយ សណ្តែករាជមាសជាច្រើន សារាយ និងកំពីងពួយ ជាច្រើនដុះក្បែរមាត់ទឹកមុចលិន្ទស្រះនុ៎ះ ។ ទឹកនោះ មានប្រាំងជាទំនប់ ត្រូវខ្យល់បក់មក រលកក៏

ខ្លាឃ្មុំរទើង មានពួកមេឃ្មុំ ឃុំដោយសំឡេងដ៏ពីរោះ ហើរ
ធ្វៀលធ្វាត់ គុម្ពឈើមានម្ជូក្នុំ ស្វាស្នាប់ ស្វាធំ ក្នុងទីទំនាប ទៀប
មុចលិន្ទស្រះនោះ មានត្រកួនជាច្រើន ។ ម្នាលព្រាហ្មណ៍ ពួក
ព្រឹក្សាសឹងដ៏ដេរដាស ដោយពួកវល្លិឈ្មោះ ឯឡម្ពកៈផុះនៅ
ក្លិនរបស់ផ្កានៃវល្លិទាំងនោះ ដែលគេទ្រទ្រង់អស់ ៧ ថ្ងៃ មិនទាន់
បាត់ក្រអូបឡើយ ។ ពួកផ្កាផុះនៅក្នុងចំណែកទាំងពីរនៃមុចលិន្ទ
ស្រះ ព្រៃនោះដ៏ដេរដាសដោយពួកផ្កាលំចង់ ដ៏រុងរឿង ក្លិនរបស់
ផ្កាទាំងនោះ ដែលគេទ្រទ្រង់អស់កន្លះខែ ក៏មិនទាន់បាត់ក្រអូប
ឡើយ ។ រីឯអញ្ចាញនខៀវ អញ្ចាញនស អញ្ចាញនលឿង មានផ្ការីកស្គុះ
ស្គាយ ព្រៃនោះដ៏ដេរដាសដោយម្ទិះរួត ម្ទិះលា ។ រីឯព្រៃនោះដូច
ជាញុំាងជនដែលមកដល់ ឲ្យរីករាយដោយក្លិនផង ដោយមែក
មានផ្កាទាំងឡាយផង ឯពួកកន្ទង់មានសូរសព្ទទ្រហឹងអឺងកងជុំ
វិញ ព្រោះក្លិនផ្កា ។ ម្នាលព្រាហ្មណ៍ ក្នុងមុចលិន្ទស្រះនោះ មាន
ពួកត្រឡាចបីមុខ គឺ មួយពួកផ្លែប៉ុនក្អម ពីរពួកទៀតផ្លែប៉ុន
សម្ភោរ ។ មួយទៀត មានស្ពៃដ៏ច្រើន និងខ្ទឹមស លាយដោយខ្ទឹម
ក្រហមជាច្រើន ដើមរកាទាំងឡាយ ផុះនៅដូចជាដើមត្នោត មាន

ទាំងពួកលំចង់ដ៏ច្រើន ដែលគេគប្បីក្តិច ដុះនៅក្បែរមុចលិន្ទស្រះ ន៎ុះ ។ មានវល្លិម្ទិះរួត ម្ទិះលា ក្ងាំពាក់ ឈើឯម ពួកអសោកព្រឹក្ស និងដើមទៀនព្រៃ ល្ពៅ វល្លិផ្ដៅធ្ងាំង ។ ស្មៅកន្ទុយដំរី រនោងព្រៃ ដើមខ្ទឹម ដើមម្ទិះសឹងដ៏មានផ្ការីកស្គុះស្គាយ វល្លិចារ មានផ្ការីក ដុះព័ទ្ធព័ន្ធដើមឈើ ។ ពួកឈើនាងនួន មៀនព្រៃ យុថ្កា មានក្លិន ដូចជាទឹកឃ្មុំ ម្ទិះវល្លិ ម្ទិះប្រក្រតី ច្បា បទុមុត្តរព្រឹក្ស សឹងដ៏រុង រឿងល្អ ។ ពួកប្រនៀង កប្បាសមុទ្រ កណិការសឹងដ៏មានផ្ការីក ស្គុះស្គាយ ប្រាកដដូចជាបណ្ដាញមាស សឹងដ៏រុងរឿងល្អ ដូចជា អណ្ដាត ភ្លើង ។ ពួកផ្កាណា កើតលើគោកនិងកើតក្នុងទឹក ពួកផ្កា ទាំងអស់នោះ ប្រាកដក្នុងមុចលិន្ទស្រះនោះ មុចលិន្ទស្រះទ្រទ្រង់ ទឹកច្រើន គួរឲ្យត្រេកអរ យ៉ាងនេះឯង ។ មួយទៀត ក្នុងស្រះ បោក្ខរណីនោះ មានពួកសត្វដែលត្រាច់ទៅ ក្នុងទឹកជាច្រើន គឺត្រី ឆ្ពិន ត្រីរ៉ស់ ត្រីអណ្ដែង ក្រពើ មករ[៦១] ឆ្ងាម ។ មានទាំងផ្ទិតឃ្មុំ ឈើឯម ធ្ងាំពួ ប្រយង្គុ ស្មៅក្រវាញជ្រូក ស្មៅមាត់ក្អែក ដើមសត្ត

[៦១] (ន.) (ម:ក) (មករ ឬ មង្ករ) ឈ្មោះត្រីសមុទ្រមួយប្រភេទ មានខ្លួនធំ ក្បាលខ្ញីក្រមុប ធ្មេញនឹងចង្កូមស្វាញគួរស្ញើម (មានតំណាលក្នុងរឿងរ៉ាវពីព្រេងនាយ); ខ្មែរហៅ សំដៅ ត្រីថ្កុរ ក៏មាន, ច្រើននិយាយថា ឆ្ងាមមករ ។

បុស្ស សម្បុរល្វែង ។ ដើមពុំសែន ដើមឫសសាមសិប ក្រឹស្នា វល្លិ ជណ្តើរស្វា ឈូកត្រាញ់ ក្រវាន់ កោដ្ឋ ព្រហូត បាយម៉ាត ។ ពួករមៀត ហរតាន យ៉ាងណា ហិរិវេរព្រឹក គ្រើល សម៉ពិភេទក៏ប្រោស កប្បូរ រង្គក្រហម ។ មួយទៀត ក្បែរស្រះបោក្ខរណីនោះ មានពួករាជសីហ៍ ខ្លាធំ យក្ខិនី មានមុខដូចជាមុខមេសេះ ដំរីទ្រាយ ស្វាន រមាំង សរម្រឹគ ។ ហ្វូងចចក ទន្សាយ ឆ្មាបា ឆ្កែព្រៃ មានសម្បុរដូចជាផ្កាបបុស ចាមរី ទោច ឈ្លូស ស្វាព្រាម ស្វាក្រិស ស្វាខោល ។ ទន្សោង ខ្ទីង ខ្លាឃ្មុំ គោព្រៃ ជាច្រើន ហ្វូងរមាស ជ្រូកព្រៃ ស្កា កង្ហែន ដោយច្រើន ក្បែរមុចលិន្ទស្រះនុ៎ះ ។ មានទាំងហ្វូងក្របី ឆ្កែព្រៃ ចចក មានស្នាប់ឫស្សីធំ ព័ន្ធព័ទ្ធជុំវិញអាស្រមបទ ទន្សង បចលាកម្រឹគ វិចិត្រម្រឹគ ខ្លាដំបង ។ ហ្វូងទន្សាយឆ្មាត កេសរសីហៈ កោកនិសាតកម្រឹគ សរភៈ ក្ងោក ក្ងាន អាអូតភ្ញើង ។ ពួកមាន់ទឹក មាន់ព្រៃ ដំរី ស្រែកយំឆ្លើយឆ្លងរកគ្នា ទៅវិញទៅមក ពួកកុកសាប់ កុកក្រក ប៉ោលតោក ត្រដេវវិច ក្រៀលរនាល ។ ពួកខ្លែង ប្រមង់ ចង្កៀលខ្យង ចាបស្រុក ចចាត ទទាខ្វែក អាអូត ។ ពួកចចាតធំ ប្រខ្មែ ក្រួច ទទា ចាបស្រុក ចាបព្រៃ

សាលិកា កែវគោ គ្រលីងគ្រលោង ។ ពួកករវិកផង ត្រចៀកកាំផង មៀមផង អកផង មុចលិន្ទស្រះនោះ កុះករដោយហ្វូងបក្សីផ្សេង ៗ ជាទី ទ្រហឹងអឹងកងដោយសំឡេងផ្សេង ៗ ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានសត្វស្លាបទាំងឡាយគឺពួក សាលិកា កែវ មានសំឡេងពីរោះ ស្រែកយំឆ្លើយឆ្លងរកគ្នាទៅវិញទៅ មក រីករាយជាមួយនឹងញីរបស់ខ្លួន ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបកើតពីរដង មានសំឡេងពីរោះ មានរង្វង់ភ្នែកស មានភ្នែកល្អ កើតក្នុងពង មានស្លាបដ៏វិចិត្រ ។ មួយទៀត ក្បែរមុចលិន្ទ ស្រះនុ៎ះ មានពួកបក្សី មានសំឡេងពីរោះ គឺក្ងោកមានកខៀវ ស្រែកយំ ឆ្លើយឆ្លងគ្នាទៅវិញទៅមក ។ អាអូតក្ងើង មាន់ព្រៃ កោដ្ឋបក្សីពញាក់ ត្រចៀកកាំសមុទ្រ ខ្វែងជ្រក បក្សប្រវឹក សេក និងសាលិកា ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកហង្ស ច្រើន មានសម្បុរលឿង ក្រហម ស សត្វហត្ថិលិង្គ សម្បកត្រពាំង ប្រវឹក សេកនិងតាវៅ ។ ពួកអង្កត់ខ្មៅ អង្កត់ស ហង្ស រអាជ ក្ងែង ស្រាក ចាកហង្ស កុកគ្រោង ប៉ោលតោក ចាបស្រុក ។ ហ្វូងព្រាប គ្រលែងវែក ចាក្រពាក ក្អែកទឹក វារណបក្សី មានសំឡេងគួរឲ្យត្រេកអរ ស្រែកយំហៅគ្នាក្នុងកាលទាំងពីរ គឺព្រឹកល្ងាច ។ មួយ

ទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វ ស្វាបកើតពីរដង មាន សម្បុរផ្សេង ៗជាច្រើន ស្រែកយំឆ្លើយឆ្លងគ្នាទៅ វិញទៅមក រីករាយជាមួយនឹងញី ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្វាបមានកំណើតពីរដង មានសម្បុរផ្សេង ៗ ជាច្រើន សុទ្ធតែមានសំឡេងពីរោះ ស្រែកសព្ទស៊ានត្រង់ឆ្នេរទាំងសងខាងមុចលិន្ទស្រះ ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកករវិក សត្វទាំងនោះ មានកំណើតពីរដង រមែងស្រែកហៅគ្នា រីករាយជាមួយនឹងញី ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកករវិក សត្វទាំងនោះមានកំណើត ពីរដង សុទ្ធតែមានសំឡេងដ៏ពីរោះស្រែកសព្ទស៊ានត្រង់ឆ្នេរទាំងសង ខាងមុចលិន្ទស្រះ ។ ព្រៃជិតស្រះបោក្ខរណីនោះ ដែលពួកដំរីអាស្រ័យ នៅហើយ សឹងដ៏កុះករដោយទ្រាយ ស្វាន ទាំងដេរដាសដោយពួកវល្លិផ្សេង ៗ ដែលពួកសត្វឈ្លូសអាស្រ័យនៅហើយ ។ ម្យ៉ាងទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានស្រងែច្រើន ស្កួយច្រើន ពោតច្រើន ស្រូវសាលី ដុះឯងមិនបាច់មានអ្នកណាភ្ជួររាស់ដាំឡើយ ទាំងអំពៅសោតក៏មានច្រើន ដុះក្បែរមុចលិន្ទស្រះនុ៎ះ ។ ផ្លូវដើរនេះចុះតែដើងមួយ

បុគ្គលដើរ ទៅត្រង់អាស្រម ដល់ទៅទីនោះហើយ ក៏មិនបាន សម្រេក គម្លាន និងសេចក្ដីអផ្សុកឡើយ ។ អាស្រមដែលព្រះបាទវេស្សន្តរគង់នៅ ព្រមទាំងព្រះរាជបុត្រ និងព្រះរាជទេពី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរ មានតម្លក់និងវែកសម្រាប់បូជាភ្លើង និងសក់កណ្ដាញ់ ទ្រង់ស្បែកខ្លា ផ្ទំ ផ្ទាល់ផែនដី នមស្ការភ្លើង" ។

ជូជកជាផៅពង្សនៃព្រហ្ម ឮពាក្យនេះហើយក៏ធ្វើប្រទក្សិណឥសី មានចិត្តត្រេកអរ ក៏ដើរចេញសំដៅទៅអាស្រម ដែលព្រះបាទវេស្សន្តរគង់នៅ ។

មហាវនវណ្ណនា ចប់ ។

# ជំពូកទី ៨

## ការកបព្វវណ្ណនា

### ព្រះនាងមទ្រីយល់សុបិនអាក្រក់

ព្រាហ្មណ៍ជូជក ដើរតាមផ្លូវដែលអច្ចុតតាបសប្រាប់ ដល់នូវស្រះបោក្ខរណី ៤ ជ្រុង គាត់គិតថា ៖

"ថ្ងៃនេះ ល្ងាចពេកណាស់ហើយ ឥឡូវនេះសមព្រះនាងមទ្រីមកអំពីព្រៃវិញ ។ ធម្មតា មាតុគ្រាម[៦២] តែងធ្វើសេចក្ដីអន្តរាយចំពោះទាន ចាំថ្ងៃស្អែកពេលនាងទៅព្រៃបាត់សិន សឹមអញទៅអាស្រមបទ ចូលគាល់ព្រះបាទវេស្សន្តរ សូមទារកទាំងពីរ រួចអញនឹងយកពួកគេចេញទៅ ក្នុងពេលដែលព្រះនាងមទ្រីមកមិនទាន់ដល់" ។

គ្រានោះ គាត់ឡើងភ្នំសានុមួយ នៅមិនឆ្ងាយអំពីគាត់ប៉ុន្មាន គាត់ដេកនៅកន្ទេងមួយដែលមានផាសុកភាព ។ ប៉ុន្តែ ក្នុងរាត្រីនោះ នាវេលាទៀបភ្លឺ ព្រះនាងមទ្រីបានយល់សុបិន ។ ឯសុបិននោះ មានសភាពបែបនេះគឺ បុរសម្នាក់ សម្បុរខ្មៅ ស្លៀកដណ្ដប់សំពត់កាសាយៈ

---

[៦២] អ្នកដែលមានលម្អានដូចជាម្ដាយ ។

ពីរផ្ទាំង ពាក់កម្រងផ្កាពណ៌ក្រហមទាំងសងខាងត្រចៀក ដៃកាន់អាវុធស្រែកគំហក រត់ចូលមកបណ្ណសាលា ចាប់ព្រះនាងមទ្រីត្រង់ផ្នួងសក់ទាញបណ្ដួលផ្ងារពោះលើផែនដី កាលដែលក្សត្រីកំពុងយំ គេឆ្កៀលខ្វេះយកព្រះនេត្រទាំងគូកាត់ដើមដៃពុះទ្រូងរូងយកសាច់បេះដូងដែលមានតំណក់ឈាមហូរស្រោក់ ៗ ដើរចៀសចេញទៅ ។ ព្រះនាងមទ្រីតើនឡើង កើតភ័យតក់ស្លុត ទ្រង់ព្រះចិន្ដាថា "អាក្រក់អ្វីម្ល៉េះទេសុបិនដែលអញយល់នេះ ប៉ុន្ដែអ្នកទាយសុបិនដែលស្មើនឹងព្រះវេស្សន្ដរមិនមានទេ អញនឹងទូលពិតព្រះអង្គទាយមើល" គិតហើយព្រះនាងទៅបណ្ណសាលា គោះទ្វារបណ្ណសាលារបស់ព្រះមហាសត្ត ។

"នរណាហ្នឹង ?" វេស្សន្ដរសួរ ។

"ខ្ញុំម្ចាស់មទ្រី ព្រះសម្មតិទេព" មទ្រីឆ្លើយ ។

"ហៃអូនសម្លាញ់ នាងធ្វើឲ្យខូចខសន្យារបស់យើង មកក្នុងកាលខុស ព្រោះហេតុអ្វីទៅ ?" វេស្សន្ដរសួរ ។

"បពិត្រព្រះសម្មតិទេព ពុំមែនខ្ញុំម្ចាស់មកនេះទាក់ ទងនឹងរឿងកិលេសអ្វីទេ ប៉ុន្ដែខ្ញុំម្ចាស់យល់សុបិនអាក្រក់ណាស់ ក្រាបទូល" ។

"បើអ៊ីចឹង ប្រាប់មកចុះ មទ្រី" ព្រះវេស្សន្ដរត្រាស់ ។

ព្រះនាងមទ្រីនោះ បានប្រាប់តាមទំនងដែលខ្លួនបានយល់សប្តិនោះឯង ។ រីឯព្រះមហាសត្វទ្រង់ឆ្ងល់យល់សុបិននោះ ប៉ុន្តែទ្រង់ព្រះតម្រិះថា "ទានបារមីរបស់អញ នឹងពេញបរិបូណ៌ ដ្បិតថ្ងៃស្អែកនឹងមានស្មូមយាចកមករកអញសូមកូន អញលួងលោមនាងមទ្រីឲ្យទៅវិញ"។ ព្រះអង្គបានលួងលោមបង្វែងដានដូច្នេះវិញថា ៖

"ហៃមទ្រី ដោយសារតែទីដេកមិនស្អាត និងភោជនមិនល្អ ទើបចិត្តរបស់នាងប្រែប្រួលប្រែបល់ កុំខ្លាចអ្វីឡើយ"

ថាតែប៉ុណ្ណោះហើយ ទ្រង់ឲ្យព្រះនាងត្រឡប់ទៅវិញ ។

នាកាលរាត្រីភ្លឺច្បាស់ហើយ ព្រះនាងបានធ្វើកាតព្វកិច្ចទាំងពួងឱបកូន ទាំងពីរថើបក្បាល ទូន្មានថា ៖

"ហៃបា ថ្ងៃនេះម្តាយឃើញសុបិនអាក្រក់ បាកុំប្រហែសណា"

រួចព្រះនាងផ្ញើកូននឹងព្រះមហាសត្វថា ៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំប្រហែសធ្វេសកុមារទាំងពីរឡើយ"

ហើយ ព្រះនាងកាន់កញ្ច្រែង ជ្រនីកជាដើម ជូតទឹកជលនេត្របណ្តើរក្បត្រីចូលទៅក្នុងព្រៃ រកជីកមើមឈើ និងបេះផលាផល ។

និយាយពីព្រាហ្មណ៍ជូជក គ្រានោះ គាត់គិតថា "ឥឡូវនេះព្រះនាងមទ្រី សមជាទៅព្រៃបាត់ហើយ" គាត់ចុះពីភ្នំសានុ ឆ្ពោះមុខទៅកាន់អាស្រម តាមផ្លូវដើរចុះតែដើងមួយ ។ ចំណែកព្រះមហាសត្តចេញពីបណ្ណសាលា ប្រថាប់គង់លើផែនថ្មទៀបទ្វារបណ្ណសាលា ហាក់ដូចជារូបសំណាកមាស ព្រះអង្គគង់មើលទៅឯផ្លូវមករបស់ព្រាហ្មណ៍នោះថា "ស្ងួមនឹងមកឥឡូវនេះ ៗ" ហាក់ដូចមាណពប្រមឹកស្រេកផឹកស្រា ។ កូន ៗ របស់ព្រះអង្គ កំពុងតែលេងជិតបាទមូល ។ កាលព្រះអង្គសម្លឹងមើលទៅផ្លូវ ទ្រង់ឃើញព្រាហ្មណ៍កំពុងមក ទ្រង់មានសោមនស្សថា "អ្នកមកណោះ ព្រាហ្មណ៍ដ៏ចម្រើន ៗ" ហាក់ដូចជាលើកទានធុរៈដែលដាក់ចុះ ៧ ខែហើយឲ្យខ្ពស់ឡើងវិញ ទ្រង់ហៅជាលីកុមារប្រាប់ថា ៖

"ហៃបាជាលី អ្នកចូរក្រោកឡើង ដំណើរមករបស់ស្ងួម ប្រាកដ
ដូចជាដំណើរមកអំពីមុន ៗ បិតាមើលទៅឃើញដូចជាព្រាហ្មណ៍
តាំងអំពីឃើញព្រាហ្មណ៍នុ៎ះ សេចក្ដីរីករាយ ក៏មកស្រោចស្រព
លើបិតា ដូចគេស្រោចទឹកត្រជាក់ ១.០០០ ក្អម លើក្បាលបុរស
ដែលដើរហាលក្ដៅក្នុងគិម្ហរដូវ ។

ជាលីកុមារ ឮហើយ ក្រាបទូលថា ៖

"បពិត្រព្រះវរបិតា ទូលបង្គំរមិលមើលទៅឃើញប្រាកដដូចជាព្រាហ្មណ៍ ដូចជាមានអ្នកដំណើរមក នឹងជាភ្ញៀវរបស់យើង" ។

**តាជូជកបដិសេធសេចក្តីស្នើរបស់ព្រះវេស្សន្តរ**

លុះពោលហើយ ព្រះកុមារធ្វើសេចក្តីកោតក្រែងចំពោះព្រះមហាសត្ត ក្រោកអំពីអាសនៈក្រោកទៅទទួលព្រាហ្មណ៍ សូមជួយកាន់នូវបរិក្ខារ ។ ព្រាហ្មណ៍ជូជក លោតែឃើញព្រះកុមារ គិតថា "នេះជាក់ជាបុត្ររបស់ព្រះបាទវេស្សន្តរ ឈ្មោះជាលី ចាប់ដើមពីនេះទៅ អញនឹងពោលពាក្យទ្រគោះបោះបោក" ផ្ទាត់ម្រាមដៃថា "ចៀសចេញ ៗ"។ កុមារគិតថា "ព្រាហ្មណ៍នេះ ឃោរឃៅម្ល៉េះ ! ហេតុអ្វីហ្ន៎" មើលទៅសរីរៈរបស់ព្រាហ្មណ៍ ឃើញទោសអប្បលក្ខណ៍នៃរូបកាយព្រាហ្មណ៍ដល់ទៅ ១៨ ប្រការ ។ ចំណែកព្រាហ្មណ៍ ចូលគាល់ព្រះពោធិសត្វ ធ្វើនូវបដិសណ្ឋារៈថា ៖

"ព្រះអង្គបានសេចក្តីសុខសប្បាយទេឬ ? ព្រះអង្គមិនមានរោគាពាធទេឬ ? ព្រះអង្គចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ ? មើមឈើ និងផ្លែឈើ មានច្រើនឬ ? ។ ពួករបោម មូស ពស់មាន

តិចទេឬ ? ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀត
បៀនព្រះអង្គទេឬ ?” ។

ពោធិសត្វ បានឆ្លើបដិសណ្ឋារៈជាមួយនឹងព្រាហ្មណ៍វិញថា ៖

“ម្នាលព្រាហ្មណ៍ យើងបានសេចក្ដីសុខសប្បាយទេ ម្នាល
ព្រាហ្មណ៍ មួយទៀត យើងមិនមានរោគាពាធទេ យើងចិញ្ចឹម
ជីវិត ដោយការស្វែងរកស្រួលទេ ទាំងមើមឈើនិងផ្លែឈើក៏មាន
ច្រើនដែរ។ មួយវិញទៀត ពួករបោម មូស ពស់ ក៏មានតិចទេ
ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើង
ទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែហើយ រស់នៅទាំងទុក្ខសោក
ទើបតែនឹងបានឃើញ ព្រាហ្មណ៍ឯងជាដំបូងមានភេទដ៏ប្រសើរ
កាន់ឈើច្រត់ មានសម្បុរដូចផ្លែព្នៅទុំ មានវែកសម្រាប់បូជាភ្លើង
និងកុណ្ឌី ។ ហៃមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀត អ្នក
មិនមែនមកអាក្រក់ទេ អ្នកចូរចូលមកខាងក្នុង សេចក្ដីចម្រើនចូរ
មានដល់អ្នក អ្នកចូរលាងជើងរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នក
ចូរបរិភោគផ្លែឈើដ៏ឆ្ងាញ់ពិសាដូចទឹកឃ្មុំ គឺផ្លែ ទន្ទាប់ ផ្លែទ្រយឹង
ផ្លែមាក់ប្រាង ផ្លែមាក់ដោក ។ ទឹកដ៏ត្រជាក់នេះឯង ដែលដងមក

អំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ បើអ្នកប្រាថ្នាចង់ផឹក ចូរដង

យកអំពីពេងទឹកនោះហើយផឹកចុះ" ។

លុះពោលយ៉ាងនេះហើយ ព្រះមហាសត្តគិតថា "ព្រាហ្មណ៍នេះ មិនមែនមកព្រៃធំនេះ ដោយឥតហេតុទេ អញនឹងសួរនូវហេតុមករបស់គេមិនបង្អង់យូរឡើយ" រួចទ្រង់សួរតែម្ដងថា ៖

"អ្នកមកដល់ព្រៃធំ ដោយហេតុដូចម្ដេច ដោយបច្ច័យដូចម្ដេច

យើងសួរហើយ អ្នកចូរប្រាប់ហេតុនោះ" ។

ជូជក តបថា ៖

"ផ្លូវទឹកមានទន្លេនិងស្ទឹងជាដើម ដ៏ពេញប្រៀបមិនចេះអស់ទៅ

សព្វកាល យ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំមកដើម្បីសូមទាន

ព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមហើយ សូមប្រទានព្រះរាជបុត្រ

ទាំងពីរ ក៏យ៉ាងនោះដែរ" ។

ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះមហាសត្ត មានសោមនស្ស ទ្រង់បានញ៉ាំងដើងភ្នំឲ្យលាន់សូរសំឡេងកងរំពង ដោយត្រាស់ពាក្យទាំងនេះហាក់ដូចដាក់ស្បោងប្រាក់ ១.០០០ កហាបណៈ លើដៃមនុស្សដែលលាស្រាប់ថា ៖

"ម្នាលព្រាហ្មណ៍ យើងឲ្យយើងមិនរួញរាទេ អ្នកជាម្ចាស់នៃពួកបុត្ររបស់យើង ចូរនាំយកទៅចុះ រាជបុត្រីជាមាតានៃបុត្រទាំងពីរនោះ បានចេញទៅរកផលាផលអំពីព្រឹក នាងនឹងត្រឡប់មកអំពីការស្វែងរក ក្នុងវេលាល្ងាច ម្នាលព្រាហ្មណ៍ អ្នកចូរឈប់ សម្រាកបានមួយយប់សិន លុះព្រឹកឡើង សឹមទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកឈប់សម្រាក បានមួយយប់នៅទីនេះ បរិភោគផលាផលដែលមានរសផ្អែម ដែលម្ដាយកុមារនាំយកមកសិន លុះព្រឹកឡើង សឹមនាំយកកុមារទាំងពីរនោះ ដែលមាតានោះដុសក្បាល ហើយប្រដាប់ដោយផ្កាកម្រងហើយ ទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកចូរនាំយកកុមារទាំងពីរនោះ ដែលពាក់ដោយផ្កាផ្សេង ៗ ស្អិតស្អាងដោយគ្រឿងក្រអូបផ្សេង ៗ សម្បូណ៌ដោយមើមឈើនិងផ្លែឈើផ្សេង ៗ ហើយទៅចុះ" ។

ជូជក ក្រាបទូលថា ៖

"បពិត្រព្រះអង្គប្រសើរក្នុងរថ ទូលព្រះបង្គំ មិនគាប់ចិត្តនឹងការនៅទេ គាប់ចិត្តតែនឹងការទៅ ក្រែងអន្តរាយមានដល់ទូលព្រះបង្គំ ឯទូលព្រះបង្គំនឹងទៅខានពុំបាន ។ ជម្មតាពួកស្រីនុ៎ះ មិនមែនជាអ្នកគួរដល់ស្នូមទេ តែងធ្វើសេចក្ដីអន្តរាយ ពួកស្រីរមែងចេះកិច្ច

កលមាយាតែងកាន់យកកិច្ចការទាំងពួងដោយខាងឆ្វេង។ បពិត្រព្រះអង្គប្រសើរក្នុងរថ កាលបើព្រះអង្គប្រទានដោយសទ្ធា សូម កុំឲ្យទូលព្រះបង្គំជាខ្ញុំជួបនឹងព្រះមាតារបស់កុមារទាំងនោះឡើយ ក្រែងលោព្រះនាងនោះធ្វើ សេចក្ដីអន្តរាយ ទូលព្រះបង្គំនឹងទៅខានពុំបាន ។ សូមព្រះអង្គត្រាស់ ហៅបុត្រទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្រទាំងនោះ បានឃើញព្រះមាតាឡើយ កាលបើព្រះអង្គប្រទានដោយសទ្ធា ជឿនូវកម្មនិងផល បុណ្យតែងចម្រើនលូតលាស់យ៉ាងនេះ ។ សូមព្រះអង្គត្រាស់ហៅ បុត្រទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្រទាំងនោះបានឃើញព្រះមាតាឡើយ បពិត្រព្រះរាជា លុះព្រះអង្គប្រទានព្រះរាជទ្រព្យ ដល់បុគ្គលប្រាកដដូចជាខ្ញុំហើយ ព្រះអង្គនឹងយាងទៅកាន់ឋានសួគ៌" ។

ព្រះបាទវេស្សន្តរ ត្រាស់ថា ៖

"បើអ្នកមិនប្រាថ្នាចង់ជួបនឹងភរិយារបស់យើង ដែលជាស្ត្រីមានវ័តក្នុងស្វាមីទេ អ្នកចូរឲ្យកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនានេះ ដល់ព្រះអយ្យកោចុះ ។ ព្រះអយ្យកោនោះ ទ្រង់ទតឃើញកុមារទាំងនេះដែលមានសម្ដីពីរោះ និយាយពាក្យជាទីស្រឡាញ់ហើយ

ទ្រង់សប្បាយ រីករាយ ត្រេកអរ មុខតែប្រទាននូវព្រះរាជទ្រព្យជា

ច្រើនដល់អ្នក" ។

ព្រាហ្មណ៍ជូជក ក្រាបទូលតបថា ៖

"បពិត្រព្រះរាជបុត្រ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់

ទូលព្រះបង្គំទូលព្រះបង្គំខ្លាចក្រែងព្រះអយ្យកោដណ្ដើមយកព្រះ

រាជកុមារ ព្រះអយ្យកោនឹងប្រទានទូលព្រះបង្គំដល់ពួកអាមាត្យ

ដើម្បីព្រះរាជទណ្ឌ ឬផាកពិន័យ ពុំនោះសោត នឹងសម្លាប់ពុំខាន

ទូលព្រះបង្គំ មុខជានឹងដាច់ចាកទ្រព្យផង ចាកពួកទាសៈផង ត្រូវ

នាងព្រាហ្មណីតិះដៀលផង" ។

ព្រះបាទវេស្សន្តរ ពោលថា ៖

"ព្រះមហារាជដែលទ្រង់បិតនៅក្នុងធម៌ ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យ

ចម្រើន កាលទ្រង់ទតឃើញកុមារទាំងនេះ ដែលមានសម្ដីពីរោះ

និយាយពាក្យជាទីស្រឡាញ់ ទ្រង់បានបីតិនិងសោមនស្សនឹងព្រះ

រាជទានព្រះរាជទ្រព្យជាច្រើនដល់អ្នក" ។

ជូជក តបថា ៖

"ទូលព្រះបង្គំមិនធ្វើតាមព្រះបន្ទូលដែលទ្រង់បង្គាប់នោះទេ ទូល

ព្រះបង្គំសូមនាំយកទារកទាំងពីរទៅឲ្យបម្រើនាងព្រាហ្មណី" ។

## ជាលីនិងក្រឹស្នារត់ពួន

ចំណែកខាងកុមារទាំងពីរ ស្ដាប់ឮសម្ដីដ៏រឹងរូស របស់ព្រាហ្មណ៍ម្នាក់ ៗ សែនភ័យតក់ស្លុត នាំគ្នារត់ទៅពួននៅខាងក្រោយបណ្ណសាលារត់ពីនោះទៅទៀត ពួនក្នុងគុម្ពោតស៊ុមទ្រុម ឃើញខ្លួនហាក់ដូចត្រូវជូជកដេញតាមចាប់ ពីរនាក់បងប្អូនញ័រខ្លួនចំប្រប់ទ្រាំពួននៅកន្លែងណាមួយប្រាកដពុំបាន រត់ឡាចុះឡាឡើង ទៅកន្លែងនេះផងកន្លែងនោះផង នៅពុំសុខ រត់ទៅកាន់ស្រះបោក្ខរណីជ្រុង ៤ ចង់ក្បិនសំពត់សំបកផ្ទៃយ៉ាងមាំ ចុះទៅក្នុងទឹកស្រះ កាច់ស្លឹកឈូកបាំងគ្របក្បាល សំងំឈរប៉ប្រះផ្ទៃទឹក ។

កាលជូជកមិនឃើញកុមារទាំងពីរ គាត់បានតិះដៀលព្រះបាទវេស្សន្តរថា៖

"នៃវេស្សន្តរ អម្បាញ់មិញក្រែងអ្នកឲ្យកុមារដល់ខ្ញុំ លុះឮខ្ញុំថា មិនទៅជេតុត្តរនគរ នឹងនាំកុមារទាំងពីរទៅឲ្យបម្រើនាងព្រាហ្មណី អ្នកបែរជាឲ្យសញ្ញាដល់ពួកកុមាររត់គេចខ្លួនអស់ញ៉ាំងឲ្យកូនរត់ហើយ អង្គុយធ្វើដូចជាមិនដឹង ក្នុងលោកនេះទំនងជាគ្មានអ្នកពូកែល្បិចកុហកប្រហែលអ្នកទេ" ។

ឮសម្ដីព្រាហ្មណ៍ដូច្នោះ ព្រះមហាសត្វ ទ្រង់ធ្លួលចិត្តគិតថា "ប្រាកដជាពួកកុមាររត់ហើយ" ទ្រង់អះអាងថា ៖

"នែព្រាហ្មណ៍ កុំព្រួយបារម្ភអ្វី ចាំយើងនាំកុមារទាំងនោះមកឲ្យ" ថាហើយទ្រង់ក្រោកយាងទៅ រកមើលខាងក្រោយបណ្ណសាលា យល់ថាកុមារទាំងពីរចូលទៅគុម្ពោតស៊ុមទ្រុម ទ្រង់យាងតាមដានស្នាមជើងតាមទៅ ៗ ដល់ស្រះបោក្ខរណី ប្រទះស្នាមជើងឡើងពីទឹក ទ្រង់ជ្រាបថា "កុមារប្រាកដជាចុះទៅឈរក្នុងទឹក "ហៃបាជាលី ៗ" ហៅដូច្នេះហើយ ទ្រង់ត្រាស់ថា ៖

"ហៃបា ជាកូនស្ងួនសម្លាញ់ កូនចូរមកអាយ ចូរបំពេញបារមីរបស់បិតា កូនចូរស្រោចស្រប់ហឫទ័យរបស់បិតា កូនចូរធ្វើតាមពាក្យរបស់បិតា ។ កូនចូរដូចជាយាននាវា របស់បិតា ឲ្យនឹងថ្កល់ក្នុងសាគរគឺភព បិតានឹងឆ្លងចាកត្រើយគឺជាតិ នឹងចម្លងមនុស្សព្រមទាំងទេវតា ទៅកាន់ត្រើយគឺព្រះនិព្វាន" ។

ជាលីកុមារ ឮពាក្យបិតាហៅ គិតក្នុងចិត្តថា "ខ្លួនអញទុកណាជាព្រាហ្មណ៍ចង់ធ្វើអ្វី ក៏ធ្វើស្រេចតែចិត្តគេចុះ អញនឹងមិនដំអក់ឲ្យបិតាហៅ ដល់ពីរព្រះឱស្ឋឡើយ" លុះគិតរួច ជាលីកុមារស្រាប់តែលេច

ក្បាលប៉ឹមពីទឹក គ្រវាសស្អឹកឈូកចេញ ដើរឡើងពីទឹក ក្រាបចុះទៀប ព្រះបាទខាងស្តាំ ដៃស្រវាឈោងចាប់កជើងព្រះបិតាយ៉ាងមាំ ទាំងមាន ទឹកជលនេត្រលើងរលោង ទ្រហោយំយ៉ាងអាណោចអាធ័ម ។

គ្រានោះ ព្រះមហាសត្ត សួរកុមារថា ៖

"ហៃបា ចុះឯណាទៅប្អូនស្រីរបស់អ្នក ?" ។

កុមារ ក្រាបទូលថា ៖

"បពិត្រព្រះបិតា ជាធម្មតាសត្វទាំងឡាយនេះ កាលបើភ័យកើត ឡើងហើយ តែងតែរក្សាខ្លួនដោយពិត" ។

គ្រានោះ ព្រះមហាសត្ត យល់ថា កូនទាំងពីររបស់ព្រះអង្គ ប្រាកដជា ធ្វើការមត់គ្នា ។ "ហៃកណ្ហាជិនាកូន ៗ" ហៅដូច្នេះហើយ ព្រះអង្គត្រាស់ថា ៖

"ហៃធីតាស្ងួនសម្ងាញ់ឪពុក នាងចូរមក ព្រោះទានបារមី ជា សម្ងាញ់របស់បិតា នាងចូរស្រោចស្រពហឫទ័យរបស់បិតា ឲ្យ នឹងប្តូលក្នុងសាគរគឺភព បិតានឹងឆ្លងចាកត្រើយគឺជាតិ នឹងចម្លង ពួកមនុស្ស ព្រមទាំងទេវតា" ។

## ព្រះវេស្សន្តរកាត់ថ្លៃកូនដូចកាត់ថ្លៃគោ

រីឯនាងកណ្ហាជិនា គិតថា "អញនឹងមិនជំអក់ឲ្យព្រះបិតា ហៅដល់ពីរម៉ាត់ឡើយ" រួចនាងងើបពីទឹក គ្រវៀសស្លឹកឈូកចេញ ដើរឡើងពីទឹក ក្រាបចុះទៀបព្រះបាទខាងឆ្វេង ចាប់កដើងព្រះបិតាយ៉ាងមាំ យំយ៉ាងខ្លាំង ។ តំណក់ទឹកភ្នែក របស់កុមារទាំងពីរ ធ្លាក់ចុះលើព្រះបាទារបស់ព្រះមហាសត្ត ដែលមានពណ៌ប្រៀបដូចពណ៌ផ្កាឈូកដែលទើបប៉ិចពន្លកឡើង ។ គ្រានោះព្រះមហាសត្តប្រាប់កុមារទាំងពីរឲ្យងើបឡើង ទ្រង់លួងលោមថា ៖

"ហៃបាជាលី បាមិនដឹងបិតាមានអធ្យាស្រ័យក្នុងទានទេឬ ចូរបាជួយញុាំងអធ្យាស្រ័យរបស់បិតាឲ្យដល់នូវទីបំផុត"

ព្រះមហាសត្ត ឈរនៅទីនោះ កាត់ថ្លៃកុមារ ដូចជាគេកាត់ថ្លៃគោ ។ បានឮថា ព្រះបាទវេស្សន្តរអង្គនោះហៅបុត្រមកហើយទ្រង់ត្រាស់ថា ៖

"នៃបាជាលី ប្រសិនបើបាមានបំណងចង់រួចជាអ្នកជា បាត្រូវឲ្យមាសនេ្តា ១.០០០ តម្លឹងដល់ព្រាហ្មណ៍ ទើបរួចជាអ្នកជាបាន រីឯប្អូនស្រីរបស់អ្នកវិញ មានរូបឆោមឧត្តម អ្នកមានជាតិទាបណាមួយ ឲ្យទ្រព្យបន្តិចបន្តួចដល់ព្រាហ្មណ៍ លោះប្អូនស្រីរបស់អ្នក

ធ្វើជាតិសម្តេទ តែថាអ្នកឲ្យរយនៃវត្ថុគ្រប់មុខ មិនមានទេ លើក

លែងតែព្រះរាជា ហេតុនោះ ប្អូនស្រីរបស់អ្នក បើមានបំណងចង់

រួចជាអ្នកជា ចូរឲ្យរយនៃវត្ថុគ្រប់មុខដល់ព្រាហ្មណ៍ យ៉ាងនេះគឺ

ខ្ញុំប្រុស ១០០ ខ្ញុំស្រី ១០០ ដំរី ១០០ សេះ ១០០ គោឧសភៈ១០០

មាសផ្តៅ ១០០ តម្លឹង ទាល់តែឲ្យយ៉ាងនេះ ទើបរួចខ្លួនជាអ្នកជា

បាន" ។

លុះកាត់ថ្លៃកុមារទាំងពីរ និងលួងលោមយ៉ាងនេះហើយ ទ្រង់យាងទៅ កាន់អាស្រមបទ ចាប់កំសៀវទឹក ហៅព្រាហ្មណ៍មកថា "នៃព្រាហ្មណ៍ មកណេះមក" ។ ទ្រង់តាំងសេចក្តីប្រាថ្នា **សព្វញ្ញុតញ្ញាណស្ស បច្ចយោ ហោតុ** សូមទាននេះជា បច្ច័យនៃសព្វញ្ញុតញ្ញាណ ទ្រង់បានច្រួចទឹក ពោលថា ៖

"នៃព្រាហ្មណ៍ដ៏ចម្រើន សព្វញ្ញុតញ្ញាណមួយគត់ ជាទីស្រឡាញ់

របស់យើងលើសពីកូនទាំងឡាយ រាប់រយ រាប់ពាន់ រាប់សែនដង"

ទ្រង់ញ៉ាំងប្រឹថពីឲ្យឮសូរលាន់រំពង ហើយទ្រង់ប្រទានបុត្រ ជាទី ស្រឡាញ់ឲ្យជាទានដ៏ឧត្តមដល់ព្រាហ្មណ៍ ។ ហេតុដែលគួរស្ញប់ស្ញែង សេចក្តីព្រឺព្រួចរោម ក៏កើតមាន ផែនដីក៏កម្រើកញាប់ញ័រ ក្នុងកាល នោះ ។ ដោយតេជះនៃទានរបស់ព្រះបាទវេស្សន្តរគ្រានោះ មហា

ប្រឹថពី ដែលមានកម្រាស់ ២ សែន ៤ នហុត បានលាន់សំឡេងកគ្រើក ញាប់ញ័រៗ សាគររញ្ជួយកក្កុកក្កឹក ។ ភ្នំព្រះសុមេរុដែលជាស្តេចភ្នំ ទោរទន់ដូចវល្លិ ផ្តៅត្រូវភ្លើង ឈមមុខឆ្ពោះទៅចំភ្នំវង្កត ។ សក្កទេវរាជ ទះដៃ មហាព្រហ្ម ថ្វាយសព្ទសារធុការពរ ។ កោលាហល មានដល់ព្រហ្មលោកតែមួយដូចគ្នា ។ ដោយសំឡេងលាន់ឮនៃប្រឹថពី ផ្ទៃមេឃតាំងអឮ លាន់ផ្គរដូចហែកមេឃ បង្អុរភ្លៀងចុះមួយរំពេច ។ ឯលើអាកាសផ្ទេកបន្ទោរ ដាលប្រវាត់ភ្លឺផ្ទេកភ្លេត ៗ ខុសកាល ។ សត្វសីហៈជាដើម ដែលរស់នៅក្នុងព្រៃហិមពាន្ត បានបន្លឺសំឡេងស្របពេលគ្នាតែមួយ ឮយ៉ាងទ្រហឹងពេញព្រៃ ដែលបែបនេះ បណ្តាលនូវសភាពគួរខ្លាចស្ញប់ស្ញែង ឲ្យមានឡើង ក្នុងពេលដែលព្រះបាទវេស្សន្តរត្រាស់ថា ៖

"នែព្រាហ្មណ៍ដ៏ចម្រើន សព្វញ្ញុតញ្ញាណមួយគត់ ជាទីស្រឡាញ់របស់យើងលើសពី កូនទាំងឡាយ រាប់រយ រាប់ពាន់ រាប់សែនដង" ។

ព្រះមហាសត្ត លុះឲ្យទានហើយ ទ្រង់ញ៉ាំងបីតិឲ្យកើតឡើងថា "ទានគឺអញបានឲ្យប្រពៃហើយ"រួចទ្រង់ឈរសម្លឹងមើលកុមារទាំងពីរ ។ ចំណែកជូជក ចូលទៅគុម្ពោតព្រៃ ខាំកាត់វល្លិដោយធ្មេញទាំងឡាយ

យកមកចងដៃស្តាំរបស់ជាលីកុមារ ព្រួតជាមួយគ្នានឹងដៃខាងឆ្វេង របស់នាងកណ្ហាជិនា ហើយចាប់ចុងវល្លិនុំះឯង វាយវាត់បណ្តើរទៅ ។ តពីនោះ ព្រាហ្មណ៍នោះកាន់ខ្សែផង កាន់ឈើច្រត់ផង វាយកុមារទាំងពីរនោះ នាំបណ្តើរទៅនៅទីចំពោះព្រះភក្ត្រនៃព្រះបាទវេស្សន្តរ ។

**ជាលីកុមារថាយក្សនិម្មិតខ្លួនជាព្រាហ្មណ៍**

កន្លែងណាដែលជូជកវាយវាត់នឹងវល្លិ សុទ្ធតែមានស្នាមដាច់រលាត់ស្បែកហូរឈាម ប្រាកដដល់កុមារទាំងពីរ ។ ក្នុងកាលជូជកកំពុងផាដៃវាយ កុមារទាំងពីរតែងឲ្យខ្នងរងជំនួសគ្នានឹងគ្នា ។ ដល់ទៅទីមិនស្មើមួយ ព្រាហ្មណ៍ផ្ទាតជើងរអិលដួល ។ ចំណងវល្លិក្នុងដៃដ៏ទន់ល្មើយរបស់ព្រះកុមារទាំងពីរ ក៏រអិលរបូតចេញ ។ ពួកគេស្រែកយំរត់តម្រង់មកកាន់សម្នាក់របស់ព្រះមហាសត្ត ។ កុមារនោះមាននេត្រាទាំងពីរដ៏ពោរពេញដោយទឹកភ្នែក ងើបមើលព្រះបិតា ។ កុមារក៏ញាប់ញ័រចំប្រប់ដូចជាស្លឹកពោធិ៍ ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះបិតា លុះថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះបិតា បានពោលពាក្យនេះថា ៖

"បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រព្រះបិតា ចាំយើងខ្ញុំជួបនឹងព្រះមាតាសិនសឹមព្រះអង្គប្រទានយើងខ្ញុំ ។ បពិត្រព្រះបិតា ព្រះ

មាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រព្រះបិតា ព្រះអង្គកុំអាលប្រទានយើងខ្ញុំឡើយ រង់ចាំព្រះមាតារបស់យើងខ្ញុំ ត្រឡប់មកសិន ។ ក្នុងពេលនោះ ព្រាហ្មណ៍នេះ ចង់លក់ឬចង់សម្លាប់ក៏តាមប្រាថ្នាចុះ ដូជកព្រាហ្មណ៍នេះមានជើងត្រប៉ាត ក្រចកស្អុយ មួយទៀត មានដុំសាច់យូរយារបបូរមាត់ខាងលើវែង មានទឹកមាត់ហៀរចេញ ធ្មេញស្ញេញដូចខ្នាយជ្រូក ច្រមុះបាក់ ។ មានពោះធំកំប៉ោង ខ្នងកោង ភ្នែកស្រលៀង ពុកមាត់ពុកចង្កាក្រហម សក់លឿង ស្បែកជ្រួញជ្រីវទុះដោយអាចម៍រុយ ។ មានភ្នែកលៀនក្ងោតដូចភ្នែកឆ្មា ចង្កេះខ្នង ក វៀច សន្ទាក់ឆ្អឹងលាន់ឮប្រស ៗ ធំដំបង ឈ្មានពាន ទុកជាស្បៀក ដណ្តប់ស្បែកខ្លា ក៏ដូចជាអមនុស្ស គួរស្ញើម ។ បពិត្រព្រះបិតា ព្រាហ្មណ៍នេះ ជាមនុស្សឬជាយក្ស ជាអ្នកស៊ីសាច់និងឈាមចេញអំពីស្រុកមកកាន់ព្រៃ សូមទ្រព្យគឺកូននឹងព្រះបិតាទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ព្រះបិតាទតឃើញឬទេ ព្រះហឫទ័យ របស់ព្រះបិតា ធួន់ដូចថ្ម ឬដូចជាចំណងដែកដ៏មាំ ព្រះអង្គមិនជ្រាបយើងខ្ញុំ ដែលព្រាហ្មណ៍ជា

អ្នកស្វែងរកទ្រព្យល្មោភហួសប្រមាណចាប់ចងហើយវាយយើងខ្ញុំ ដូចជាគេវាយគោ ។ នាងកណ្ហាជិនាចូរនៅក្នុងទីនេះចុះ ដ្បិតនាងមិនទាន់ដឹងក្តីនៅឡើយ រមែងកន្ទក់កន្ទេញដូចជាកូន ម្រឹគនៅបៅដោះហើយព្រាត់ប្រាសចាកហ្វូង” ។

កាលបើព្រះកុមារពោលយ៉ាងនេះហើយ ព្រះមហាសត្តមិនតបតអ្វីមួយម៉ាត់សោះ ។ គ្រានោះ ព្រះកុមារខ្សឹកខ្សួលប្រារព្ធទៅនឹងព្រះមាតាបិតាដូច្នេះថា ៖

“ទុក្ខដូច្នោះនេះមិនមែន ជាទុក្ខដល់អញទេ ព្រោះទុក្ខនេះ បុរសដែលរង្គាត់ទៅក្នុងភព ត្រូវបានអញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះ ជាសេចក្តីទុក្ខក្រៃលែងរបស់អញ ជាងសេចក្តី ទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ទុក្ខដូច្នោះនេះមិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះបុរស ត្រូវបានមិនឃើញព្រះបិតាណា ការមិនឃើញព្រះបិតានោះ ជាសេចក្តីទុក្ខក្រៃលែងរបស់អញ ជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ព្រះមាតានោះ ជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនាល្អគួរមើលមុខ ជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រា ដោយពិត

កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនាល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះមាតានោះ ជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនាល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះបិតានោះជាមនុស្ស កំព្រាដោយពិត កាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនាល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះមាតានោះ ជាមនុស្សកំព្រាពិត រលឹកពួកយើងក្នុងពាក់កណ្តាលអធ្រាត ឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចស្ទឹង ។ ព្រះបិតានោះ ជាមនុស្សកំព្រាពិត រលឹកពួកយើងក្នុងពាក់កណ្តាល អធ្រាតឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចស្ទឹង ។ រុក្ខជាតិផ្សេង ៗទាំងនេះ គឺដើមព្រីង ឈើទាលខ្យាប់ មានមែកត្រសុំត្រសាយ ថ្ងៃនេះ យើងនឹងបោះ បង់ពួករុក្ខជាតិទាំងនោះចោលហើយ ។ ពួលផលជាតិផ្សេង ៗ ទាំងនេះគឺពោធិ៍ ខ្នុរ ជ្រៃក្រសាំង ថ្ងៃនេះ យើងនឹងបោះបង់ពួកផលជាតិទាំងនោះចោលហើយ ។ នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើម យើង

លេងក្នុងទីណា ថ្ងៃនេះ យើងនឹងបោះបង់ទីទាំងនោះ ។ ពីដើម ពួកយើងទ្រទ្រង់ផ្កាណាច្រើនយ៉ាង លើភ្នំនេះ ថ្ងៃនេះ យើងនឹងបោះបង់ផ្កាទាំងនោះ ។ ពីដើម ពួកយើងបរិភោគផ្លែឈើណាច្រើនយ៉ាងលើភ្នំនេះថ្ងៃនេះ យើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ពីដើមយើងលេងដោយរូបណា ថ្ងៃនេះ យើងនឹងបោះបង់រូបទាំងនោះ" ។

កាលជាលីកុមារ កំពុងតែខ្សឹកខ្សួលជាមួយនឹងប្អូនស្រីយ៉ាងនេះ ជូជកតាមមកទាន់ វាយសំពងចាប់បណ្ដើរទៅទៀត ។ កុមារទាំងនោះកាលជូជកព្រាហ្មណ៍កំពុងនាំទៅ បានពោលនឹងព្រះបិតាដូច្នេះថា ៖

បពិត្រព្រះបិតា សូមព្រះអង្គប្រាប់នូវភាពរបស់យើងខ្ញុំ ជាបុគ្គលមិនមានរោគដល់ព្រះមាតាផង ទាំងព្រះអង្គសោត ក៏សូមឲ្យបានសេចក្ដីសុខ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ សូមព្រះអង្គប្រទានរូបទាំងនោះដល់ព្រះមាតា ព្រះមាតានឹងបន្ទោបង់សំណោក ព្រោះរូបទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ ព្រះមាតាកាលបើក្រឡេកឃើញរូបទាំងនោះហើយ នឹងបន្ទោបង់សំណោកចេញបាន ។

## ព្រះវេស្សន្តរញ៉រខ្លួនដូចព្រះចន្ទក្នុងមាត់រាហូ

គ្រានោះ សេចក្ដីសោករបស់ពោធិសត្វ កើតឡើងយ៉ាងខ្លាំង ប្រារព្ធទៅនឹងកូន ។ សាច់បេះដូង មានអាការក្ដៅ ។ ព្រះអង្គញ៉័រខ្លួន ចំប្រប់ ពុំអាចទប់លំនឹងខ្លួនបាន ប្រៀបដូចដំរីចុះប្រេងត្រូវកេសរសីហៈ ចាប់ និងប្រៀបដូចព្រះចន្ទចូលក្នុងមាត់ព្រះរាហូ ទ្រង់យាងចូលកាន់ បណ្ណសាលា ទាំងមានព្រះនេត្រាពោរពេញដោយអស្សុធារា ខ្សឹកខ្សួល ម្នាក់ឯងយ៉ាងអាណោចអាធ័ម ។ ព្រះមហាសត្តទ្រង់ពិលាបថា ៖

ក្នុងថ្ងៃនេះ ទារកទាំងពីរ មានសេចក្ដីស្រេកឃ្លាន ហើយយំទារ នរណា អ្នកណាហ្ន៎ នឹងឲ្យភោជនដល់ទារកទាំងពីរនោះ ក្នុង កាលជាទីអង្គាសអាហារ ក្នុងវេលាល្ងាច ។ ក្នុងថ្ងៃនេះ ទារកទាំង ពីរ មានសេចក្ដីស្រេកឃ្លាន ហើយយំទារនរណា បពិត្រព្រះមាតា យើងខ្ញុំមានសេចក្ដីស្រេកឃ្លាន សូមព្រះមាតាប្រទានភោជន ដល់យើងខ្ញុំ ក្នុងកាលជាទីអង្គាសអាហារ ក្នុងវេលាល្ងាច ។ ទារក ទាំងពីរដើរទៅដោយជើងទទេ មិនមានស្បែកជើង នឿយហត់ មានជើងទាំងពីរដ៏ពុរពង ទៅកាន់ផ្លូវ ដូចម្ដេចបាន អ្នកណានឹង ដឹកដៃទារកទាំងនោះទៅ ។ កោតតែព្រាហ្មណ៍នោះ ហ៊ានវាយ

កូនទាំងពីររបស់អញ ជាអ្នកមិនមានកំហុស ក្នុងទីចំពោះមុខ មិន
អៀនខ្មាស ព្រាហ្មណ៍នេះហៅពេញជាមនុស្សឥតអៀនខ្មាស ។
អ្នកណាមានសេចក្ដីអៀនខ្មាស នឹងវាយពួកជនសូម្បីជាខ្ញុំស្រីខ្ញុំ
ប្រុស ឬជាអ្នកបម្រើដទៃរបស់អញ ដែលលះឲ្យហើយនោះ ។
ព្រាហ្មណ៍ហ៊ានជេរ ហ៊ានវាយដំកូនសម្លាញ់របស់អញដែល
កំពុងមើលឃើញ ដូចជាត្រីដែលជាប់នៅក្នុងមាត់លប" ។

**ព្រះវេស្សន្តរចិះតែប្រហារជីវិតតាជូជក**

ដោយសេចក្ដីស្នេហាទៅលើកុមារទាំងពីររបស់ព្រះអង្គ បរិវិតក្កៈ
បានកើតឡើងយ៉ាងនេះថា ៖

"ព្រាហ្មណ៍នេះ វាយកូនអញខ្លាំងម្ល៉េះ ! អញមិនអាចទ្រាំនូវ
សំណោកបានទេ អញនឹងដេញតាមព្រាហ្មណ៍ ប្រហារជីវិតគេ
ឲ្យក្ស័យ នាំកុមារទាំងនោះមកវិញឲ្យបាន" ។

រំពេចនោះ ព្រះអង្គទ្រង់ព្រះចិន្ដាថា ៖

"មិនសមហេតុផលទាល់តែសោះ ត្រង់ដែលអញដាក់ទានហើយ
ក្ដៅក្រហាយក្រោយ ដ្បិតយល់ដល់ការបៀតបៀន កុមារជាទុក្ខ
នេះមិនមែនជាធម៌របស់សប្បុរសទេ ។ អញនឹងកាន់យកធ្នូ ស្ពាយ
ប្រឡាន់លើស្មាខាងឆ្វេង ហើយនាំកូនទាំងពីររបស់ខ្លួនមកវិញឬ

ព្រោះថាការដែលគេវាយដំកូនទាំងពីរ នាំមកនូវសេចក្តីទុក្ខ ។ កុមារទាំងពីរ គប្បីលំបាកដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីតាំងមានសភាពជាទុក្ខទេ នរណាយល់ប្រពៃណីធម៌របស់ពួកសប្បុរសគឺ ពោធិសត្វអំពីបុរាណ ហើយឲ្យទានរួចក្តៅក្រហាយរឿយ ៗ" ។

បានឮមកថា ព្រះបាទវេស្សន្តរ រលឹកឃើញទាន់នូវប្រពៃណី របស់ព្រះពោធិសត្វទាំងឡាយ ក្នុងខណៈនោះ ។ គ្រានោះព្រះអង្គមានព្រះចិន្តាថា ៖

"តាំងពីបុរាណកាលមក គ្រប់ ៗព្រះពោធិសត្វ ពុំធ្លាប់មានត្រាស់ដឹងជាព្រះពុទ្ធ ដោយមិនដែលធ្លាប់ធ្វើនូវមហាបរិច្ចាគ ៥ ប្រការ គឺ ធនបរិច្ចាគ ១ អង្គបរិច្ចាគ ១ បុត្តបរិច្ចាគ ១ ភរិយាបរិច្ចាគ ១ ជីវិតបរិច្ចាគ ១ ឡើយ ។ ចុះចំណែកអញវិញ ជាមនុស្សមួយរូបក្នុងចំណោមនៃព្រះពោធិសត្វទាំងនោះដែរ កាលបើមិនដាក់ទានកូនប្រុសស្រី ដ៏ជាទីស្រឡាញ់ទេ ក៏មិនអាចត្រាស់ជាព្រះពុទ្ធបានដែរ ។ នៃវេស្សន្តរ អ្នកមិនដឹងទុក្ខភាព របស់កូនទាំងឡាយដែលឲ្យធ្វើជាខ្ញុំបម្រើរបស់អ្នក ដទៃទេឬអី រឿងដែលថាឲ្យទានហើយ

ក្តៅក្រហាយក្រោយ នឹកដល់ទៅដេញព្រាហ្មណ៍ប្រហារជីវិតគេ
ឲ្យក្ស័យនុ៎ះ មិនសមគួរដល់អ្នកទាល់តែសោះ ការនឹកគិតអ៊ីចឹង
គួរបើដែរទេ ។

ព្រះអង្គបានជេរខ្លួនយ៉ាងនេះ ហើយទ្រង់អធិដ្ឋាន នូវសមាទានយ៉ាង
មាំថា ៖

"តាំងពីឲ្យទានហើយ អ្វី ៗ កុំមានដល់អញឡើយ បើទុកណាជា
ព្រាហ្មណ៍នុ៎ះសម្លាប់កុមារទាំងពីរក៏ដោយចុះ" ។

ព្រះអង្គយាងចេញអំពីបណ្ណសាលាប្រថាប់គង់លើផែន ថ្មក្បែរទ្វារ
បណ្ណសាលា ប្រៀបដូចរូបបដិមាមាស ។ រីឯជូជកវាយសំពងបណ្តើរ
កុមារទាំងពីរទៅ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះពោធិសត្វ ។ គ្រានោះ
ព្រះកុមារពោលពិលាបដូច្នេះថា ៖

"បានឮថាជនពួកខ្លះក្នុងលោកនេះ បានពោលពាក្យពិតយ៉ាង
នេះថា បុគ្គលណា មិនមានមាតាបង្កើត បុគ្គលនោះ ឈ្មោះថា
មិនមានបិតា ដូចគ្នាដែរ ។ នែនាងកណ្ហាប្អូន នាងចូរមក យើង
មុខជានឹងស្លាប់ យើងមិនមានសេចក្តីត្រូវការដោយជីវិតទេ
ដោយយើងត្រូវព្រះជនិន្ទប្រទាន ដល់ព្រាហ្មណ៍អ្នកស្វែងរក
ទ្រព្យ ជាមនុស្សកំណាចលើសលន់ វាយដំ យើងដូចជាគេវាយ

ហ្វូងគោ ។ នៃនាងកណ្ហា ពួករុក្ខជាតិផ្សេង ៗ នេះ គឺ ដើមព្រីង ឈើទាលខ្សាច់ មានមែកត្រសុំត្រសាយ យើងនឹងបោះបង់ រុក្ខ-ជាតិទាំងនោះ នៃនាងកណ្ហា ពួលផលជាតិផ្សេង ៗ នេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង យើងនឹងបោះបង់ផលជាតិទាំងនោះ ។ ហៃនាង កណ្ហា នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេង ក្នុងទីណា យើងនឹងបោះបង់ទីទាំងនោះ ហៃនាងកណ្ហា ពីដើម យើងទ្រទ្រង់ផ្កាទាំងឡាយណាផ្សេង ៗ លើក្បាលនេះ យើងនឹងបោះ បង់ផ្កាទាំងនោះ ។ ហៃនាងកណ្ហា ពីដើមយើងបរិភោគផ្លែឈើ ផ្សេង ៗ ទាំងឡាយណា យើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ ហៃនាងកណ្ហា នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់ យើង ជារូបដែលយើងធ្លាប់លេង យើងនឹងបោះបង់រូបនោះ" ។

## នាងគ្រីស្នាម្ចួងសួងទេវតា

ព្រាហ្មណ៍ជូជក ដើរផ្ទាតដើងកន្ទែងជង្ហុកមួយ រអិលដួលមួយ សាទៀត ។ ចំណងវល្លិរបូតអំពីដៃរបស់កុមារទាំងពីរ ។ ពួកគេញ័រ ខ្លួនចំប្រប់ដូចមាន់គេអារក នាំគ្នារត់មកកាន់សម្នាក់ព្រះបិតាដោយ

សន្ទុះយ៉ាងលឿន ។ ជូជក ប្រវេប្រវាក្រោក ដៃកាន់វល្លិនិងឈើច្រត់ ក្នុងចិត្តខឹងធ្លួលដូចភ្លើងប្រល័យកប្ប មកស្រែកគំហកថា ៖

"យីអើ ! ពួកអាក្មេង ពូកែខាងរត់ខ្លាំងម៉្លេះ"

រួចគាត់ចងដៃ យកខ្សែនិងឈើច្រត់វាយដំកុមារទាំងពីរ នាំទៅក្នុងទីចំពោះព្រះភក្ត្រនៃព្រះវេស្សន្តរ ។ កាលពួកព្រះកុមារ កំពុងត្រូវជូជកនាំទៅយ៉ាងនេះ នាងកណ្ហាជិនាងាកមើលមកក្រោយ និយាយនឹងព្រះបិតាថា ៖

បពិត្រព្រះបិតា ព្រាហ្មណ៍នេះ វាយដំខ្ញុំម្ចាស់ដោយឈើច្រត់ដូចជាទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា នេះមិនមែនជាព្រាហ្មណ៍ទេ ដ្បិតពួកព្រាហ្មណ៍ ជាអ្នកប្រកបដោយធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍នាំយើងខ្ញុំទៅស៊ីទេដឹង បពិត្រព្រះបិតា យើងខ្ញុំ ត្រូវបិសាចកំពុងនាំទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ" ។

កាលដែលក្មេងស្រី ដើរទៅទាំងពិលាបញ័រខ្លួនចំប្រប់ សេចក្តីសោកដ៏មានកម្លាំងរបស់ព្រះមហាសត្ត បានកើតឡើង បេះដូងក្តៅខ្លោចផ្សា ។ នាកាលប្រមុះមិនគ្រប់គ្រាន់ក្នុងការដកដង្ហើមទ្រង់ដកដង្ហើមចេញចូលដ៏ក្តៅពីក្នុងទ្រូង តាមមាត់ ។ ទឹកជលនេត្រ ក្លាយជាតំណក់ឈាមហូរ

ចេញអំពីព្រះនេត្រទាំងគូ ។ ព្រះអង្គបានបន្ទោបង់នូវសេចក្ដីសោក
បែបនោះ ដោយកម្លាំងញាណថា ៖

"ទុក្ខមានសភាពបែបនេះកើតឡើង ព្រោះទោសគឺសេចក្ដីស្រឡាញ់
មិនមែនព្រោះហេតុដទៃទេ ។ ត្រូវតែអញតម្កល់ខ្លួនជាកណ្ដាល
មិនធ្វើសេចក្ដីស្រឡាញ់ឡើយ" ។

កាលកុមារិកាដើរទៅមិនទាន់ដល់ទ្វារព្រៃ នាងបានពិលាបបណ្ដើរថា ៖

"ជើងទាំងឡាយ របស់យើងខ្ញុំនេះ ក៏សែនលំបាក ផ្លូវសោតក៏
ឆ្ងាយដាច់ស្រយាល លំបាកនឹងដើរទៅណាស់ ព្រះសុរិយាក៏កាន់
តែទន់ទាប ជិតអស្ដង្គតណាស់ហើយ ព្រាហ្មណ៍ក៏នាំយើងខ្ញុំទៅ
ប្រញាប់ប្រញាល់ ។ យើងខ្ញុំសូមថ្វាយបង្គំនូវពួកភូតដែលនៅ
អាស្រ័យលើភ្នំនិងព្រៃ សូមថ្វាយបង្គំដោយសិរសា នូវពួកទេវតា
ដែលរក្សាស្រះ និងទេវតាដែលនៅអាស្រ័យក្នុងស្ទឹងមានកំពង់ដ៏
ល្អ ។ យើងខ្ញុំសូមថ្វាយបង្គំ នូវពួកទេវតាដែលនៅអាស្រ័យលើ
ស្មៅ, វល្លិ, ឈើឱសថ, ភ្នំ និងព្រៃ សូមពពួកទេវតាទាំងឡាយ
ទូលព្រះមាតាយើងផងថា យើងខ្ញុំជាអ្នកមិនមានរោគទេ ដ្បិត
ព្រាហ្មណ៍នេះកំពុងនាំយកយើងខ្ញុំទៅ ។ សូមពួកលោកដ៏ចម្រើន
ទូលដល់ព្រះមទ្រីជាព្រះមាតារបស់យើងខ្ញុំថា បើលោកចង់

អញ្ជើញមកតាមយើងខ្ញុំ គប្បីអញ្ជើញមកឲ្យឆាប់ ។ ផ្លូវនេះ ដើរបានតែមនុស្សមួយនាក់ ត្រង់ទៅកាន់អាស្រម ព្រះមាតាគប្បីស្តេចអញ្ជើញមកតាមផ្លូវនោះឯង មុខជានឹងឃើញយើងខ្ញុំភ្លាម ។ បពិត្រព្រះមាតាដ៏មានជដាអើយ ទុក្ខនោះនឹងមានដល់លោកដែលនាំមើមឈើ និងផ្លែឈើអំពីព្រៃមក ព្រោះឃើញអាស្រមស្ងាត់ជ្រងំ ។ ព្រះមាតាបានមើមឈើនិងផ្លែឈើអំពីព្រៃនិងចំណីច្រើន ដោយការស្វែងរកហួសវេលា មិនជ្រាបយើងខ្ញុំដែលព្រាហ្មណ៍អ្នកស្វែងរកទ្រព្យ កំណាចលើសលន់ ចងវាយដំយើងខ្ញុំដូចជាគេវាយហ្វូងគោ ថ្ងៃនេះយើខ្ញុំសូមជួបនឹងព្រះមាតាដែលអញ្ជើញមកអំពីការស្វែងរកផ្លែឈើ ក្នុងវេលាល្ងាច ។ ព្រះមាតាគប្បីប្រទានផ្លែឈើលាយដោយទឹកឃ្មុំដល់ព្រាហ្មណ៍ ព្រាហ្មណ៍នេះបានបរិភោគផ្លែឈើនោះឆ្អែតហើយ មុខជាមិនបង្ខំនាំយើងខ្ញុំទៅទេ ។ កុមារទាំងពីរ មានសេចក្តីជាប់ចិត្តខ្លាំង ក្នុងព្រះមាតាពិលាប ក្នុងកាលនោះយ៉ាងនេះថា ឱហ្ន៎ បាតជើងទាំងឡាយរបស់យើង ពុរពងអស់ហើយ ព្រាហ្មណ៍ ដឹកនាំយើងទៅប្រញាប់ប្រញាល់ខ្លាំងណាស់” ។

ទារកបព្វវណ្ណនា ចប់ ។

# ជំពូកទី ៩
## មទ្ទីបព្វណ្ណនា
### ទេវតាប្រជុំការពារព្រះនាងមទ្រី

ការដែលកូនជាទីស្រឡាញ់ ត្រូវព្រះបាទវេស្សន្តរប្រទានដល់ព្រាហ្មណ៍ បណ្ដាលប្រឹថពីឲ្យកក្រើកនេះ ជាហេតុនាំឲ្យទេវតាទាំងឡាយ ដែលរស់នៅក្នុងព្រៃហិមពាន្ត ស្មើរតែបែកទ្រូង ពួកគេបានឮសេចក្ដីពិលាបនោះ របស់កុមារទាំងពីរដែលកំពុងត្រូវព្រាហ្មណ៍ នាំបណ្ដើរទៅដូច្នោះហើយ ក៏បានប្រឹក្សាគ្នាថា ៖

"ប្រសិនបើព្រះនាងមទ្រីមកអាស្រមទាន់ពេលដូចសព្វដង ហើយមិនឃើញកូនតូចក្នុងអាស្រមនោះទេ មុខតែព្រះនាងសួរព្រះបាទវេស្សន្តរ កាលបើដឹងថាព្រះវេស្សន្តរប្រទានឲ្យព្រាហ្មណ៍ ប្រាកដជាព្រះនាងរត់តាមស្នាមជើងកូន ដោយអំណាចសេចក្ដីស្រឡាញ់ដ៏ខ្លាំងខ្លា ហើយនឹងរងទុក្ខដ៏មហន្តពុំខាន" ។

គ្រានោះ ទេវតាទាំងឡាយក្នុងទីជំនុំ បានចាត់បង្គាប់ទេវបុត្រ ៣ រូប មួយអង្គឲ្យប្លែងភេទជាសត្វតោ មួយឲ្យប្លែងជាខ្លាធំ មួយឲ្យប្លែងជាខ្លាដំបង នៅខាងខាំងផ្លូវមកនៃព្រះទេវី ទោះបីត្រូវព្រះនាងអង្វរយ៉ាង

ណាក៏ដោយ កុំឲ្យផ្លូវឲ្យសោះ ដរាបដល់ការអស្ដង្គតនៃព្រះសុរិយា និងឲ្យធ្វើការរក្សាការពារយ៉ាងយកចិត្តទុកដាក់ដ៏ល្អ ដើម្បីកុំឲ្យសត្វតោព្រៃ ជាដើមបៀតបៀនចំពោះព្រះនាង ក្នុងវេលាដែលទ្រង់យាងទៅអាស្រមវិញ តាមពន្លឺព្រះចន្ទវេលាយប់ ។ ប្រសិនបើសីហៈក្ដី ខ្លាធំក្ដី ខ្លាដំបងក្ដី បៀតបៀននាងមទ្រីដែលប្រកបដោយលក្ខណានោះ តើជាលិកុមារនិងនាងកណ្ហាជិនា នឹងរស់នៅដូចម្ដេចបាន នាងមទ្រីដែលប្រកបដោយលក្ខណា នឹងព្រាត់ប្រាសចាកចំណែកទាំងពីរ គឺកស្ដានិងបុត្រទាំងពីរ ។

## ព្រះនាងមទ្រីអង្វរសត្វទាំង ៣

គ្រានោះ ទេវបុត្រទាំង ៣ រូបនោះ ទទួលសេចក្ដីបង្គាប់របស់ពួកទេវតាទាំងនោះ ហើយពួកគេបានប្លែងភេទជាតោ ខ្លាធំនិងខ្លាដំបងមកដេកតាមលំដាប់កាត់ទទឹងផ្លូវមក របស់ព្រះនាងមទ្រី ។ ចំណែកព្រះនាងមទ្រី ញ័រខ្លួនចំប្រប់ថា "ថ្ងៃនេះ អញយល់សុបិនអាក្រក់ អញនឹងយកមើមនិងផលាផលទៅអាស្រមឲ្យទាន់ពេលដូចសព្វដង"គិតហើយព្រះនាង រំពៃមើលមើមឈើនិងផ្លែឈើតូចធំ ។ គ្រានោះ ជ្រនីកធ្លាក់ពីដៃ សង្រែកធ្លាក់ពីស្មា ភ្នែកស្ដាំញាក់កក្រើក ឈើទ្រទ្រង់ផ្លែ ដូចជាមិនមានផ្លែ ឈើដែលឥតផ្លែ ប្រាកដដូចជាទ្រទ្រង់ផ្លែទៅវិញ ទិសទាំង ១០

ក៏មិនប្រាកដ ។ ព្រះនាងមានព្រះតម្រិះថា "ហេតុអ្វីទៅហ្ន៎ ថ្ងៃនេះអញ ខុសប្លែកពីសព្វដង តើនឹងមានរឿងអ្វី ឬមួយអន្តរាយនឹងមានដល់អញ ឬដល់កូនទាំងពីររបស់អញ ឬថាដល់ព្រះវេស្សន្តរស្វាមីអញ ?" ហើយព្រះនាងពោលថា ៖

"ជ្រនីកធ្លាក់ចុះអំពីដៃរបស់អញ ភ្នែកស្ដាំក៏កម្រើក ទាំងដើម
ឈើមានផ្លែ ក៏ប្រែជាមិនមានផ្លែ អញវង្វេងទិសទាំងអស់" ។

ព្រះនាងមទ្រីនោះ បានដើរចៀសទៅទាំងមានសេចក្ដីខ្សឹកខ្សួល យ៉ាងនេះថា ៖

"កាលដែលអញមកកាន់អាស្រមក្នុងវេលាល្ងាច នាពេលដែល
ព្រះអាទិត្យអស្ដង្គត ក៏មានពួកម្រឹគសាហាវមកឈរពាំងផ្លូវ ។
ព្រះអាទិត្យទៀបអស្ដង្គត អាស្រមក៏នៅឆ្ងាយណាស់ អញនឹងនាំ
យកមើមឈើនិងផ្លែឈើ អំពីទីនេះទៅដើម្បីកូននិងស្វាមីអញ
បរិភោគជាភោជន ។ ក្សត្រិយ៍ជាស្វាមី គង់នៅតែមួយអង្គឯងក្នុង
បណ្ណសាលា ម៉្លេះសមព្រះអង្គខំលួងលោមកុមារទាំងពីរដែល
មានសេចក្ដីស្រេកឃ្លាន នៅពេលមិនទាន់ឃើញអញទៅដល់ ។
កូនតូចទាំងពីររបស់អញ កំព្រាកម្សត់ណាស់ ម៉្លេះសមពួកគេ

កំពុងអង្គុយចាំមើលផ្លូវអញ ទន្ទឹងចាំបរិភោគផ្លៃឈើវេលាល្ងាច បីដូចកូនម្រឹគនៅបៅទឹកដោះ ។ ម្ល៉េះសមកូនតូចទាំងពីរ របស់អញ កំព្រាកម្សត់នៅអង្គុយចាំមើលផ្លូវអញ រង់ចាំផឹកទឹកក្នុងវេលាល្ងាច ដូចកូនម្រឹគប្រាថ្នារកទឹកផឹក ។ ម្ល៉េះសមកូនតូចទាំងពីររបស់អញ កំព្រាកម្សត់ នាំគ្នាឈរចាំទទួលអញ ដូចជាកូនគោតូចឈរចាំទទួលមេ ។ ម្ល៉េះសមកូនតូចទាំងពីររបស់អញជាស្ត្រីកំព្រាកម្សត់ នាំគ្នាឈរចាំទទួលអញ ដូចជាហ្វូងហង្សឈរនៅលើភក់ ។ ម្ល៉េះសមកូនតូចទាំងពីររបស់អញ ជាស្ត្រីកំព្រាកម្សត់ នាំគ្នាឈរចាំទទួលអញ ក្នុងទីមិនឆ្ងាយអំពីអាស្រម ។ ផ្លូវតែមួយដើរបានតែបុគ្គលម្នាក់ ក្បែរខាងផ្លូវ មានស្រះ មានជ្រោះ អញមិនឃើញផ្លូវដទៃ សម្រាប់ទៅកាន់អាស្រមបានទេ ។ បពិត្រម្រឹគទាំងឡាយ ខ្ញុំសូមថ្វាយបង្គំលោកទាំងឡាយ ជាស្តេចមានកម្លាំងច្រើនក្នុងព្រៃធំ សូមលោកជាបងប្អូននឹងគ្នាដោយធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយ ក៏សូមឲ្យផ្លូវដល់ខ្ញុំ ។ ខ្ញុំជាភរិយារបស់ព្រះរាជបុត្រដ៏មានសិរី ដែលគេនិរទេស ខ្ញុំមិនហ៊ានមើលងាយព្រះរាជស្វាមីនោះ ដូចនាងសិតាជាស្ត្រីមានវ័ត មិនហ៊ានមើលងាយព្រះរាម ។ លោកទាំងឡាយ ចូរឃើញបុត្រទាំង

ឡាយចុះ ចំណែកខ្ញុំសូមឃើញស្វាមីនិងបុត្រទាំងពីរ គឺជាលីនិង
កណ្ហាជិនាក្នុងពេលល្ងាច គឺកាលជាទីទទួលចំណី ។ មើមឈើ
និងផ្លែឈើនេះសោត ក៏ច្រើន ចំណីនេះមិនមែនតិចទេ ខ្ញុំនឹងបែង
ចំណីនោះពាក់កណ្ដាលជូនលោកទាំងឡាយ កាលបើខ្ញុំអង្វរ
សូមឲ្យផ្លូវខ្ញុំ ។ ព្រះមាតារបស់យើង ជាព្រះរាជបុត្រី ព្រះបិតា
របស់យើង ជាព្រះរាជបុត្រា លោកទាំងឡាយចូរជាបងប្អូនដោយ
ធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរ សូមឲ្យផ្លូវខ្ញុំ ។ លោកទាំង
ឡាយ មេត្តាឲ្យផ្លូវខ្ញុំ ថ្ងៃនេះជាពេលទទួលទានអាហារល្ងាច
ហើយ ពួកលោកចូរឃើញកូន រីឯខ្ញុំគប្បីឃើញកូន ៗ របស់ខ្ញុំដែរ
ចូរឲ្យផ្លូវខ្ញុំមក" ។

គ្រានោះ ទេវបុត្រទាំង ៣ នោះ បានស្ដាប់វាចាពីរោះពិសា ជា
វាចាគ្រប់ដោយសេចក្ដីករុណាច្រើន របស់នាងមទ្រីដែលកំពុងលួង
លោម ហើយពួកគេក្រឡេកមើលវេលា ដឹងថា "ថ្ងៃនេះ ជាវេលាល្មម
នឹងឲ្យផ្លូវដល់ព្រះនាងមទ្រី" រួចក៏នាំគ្នាក្រោកថយចេញពីផ្លូវបាត់ទៅ ។

**ព្រះនាងមទ្រីពិលាប**

កាលបើម្រឹគសាហាវចៀសបាត់ហើយ ព្រះនាងមទ្រីនោះដើរទៅកាន់អាស្រម ។ គាប់ចួនពេលនោះ ចំថ្ងៃឧបោសថពេញបូណ៌មី ។ ព្រះនាងយាងដល់ទីចុងចង្រ្កម ចោលដួងព្រះនេត្រារំពៃមើលទីនេះទីនោះ ក្រែងបានឃើញកូនដូចសព្វដង ប៉ុន្តែពុំបានប្រទះភ្នែកនឹងកូនក្នុងទីនោះ ៗ សោះឡើយ ព្រះនាងមានព្រះសវនីយ៍ថា ៖

"កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងទីកន្លែងនេះ ដូចជាពួកកូនគោឈរចាំទទួលមេ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងទីកន្លែងនេះ ដូចជាពួកហង្សឈរនៅលើភក់ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងទីកន្លែងនេះក្នុងទីជិតអាស្រម ។ កូនតូចទាំងនោះ ធ្លាប់តែស្ទុះមកព័ទ្ធជុំវិញមានសេចក្តីត្រេកអររីករាយ នាំគ្នាលោតមកហាក់ដូចជាញ៉ាំងហឫទ័យរបស់មាតាឲ្យកម្រើក ដូចកូនម្រឹគទាំងឡាយឃើញមេហើយដំឡើងស្លឹកត្រចៀក អើតកចូលទៅជិតមេ រីករាយត្រេកអរស្ទុះទៅព័ទ្ធជុំវិញ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ អញលះបង់កូនទាំងពីរ ហើយចេញ

ទៅ ដូចមេពពែឬមេម្រឹគលះបង់កូន ដូចមេបក្សីចេញអំពីសម្បុក ឬដូចមេសីហៈប្រាថ្នាសាច់ លះបង់កូនរបស់ខ្លួនដើរចេញទៅរកចំណី ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ នេះស្នាមជើងនៃកូនទាំងពីរ ដូចស្នាមជើងនៃហ្វូងដំរីក្បែរភ្នំ ពំនូកខ្សាច់ដែលកូនទាំងពីរនាំគ្នាពូន ក៏ខ្ចាត់ខ្ចាយក្នុងទីជិតនៃអាស្រម ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនតូចទាំងពីរ ពេយពាយដោយខ្សាច់ប្រឡាក់ដោយអាចម៍ដី រមែងស្ទុះមកព័ទ្ធជុំវិញ អញមិនបានឃើញកូនទាំងពីរនោះ ។ កាលពីដើម កូនទាំងពីរណាទទួលអញដែលមកអំពីព្រៃឆ្ងាយ ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរនោះ គឺជាលីនិងនាងកណ្ហាជិនា ។ កូនទាំងពីរ តែងតែរមិលមើលផ្លូវអញ ក្នុងទីឆ្ងាយ ដូចកូនម្រឹគទទួលមេពពែ ឬម្រឹគជាមេ ។ ផ្លែល្ពៅលឿងខ្ចី ដែលជ្រុះមកនេះឯង ជាល្បែងរបស់កូនទាំងពីរនោះ ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ សុដនរបស់អញទាំងពីរនេះ ពេញដោយទឹកដោះ ទាំងទ្រូងសោតក៏ស្ទើរតែនឹងធ្លាយ អញមិនបានឃើញ

កូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនមួយ រាវរកផ្លែឈើក្នុងថ្នក់របស់អញ កូនមួយតោងដោះទាំងគូរបស់អញ ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ វេលាថ្ងៃល្ងាច កូនតូចទាំងពីរ ប្រឡាក់ដោយអាចម៍ដីននៀលលើភ្លៅរបស់អញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើម អាស្រមនេះ ប្រាកដដល់អញ ដូចជាកន្ទៃងមហោស្រព ថ្ងៃនេះ អាស្រមហាក់ដូចវិលដល់អញ ដែលមិនបានឃើញកូនទាំងនោះ ។ ហេតុដូចម្តេច បានជាអាស្រមនេះ ហាក់ដូចជាស្ងាត់សូន្យឈឹងប្រាកដដល់អញ សូម្បីពួកក្អែកព្រៃក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញ ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេចបានជាអាស្រមនេះ ហាក់ដូចជាស្ងាត់សូន្យឈឹង ប្រាកដដល់អញ សូម្បីពួកសត្វហើរ ក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញប្រាកដជាស្លាប់ហើយ" ។

ព្រះនាងមទ្រី ពិលាបយ៉ាងនេះដើរទៅកាន់សម្នាក់ របស់ព្រះមហាសត្ត ដាក់កញ្ច្រែងផ្លែឈើចុះ ឃើញព្រះមហាសត្តគង់ស្ងៀមឥតស្តី ក្សត្រីផាកសម្ទឹងមើលទៅទីក្បែរ ៗ ព្រះអង្គ ពុំឃើញកូនតូចសោះ ព្រះនាងមានព្រះសវនីយ៍ថា ៖

"ហេតុដូចម្តេច បានជាព្រះអង្គគង់ស្ងៀម ? ចិត្តរបស់ខ្ញុំម្ចាស់ ហាក់ដូចយល់សប្តិក្នុងរាត្រី សូម្បីពួកក្អែកព្រៃ ក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេច បានជាព្រះអង្គគង់ស្ងៀម ? ចិត្តរបស់ខ្ញុំម្ចាស់ ហាក់ដូចយល់សប្តិក្នុងរាត្រី សូម្បីពួកសត្វហើរក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះអយ្យបុត្រ ពួកម្រឹគស៊ីទារកទាំងពីររបស់ខ្ញុំម្ចាស់ហើយទេដឹង ឬនរណានាំយកទារករបស់ខ្ញុំម្ចាស់ ឬនរណានាំយកទារករបស់ខ្ញុំម្ចាស់ទៅ ក្នុងព្រៃដ៏ស្ងាត់ឥតជាតិដៅ ។ ព្រះអង្គធ្វើទារកទាំងនោះឲ្យជាទូតហើយប្រើទៅឬ ឬក៏ទារកទាំងនោះ ជាអ្នកពោលពាក្យពីរោះដេកលក់អស់ហើយ ឬទារកទាំងនោះខ្វល់ខ្វាយ ក្នុងល្បែងទាំងឡាយហើយនាំគ្នាចេញទៅខាងក្រៅ ។ សក់ទាំងឡាយក្តី ដៃជើងទាំងឡាយក្តី ដ៏វិចិត្រដោយបណ្តាញរបស់ទារកទាំងនោះ ក៏មិនឃើញសោះ ក្រែងពួកបក្សីធាបនាំយកទៅទេដឹង ឬនរណានាំយកទារករបស់ខ្ញុំម្ចាស់ទៅ ?" ។

**ព្រះវេស្សន្តរធ្វើលេសមិនឆ្លើយ**

កាលព្រះនាងមានព្រះសវនីយ៍យ៉ាងនេះ ព្រះមហាសត្តស្ដេចពុំត្រាស់អ្វីមួយព្រះឱស្ឋសោះ ។ គ្រានោះ ព្រះនាងក្រាបទូលព្រះបាទវេស្សន្តរថា ៖

"បពិត្រព្រះសម្មតិទេព ព្រោះហេតុអ្វីព្រះអង្គមិននិយាយជាមួយនឹងខ្ញុំម្ចាស់ តើកំហុសរបស់ខ្ញុំម្ចាស់ដូចម្ដេច ?"

រួចព្រះនាងបន្តពោលដូច្នេះថា ៖

"ការដែលព្រះអង្គមិនមានព្រះបន្ទូលនេះ ជាទុក្ខផ្ទួនលើសេចក្ដីទុក្ខរបស់ខ្ញុំម្ចាស់ ដែលមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ប្រៀបដូចជាដំបៅដែលឈឺហើយត្រូវមុតដោយព្រួញថែមទៀត ។ នេះជាព្រួញទីពីរ គឺត្រង់ដែលខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីរ ១ ដែលព្រះអង្គមិនត្រាស់ប្រាប់ខ្ញុំម្ចាស់ ១ នាំឲ្យកម្រើកហឫទ័យរបស់ខ្ញុំម្ចាស់ ។ បពិត្រព្រះរាជបុត្រ បើព្រះអង្គមិនត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់ អស់រាត្រីនេះ ក្នុងថ្ងៃនេះទេ ព្រះអង្គមុខជានឹងឃើញខ្ញុំម្ចាស់អស់ជីវិតស្លាប់ក្នុងពេលព្រឹកមិនខាន" ។

គ្រានោះ ព្រះមហាសត្តគិតថា "អញនឹងញុំាងនាងឲ្យលះបង់សេចក្តីស្តាយកូន ដោយសម្តីគ្រោតគ្រាត" រួចព្រះអង្គ មានព្រះបន្ទូលគំរាមបញ្ឆោតដូច្នេះថា ៖

"ក្រែងនាងមទ្រីមានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយសនោះឬអី ? នាងទៅស្វែងរកផ្លែឈើតូចធំ តាំងពីពេលព្រឹក ហេតុដូចម្តេច បានជាដល់ពេលល្ងាចហើយ ទើបមក ? ។ នែនាងមទ្រីនាងជានារីមានរូបឆោម ល្អល្អះ ធម្មតាពួកថ្មើរព្រៃ តាបស វិជ្ជាធរជាដើម ដែលត្រាច់ដើរក្នុងព្រៃហិមពាន្ត មានចំនួនច្រើន ។ តើនរណាដឹងថាអ្វីនឹងកើតឡើង ? នាងបានធ្វើដូចម្តេច ? នាងទៅព្រៃពីព្រលឹម មកល្ងាចថ្មើរនេះធ្វើអ្វី ? ។ ស្ត្រីទុកចោលកូនតូចដើរហើរតាមព្រៃបែបនេះ មិនមែនជាស្ត្រីមានប្តីទេ ។ នាងមិនចាំបាច់មានពាក្យថាកូនខ្ញុំយ៉ាងម៉េច ? ប្តីរបស់ខ្ញុំគិតដូចម្តេច ? ទេ ។ នាងទៅព្រៃពីព្រលឹមហើយ មកវិញតាមពន្លឺព្រះចន្ទ នេះពិតជាកំហុសនៃទុគ្គតភាពរបស់ខ្ញុំមែនទែន" ។

ព្រះនាងមទ្រីនោះ ស្តាប់សម្តីរបស់ព្រះមហាសត្តហើយ បានក្រាបបង្គំទូលតបថា ៖

"ក្រែងព្រះអង្គទ្រង់ព្រះសណ្ដាប់សំឡេងទ្រហឹងអឺងកង នៃសីហៈ និងខ្លា ដែលស្រែកបន្ទឺឡើង ព្រមទាំងម្រឹគដទៃមានដំរីជាដើម ដែលមកកាន់ស្រះនេះ ដើម្បីផឹកទឹកដែរឬទេ ? ។ បុព្វនិមិត្តបាន កើតឡើងដល់ខ្ញុំម្ចាស់ ដែលដើររង្គាត់ក្នុងព្រៃធំ ជ្រនីកក៏ធ្លាក់អំពី ដៃរបស់ខ្ញុំម្ចាស់ ទាំងកញ្ច្រែងដែលលីលើចង្កេះស្មា ក៏ធ្លាក់អំពី ស្មា ? ។ ក្នុងពេលនោះ ខ្ញុំម្ចាស់មានសេចក្ដីភិតភ័យក្រៃពេក ក៏ប្រណម្យអញ្ជលីនមស្ការគ្រប់ទិសផ្សេង ៗ សូមឲ្យសួស្ដីគប្បី កើតមាន ព្រោះការនមស្ការនេះ ។ សូមកុំឲ្យសីហៈនិងខ្លាដំបង បៀតបៀនព្រះរាជបុត្ររបស់យើងបាន មួយទៀត សូមកុំឲ្យខ្លាឃ្មុំ ឆ្កែព្រៃ និងខ្លារខិនចាប់ខាំស៊ីទារកទាំងពីរបាន ។ ពួកពាលម្រឹគ ទាំង ៣ ក្នុងព្រៃ គឺសីហៈ ១ ខ្លាធំ ១ ខ្លាដំបង ១ រាំងផ្លូវខ្ញុំម្ចាស់ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់មក ក្នុងវេលាល្ងាច" ។

## ព្រះនាងមទ្រីរករកបុត្រ

ព្រះមហាសត្វ បាននិយាយពាក្យត្រឹមប៉ុណ្ណោះជាមួយនឹងព្រះនាងមទ្រី ហើយក៏លែងតបតអ្វីទៀត រហូតដល់ការរះឡើងនៃអរុណ ។ រីឯព្រះ នាងមទ្រីក៏ពោលពិលាបដោយប្រការផ្សេង ៗ

តាំងពីពេលនោះឯងថាៈ

"ខ្ញុំម្ចាស់មានសក់កណ្តាញ់ ប្រព្រឹត្តធម៌ដ៏ប្រសើរ ស្រវាស្រទេញ ផ្គត់ផ្គង់ប្តីផង បុត្រទាំងពីរផង អស់ថ្ងៃនិងយប់ ដូចជាមាណពផ្គត់ផ្គង់អាចារ្យ ។ ហៃបុត្រកម្សត់ទាំងពីរ មាតាស្ទៀកដណ្តប់ស្បែកខ្លា ខំស្វែងរកមើមឈើនិងផ្លែឈើក្នុងព្រៃ ទាំងថ្ងៃទាំងយប់ ព្រោះតែសេចក្តីស្រឡាញ់កូនឯងទាំងពីរ ។ រមៀតមានពណ៌ដូចជាមាសនិងផ្លែញ្ញោរនេះ មាតាបាននាំមកដល់ហើយ មាតាបាននាំទាំងផ្លែឈើទាំងឡាយឯទៀតផង ហៃបុត្រកម្សត់ទាំងពីរ ផ្លែឈើទាំងនេះ ជាល្បែងរបស់កូនឯងទាំងពីរ ។ មើមឈូក ក្រអៅឈូកឧប្បល ក្រចាប់នេះ បពិត្រក្សត្រិយ៍ សូមព្រះអង្គព្រមទាំងបុត្រទាំងពីរសោយវត្ថុទាំងនោះដែលលាយដោយទឹកឃ្មុំចុះ ។ បពិត្រព្រះបាទសិវិ សូមព្រះអង្គប្រទានផ្កាឈូកដល់ជាលី សូមព្រះអង្គប្រទានផ្កាកុមុទដល់នាងកុមារី សូមទតកុមារទាំងពីរដែលប្រដាប់ដោយកម្រងផ្កាហើយរាំ សូមព្រះអង្គត្រាស់ហៅបុត្រទាំងពីរមក។ បពិត្រព្រះអង្គជាធំក្នុងរថ បណ្តាបុត្រទាំងពីរនោះ បុត្រី ឈ្មោះកណ្ហាជិនា រមែងទៅ សូមព្រះអង្គទ្រង់ព្រះសណ្តាប់សំឡេងរបស់វាដែលពីរោះ គួរចាប់ចិត្តពាក្យពីរោះ ចូលទៅកាន់អាស្រម ។

បពិត្រព្រះបាទសិវិ យើងទាំងពីរនាក់ ត្រូវគេនិរទេសចាកដែន ហើយ ជាអ្នករួមសុខរួមទុក្ខជាមួយគ្នា ព្រះអង្គឃើញបុត្រទាំងពីរ គឺជាលីនិងនាងកណ្ហាជិនាដែរឬ ។ ខ្ញុំម្ចាស់បានជេរ ប្រទេចពួក ស្រមណ៍និងព្រាហ្មណ៍ ក្នុងលោក មានព្រហ្មចរិយធម៌ ប្រព្រឹត្ត ទៅខាងមុខមានសីល ជាពហុស្សូតដោយពិត បានជាខ្ញុំម្ចាស់ មិនឃើញបុត្រទាំងពីរ គឺជាលីនិងកណ្ហាជិនានោះ ក្នុងថ្ងៃនេះ" ។

ព្រះមហាសត្តពុំមានព្រះឱស្ឋមួយម៉ាត់ ជាមួយនឹងព្រះនាងមទ្រី ឡើយ បើទុកណាជាព្រះនាងទួញពិលាបយ៉ាងនេះក៏ដោយ ។ កាលបើ ព្រះស្វាមី ពុំមានព្រះឱស្ឋ ព្រះនាងមទ្រីសែនញ័រទ្រូងចំប្រប់ រត់រក មើលកូនតាមពន្លឺព្រះចន្ទ្រាដ៏ត្រចះត្រចង់ ដល់ទីដែលកុមារធ្លាប់លេង សព្វដង មានកន្ទែងដើមព្រីងជាដើម ព្រះនាងក៏ខ្សឹកខ្សួលថា ៖

"នេះរុក្ខជាតិផ្សេង ៗ គឺព្រីង ឈើទាលខ្សាប់ មានមែកត្រសុំ ត្រសាយ កុមារទាំងនោះ អញមិនបានឃើញ ។ នេះផលជាតិ ផ្សេង ៗ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង កុមារទាំងនោះអញមិនបាន ឃើញ ។ នេះ សួនច្បារទាំងឡាយ នេះស្ទឹងមានទឹកត្រជាក់ ជាទី ដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ ផ្កាឈើច្រើនយ៉ាងលើ ភ្នំនេះ ជាផ្កាដែលកុមារទាំងពីរធ្លាប់ទ្រ

ទ្រង់ កុមារទាំងនោះ អញមិនបានឃើញ ។ ផ្លែឈើច្រើនយ៉ាងលើ
ភ្នំនេះ ជាផ្លែដែលកុមារទាំងពីរធ្លាប់បរិភោគ កុមារទាំងនោះ អញ
មិនបានឃើញសោះ ។ រូបដំរី រូបសេះ ទាំងនេះក្តី រូបគោទាំងនេះ
ក្តី ជារូបដែលកុមារទាំងពីរធ្លាប់លេងកុមារទាំងនោះអញមិនបាន
ឃើញ" ។

គ្រានោះ ទាំងម្រឹគទាំងបក្សី ផ្អើលរត់ទាំងយប់ ដោយសារតែសូរសព្ទ
ខ្សឹកខ្សួលរបស់ព្រះនាងផង ស្នូរជើងរត់របស់ព្រះនាងផង ។ ព្រះនាង
ឃើញម្រឹគនិងបក្សីទាំងនោះហើយ បានពោលថា ៖

"រូបម្រឹគមានសម្បុរពព្រុស រូបទន្សាយរូបមៀម រូបម្រឹគឈ្លូស
ជាច្រើនទាំងនេះ ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំង
នោះ អញមិនបានឃើញ ។ រូបហង្ស រូបក្រៀល រូបក្ងោក មាន
ស្លាបដ៏វិចិត្រ ជារូបដែលកុមារទាំងពីរធ្លាប់លេងកុមារទាំងនោះ
អញមិនបានឃើញ"។

ព្រះនាងមទ្រីនោះ កាលមិនឃើញកូនជាទីស្រឡាញ់ក្នុងអាស្រម ក៏
ចេញទៅ ហើយចូលក្នុងព្រៃដង្គុំផ្កា រកមើលគ្រប់ច្រកល្ហកពោលថា៖

"គុម្ពឈើទាំងនេះ មានផ្ការីកសព្វកាល ជាផ្កាដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះ អញមិនបានឃើញ ។ ស្រះបោក្ខរណីទាំងនេះ គួរជាទីត្រេកអរ ទ្រហឹងអឹងកង ដោយសត្វចាក្រពាកដេរដាស ដោយផ្កាមណ្ឌាលកៈផង ដោយផ្កាឈូកនិងផ្កាឧប្បលផង ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ" ។

កាលរកក្នុងទីកន្លែងណាហើយ មិនឃើញកូនជាទីស្រឡាញ់ ព្រះនាងក៏វិលមកកាន់សម្នាក់ របស់ព្រះមហាសត្ត្វវិញ ឃើញព្រះអង្គអង្គុយមានទឹកមុខស្រពោន ក៏ក្រាបទូលថា ៖

"ឧសទាំងឡាយព្រះអង្គមិនកាច់ទឹកព្រះអង្គមិនដង ភ្លើងព្រះអង្គមិនបង្កាត់ ហេតុអ្វីបានជាព្រះអង្គសញ្ឈប់សញ្ជឹងដូចមនុស្សខ្លៅ? ព្រះវេស្សន្តរជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ សេចក្តីព្រួយតែងរសាយព្រោះបានជួបជុំដោយព្រះអង្គជាទីស្រឡាញ់ ក្នុងថ្ងៃនេះ ខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ" ។

កាលបើព្រះនាងពោលយ៉ាងនេះហើយ ព្រះមហាសត្ត្វនៅតែអង្គុយស្ងៀមឥតស្តីអ្វីសោះ ។ កាលបើស្វាមីមិនពោល ព្រះនាងមទ្រីតឹងទ្រូងដោយសំណោក ញាប់ញ័រខ្លួនប្រាណដូចមាន់គេអារក រត់រក

មើលតាមច្រកល្អកដែលរត់ពីមុនមួយសាទៀត មិនឃើញ ក៏វិលមក វិញកាន់សម្នាក់របស់ព្រះមហាសត្វ ពោលដូច្នេះថា ៖

"បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្ររបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជាអ្នកណា នាំយកបុត្រទាំងនោះទៅទេ ទាំងពួកក្អែកព្រៃសោត ក៏មិនកញ្ជ្រៀវឡើយ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្ររបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជាអ្នកណា នាំយកបុត្រទាំងពីរទៅ ទាំងពួកសត្វស្លាបសោត ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ" ។

## ព្រះនាងមទ្រីសន្លប់ទៀបបាទមូលព្រះវេស្សន្តរ

ទោះបីព្រះនាងមានព្រះសវនីយ៍យ៉ាងនេះក៏ដោយ ព្រះមហាសត្វនៅតែមិនឆ្លើយតបអ្វីមួយព្រះឱស្ឋ[៦៣]ឡើយ ។ ព្រះនាងមទ្រីត្រូវសេចក្តីសោកស្តាយកូន ដំខ្ទេចខ្ទាំក្នុងឱរា ក្អែករំពៃមើលកូនខាងនេះខាងនោះស្ទុះរត់តាមកម្លាំងខ្យល់ ទៅទីនេះផងទីនោះផង ជាលើកទី៣ ។ កន្លែង

[៦៣] រឹមបបូរមាត់, បបូរមាត់ ។ ខ្មែរប្រើថា មាត់ ប្រើជា រ.ជ. ព្រះឱស្ឋ ។ នួនព្រះឱស្ឋ ក្រមួនមាត់ ។ មួយព្រះឱស្ឋ មួយម៉ាត់ ។ លាន់ព្រះឱស្ឋ លាន់មាត់ ។

ដែលនាងរត់មួយរាត្រី វាស់ទៅបានចម្ងាយ ១៥ យោជន៍ ។ តពីនោះ រាត្រីបែកពន្លឺភ្លឺច្បាស់ អរុណោទ័យ រះឡើង ជះសាចនូវឱភាសមក កាន់ផែនពសុធា[៦៤] ។ ព្រះនាងមទ្រី ទៅឈរយំខ្សឹកខ្សួលម្តងទៀត ក្នុងសម្នាក់របស់ព្រះមហាសត្តថា ៖

"បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីររបស់យើងសោះ ខ្ញុំមិនដឹងជាអ្នកណានាំយកបុត្រទាំងនោះទៅ ទាំងពួកក្អែកព្រៃសោត ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីររបស់យើងសោះ ខ្ញុំមិនដឹងជាអ្នកណានាំយកបុត្រទាំងនោះទៅ ទាំងពួកសត្វស្វាបសោត ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីររបស់យើងសោះ ខ្ញុំមិនដឹងជាអ្នកណានាំយកបុត្រទាំងនោះទៅទេ" ។

ក្រោយពេលនាងមទ្រីត្រាច់ទៅក្រោមម្លប់ឈើ តាមភ្នំ និងតាមគុហាមិនឃើញកូន ក៏វិលមកផ្គងដើមដៃទាំងពីរកន្ទក់កន្ទេញយ៉ាងនេះ ហើយក៏

[៦៤] ផែនដី, ពិភពលោក ។

ដួលទៅលើផែនដីដូចដើមចេកមាសគេកាត់ ទៀបព្រះបាទមូលរបស់ព្រះវេស្សន្តរ ក្នុងទីនោះឯង” ។

## ព្រះវេស្សន្តរពីតទ្រួងព្រះនាងមទ្រី

គ្រានោះ ព្រះមហាសត្តស្មានថាព្រះនាងមទ្រីស្លាប់ ទ្រង់ញាប់ញ័ររន្ធត់ មានសេចក្តីសោកស្តាយដ៏ខ្លាំងក្លាកើតឡើងថា ៖

> "មិនសមទេ មទ្រីស្លាប់ក្នុងទីនេះ បើកាលកិរិយា[៦៥]របស់នាងមាននៅឯជេតុត្តរនគរ ម៉្លេះសមមានបរិវារច្រើន មហាជនគប្បីញុំាងដែនទាំងពីរឲ្យរំជួល ។ បងនៅឯកោម្នាក់ឯងក្នុងព្រៃហើយ បងនឹងធ្វើដូចម្តេចទៅ?"

រួចទ្រង់តាំងសតិស្មារតីឡើង មានព្រះបំណងដឹងនូវជីពចរ[៦៦] ក្រោកទៅស្ទាបទ្រូងរបស់ព្រះនាងមើល ដឹងដំណើរកម្តៅប្រព្រឹត្តទៅនៅឡើយ ទ្រង់យកកំសៀវ ទៅដងទឹក ។ ក្នុងអំឡុងពេល ៧ ខែ ព្រះអង្គពុំធ្លាប់ដល់នូវកាយសំសគ្គៈទេ ប៉ុន្តែថាដោយសេចក្តីសោកស្តាយពេញទំហឹង

---

[៦៥] សេចក្តីស្លាប់, មរណកាល ។

[៦៦] ដង្ហើមនៃសរសៃលោហិតដែលកម្រើកលោត ៗ នៅសព៌ាង្គកាយ (អ្នកខ្លះនិយាយក្លាយថា ចីបចរ, គួរកុំប្រើ) ។

ទ្រង់ភ្ញាក់ហើយ

ទ្រង់ក្មេចអស់ លែងកំណត់ខ្លួនឯងជាបព្វជិតបាន ទ្រង់មានព្រះនេត្រទាំងគូពោរពេញដោយអស្សុធារា លើកសីសៈព្រះនាងមទ្រីដាក់លើឱរូព្រះអង្គ រួចទ្រង់អង្គុយប្រោះទឹកបំព្រំ ស្បេត[៦៧]មុខរីតទ្រូងរបស់ព្រះនាងមទ្រី ។ ចំណែកឯព្រះនាងមទ្រី មួយស្របក់ក្រោយមក ព្រះនាងបានសតិស្មារតីឡើងវិញ តាំងហិរោត្តប្បៈ[៦៨] ក្រោកថ្វាយបង្គំព្រះមហាសត្តហើយសួរថា ៖

"បពិត្រព្រះវេស្សន្តរជាស្វាមី ពួកកូនរបស់ព្រះអង្គទៅឯណា ?"។

ព្រះវេស្សន្តរឆ្លើយថា ៖

"ហៃព្រះទេវី ពួកគេត្រូវបានបងប្រទានឲ្យធ្វើជាខ្ញុំបម្រើ ដល់តាព្រាហ្មណ៍ម្នាក់ទៅហើយ" ។

គ្រានោះ ព្រះនាងមទ្រីមានសវនីយ៍ថា ៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គប្រទានកូនដល់ព្រាហ្មណ៍ហើយម្តេចក៏មិនប្រាប់ ទុកឲ្យខ្ញុំម្ចាស់ខ្សឹកខ្សួលរត់រកពេញមួយរាត្រី" ។

ព្រះមហាសត្ត ពោលថា ៖

[៦៧] ផ្ទិតផ្ទង់, ពិនិត្យពិច័យ យ៉ាងយឺត ៗ ឬ សំរៀម ៗ ។

[៦៨] សេចក្តីខ្មាសអៀន ។

"ហៃអូនមទ្រី បងមិនចង់ប្រាប់សេចក្ដីទុក្ខដល់អូនអំពីដំបូងទេ មានព្រាហ្មណ៍ចាស់កម្សត់ម្នាក់ជាស្ទូម បានមកលំនៅយើង ។ អូនអើយ បងបានឲ្យបុត្រទាំងពីរដល់ព្រាហ្មណ៍នោះ អូនកុំភិតភ័យអ្វី អូនចូរស្រួលចិត្តចុះ ។ ហៃមទ្រីករិយាសម្លាញ់ អូនចូរសម្លឹងមើលមកបង កុំមើលបុត្រទាំងពីរ កុំខ្សឹកខ្សួលខ្លាំងឡើយ កាលបើយើងរស់នៅ បានសុខសប្បាយ ក៏គង់តែបានជួបប្រទះនឹងបុត្រយើងវិញទេ ។ សប្បុរស បានឃើញពួកស្ទូមមកហើយ គប្បីឲ្យកូន សត្វចិញ្ចឹម ធញ្ញជាតិ និងទ្រព្យដទៃដែលមានក្នុងផ្ទះជាទាន ។ សប្បុរសកាលប្រាថ្នានូវប្រយោជន៍ដ៏ឧត្ដម គប្បីពុះទ្រូងរូងយកសាច់បេះដូងឲ្យជាទានផងដែរ ។ ហៃមទ្រីអូន នាងចូររីករាយទៅតាមអំណោយបុត្រដ៏ឧត្ដមរបស់បង" ។

មទ្រីពោលថា ៖

"បពិត្រព្រះទេវៈ ខ្ញុំម្ចាស់សូមរីករាយតាម នូវអំណោយបុត្រដ៏ឧត្ដមរបស់ព្រះអង្គ ព្រះអង្គប្រទានហើយ សូមធ្វើហឫទ័យឲ្យជ្រះថ្លាចុះ សូមព្រះអង្គទ្រង់ឲ្យទានជាតិយ្យោភាពចុះ ។ បពិត្រព្រះជនាធិបៈ កាលដែលពួកមនុស្ស កំពុងមានសេចក្ដីកំណាញ់ ព្រះ

អង្គជាអ្នកញ៉ាំងពួកអ្នកសិរិរាស្ត្រឲ្យចម្រើន ទ្រង់បានដាក់ទាន ដល់ព្រាហ្មណ៍" ។

កាលបើព្រះនាងមទ្រីពោលយ៉ាងនេះ ព្រះមហាសត្តត្រាស់ថា ៖

"ហៃនាងមទ្រី ថីក៏និយាយអ៊ីចឹង បើខ្ញុំឲ្យកូនជាទានហើយមិន ញ៉ាំងចិត្តឲ្យជ្រះថ្លា ម៉្លេះសមអច្ឆរិយៈទាំងឡាយនេះ មិនប្រព្រឹត្ត ទៅទេ"

រួចទ្រង់បានរៀបរាប់សព្វគ្រប់ នូវការរញ្ជួយប្រឹថពីជាដើម ។ គ្រានោះ ព្រះនាងមទ្រីមានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយស បាន រីករាយតាមព្រះរាជអំណោយបុត្រដ៏ឧត្តម របស់ព្រះបាទវេស្សន្តរថា ៖

"ព្រះអង្គបានញ៉ាំងផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គទៅ ដល់ទេវលោក ផ្លេកបន្ទោរពុំជួកាល ដាលប្រវាត់ជុំវិញព្រៃហេម-ពាន្ត ដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ។ ពួកទេវតាទាំងពីរ ក្រុម គឺនារទៈនិងបព្វតៈ ព្រមទាំងព្រះឥន្ទ្រព្រះព្រហ្ម និងបជាបតិ ទេវបុត្រ សោមទេវបុត្រ ព្រះបាទយមៈនិងព្រះបាទវេស្សវ័ណ ក៏នាំគ្នារីករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ដែលកើត ក្នុងឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ក៏រីករាយតាម" ។

កាលព្រះមហាសត្តសរសើរនូវទានទាំងឡាយរបស់ខ្លួនព្រះអង្គ យ៉ាង នេះ ព្រះនាងមទ្រីដែលអង្គុយក្បែរនោះ ក៏រីករាយតាមសរសើរនូវទាន នោះផងដែរថា ៖

"បពិត្រមហារាជវេស្សន្តរទានរបស់ព្រះអង្គបាន ឲ្យល្អប្រពៃ ហើយ" ។

មទ្រីបព្វវណ្ណនា ចប់ ។

# ជំពូកទី ១០
# សក្កបព្វវណ្ណនា

## សក្កទេវរាជប្លែងភេទជាព្រាហ្មណ៍

កាលជនទាំងពីរ កំពុងពោលសម្ដីរីករាយស្រស់ស្រាយចំពោះគ្នាទៅវិញទៅមក យ៉ាងនេះ សក្កទេវរាជគិតថា "ព្រះរាជវេស្សន្តរអង្គនេះ កាលពីម្សិលមិញបានញ៉ាំងប្រឹថពីឲ្យបន្លឺសំឡេងហើយឲ្យទារកទាំងពីរដល់ជូជក ។ ឥឡូវនេះ ខ្លាចក្រែងលោបុរសហីនជាតិណាមួយចូលទៅគាល់ សូមព្រះនាងមទ្រីដែលបរិបណ៌ដោយលក្ខណៈទាំងពួងនឹងព្រះអង្គ ធ្វើឲ្យស្ដេចនៅបែកគ្នា យកព្រះនាងមទ្រីទៅបាត់ សមព្រះរាជាវេស្សន្តរនៅអនាថា ឥតទីពឹងពំនាក់ ។ បើអ៊ីចឹងមានតែអញប្លែង[៦៩] ភេទជាព្រាហ្មណ៍ ចូលទៅគាល់ព្រះអង្គ សូមព្រះនាងមទ្រី ជួយទ្រង់ឲ្យកាន់ខ្ជាប់នូវបារមីកំពូល ហើយអញមិនលះនាងឲ្យដល់អ្នកណាឡើយ នឹងថ្វាយព្រះនាងដល់ព្រះបាទវេស្សន្តរវិញនោះពុំខាន រួចនឹងត្រឡប់មកឋានអញវិញ" ។ លុះដល់វេលារះឡើងនៃអរុណ សក្កទេវរាជបាន

[៦៩] ប្រែ, បែរ, ឃ្លាត ចាកភាពដើមឬចាកភេទដើម ។

មកកាន់សម្នាក់របស់ព្រះបាទវេស្សន្តរ ឈរពីមុខក្សត្រទាំងពីរហើយ សក្កៈបានធ្វើបដិសណ្ឋារៈថា ៖

"ព្រះអង្គសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការស្វែងរកស្រួលទេឬ មើម ឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស និង ពស់ មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនទេឬ"។

ព្រះមហាសត្ត ឆ្លើយតបថា ៖

"ម្នាលព្រាហ្មណ៍ពួកយើងសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មិនមានរោគាពាធអ្វីទេ មួយទៀត យើងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការស្វែងរកស្រួលទេ មើមឈើនិងផ្លែឈើទាំងឡាយ ក៏បរិបូណ៌ដែរទេ ។ ទាំងពួករបោមមូសនិងពស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយ ម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែ រស់នៅទាំងសំណោក ទើបឃើញព្រាហ្មណ៍ជាគម្រប់ពីរនេះ មានភេទដ៏ប្រសើរ កាន់ឈើច្រត់មានពណ៌ដូចជាផ្លែព្នៅទុំ ទ្រទ្រង់ស្បែកខ្លាទាំងក្រចក ។ នៃមហា

ព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀត អ្នកមិនមែនមកអាក្រក់ទេ អញ្ជើញអ្នកចូលទៅខាងក្នុងសេចក្តីចម្រើនចូរមាន ដល់អ្នក អ្នកចូរលាងជើងទាំងឡាយរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើយ៉ាងឆ្ងាញ់ ៗ ដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ទ្រយឹង មាក់ប្រាង មាក់ដោក ។ ទឹកត្រជាក់នេះ ដងមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនេះចុះ បើអ្នកប្រាថ្នាចង់ផឹក" ។

លុះបានធ្វើបដិសណ្ឋារៈ ជាមួយនឹងឥន្ទកព្រាហ្មណ៍យ៉ាងនេះហើយ ព្រះមហាសត្តសួរនូវហេតុនៃដំណើរមកថា ៖

"យើងសូមសួរអ្នក អ្នកបានមកដល់ព្រៃធំ ដោយរឿងដូចម្តេច ឬដោយហេតុដូចម្តេច ? អ្នកកាលបើយើងសួរហើយ ចូរប្រាប់រឿងនោះ" ។

គ្រានោះ សក្កទេវរាជ បានក្រាបទូលព្រះបាទវេស្សន្តរនោះថា ៖

"បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំមានវ័យចំណាស់ហើយ មកនេះ មានគោលបំណងសូមព្រះនាងមទ្រីជាភរិយារបស់ព្រះអង្គ សូមព្រះអង្គប្រទានព្រះនាង ដល់ទូលបង្គំជាខ្ញុំ"

រួចគាត់បានបន្តពោលដូច្នេះ ៖

"ផ្លូវទឹកពេញប្រៀបមិនអស់ទៅសព្វកាល យ៉ាងណាមិញ ទូលបង្គំជាខ្ញុំ មកដើម្បីសូមទានព្រះអង្គ ទូលបង្គំជាខ្ញុំសូមហើយ សូមព្រះអង្គប្រទានភរិយាដល់ខ្ញុំ ក៏យ៉ាងនោះដែរ" ។

## ព្រះវេស្សន្តរប្រទានភរិយាដល់ឥន្ទកព្រាហ្មណ៍

កាលបើឥន្ទព្រាហ្មណ៍ក្រាបទូលយ៉ាងនេះ ព្រះមហាសត្តមិនបាននិយាយថា "ម្សិលមិញ យើងបានប្រទានទារកពីរនាក់ដល់ព្រាហ្មណ៍ តើយើងនឹងប្រទាននាងមទ្រីទៅអ្នក សុខចិត្តរស់នៅម្នាក់ឯង ដូចម្ដេចកើត" ព្រះអង្គទ្រឹងនឹងថាឲ្យក៏ទេ នឹងថាមិនឲ្យក៏ទេ ប៉ុន្តែហឫទ័យមិនរួញរាឡើយ ទ្រង់បានពោលពាក្យនេះញុំាងភ្នំឲ្យលាន់សូរ ដូចហុចថង់ប្រាក់ ១.០០០ កហាបណៈ លើដៃស្ទូមដែលលាថា ៖

"ម្នាលព្រាហ្មណ៍ យើងឲ្យរបស់ដែលអ្នកសូមនឹងយើង យើងមិនរួញរាទេ យើងមិនលាក់លៀមវត្ថុដែលមាន ចិត្តរបស់យើងត្រេកអរក្នុងទាន" ។

លុះពោលយ៉ាងនេះហើយ ព្រះបាទវេស្សន្តរយកទឹកមួយកំសៀវ យ៉ាងលឿន ច្រួចទឹកនោះលើដៃព្រាហ្មណ៍ រួចទ្រង់ប្រទានភរិយាជាទីស្រឡាញ់ ដល់ព្រាហ្មណ៍ ។ រំពេចនោះឯង ហេតុអស្ចារ្យដែលគួរស្ញប់

ស្មែង ក៏កើតមាន ក្នុងកាលនោះ សេចក្តីព្រឺរោម ក៏កើតមាន ក្នុងកាលនោះ ផែនដីក៏ញាប់ញ័រ ។ ព្រះនាងមទ្រី មិនមានមុខក្រញូវ មិនអៀន មិនយំ ព្រះនាងស្ងៀមសម្លឹងព្រះភក្ត្ររបស់ព្រះបាទវេស្សន្តរនោះ ដោយគិតថា ព្រះរាជានេះ ជ្រាបនូវហេតុដ៏ប្រសើរ ។ ព្រះវេស្សន្តរបានឲ្យទានទ្រង់ត្រាស់បណ្តើរថា ៖

"ម្នាលព្រាហ្មណ៍ដ៏ចម្រើន មានតែសព្វញ្ញុតញ្ញាណទេ ដែលជាទីស្រឡាញ់លើសនាងមទ្រីនៃយើង រាប់រយរាប់ពាន់រាប់សែនដង ។ ចូរទានរបស់យើង ជាបច្ច័យនៃការចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ" ។

**កំណត់សម្គាល់**

ពាក្យនេះសមដូចពុទ្ធដីកាដែលត្រាស់ទុកថា ៖

"ជាលឹ កណ្ហាជិនំ ធីតំ, មទ្ទិំ ទេវិំ បតិព្វតំ;
ចជមានោ ន ចិន្តេសិំ, ពោធិយាយេវ ការណា ។

ន មេ ទេស្សា ឧភោ បុត្តា, មទ្ទី ទេវី ន ទេស្សិយា;
សព្វញ្ញុតំ បិយំ មយ្ហំ, តស្មា បិយេ អទាសហំ" ។

"តថាគត កាលដែលលះរាជបុត្រាឈ្មោះជាលី រាជធីតាឈ្មោះកណ្ហាជិនា និងនាងទេវីឈ្មោះមទ្រី ដែលមានវ័តដ៏ល្អក្នុងប្តី មិន

គិតស្ដាយ ព្រោះហេតុតែពោធិញ្ញាណដោយពិត ។ បុត្រទាំងពីរ មិនមែនជាទីស្អប់របស់តថាគតទេ នាងទេវីឈ្មោះមទ្រី មិនមែន មិនជាទីស្រឡាញ់ របស់តថាគតដែរ សព្វញ្ញុតញ្ញាណជាទី ស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យជន ទាំង ៣ នាក់ ជាទីស្រឡាញ់ដល់ព្រាហ្មណ៍" ។

ប្រើចពីបានរញ្ជួយរហូតដល់ទីបំផុតនៃទឹក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងខណៈនោះ ព្រះនាងមទ្រីពុំមានមុខក្រញូវ ខឹងនឹងស្ដេចថាទ្រង់ឲ្យ ព្រះនាងដល់ព្រាហ្មណ៍ចាស់ដូច្នេះឡើយ ព្រះនាងមិនមានមុខខ្នួរ ភ្នែក ពេញលេញ មិនមានទឹកភ្នែករលីងរលោង អង្គុយស្ងៀម សម្លឹងមើល ព្រះភក្ត្ររបស់ព្រះស្វាមីដែលមានពណ៌ដូចផ្កាបទុមកំពុងរីកដោយនឹក ក្នុងព្រះទ័យថា ព្រះស្វាមីឲ្យឥត្ថីរតនៈប្រហែលអញ ច្បាស់ជាមិនឥត ហេតុទេ ទ្រង់ដឹងនូវពរដែលព្រះអង្គឲ្យ។

គ្រានោះ ព្រះមហាសត្តមើលទៅមុខព្រះនាងមទ្រីវិញ ដោយនឹក ថា ដូចម្ដេចដែរ មទ្រី ។ ព្រះនាងមទ្រី មានព្រះសវនីយ៍ថា "បពិត្រព្រះ

ស្វាមី ម្ដេចឡើយក៏ព្រះអង្គមើលខ្ញុំម្ចាស់” រួចនាងបានបន្លឺសីហនាទ[៣០] ថា ៖

“ខ្ញុំម្ចាស់ជាភរិយារបស់ព្រះអង្គអំពីក្មេង ព្រះអង្គជាស្វាមី ជាឥស្សរៈរបស់ខ្ញុំម្ចាស់ស្រាប់ហើយ ចង់ឲ្យខ្ញុំម្ចាស់ដល់អ្នកណា គប្បីឲ្យដល់អ្នកនោះចុះ ត្រូវការទ្រព្យ ព្រះអង្គលក់ខ្ញុំម្ចាស់ចុះ ឬត្រូវការសាច់ ព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ចង់លក់ឬចង់សម្លាប់ក៏បានតាមសេចក្ដីគាប់ចិត្ត ខ្ញុំម្ចាស់មិនក្រោធខឹងទេ” ។

សក្កទេវរាជ ជ្រាបច្បាស់នូវអធ្យាស្រ័យដ៏ប្រណីតរបស់ពួកគេ ទ្រង់បានជញ្ជក់មាត់សរសើរថា ៖

“ពួកសត្រូវទាំងអស់ ដែលឃាត់នូវទិព្វ សម្បត្តិនិងមនុស្សសម្បត្តិ ព្រះអង្គក៏បានឈ្នះហើយ ព្រះអង្គបានញ៉ាំង ផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គ ផ្សាយទៅដល់ទេវលោក ផ្ទេកបន្ទោរក៏ដាលប្រវាត់ជុំវិញ ដូចជាសំឡេងលាន់នៃភ្នំទាំងឡាយៗ ពួកទេវតាទាំងពីរក្រុម គឺនារទៈនិងបព្វតៈ ទាំងព្រះឥន្ទ្រ ព្រះព្រហ្ម និងបជាបតិទេវបុត្រ សោមទេវបុត្រ ព្រះបាទយមៈនិងព្រះបាទវេស្សវ័ណ រីក

[៣០] កម្ចរសូរសព្ទឮខ្លាំង ៗ ឥតញញើត, និយាយក្អេងពេញត្រពងមាត់ ។

វាយតាមព្រះអង្គនោះ ពួកទេវតាទាំអស់ ក៏រីកវាយតាមយ៉ាងនេះ ថា មែនពិត ព្រះបាទវេស្សន្តរនោះ ធ្វើអំពើដែលគេធ្វើបានដោយកម្រ ។ កាលដែលពួកជនកំពុងឲ្យវត្ថុ ដែលគេឲ្យបានដោយកម្រ កំពុងធ្វើអំពើ ដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសរមែងមិនធ្វើតាមអំពើនោះឡើយ ធម៌របស់ពួកសប្បុរស គឺគេដឹងបានដោយក្រ ។ ព្រោះហេតុនោះ ដំណើរទៅអំពីលោកនេះ ទៅកាន់បរលោកនៃពួកសប្បុរស និងពួកអសប្បុរស ជាដំណើរផ្សេងគ្នា ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាមុខ ។ ព្រះអង្គកាលដែលគង់នៅក្នុងព្រៃ បានប្រទានកុមារទាំងពីរ ទាំងបានប្រទានភរិយា ទានទាំង ពីរនោះឈ្មោះជាយានដ៏ប្រសើរ មិននាំចុះទៅកាន់អបាយភូមិទេ យានដ៏ប្រសើរនោះ សូមសម្រេចដល់ព្រះអង្គក្នុងឋានសួគ៌ ។ ម្យ៉ាងទៀត ក្នុងទីបំផុតនៃវិបាកទាននេះ ចូរឲ្យសម្រេចនូវសព្វញ្ញុតញ្ញាណ” ។

កាលបើបានធ្វើអនុមោទនា[៧១] ដល់ព្រះបាទវេស្សន្តរយ៉ាងនេះរួច សក្កៈគិតថា "ឥឡូវនេះ អញឃើតយូរទៀតនៅទីនេះមិនបានឡើយ គួរតែថ្វាយព្រះនាងមទ្រីនេះដល់ព្រះអង្គវិញចុះ ទ្បាលនឹងទៅវិញ" រួចសក្កទេវរាជ ក្រាបទូលថា ៖

"ឥឡូវខ្ញុំសូមថ្វាយនាងមទ្រី ជាស្ត្រីមានសព៌ាង្គដ៏ល្អ ជាភរិយារបស់ព្រះអង្គវិញ ព្រះអង្គសមគួរនឹងនាងមទ្រីដោយពិត នាងមទ្រី ក៏សមគួរនឹងព្រះអង្គ ដែលជាកស្តាដែរ ។ វត្ថុទាំងពីរ គឺទឹកដោះស្រស់១ ស័ង្ខ១ មានសម្បុរស្មើគ្នា យ៉ាងណាមិញ ព្រះអង្គនិងនាងមទ្រីមានព្រះហឫទ័យស្មើគ្នា ក៏យ៉ាងនោះដែរ ។ ព្រះអង្គទាំងពីរ ជាក្សត្រិយ៍ បរិបូណ៌ដោយគោត្រ មានព្រះជាតិល្អ ទាំងខាងមាតានិងខាងបិតា ត្រូវគេនិរទេសមកគង់នៅក្នុងអាស្រមនាព្រៃនេះ ព្រះអង្គគប្បីធ្វើបុណ្យឲ្យទានតាមសមគួរត ៗ ទៅ" ។

[៧១] សេចក្តីត្រេកអរតាម, ការជួយត្រេកអរ, អំណរជាមួយ; វាចាសម្តែងសេចក្តីត្រេកអរតាម : ធ្វើអនុមោទនា ។ ខ្មែរប្រើជាកិ. ផងក៏បាន "ត្រេកអរតាម, ជួយត្រេកអរ, ត្រេកអរជាមួយផង, ទទួលអំណរ" ។

លុះពោលយ៉ាងនេះហើយ សក្កទេវរាជអញ្ជើញព្រះមហាសត្វ ឲ្យទទួលព្រះនាងមទ្រីវិញ រួចព្រះអង្គបង្ហាញតួខ្លួនពិតព្រះអង្គ ដើម្បីប្រទានពរដល់ព្រះបាទវេស្សន្តរ ដូច្នេះថា ៖

"ខ្ញុំជាទេវិន្ទឈ្មោះសក្កៈ បានមកក្នុងសម្នាក់ព្រះអង្គ បពិត្រព្រះរាជា ជាឥសី សូមព្រះអង្គទទួលយកពរចុះ ខ្ញុំសូមថ្វាយពរ ៨ យ៉ាង ចំពោះព្រះអង្គ" ។

កាលព្រាហ្មណ៍កំពុងតែពោល ៗ ស្រាប់តែចេញពន្លឺរុងរឿងអំពីកាយ លេចអត្តភាពជាទិព្វមកភ្លោ ហើយអណ្តែតឋិតនៅលើអាកាស ដូចព្រះអាទិត្យពណ៌ក្រហមរះសន្សឹម ៗ ។ គ្រានោះ ព្រះពោធិសត្វបានស្នើសូមពរអំពីសក្កទេវរាជ ដូច្នេះថា ៖

"បពិត្រសក្កៈ ជាធំជាងទេវតាទាំងពួង បើព្រះអង្គនឹងប្រទានពរដល់ខ្ញុំ ខ្ញុំសូមឲ្យព្រះបិតាស្រុះស្រួលទទួលខ្ញុំដែលទៅអំពីព្រៃនេះដល់ដំណាក់របស់ខ្លួន សូមអញ្ជើញខ្ញុំដោយអាសនៈ(រាជសម្បត្តិ) ខ្ញុំសូមពរទី ១ នេះ ។ ខ្ញុំសូមមិនចូលចិត្តនឹងការសម្លាប់បុរស ខ្ញុំសូមដោះអំពី ការសម្លាប់នូវមនុស្សដែលគេត្រូវសម្លាប់ សូម្បីមនុស្សនោះធ្វើអំពើមោះមៃ មានកំហុសក្នុងព្រះរាជាក៏ដោយ ខ្ញុំ

សូមពរទីពីរនេះ ។ សូមឲ្យពួកបុរសទាំងចាស់ក្មេង ទាំងកណ្ដាល រស់នៅអាស្រ័យនឹងខ្ញុំ ខ្ញុំសូមពរទី ៣ នេះ ។ ខ្ញុំសូមមិន គប់រកប្រពន្ធអ្នកដទៃ ខ្ញុំសូមជាអ្នកខ្វល់ខ្វាយ ចំពោះតែប្រពន្ធ របស់ខ្លួន ខ្ញុំសូមមិនលុះក្នុងអំណាចពួកស្ត្រី ខ្ញុំសូមពរទី ៤ នេះ ។ បពិត្រសក្កៈ បុត្ររបស់ខ្ញុំកើតហើយ សូមឲ្យបុត្រនោះមានអាយុ វែង សូមឲ្យបានត្រួតត្រាផែនដីដោយធម៌ ខ្ញុំសូមពរទី ៥ នេះ ។ តអំពីនោះមក នាកាលរាត្រីកន្លងទៅ ព្រះអាទិត្យរះឡើង សូមចំណីជាទិព្វទាំងឡាយ មានប្រាកដ ខ្ញុំសូមពរទី ៦ នេះ ។ កាលបើខ្ញុំកំពុងឲ្យ សូមទេយ្យធម៌ កុំបីអស់ទៅ លុះខ្ញុំឲ្យហើយ សូមកុំក្ដៅក្រហាយស្ដាយក្រោយ ខ្ញុំកំពុងឲ្យសូមឲ្យចិត្តជ្រះថ្លា ខ្ញុំសូមពរទី៧ នេះ ។ កាលបើខ្ញុំច្យុតចាកអត្តភាពនេះ សូមឲ្យបានទៅកាន់ឋានសួគ៌ ដល់នូវឋានដ៏វិសេស គឺកើតក្នុងតុសិតបុរី កាលបើខ្ញុំច្យុតចាកតុសិតនោះមក សូមកុំឲ្យកើតក្នុងភពថ្មីទៀត មានអត្តភាពជាមនុស្ស គប្បីសម្រេចនូវភាពជាសព្វញ្ញូ ខ្ញុំសូមពរទី ៨ នេះ" ។

ព្រះឥន្ទ្រជាធំជាងទេវតា បានទ្រង់ព្រះសណ្ដាប់នូវព្រះបន្ទូលព្រះបាទវេស្សន្តរនោះហើយ ក៏ពោលពាក្យយ៉ាងនេះថា ៖

"ព្រះមាតាបិតា បង្កើតរបស់ព្រះអង្គ មិនយូរប៉ុន្មានទេ មានព្រះ
បំណងឃើញព្រះអង្គ ហើយនឹងយាងមកជួបព្រះអង្គ ក្នុងទីនេះ
លុះមកហើយ ពួកទ្រង់នឹងថ្វាយស្វេតច្ឆត្រ ប្រគល់រាជសម្បត្តិ
នាំព្រះអង្គទៅកាន់ជេតុត្តរនគរវិញ ពុំខានឡើយ ក្តីប្រាថ្នារបស់
ព្រះអង្គទាំងប៉ុន្មាន ក៏នឹងដល់នូវទីបំផុតដែរ កុំព្រួយអ្វីឡើយ សូម
កុំធ្វេសប្រហែសចុះ មហារាជ" ។

លុះឲ្យឱវាទដល់ព្រះមហាសត្តយ៉ាងនេះហើយ សក្កទេវរាជបាន
ប្រទាននូវពរដល់ព្រះបាទវេស្សន្តរ ហើយក៏ចៀសចេញទៅកាន់ពួក
ទេវតាក្នុងឋានសួគ៌ ។

សក្កបព្វវណ្ណនា ចប់ ។

# ជំពូកទី ១១

# មហារាជបព្វវណ្ណនា

## តាជូជកវង្វេងផ្លូវ

ព្រះពោធិសត្វ និងព្រះនាងមទ្រី រីករាយសប្បាយរស់នៅក្នុងអាស្រមដែលសក្កទេវរាជថ្វាយ ។ ចំណែកឯជូជក យកកុមារទាំងពីរដើរផ្លូវចម្ងាយ ៦០ យោជន៍ ។ ទេវតាទាំងឡាយ តែងជួយធ្វើការរក្សាការពារព្រះកុមារទាំងពីរនោះ ។ តាជូជក នាកាលសូរិយាអស្ដង្គត គាត់ចងកុមារនៅគុម្ពឈើ ឲ្យដេកនៅលើដី ខ្លួនគាត់វិញ ឡើងលើដើមឈើដេកនៅចន្លោះប្រគាបឈើ ពីព្រោះគាត់ខ្លាចម្រឹគកាចសាហាវស៊ី។ ក្នុងខណៈនោះ ទេវបុត្រមួយ ប្លែងភេទជាវេស្សន្តរ ទេពធីតាមួយប្លែងភេទជាព្រះនាងមទ្រី មកស្រាយចំណងកុមារច្របាច់ជើងដៃ ផ្ងូតទឹកឲ្យប្រដាប់ឲ្យ បញ្ចុកភោជនជាទិព្វ រួចឲ្យដេកលើគ្រែទិព្វ កាលអរុណជិតរះ ឲ្យដេកតាមអាការចំណងដែលវិញ រួចពួកគេអន្តរធានបាត់ទៅ ។ ដោយសារសេចក្ដីសង្គ្រោះរបស់ពួកទេវតា យ៉ាងនេះ ទើបបានកុមារទាំងពីរនោះ ធ្វើដំណើរទៅជាមួយដោយឥតមានរោគា ។ តាជូជកត្រូវទេវតាជ្រែក គាត់គិតថានឹងទៅដែនកាលិង្គៈ ដើរទៅ ៗ ក៏ស្រាប់តែដល់ជេតុត្តរនគរ ដោយចំណាយពេលកន្លះខែ ។ គាប់ចួនក្នុងវេលាទៀបភ្លឺ

ថ្ងៃនោះ ស្ដេចសញ្ជ័យមហារាជ បានយល់សុបិន ។ ឯសុបិននោះមាន សភាពបែបនេះគឺ ស្ដេចកំពុងគង់ប្រថាប់ក្នុងទីមហាវិនិច្ឆ័យ មានបុរសម្នាក់សម្បុរខ្មៅ យកផ្កាឈូកពីរដើម ដាក់លើព្រះហស្តរបស់ព្រះមហាក្សត្រ ។ ស្ដេចសៀតផ្កាឈូកទាំងនោះត្រង់ព្រះកាណ៌ទាំងគូ ។ លម្អងផ្កាឈូកទាំងនោះ រអិលធ្លាក់លើទ្រូងព្រះមហាក្សត្រ ។ ព្រះអង្គតើនឡើង ស្ដេចបានសាកសួរព្រាហ្មណ៍ទាំងឡាយ ក្នុងព្រឹកព្រហាម ។ ពួកព្រាហ្មណ៍ហោរា ទាយថា "បពិត្រព្រះសម្មតិទេព មនុស្សដែលព្រះអង្គឲ្យនៅក្រៅស្រុកយូរហើយ នឹងមកដោយមានចំណង" ។ ស្ដេចសញ្ជ័យមហារាជនោះ ងូតសីសៈពីព្រលឹម សោយក្រយាដែលមានរសប្លែកផ្សេង ៗ តុបតែងប្រាណ រួចស្ដេចយាងមកគង់ក្នុងទីវិនិច្ឆ័យ ។ ទេវតាទាំងឡាយ នាំព្រាហ្មណ៍ជាមួយនឹងកុមារទាំងពីរមកឈរនៅក្នុងព្រះលានហ្លួង ។ ក្នុងខណៈនោះ ព្រះរាជាក្រឡេកមើលទៅផ្លូវ ឃើញកុមារទាំងពីរ ទ្រង់ត្រាស់ថា ៖

"មុខអ្នកណានុ៎ះ ភ្លឺដូចមាសដែលគេរំលាយដោយភ្លើង ឬដូចមាសផ្ដោរ ភ្លឺចិញ្ចែងចិញ្ចាចក្នុងមាត់បាវ ។ កុមារទាំងពីរ មានអវយវៈស្រដៀងគ្នាកុមារទាំងពីរមានលក្ខណៈស្រដៀងគ្នា កុមារ

ម្នាក់ ស្រដៀងនឹងជាលី កុមារីម្នាក់ដូចនាងកណ្ហាជិនា ។ កុមារទាំងពីរ បរិបូណ៌ដោយរូបសម្បត្តិ ដូចជាពួកសីហៈដែលចេញអំពីរូងទារកទាំងនេះ ប្រាកដដូចរូបជាវិការៈនៃមាស" ។

ស្ដេចពណ៌នាកុមារទាំងពីរដោយពាក្យទាំងនេះដូច្នេះហើយ ទ្រង់ក៏បង្គាប់អាមាត្យម្នាក់ថា ៖

"អ្នកចូរទៅនាំព្រាហ្មណ៍ព្រមទាំងកុមារពីរនាក់នោះមកមើល" ។ អាមាត្យនោះ ម្នីម្នាទៅយ៉ាងរហ័ស នាំព្រាហ្មណ៍មក ។

គ្រានោះ ព្រះរាជាសួរព្រាហ្មណ៍ថា ៖

"ម្នាលភារទ្វាជៈ អ្នកនាំទារកទាំងពីរនេះមកអំពីទីណាហ្ន៎ ម្នាលព្រាហ្មណ៍ អ្នកមកដល់ដែនក្នុងថ្ងៃនេះ តើអ្នកមកអំពីទីណា" ។

ជូជក ក្រាបទូលថា ៖

"បពិត្រព្រះទេវៈ ទ្រង់ព្រះនាមសញ្ជ័យ ព្រះបាទវេស្សន្តរ ទ្រង់មានព្រះហឫទ័យត្រេកអរ បានប្រទានទារកទាំងនោះ ដល់ទូលព្រះបង្គំជាខ្ញុំ តាំងពីថ្ងៃដែលទូលព្រះបង្គំជាខ្ញុំ បានទារកមក ១៥ រាត្រី ក្នុងថ្ងៃនេះហើយ" ។

ស្ដេចសញ្ជ័យ ត្រាស់ថា ៖

"អ្នកឯងធ្វើយើងឲ្យជឿដោយពាក្យជាទីស្រឡាញ់ តាមហេតុត្រឹមត្រូវដូចម្ដេចបាន នរណាហ៊ានលើកបុត្រទាំងពីរឲ្យជាទានដ៏ឧត្តម ហើយឲ្យដល់អ្នក" ។

ជូជក ក្រាបទូលថា ៖

"ព្រះបាទវេស្សន្តរណា ជាទីពឹងរបស់ពួកស្នូម ដូចជាព្រះធរណី ជាទីពឹងរបស់ពួកសត្វ ព្រះបាទវេស្សន្តរនោះ ទ្រង់គង់នៅក្នុងព្រៃ បានប្រទានបុត្រទាំងពីរដល់ទូលព្រះបង្គំជាខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីប្រព្រឹត្តទៅនៃពួកស្នូម ដូចសាគរជាទីប្រព្រឹត្តទៅ នៃស្ទឹងទាំងឡាយ ព្រះបាទវេស្សន្តរនោះ ទ្រង់គង់នៅក្នុងព្រៃបាន ប្រទានបុត្រទាំងពីរ ដល់ទូលព្រះបង្គំជាខ្ញុំ" ។

ពួកប្រជុំ អាមាត្យទាំងឡាយ បានរិះគន់ព្រះវេស្សន្តរថា ៖

"ម្នាលគ្នាយើង ព្រះរាជាកាលទ្រង់គង់នៅក្នុងព្រះរាជដំណាក់ ទ្រង់មានសទ្ធា ធ្វើអាក្រក់ណាស់ ព្រះបាទវេស្សន្តរត្រូវគេនិរទេស ទៅគង់នៅក្នុងព្រៃហើយ ម្ដេចក៏នៅតែប្រទានបុត្រទាំងពីរទៀត ។ នៃអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងប៉ុន្មាននាក់ដែលបានមកជួបជុំ គ្នាក្នុងទីនេះ ចូរស្ដាប់រឿងនេះចុះ ហេតុដូចម្ដេចបានជាព្រះ

បាទវេស្សន្តរទៅគង់នៅក្នុងព្រៃហើយក៏ប្រទានបុត្រទាំងពីរ។ ព្រះអង្គគួរប្រទានទាសាទាសី សេះ រថ ដែលទឹមដោយសេះអស្សតរផង គួរប្រទានដំរីកុញ្ជរផង ហេតុដូចម្ដេចបានជាដាក់ទានទារកទាំងពីរទៀត" ។

**ស្ដេចសញ្ជ័យលោះព្រះរាជនត្តា**

ឮដូច្នោះ ជាលីកុមារ អត់ទ្រាំចិត្តមិនបាន ចំពោះតំណិះដំណៀលបិតាខ្លួននោះ ក៏ស្រដីតបត ដូចលើកដៃរង់ទប់ភ្នំព្រះសុមេរុ[៧២]ដែលត្រូវខ្យល់វាយបក់មករកខ្លួន ដូច្នេះថា ៖

"បពិត្រព្រះអយ្យកោ ទាសៈ សេះ ឬរថ ដែលទឹមដោយសេះអស្សតរនិងដំរីកុញ្ជរ មិនមានក្នុងផ្ទះនៃបុគ្គលណា បុគ្គលនោះនឹងឲ្យដូចម្ដេចកើត" ។

ព្រះបាទសញ្ជ័យ ត្រាស់ថា ៖

"នៃចៅ យើងសរសើរទានបិតារបស់អ្នក យើងមិនមែនបន្ទុះបង្អាប់ទេ ចុះហឫទ័យនៃបិតារបស់ចៅ តើដូចម្ដេច បានជាឲ្យចៅទាំងពីរដល់ស្នូម" ។

---

៧២ ភ្នំខ្ពស់ជាងភ្នំទាំងអស់ ក្នុងសាកលលោក ដែលជាទីតាំងនៃត្រៃត្រិង្សសួគ៌ អាណាចក្ររបស់ព្រះឥន្ទ្រ ។

ពុទ្ធដូច្នោះ ជាលីកុមារឆ្លើយថា ៖

"បពិត្រមហារាជ ការណ៍ដែលព្រះបិតារបស់ទូលបង្គំជាខ្ញុំ ទ្រង់ប្រទានយើងខ្ញុំដល់ស្នូមនោះ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ នូវវាចាគួរឲ្យអាណោចអាធ័មដែលនាងកណ្ហាជិនាជាប្អូនពោលចុះ។ ហឫទ័យនៃព្រះបិតា របស់ទូលព្រះបង្គំជាខ្ញុំនោះ ជាទុក្ខទាំងទ្រង់មានអស្សាសបស្សាស:[៧៣]ដ៏ក្ដៅ ព្រះបិតាមានព្រះនេត្រក្រហមដូចជាផ្កាយរោហិណី ទ្រង់សម្រក់ទឹកព្រះនេត្រ" ។

និយាយនូវពាក្យនេះហើយ ជាលីកុមារបានរៀបរាប់ពាក្យរបស់នាងកណ្ហាជិនាជាប្អូនដូចតទៅនេះ ៖

"នាងកណ្ហាជិនា បានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតាព្រាហ្មណ៍នេះវាយខ្ញុំម្ចាស់ ដោយឈើច្រត់ ដូចម្ចាស់វាយទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា អ្នកនេះមិនមែនជាព្រាហ្មណ៍

[៧៣] (ន.) (បា.) (អ័ស-សាស័ប-ប័ុស-សាស:) (អស្សាស + បស្សាស; អាគ្វាស + ប្រគ្វាស) ខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល (ខ្យល់ដង្ហើមចេញចូល) : រលត់អស្សាសប្បស្សាស: ។ រ. ស. ព្រះអស្សាសប្បស្សាស: ។ (សរសេរជា អស្សាស:បស្សាស: ក៏បាន ប៉ុន្តែឃ្លាតឃ្លៀងពីវិធីវេយ្យាករណ៍; ព. កា ប្រើជា អស្សាសប្បស្សាស ក៏បាន) ។ ម. ព. អានាបាណ ផង ។

ទេ ព្រោះពួកព្រាហ្មណ៍តែងជាអ្នកប្រព្រឹត្តធម៌ បពិត្រព្រះបិតា
យក្សក្លែងភេទជាព្រាហ្មណ៍ នាំពួកយើងខ្ញុំយកទៅស៊ីទេដឹង ។
បពិត្រព្រះបិតា យើងខ្ញុំកាលបិសាចនាំយកទៅ ហេតុអ្វីក៏ព្រះ
អង្គទ្រង់ទតព្រងើយ" ។

គ្រានោះ ព្រះបាទសញ្ជ័យ ឃើញកុមារទាំងពីរនោះនៅមិនរបេះ អំពី
ព្រាហ្មណ៍ រួចត្រាស់សួរ ៖

"មាតារបស់អ្នកជាព្រះរាជបុត្រី បិតារបស់អ្នកជាព្រះរាជបុត្រា
ក្នុងកាលពីដើមបាទាំងពីរឡើងកាន់ក្អែនរបស់អញ
ចុះហេតុអ្វីបាន ជាបាទាំងពីរបិតនៅក្នុងទីឆ្ងាយ?" ។

ជាលីកុមារ ក្រាបទូលថា ៖

"ព្រះមាតារបស់ពួកទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រី ព្រះបិតា
របស់ពួកទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រា ទូលព្រះបង្គំជាខ្ញុំទាំង
ពីរនាក់ ឥឡូវនេះ កំពុងតែជាទាសារបស់ព្រាហ្មណ៍ ហេតុនោះ
បានជាទូលព្រះបង្គំជាខ្ញុំបិតនៅក្នុងទីឆ្ងាយ" ។

ព្រះបាទសញ្ជ័យ ត្រាស់ថា ៖

"នែចៅសម្លាញ់ទាំងពីរបាទាំងពីរកុំពោលយ៉ាងនេះឡើយ នាំឲ្យ
ក្តៅហឫទ័យរបស់ជីតាណាស់ កាយរបស់ជីតា ហាក់ដូចជាគេ

លើកដាក់លើជើងថ្កល់ ជីតាមិនបានសុខលើអាសនៈទេ ។ នែចៅសម្លាញ់ទាំងពីរ បាទាំងពីរ កុំពោលយ៉ាងនេះឡើយ បាឯងរឹងរឹតតែញុំាងសំណោកឲ្យកើតដល់ជីតា ជីតានឹងលោះដោះសាបាដោយទ្រព្យ មិនឲ្យបានៅជាទាសាគេទេ ។ នែបា បិតារបស់បាបានកាត់ថ្លៃប៉ុន្មានហើយបានឲ្យបាទាំងពីរដល់ព្រាហ្មណ៍ បាចូរប្រាប់ដល់ ជីតាឲ្យត្រង់ពួកអាមាត្យ ចូរញុំាងព្រាហ្មណ៍ឲ្យទទួលទ្រព្យ" ។

ជាលីកុមារ ក្រាបទូលថា ៖

"បពិត្រព្រះអយ្យកោ ព្រះបិតាបានប្រទានទូលព្រះបង្គំជាខ្ញុំដល់ព្រាហ្មណ៍ ដោយកាត់ថ្លៃមួយពាន់និក្ខៈប្រទានកញ្ញាឈ្មោះកណ្ហាជិនា ជាប្អូនស្រី ដោយកាត់ថ្លៃមួយរយនៃវត្ថុគ្រប់មុខ គឺដំរី ១០០, សេះ ១០០ គោឧសភៈ ១០០, មាសស្ពោរ ១០០ រួមទាំងគ្រែ តាំងនិងទ្រនាប់ជើង ជាដើម" ។

ព្រះរាជាបង្គាប់ឲ្យលោះកុមារទាំងពីរនោះដូច្នេះថា ៖

"នែនាយអាមាត្យ អ្នកចូរក្រោកឲ្យឆាប់ ហើយចូរឲ្យទាសី ១០០ ទាសា១០០ គោ ១០០ ដំរី ១០០ គោបា ១០០ សេះ ១០០ និក្ខៈ

១០០ និងមាស ១.០០០ តម្លឹង ដល់ព្រាហ្មណ៍ ឲ្យជាតម្លៃលោះ

យកចៅទាំងពីរ" ។

លំដាប់នោះ ពួកនាយអាមាត្យក៏ប្រញាប់ប្រញាល់ឲ្យនូវទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ សេះ ១០០ និក្ខៈ ១០០ និងមាស ១.០០០ តម្លឹង ដល់ព្រាហ្មណ៍ ជាអ្នកស្វែងរកទ្រព្យ ជាមនុស្ស ឈ្លានពានលើសលន់ ឲ្យជាតម្លៃលោះយកព្រះរាជនត្តាទាំងពីរ ។

**ជាលីស្នើសូមព្រះអយ្យកោ**

ព្រះបាទសញ្ជ័យ បានប្រទានរយនៃវត្ថុគ្រប់មុខ និងមាសធ្ងោរ ១.០០០ តម្លឹងជាតម្លៃលោះយកកុមារទាំងពីរ យ៉ាងនេះហើយ ព្រះអង្គ បានប្រទានប្រាសាទ ៧ ជាន់ ដល់តាព្រាហ្មណ៍ទៀត ។ ព្រាហ្មណ៍ជូជក មានបរិវារជាច្រើនចោមរោមគាត់ ។ គាត់ចាត់ទុកដាក់ទ្រព្យ រួចឡើង លើប្រាសាទ បរិភោគភោជនមានរសឆ្ងាញ់ ហើយដេកលើគ្រែដ៏ធំល្អ ស្រឡះ ។ រីឯព្រះអយ្យកោនិងព្រះអយ្យិកា ផ្ងូតទឹកកុមារ ឲ្យបរិភោគ តុបតែខ្លួនដោយគ្រឿងប្រដាប់ទាំងឡាយ រួចពួកទ្រង់ឲ្យចៅទាំងពីរ នោះអង្គុយលើភ្នែន ។ ព្រះរាជាជាព្រះអយ្យកោ ដាក់ជាលីកុមារលើ ភ្នែនហើយ សាកសួរទារកទាំងពីរ ដែលកក់សីសៈហើយ មានសំពត់ដ៏

ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង មានកុណ្ឌលព្យួរត្រចៀក កង
មានផ្កាកម្រង ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងថា ៖

"នែជាលី មាតានិងបិតារបស់បាទាំង ពីរនោះ សុខសប្បាយទេឬ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែង រកផលាផលស្រួលទេឬ ទាំង មើមឈើនិងផ្លែឈើ មានច្រើនដែរ ឬ ពួករបោម មូសនិងពស់ មានតិចតួចទេឬ ក្នុងព្រៃដ៏កុះករ ដោយម្រឹគយង់ឃ្នង មិនមាន ការបៀតបៀនទេឬ?" ។

ជាលីកុមារ ក្រាបទូលថា ៖

"បពិត្រព្រះទេវៈ មាតាបិតារបស់ទូលព្រះបង្គំជាខ្ញុំទាំងពីរនោះ សុខសប្បាយជាទេ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរកផលា-ផលស្រួលទេ មើមឈើនិងផ្លែឈើមានច្រើន ។ ឯពួករបោម មូស និងពស់មានតិច ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមាន ការបៀត បៀនព្រះអង្គទេ ។ ព្រះមាតានោះ ជីកយកមើមដំឡូង ស្បា ដំឡូងដូង ដំឡូងដៃខ្លា ដំឡូងទៀន ទាំងបាននាំយកផ្លែពុទ្រា ផ្លែពាក់ខ្មៅ ផ្លែព្នៅ មកចិញ្ចឹមយើងខ្ញុំផង ។ បើព្រះមាតា នោះជា ជាអ្នកនាំយកមើមឈើនិងផ្លែឈើក្នុងព្រៃ នាំយកវត្ថុណា មក

ពួកយើងខ្ញុំទាំងអស់គ្នាក៏មកជុំគ្នា បរិភោគវត្ថុនោះតែក្នុងវេលា
យប់ មិនបានបរិភោគក្នុងវេលាថ្ងៃទេ ។ ព្រះមាតារបស់ យើងខ្ញុំ
ជាស្រីធ្លាប់សុខស្រួល ខំនាំយកផ្លៃឈើមក ក៏ទៅជា មានកាយ
ស្គម ស្លេកស្លាំងដោយត្រូវខ្យល់និងកម្តៅថ្ងៃ ដូចជាផ្កាឈូកដែល
គេឈ្លីដោយដៃ ។ ព្រះកេសាទាំងឡាយ របស់ព្រះមាតាក៏ជ្រុះ
ព្រោះត្រាច់ទៅក្នុងព្រៃធំ ជាព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង ជា
ទីដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ។ ព្រះបិតាបួងក្អួង
សក់ទាំងឡាយ ទ្រទ្រង់ញើសក្អែលឰដ៏ក្លៀក ទ្រទ្រង់ភេទនៃ
បព្វជិតដ៏ប្រសើរ ទ្រទ្រង់តម្ពក់ ស្លាបព្រា សម្រាប់បូជា ភ្លើងនិង
ជដា ស្លៀកពាក់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការភ្លើង" ។

កាលពោលអំពីទុក្ខិតភាពរបស់មាតាយ៉ាងនេះហើយ ជាលីកុមារក៏
ពោលពាក្យតឿនព្រះអយ្យកោថា ៖

"បុត្រជាទីស្រឡាញ់ នៃមនុស្សក្នុងលោក ចម្លែកតែសេចក្តីស្នេហា
ក្នុងបុត្រ មិនកើតដល់ព្រះអយ្យកោរបស់យើងខ្ញុំ ដោយពិត" ។

គ្រានោះ ព្រះរាជាពោលបង្ហាញទោសរបស់ខ្លួនព្រះអង្គថា ៖

"នៃចៅ អំពើអាក្រក់របស់យើងបានធ្វើហើយ ទាំងអំពើដែល
បង្ខូចសេចក្តីចម្រើន យើងក៏បានធ្វើហើយ ព្រោះជីតាបាន

និរទោសបុត្រ ឥតកំហុស តាមពាក្យនៃពួកអ្នកសិវិរាស្ត្រ ។ វត្ថុណាទីមួយរបស់យើង មានក្នុងទីនេះ ទាំងទ្រព្យនិងធញ្ញជាតិជីតា ក៏នឹងឲ្យវត្ថុនោះ ដល់បិតារបស់បា សូមវេស្សន្តរចូលមកចូរជាព្រះរាជាត្រួតត្រាក្នុងដែនសិវិវិញចុះ"។

ជាលិកុមារ ក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ព្រះរាជាដ៏ឧត្តមរបស់ពួកអ្នកសិវិរាស្ត្រនឹងមិនយាងមកតាមពាក្យរបស់ទូលព្រះបង្គំទេ សូមព្រះសម្មតិទេព ទ្រង់ស្ដេចយាងទៅដោយព្រះអង្គឯងវិញ ហើយស្រោចស្រពព្រះរាជបុត្របង្កើត ដោយភោគៈទាំងឡាយ" ។

លំដាប់នោះ ព្រះរាជាព្រះនាមសញ្ជ័យ បានត្រាស់នឹងសេនាបតី ថា ៖

"ពួកសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើង ចូរសៀតអាវុធទាំងឡាយ ពួកអ្នកនិគម ព្រាហ្មណ៍ បុរោហិត អាមាត្យ ៦០.០០០ និងពួកទាហានដ៏ល្អមើល ចងគ្រឿងក្រោះ ប្រដាប់ដោយគ្រឿងប្រដាប់ មានបែបផ្សេង ៗ ចូរនាំគ្នាមកឲ្យឆាប់ ជូនអញទៅ ។ ពួកទាហានខ្លះ ស្លៀកពាក់សំពត់ខៀវ ពួកទាហានខ្លះស្លៀកពាក់សំពត់លឿង ពួកទាហានដទៃជួតឈ្នួតក្រហម ពួក

ទាហានខ្លះស្លៀកពាក់សំពត់ស ចងគ្រឿងក្រោះ ប្រដាប់ដោយគ្រឿងប្រដាប់មានបែបផ្សេង ៗ ចូរនាំគ្នាមកឲ្យឆាប់ ។ ភ្នំហិមពាន្តនិងភ្នំគន្ធមាទន៍ ដ៏ទ្រទ្រង់ក្លិន ដ៏ដេរដាសដោយ ពួកឈើផ្សេង ៗ ជាលំនៅនៃពួកភូតដ៏ច្រើន ញ៉ាំងទិសទាំងឡាយឲ្យភ្លឺ ផ្សាយទៅដោយឱសថទាំងឡាយជាទិព្វ យ៉ាងណា ពួកទាហាននាំគ្នា ចងគ្រឿងក្រោះ ចូរមកឲ្យឆាប់ ចូរញ៉ាំងទិសទាំងឡាយ ឲ្យភ្លឺរុងរឿងផ្សាយទៅ យ៉ាងនោះដែរ ។ ពួកអ្នកជិះដំរី ចូររៀបចំដំរី១៤ពាន់ជាសត្វមានសរីរៈធំ មានខ្សែដង្កូន់ជាវិការៈនៃមាស មានសរីរៈស្រោប ដោយគ្រឿងតែងតួ ជាវិការៈនៃមាស ។ ពួកអ្នកបង្ហឹកដំរីមានដៃកាន់ដែកចំពុះទុងនិងកង្វេរ មានគ្រឿងស្អិតស្អាងប្រាកដហើយ ចងគ្រឿង ក្រោះហើយ ចូរនាំគ្នាឡើងជិះកដំរីទាំងឡាយបរមកឲ្យឆាប់ ។ ពួកអ្នកជិះសេះ ចូររៀបចំសេះ ទាំង ១៤ ពាន់ជាជាតិសេះសិន្ធពអាជានេយ្យ មានសន្ទុះដ៏លឿន ។ ពួកអ្នកបង្ហឹកសេះ ទ្រទ្រង់ស៊ែនិងធ្នូ ចងគ្រឿងក្រោះ ប្រដាប់លើខ្នង សេះហើយចូរឡើងជិះបរមកឲ្យឆាប់ ។ លំដាប់ពីនោះមក ពួកអ្នកបររថ ចូររៀបចំរថទាំង ១៤ ពាន់ ជារថមានខ្នងកង់ ពាសដោដែកដ៏ល្អ មានផ្ទះរំលេចដោយមាស ។ ពួកខ្មាន់ធ្នូស្ទាត់ក្នុងការប្រហារ

ពួកជាងរថ ចូរនាំគ្នាលើកទង់ទ័យ ខែលនិងគ្រឿងក្រោះទាំង-
ឡាយ ក្នុងរថទាំងនោះ ចូរដំឡើងធ្នូ ចងគ្រឿងក្រោះ ហើយចូរបរ
រថទាំងឡាយមកឲ្យឆាប់" ។

ព្រះរាជា ចាត់ចែងអង្គសេនាយ៉ាងនេះហើយទ្រង់បានបង្គាប់ទៀតថា ៖

"អ្នកទាំងឡាយ ចូរធ្វើផ្លូវមករបស់បុត្រយើងឲ្យរៀបស្មើទទឹង ៨
ឧសភៈ ពីជេតុត្តរនគររហូតដល់ភ្នំវង្កត ធ្វើនេះផងនោះផងដើម្បី
លម្អផ្លូវ"

រួចស្តេចទ្រង់បង្គាប់ទៀតថា ៖

"អ្នកទាំងឡាយ ចូរតាក់តែងផ្កាទាំងឡាយមានលាជជាគម្រប់៥
និងផ្កាសម្រាប់រោយរាយ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប
ស្រឡាប និងផ្កាដ៏មានតម្លៃទាំងឡាយ ចូរបិតនៅត្រង់ផ្លូវដែល
បុត្ររបស់អញមក ។ គ្រប់ទ្វារស្រុក ចូរតាក់តែងតាំងទុកឱទិន
មេរ័យនិងសុរាច្រើន ត្រង់ផ្លូវដែលបុត្ររបស់អញមក ។ ចូរតាក់
តែងតាំងទុកសាច់ នំទ្រាបល្វ នំកុម្មាសដែលលាយដោយសាច់ត្រី
ត្រង់ផ្លូវដែល បុត្ររបស់អញមក ។ ចូរតាក់តែងតាំងទុកទឹកដោះ
រាវ ប្រេង ទឹកដោះ ជូរ ទឹកដោះស្រស់ និងសុរាដ៏ច្រើន ដែលធ្វើ

ដោយម្សៅថ្ពៅ ត្រង់ផ្លូវ ដែលបុត្ររបស់អញមក ។ ពួកអ្នកធ្វើ ម្ហូប អ្នកធ្វើបាយ អ្នករាំនិង ច្រៀង អ្នកច្រៀងទះដៃ អ្នកវាយស្គរ អ្នកច្រៀងដោយសំឡេងដ៏ស្រទន់ និងពួកអ្នកចាក់ត្មុក ។ ពួកជន ចូរដេញពិណគ្រប់បែប ចូរវាយស្គរ និង មហោរធឹកទាំងឡាយ ចូរផ្លុំស័ង្ខនិងទះស្គរទាំងឡាយ ។ ជនទាំងឡាយ ចូរទះសម្ភោរ វាយស្គរធំ ផ្លុំស័ង្ខ ដេញតាខេ[៧៤] ដេញពិណខ្សែ ៧ វាយ មហោរ ធឹក វាយស្គរទង់ដែង វាយស្គរមង្គល" ។

ព្រះបាទសញ្ជ័យ ទ្រង់បានបង្គាប់ឲ្យគេតុបតែងផ្លូវយ៉ាងនេះ ។ រីឯតាជូជក គាត់បរិភោគហួសប្រមាណ មិនអាចញ៉ាំងអាហារឲ្យរលួយបាន គាត់ក៏បានធ្វើមរណកាល ក្នុងនគរជេតុត្តរនោះឯង ។ ព្រះរាជាទ្រង់ឲ្យគេធ្វើពិធីឈាបនកិច្ចសពគាត់រួច ទ្រង់ឲ្យគេទូងស្គរអំពាវនាវប្រាប់ឲ្យដឹងទូទៅថា "ក្នុងនគរនេះ មាននរណាមួយជាញាតិរបស់ជូជកព្រាហ្មណ៍ឬទេ សូមអញ្ជើញមកយកទ្រព្យនេះចុះ" ។ លុះមិនឃើញញាតិរបស់ព្រាហ្មណ៍ណាមួយហើយ ទ្រព្យទាំងអម្បាលម៉ាន ក៏មកជាព្រះរាជទ្រព្យរបស់ព្រះរាជាវិញ ។ តពីនោះ ដល់ថ្ងៃទី៧ សេនាទាំងពួង

---

[៧៤] (ន.) (ស.) ឈ្មោះគ្រឿងភ្លេងមួយប្រភេទមានខ្សែធ្វើដោយលួស មានស្នូករាងដូចក្រពើ : តាខេមានសូរសព្ទពុក្រោងក្រអៅជាងចាប៉ី (គួរទម្លាប់ហៅ ក្រពើ វិញ) ។

បានមកជួបជុំយ៉ាងកុះករ។ គ្រានោះ ព្រះរាជាចាត់ជាលីជាមគ្គនាយក រួចទ្រង់ចេញដំណើរទៅ ដោយមានបរិវារជាច្រើនហែហមទៅជាមួយផងដែរ ។ សេនាដ៏ច្រើននោះ ជាកងទ័ពក្នុងដែនសិវិ លើកចេញទៅមាន ជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កតបព៌ត ។ ដំរីដ៏ប្រសើរមានអាយុ ៦០ ខួប បន្ទឺកោញ្ចនាទ ដំរីកាលបើមានខ្សែជង្គង់ជាប់ នៅហើយ ក៏បន្ទឺកោញ្ចនាទ ។ សេះអាជានេយ្យទាំងឡាយស្រែកកងរំពង សំឡេងគឹកកងនៃខ្នងកង់ ក៏កើតមានក្នុងកាលនោះ ធូលីក៏ហុយ បាំងដូចពពក កងទ័ពក្នុងដែនសិវិបានលើកចេញទៅ ។ សេនាដ៏ច្រើននោះ អាចនាំយករបស់ដែលគួរនាំយកទៅបាន លើកចេញទៅមានជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កតបព៌ត ។ កងទ័ពទាំងនោះ បានចូលទៅកាន់ព្រៃធំ មានមែកឈើច្រើន មានទឹកច្រើន ដេរដាសដោយឈើមានផ្កា និងឈើមានផ្លែទាំងសងខាងផ្លូវ ។ ពួក សត្វស្លាបដ៏ច្រើនក្នុងព្រៃធំនោះ មានសំឡេងមូល មានសំឡេងពីរោះ មានត្រកូលផ្សេង ៗ ស្រែកហៅសត្វស្លាប ដែលកំពុងស្រែកលើដើម ឈើដែលផ្កាតាមរដូវ។ កងទ័ពទាំងនោះទៅកាន់ផ្លូវឆ្ងាយដាច់

ស្រយាល ក្នុងកាលអំណើះទៅនៃថ្ងៃនិងយប់បានចូលទៅដល់ប្រទេស ដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ។

មហាពជបព្វវណ្ណនា ចប់ ។

# ជំពូកទី ១២
# ឆខត្តិយកម្មវណ្ណនា

## ជំនួបរបស់ក្សត្រិយ៍ ៦ អង្គ

ជាលិកុមារ បានបណ្ដាក់កង់ទ័ពឲ្យបោះបន្ទាយនៅទៀបឆ្នេរស្រះមុចលិន្ទ បំបែររទេះទាំង ១៤.០០០ គ្រឿង ទៅមុខផ្លូវដែលមក ចាត់ចែងការរក្សាការពារសត្វតោខ្លាធំខ្លាដំបង ជាដើម ក្នុងតំបន់នោះ ៗ ។ សូរសព្ទនៃសត្វដំរីជាដើម បានលាន់ឮទ្រហឹងអឺងកងរំពងខ្ទៀវខ្ទា ។ គ្រានោះ ព្រះមហាសត្វ ទ្រង់បានឮសំឡេងគឹកកងនៃកងទ័ពទាំងនោះ ទ្រង់ភិតភ័យសេចក្ដីស្លាប់ថា "ឱះឱ ! បច្ចាមិត្ររបស់អញ ធ្វើឃាតព្រះបិតាអញហើយ ប្រហែលជាមករកសម្លាប់អញទៀត ទេដឹង" ទ្រង់ក៏ចាប់ព្រះនាងមទ្រីឡើងទៅលើភ្នំ គយគន់មើលទាហានទាំងនោះ យ៉ាងលប ៗ មានបន្ទូលទាំងភិតភ័យថា ៖

"នែនាងមទ្រី នាងចូរពិចារណាមើលសំឡេងគឹកកងក្នុងព្រៃយ៉ាងនេះ មានទាំងសេះអាជានេយ្យស្រែកកងរំពង ទាំងចុងទង់ជ័យក៏ប្រាកដ ។ ជនទាំងនោះ ដូចជាព្រានចោមព័ទ្ធហ្វូងម្រឹគ ក្នុងព្រៃ

ដោយបង្ហាត់ទាំងឡាយ ដេញទម្លាក់ក្នុងរណ្ដៅ ហើយចាក់កាប់សម្លាប់ ពន្ធះយកតែសាច់ល្អ ៗ នៃម្រឹគទាំងនោះ ដោយកាំបិតដ៏មុត ដោយពិត ។ ពួកយើងមិនមានទោស ត្រូវគេនិរទេសមកនៅក្នុងព្រៃ ដល់នូវសេចក្ដីវិនាសក្នុងកណ្ដាប់ដៃសត្រូវ ក៏ដូចជាម្រឹគយ៉ាងនោះដែរ នាងចូរមើលអ្នកសម្លាប់បុគ្គលខ្សោយ" ។

ព្រះនាងមទ្រីនោះ ស្ដាប់ព្រះបន្ទូលរបស់ព្រះបាទវេស្សន្តរហើយ ក៏បោលព្រះនេត្រមើលទៅទាហាននោះដែរ មើល ៗ ទៅ ក៏ប្រាកដក្នុងចិត្តថាជាក់ជាទាហានរបស់ខ្លួន ក៏មានព្រះសវនីយ៍លួងលោមព្រះមហាសត្តថា ៖

"ពួកសត្រូវមិនអាចគ្របសង្កត់ព្រះអង្គបានទេ ដូចជាភ្លើងមិនអាចគ្របសង្កត់ទឹកសមុទ្របាន សូមព្រះអង្គទ្រង់ព្រះចិន្ដាដល់ពាក្យ ដែលសក្កទេវរាជពោលហើយនោះឯងថា មិនយូរប៉ុន្មានព្រះបិតាព្រះអង្គនឹងយាងមកឆាប់ ប្ដីក៏ព្រះអង្គគិតផ្ដេសផ្ដាសអ៊ីចឹង ទំនងជាសួស្ដីនឹងមានដល់ព្រះអង្គ ព្រោះពួកពលនេះ" ។

គ្រានោះ ព្រះមហាសត្វ ដកដង្ហើមធូរ រសាយសំណោក[៧៥] បន្តិច ទ្រង់ចុះពីលើភ្នំវិញជាមួយនឹងព្រះនាងមទ្រី គង់ប្រថាប់ទៀបទ្វារបណ្ណ-សាលា ទ្រង់បានធ្វើព្រះហឫទ័យឲ្យមាំថា "យើងឈ្មោះថាបព្វជិត តើនរណានឹងធ្វើអ្វីចំពោះយើង ?" ។ ចំណែកឯព្រះនាងមទ្រីក៏គង់ប្រថាប់នៅទៀបទ្វារបណ្ណសាលារបស់ខ្លួនដែរ ។

ក្នុងខណៈនោះ ព្រះបាទសញ្ជ័យត្រាស់ហៅព្រះទេវីថា "ហៃផុស្សតីទេវី កាលបើយើងទៅព្រមទាំងអស់គ្នាតែម្តង ប្រាកដជាសេចក្តីសោកនឹងកើតខ្លាំង ខ្ញុំសូមទៅមុនចុះ បន្ទាប់មក នាងត្រូវកំណត់ថាពួកបុត្រយើងអង្គុយរំសាយសេចក្តីសោកស្តាយបានឥឡូវនេះហើយ នាងត្រូវមកព្រមទាំងបរិវារជាច្រើន បានមួយស្របក់ ជាលីនិងកណ្ហាជិនាចូរមកតាមក្រោយ" ។ ត្រាស់ដូច្នេះរួច ទ្រង់ឲ្យគេបំបែររថឆ្ពោះមុខទៅចំផ្លូវដែលមក ចាត់ចែងការរក្សាយ៉ាងហ្មត់ចត់ក្នុងទីនោះ ៗ រួចទ្រង់ចុះអំពីកដំរីដ៏ទ្រទ្រង់គ្រឿងអលង្ការ លុះយាងចុះអំពីកដំរីហើយ ទ្រង់ឧត្តរាសង្គៈ[៧៦] ឆៀងស្មាម្ខាង ផ្គងអញ្ជលី មានពួកអាមាត្យហែហមយាង

---

[៧៥] សេចក្តីសោក, សូរសព្ទយំសោក : នឹកស្តាយអាល័យណាស់ ទប់សំណោកពុំបាន ។

[៧៦] សំពត់ពានា, សំពត់បង់ក ។

ឆ្ពោះទៅកាន់សម្នាក់ព្រះរាជបុត្រដែលគង់នៅក្នុងព្រៃតែម្នាក់ឯង ។ ព្រះអង្គបានទតឃើញរាជបុត្រមានរូបគួរគ្រេកអរ សម្រឹងព្រះហឫទ័យកំពុងត្រិះរិះមិនមានភ័យអំពីទីណាមួយ ដែលគង់នៅក្នុងបណ្ណសាលានោះ ។

ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បានទតឃើញព្រះបិតានោះមានសេចក្ដីជាប់ព្រះហឫទ័យក្នុងបុត្រ កំពុងយាងមក ក៏ក្រោកទៅទទួល ថ្វាយបង្គំ ។ ចំណែកព្រះនាងមទ្រី ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសុស្សរៈដោយព្រះសិរ្ស៍ ហើយក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ខ្ញុំឈ្មោះមទ្រី ជាសុណិសារបស់ព្រះអង្គសូមថ្វាយបង្គំ ព្រះបាទទាំងគូរបស់ព្រះអង្គ" ។

ព្រះរាជបិតា ទ្រង់ឱបរឹតជនទាំងពីរនោះ ក្រសោបមកផ្អឹបនឹងទ្រូង ថើបត្រង់សីសៈ ហើយទ្រង់បបោសអង្អែលខ្នង ដោយព្រះហស្តដ៏ទន់ល្វន់ ។

ព្រះបាទសញ្ជ័យ ទ្រង់យំខ្សឹកខ្សួលភ្ញាម ៗ នោះ កាលបើសេចក្ដីសោករសាយពីចិត្តហើយ ទ្រង់បានធ្វើសេចក្ដីសំណេះសំណាល ជាមួយនឹងកូនទាំងពីរថា ៖

"នៃបុត្រ អ្នកទាំងពីរសុខសប្បាយទេឬ? នៃបុត្រ អ្នកទាំងពីរមិនមានជំងឺតម្កាត់ទេឬ? អ្នកទាំងពីរចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ? មើមឈើនិងផ្លែឈើមានច្រើនឬទេ? ។ ពួករបោមមូស ពស់ មាន តិចទេឬ? ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ?" ។

ព្រះមហាសត្តស្ដាប់ពាក្យព្រះបិតាហើយ ទ្រង់ឆ្លើយតបថា ៖

"បពិត្រព្រះសម្មតិទេព ការរស់នៅរបស់យើងខ្ញុំ ជាការរស់នៅផ្ដេសផ្ដាសទេ យើងខ្ញុំជាអ្នករស់នៅត្រដាបត្រដួស ព្រោះការរស់នៅ ដោយការស្វែងរកផលាផល ។ បពិត្រមហារាជ សេចក្ដីខ្វះខាតរមែងទូន្មានបុរសកម្សត់ ដូចជានាយសារថីទូន្មានសេះ យើងខ្ញុំទាំងនោះ ជា បុគ្គលមានសេចក្ដីខ្វះខាតទូន្មានហើយ សេចក្ដីខ្វះខាតរមែងទូន្មានយើងខ្ញុំ ។ បពិត្រមហារាជ យើងខ្ញុំត្រូវគេនិរទេសហើយមានសេចក្ដីរស់នៅ ទាំងទុក្ខសោកក្នុងព្រៃ ទាំងសាច់ឈាមទៀតសោត ក៏ស្គាំងស្គម ព្រោះមិនបានឃើញព្រះមាតាបិតា" ។

លុះទ្រង់ពោលយ៉ាងនេះហើយ ព្រះមហាសត្តទ្រង់សួរពត៌មានកូនព្រះអង្គទៀតថា ៖

"កុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាណាដែលជាទាយាទ[៧៧]ព្រះរាជនត្តារបស់ព្រះអង្គ ជាបុគ្គលប្រសើរបំផុតក្នុងដែនសិវិ មានបំណង មិនទាន់បានសម្រេចនៅឡើយ លុះអំណាចព្រាហ្មណ៍ជាបុគ្គលឃ្នោន ពានលើសលន់ វាយកុមារទាំងពីរនោះ ដូចជាគេវាយហ្វូងគោ ។ បើព្រះអង្គជ្រាបបុត្រទាំងនោះរបស់រាជបុត្រី សូមប្រាប់ដល់យើងខ្ញុំឲ្យឆាប់ ដូចជាពួកពេទ្យដែលព្យាបាលមាណពត្រូវពស់ចឹក" ។

ព្រះបាទសញ្ជ័យ ត្រាស់ថា ៖

"កុមារទាំងពីរគឺជាលីនិងកណ្ហាជិនាន៉ុះ បិតាបានប្រគល់ទ្រព្យឲ្យដល់ព្រាហ្មណ៍ លោះមកហើយ បាកុំភ័យឡើយ បាចូរស្រួលចិត្តចុះ" ។

ឮដូច្នោះ ព្រះមហាសត្វ ដកដង្ហើមធូរស្រួល ហើយបានធ្វើការសំណេះសំណាលជាមួយនឹងព្រះបិតាថា ៖

---

[៧៧] បុត្រ, បុត្រី; ញាតិ ។ អ្នកដែលត្រូវទទួលទ្រព្យសម្បាច់, ដែលត្រូវទទួលមរតក ។ អ្នកដែលបន្តវង្សត្រកូល ។

"បពិត្រព្រះបិតាព្រះអង្គសុខសប្បាយទេឬ? បពិត្រព្រះបិតា ព្រះអង្គមិនមានរោគាពាធទេឬ? បពិត្រព្រះបិតា ព្រះនេត្ររបស់ព្រះមាតានៃខ្ញុំព្រះអង្គ មិនទាន់ងងឹតទេឬ?" ។

ព្រះរាជា ឆ្លើយថា ៖

"នែបុត្រ យើងសុខសប្បាយទេ នែបុត្រ យើងមិនមានជំងឺតម្កាត់ទេ នែបុត្រ ចក្ខុមាតារបស់បា មិនទាន់ងងឹតទេ" ។

ពោធិសត្វ ពោលថា ៖

"យានរបស់ព្រះអង្គមិនទាន់ចាស់ទេឬ? វាហនៈរមែងនាំទៅបានទេឬ? ជនបទសម្បូរដែរឬ? ភ្លៀងមិនដាច់ទេឬ?" ។

ព្រះរាជា ឆ្លើយថា ៖

"យានរបស់យើងមិនទាន់ចាស់ទេ ទាំងវាហនៈក៏នាំទៅបាន ជនបទក៏សម្បូរសប្បាយ ទាំងភ្លៀងក៏បង្អុចចុះមិនដែលដាច់ទេ" ។

កាលដែលក្សត្រទាំងបីអង្គ កំពុងចរចាគ្នាយ៉ាងនេះឯង ព្រះនាងផុស្សតីទេវីកំណត់ថា "ឥឡូវ ពួកគេអង្គុយស្រាកស្រាន្តសេចក្តីសោកហើយ" រួចព្រះនាងយាងដោយព្រះបាទាឥតមានសុពណ៌បាទ ទៅសម្នាក់ព្រះរាជបុត្រ ជាមួយនឹងបរិវារជាច្រើន ។ ឯព្រះបាទវេស្សន្តរនិង

ព្រះនាងមទ្រី បានឃើញព្រះមាតានោះ ដែលមានព្រះហឫទ័យជាប់ក្នុងបុត្រ កំពុងយាងមក ក៏ក្រោកទទួលហើយថ្វាយបង្គំ ។ ចំណែកព្រះនាងមទ្រីថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមាតាក្មេកដោយព្រះសិរ្ស ក្រាបបង្គំទូលថា ៖

"បពិត្រព្រះមេម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនាងមទ្រីជាព្រះសុណិសា[៧៨] របស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមេម្ចាស់" ។

ក្នុងពេលជនទាំងនោះឈរសំពះព្រះនាងផុស្សតីទេវី ជាលីនិងនាងកណ្ហាជិនា មានកុមារកុមារិកាជាច្រើនចោមរោម ដើរមក ។ ព្រះនាងមទ្រី ឈរក្អែករំពៃមើលតែផ្លូវមក របស់បុត្រ ។ កាលព្រះនាងឃើញបុត្រមកដោយសួស្តី ព្រះនាងពុំអាចទប់ជំហរខ្លួននឹងបានឡើយ ញាប់ញ័រដូចជាស្រីមេមត់ ទនៃទឹកក្សីរក៏ហូរចេញមក ទ្រង់ព្រះកន្សែងសោយសោកអួលអាក់ ម្ទីម្ទាតម្រង់ទៅ ដូចមេគោមានកូនខ្ចី ។ រីឯកុមារទាំងពីរវិញ ដែលមកអំពីទីឆ្ងាយដោយសួស្តី បានឃើញព្រះនាងមទ្រីហើយ ក៏ទ្រង់ព្រះកន្សែងអួលអាក់ នាំគ្នាស្ទុះចូលទៅរក ដូចកូនគោតូចស្ទុះទៅរកមេ ។

---

[៧៨] កូនប្រសាស្រី; (រ. ស.) : ព្រះសុណិសា ឬ ព្រះសុណ្ហា (បុត្រីប្រសា ឬព្រះរាជបុត្រីប្រសា) ។ ព. ផ្ទ. ជាមាតា (--ជា) "កូនប្រសាប្រុស" ។ សុណ្ហា (សុន-ហា)

បានឮថា ដោយសំឡេងដ៏ខ្លាំងនោះ ព្រះនាងមទ្រីខ្សឹកខ្សួល ញ័រខ្លួន សន្ទប់បាត់ស្មារតីដួលស្តូកស្តឹងលើផែនដី ។ ចំណែកកុមារទាំងពីរដែលស្ទុះរត់មក ក៏សន្ទប់បាត់ស្មារតីដូចគ្នា ហើយពួកគេដួលពីលើព្រះមាតា ។ ក្នុងខណៈនោះ ផ្ការទឹកដោះស្រស់ពីរផ្ការ ហូរចេញអំពីស្តនទាំងគូរបស់ព្រះនាងមទ្រី ចូលក្នុងមាត់របស់កុមារទាំងនោះ ។ បានឮថា ប្រសិនបើខ្យល់ដកដង្ហើមប៉ុណ្ណោះ មិនបានមានទេ កុមារទាំងពីរមុខជាស្ងួតបេះដូងស្លាប់ដោយពិត ។ ចំណែកព្រះវេស្សន្តរ ឃើញកូនជាទីស្រឡាញ់ហើយ ក៏ពុំអាចទប់សំណោកបានដែរ ទ្រង់សន្ទប់បាត់ស្មារតីដួលចុះក្នុងទីនោះឯង ។ រីឯព្រះមាតាបិតារបស់ព្រះអង្គ ក៏សន្ទប់ដួលនៅទីនោះផងដែរ ។ សូម្បីអាមាត្យ ៦០.០០០ នាក់ ដែលកើតក្នុងថ្ងៃដំណាលព្រះអង្គ ក៏មានសភាពដូច្នោះដែរ ។ កាលដែលមហាជនមើលឃើញហេតុគួរអាណិតអាសូរនោះ ពុំមានជនណាម្នាក់អាចទប់ដំហរខ្លួនបានឡើយ ។ អាស្រមទាំងមូល ដូចព្រៃសាលវ័នត្រូវខ្យល់យុគន្ធរបក់បោកកម្ទេចកម្ទី ។ រំពេចនោះ ភ្នំលាន់ស្នូរ មហាប្រឹថពី រញ្ជួយញាប់ញ័រ មហាសមុទ្រកក្រើកក្អកក្អឹក ស្តេចភ្នំសិនេរុ ទ្រេតទន់ទោរ ។ ឆកាមាវចរសួគ៌ទេវលោក កើតការជ្រួលជ្រើមតែមួយដូចគ្នា ។

## សក្កទេវរាជប្រោសក្សត្រិយ៍ទាំង ៦ អង្គ

សក្កទេវរាជ គិតថា "ក្សត្រិយ៍ ៦ អង្គ ព្រមទាំងបរិស័ទ សន្ទប់អស់ហើយ បណ្ដាពួកគេ គ្មាននរណាមួយអាចក្រោកស្រោចស្រពទឹកលើក្បាលរបស់នរណាម្នាក់បានឡើយ អញនឹងបង្អុរភ្លៀងបោក្ខរព័ស៌ដល់ពួកគេ ឥឡូវនេះចុះ" គិតដូច្នេះ ទ្រង់ក៏ញុាំងភ្លៀងបោក្ខរពស៌ ឲ្យធ្លាក់អុរចុះ ក្នុងជំនួបក្សត្រិយ៍ទាំង ៦ អង្គ ។ ក្នុងទីនោះ ជនណាចង់សើម ពួកគេក៏សើម ថាបើមិនចង់សើមទេ តំណក់ទឹកពុំធ្លាក់ត្រូវលើគេសូម្បីតែមួយដំណក់ឡើយ ទឹកនោះបែរចេញទៅដូចទឹកកំពប់ពីស្លឹកឈូក ។ រួមមក ភ្លៀងនោះ ប្រៀបដូចជាភ្លៀងធ្លាក់ក្នុងព្រៃឈូក ។ រីឯក្សត្រិយ៍ទាំង ៦ អង្គ បានខ្យល់ដង្ហើមវិញ ។ មហាជនឃើញដូច្នោះ ក៏ស្ញើចសរសើរនូវភាពអស្ចារ្យនោះថា "អស្ចារ្យអ្វីម៉េ្លះទេ ! ចម្លែកអ្វីម៉េ្លះទេ ត្រង់ដែលភ្លៀងបោក្ខរពស៌បង្អុរចុះក្នុងញាតិសមាគមបែបនេះ មហាប្រឹថពី ក៏ក្រើកញាប់ញ័រ" ។ កាលពួកព្រះញាតិជួបជុំគ្នាហើយ សំឡេងគឹកកងខ្លាំង ក៏កើតឡើង ភ្នំទាំងឡាយក៏បន្លឺឡើង ទាំងផែនពសុធា ក៏រំភើបញាប់ញ័រ ។ ភ្លៀងក៏ញុាំងផ្គរទឹកឲ្យធ្លាក់ចុះក្នុងខណៈនោះ ព្រះបាទវេស្សន្តរ ក៏បានជួបនឹងញាតិទាំងឡាយក្នុងខណៈនោះ ។ ព្រះនត្តាទាំងពីរ ព្រះសុណិសា ព្រះរាជបុត្រ ព្រះរាជានិងព្រះទេវី បានជួបក្នុង

ទីជាមួយគ្នាក្នុងកាលណា សេចក្តីព្រឺព្រួចរោមក៏មានក្នុងកាលនោះ ពួកអ្នកនគរទាំងអស់ បានផ្គងអញ្ជលីចំពោះព្រះបាទវេស្សន្តរនោះ នាំគ្នាយំក្នុងព្រៃ មុខគួរឲ្យស្ញប់ស្ញែង ទូលអារាធនា ។ ពួករាស្ត្រទាំងអស់ ជួបជុំគ្នា បានពោលនឹងព្រះបាទវេស្សន្តរផង នឹងព្រះនាងមទ្រីផងថា ៖

"ព្រះអង្គជាព្រះរាជាឥស្សរៈរបស់ពួកយើង ព្រះបិតាព្រះអង្គមានបំណងអភិសេកព្រះអង្គក្នុងទីនេះ ហើយនាំទៅនគរវិញ សូមព្រះអង្គទាំងពីររបស់ពួកយើង ទទួលនូវស្វេតច្ឆត្រស្នងត្រកូល សោយនូវរាជសម្បត្តិ" ។

ឆខត្តិយកម្មវណ្ណនា ចប់ ។

# ជំពូកទី ១៣
## នគរកេណ្ឌាវណ្ណនា

**ព្រះវេស្សន្តរយាងចូលនគរវិញ**

*ឮដូច្នោះ ព្រះមហាសត្វ ចរចាជាមួយនឹងព្រះបិតាថា ៖*

*"ព្រះអង្គនិងពួកអ្នកជនបទអ្នកនិគម បានព្រមព្រៀងគ្នានិរទេស ខ្ញុំព្រះអង្គ ដែលកំពុងសោយរាជ្យតាមធម៌ ចាកដែនហើយ" ។*

*ពេលនោះ ព្រះរាជាសូមខមាទោសចំពោះបុត្ររបស់ខ្លួនថា ៖*

*"ម្នាលបុត្រ នេះពិតជាកំហុសរបស់យើង យើងបានធ្វើអំពើបំផ្លិច បំផ្លាញសេចក្ដីចម្រើន បាននិរទេសបាដែលមិនមានកំហុស ព្រោះតែជឿតាមពាក្យពួកអ្នកសិវិរាស្ត្រ" ។*

*លុះពោលដូច្នេះហើយ ព្រះរាជាស្នើសូមបុត្រដើម្បីដោះទុក្ខរបស់ខ្លួន ថា ៖*

*"កូនគួរដោះទុក្ខរបស់បិតាមាតា ឬរបស់បងប្អូនស្រី ដោយហេតុ ណាទីមួយ សូម្បីដោយជីវិតរបស់ខ្លួន ដូច្នោះ កូនកុំទុកកំហុស របស់បិតាក្នុងហឫទ័យឡើយ ចូរធ្វើតាមពាក្យរបស់ឪពុក ចូរដោះ ភេទឥសីនេះចេញ កាន់ភេទជាស្ដេចផែនដីវិញចុះ" ។*

ព្រះពោធិសត្វ ក៏ទ្រង់សព្វព្រះរាជហឫទ័យសោយរាជ្យដែរ ទ្រង់បានពោលថា "ត្រឹមតែហេតុប៉ុណ្ណោះ មិនចាំបាច់និយាយទេ ដ្បិតមិនមានសភាពធ្ងន់ធ្ងរឡើយ" ។ ព្រះមហាសត្វ ទទួលថា "ប្រពៃណាស់"។ គ្រានោះ អាមាត្យសហជាត ៦០.០០០ នាក់ ដឹងច្បាស់ការយល់ព្រមរបស់ព្រះអង្គ ក៏នាំគ្នាពោលឡើងថា "បពិត្រមហារាជ កាលនេះជាកាលគួរស្រង់ទឹក សូមទ្រង់ដុសជម្រះព្រះរជោជលៈ" ។ គ្រានោះ ព្រះមហាសត្វប្រាប់ពួកគេថា "ចូរអ្នកទាំងឡាយ រង់ចាំបន្តិចសិន" រួចទ្រង់ចូលទៅបណ្ណសាលា ដោះគ្រឿងឥសី រៀបចំទុកដាក់ ហើយស្លៀកសាដកពណ៌ស ចេញអំពីបណ្ណសាលា ដើរប្រទក្សិណបណ្ណសាលា៣ជុំ ពោលថា "នេះ ជាកន្លែងដែលអញរស់នៅ ៩ ខែកន្លះ ធ្វើសមណធម៌ អញបានឲ្យទានដោយជំនឿថាជាកំពូលនៃបារមី ញ៉ាំងផែនដីឲ្យរញ្ជួយញាប់ញ័រ" លុះពោលដូច្នេះ ព្រះអង្គថ្វាយបង្គំនូវបណ្ណសាលាដោយបញ្ចប្រតិស្ឋ រួចទ្រង់ឈរ ។ គ្រានោះ ខ្មាន់ព្រះកេសជាដើម បានធ្វើកេសមស្សុកម្មជាដើម ។ គ្រានោះ ព្រះបាទវេស្សន្តរ ក៏ដុសជម្រះក្អែល លុះដុសជម្រះក្អែលហើយ បានទ្រទ្រង់ព្រះពស្ត្រមានពណ៌ ដូច

សន្ធ ពួកគេបានអភិសេកព្រះអង្គ ដែលប្រដាប់អាភរណៈទាំងពួង រុង
រឿងបីដូចទេវរាជ ក្នុងរាជសម្បត្តិ ។

ក្នុងពេលនោះ ព្រះវេស្សន្តរទ្រង់មានយសធំឡើងវិញ ។ កន្លែង
ដែលទ្រង់ទតទៅ តែងកក្រើកញាប់ញ័រ ។ ជនទាំងឡាយ អ្នកមានមាត់
ជាមង្គល ក៏ប្រកាសនូវមង្គលយ៉ាងរត់មាត់ និងបានប្រគំសព្វតូរ្យតន្ត្រី
ដ៏ពីរោះល្វេងល្វើយ ។ សំឡេងក្រាងក្រអៅនៃតូរ្យតន្ត្រីលាន់ឮទៅ ដូច
សំឡេងមេឃគ្រហឹមក្នុងផ្ទៃមហាសមុទ្រ ។ ពួកអាមាត្យ តុបតែងដំរី
កែវ នាំបង្អោនចូលមក។ ព្រះវេស្សន្តរសៀតព្រះខាន់កែវដែលដុតកម្តៅ
សត្រូវ ហើយទ្រង់ឡើងគង់លើដំរីដ៏ប្រសើរឈ្មោះបច្ច័យ ដែលកើតក្នុង
ថ្ងៃដំណាលព្រះអង្គនោះ ។ រំពេចនោះ អាមាត្យសហជាត ៦០.០០០
នាក់ ដែល មានខ្លួនប្រដាប់ដោយអលង្ការទាំងពួងស្រាប់ហើយ បាននាំ
គ្នាចោមរោមព្រះអង្គ ញ៉ាំងឲ្យរីករាយ ។ កញ្ញាទាំងពួងទាំងឡាយ
អញ្ជើញព្រះនាងមទ្រីឲ្យងូតទឹក រួចតុបតែងខ្លួនថ្វាយហើយអភិសេក ។
ពួកគេបានស្រោច នូវទឹកអភិសេក លើព្រះសិរ្សរបស់នាង បានពោល
ពាក្យមង្គលថា ៖

"សូមព្រះបាទវេស្សន្តរ និងជាលីកណ្ហាជិនាទាំងពីរ បីបាច់ថែរក្សាព្រះនាង ទាំងមហារាជព្រះនាមសញ្ជ័យក៏សូមឲ្យថែរក្សាព្រះនាងដែរ" ។

## ព្រះនាងមទ្រីជូនពរដល់រាជបុត្ររាជធីតា

ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បានទូវទីពឹងនេះ បានតម្កល់ក្នុងរាជសម្បត្តិ ហើយភ្នករលឹក នូវសេចក្តីសៅហ្មងរបស់ព្រះអង្គដែលទ្រង់ធ្លាប់នៅក្នុងព្រៃពីដើម ក៏ទ្រង់ឲ្យទូងអានន្ទីយភេរីត្រាច់ទៅទៀបភ្នំវង្កត ដែលគួរជាទីរីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈបានទីពឹងនេះហើយ ក៏ភ្នករលឹក នូវសេចក្តីសៅហ្មងរបស់ព្រះនាង ដែលធ្លាប់នៅក្នុងព្រៃពីដើម បានជួបនឹងបុត្រទាំងពីរហើយត្រេកអររីករាយ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈ បានទីពឹងនេះហើយ ក៏មានព្រះហឫទ័យភ្នករលឹកសេចក្តីសៅហ្មងរបស់ព្រះនាង ដែលធ្លាប់នៅក្នុងព្រៃពីដើម មានចិត្តត្រេកអររីករាយជាមួយនឹងបុត្រទាំងពីរ ។

លុះព្រះនាងមានសោមនស្សរីករាយយ៉ាងនេះហើយ ទ្រង់មានព្រះសវនីយ៍បុត្រទាំងពីរថា ៖

"នៃបុត្រទាំងពីរ កាលពីដើម មាតាបរិភោគភត្តតែមួយពេល ដេក ផ្ទាល់នឹងដីជានិច្ច មាតាប្រព្រឹត្តវត្តប្រតិបត្តិបែបនេះ ព្រោះមាតា ប្រាថ្នាចង់ជួបនឹងបាទាំងពីរ ។ ម្នាលបុត្រទាំងពីរ វត្តប្រតិបត្តិនោះ សម្រេចដល់មាតាក្នុងថ្ងៃនេះហើយ ព្រោះមាតាបានជួបនឹងបា ទាំងពីរ ។ ម្នាលបុត្រទាំងពីរ សូមឲ្យបុណ្យដែលកើតអំពីមាតា និងបិតា រក្សាបាទាំងពីរ ទាំងមហារាជព្រះនាមសញ្ជ័យ ក៏សូមឲ្យ រក្សាបាទាំងពីរផង ។ បុណ្យឯណានីមួយដែលមាតាក្តី បិតាក្តី របស់បាបានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមបាទាំង ពីរកុំចាស់ កុំស្លាប់ឡើយ" ។

## តទ្វាយថ្វាយព្រះនាងមទ្រី

រីឯព្រះនាងផុស្សតីទេវី គិតថា "តាំងពីគ្រានេះទៅ ចូរបុត្រី ប្រសាររបស់ អញ ស្លៀកសំពត់ទាំងនេះ ទ្រទ្រង់គ្រឿងអាភរណៈទាំងនេះ" គិតរួច ព្រះនាងបានបញ្ជូនកប្បាសិកពស្ត្រ កោសេយ្យពស្ត្រ ខោមពស្ត្រ និង កោទុម្ពរពស្ត្រ ទៅថ្វាយព្រះសុណ្ហា ដែលជាសំពត់សម្រាប់លម្អព្រះ នាងមទ្រី ។ លំដាប់តមក ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសុវណ្ណ ជាវិការៈនៃមាស និងគ្រឿងប្រដាប់ព្រះសុវណ្ណ ជាវិការៈនៃកែវ ទៅថ្វាយ ព្រះសុណ្ហា ។ លំដាប់តមកទៀត ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់

ព្រះសុវណ្ណ ជាវិការៈនៃមាស និងកន្ទ្រំនិងខ្សែក្រវាត់ជាវិការៈនៃកែវមណី ទៅថ្វាយព្រះសុណ្ហា ។ ព្រះសស្សុ បានបញ្ជូនគ្រឿងប្រដាប់នលាដៈ ជាគ្រឿងប្រដាប់សម្រាប់ព្រះភក្ត្រមានពណ៌ផ្សេង ៗ ដែលជាវិការៈនៃ កែវមណី ទៅថ្វាយព្រះសុណ្ហា ។ ព្រះសស្សុ បានបញ្ជូនទូវគ្រឿង ប្រដាប់សម្រាប់ព្រះស្តន និងគ្រឿងប្រដាប់ស្មា និងខ្សែក្រវាត់ កងជើង ទៅថ្វាយព្រះសុណ្ហា ។ ព្រះរាជបុត្រីជាស្ត្រីប្រសើរ បានគយគន់មើល គ្រឿងប្រដាប់ល្បើកដោយអំបោះ និងគ្រឿងប្រដាប់វៀរចាកអំបោះ ដ៏ ល្អក្រៃពេក ហាក់ដូចទេវកញ្ញាក្នុងនន្ទនឧទ្យាន ។ ព្រះរាជបុត្រី កក់ព្រះ សិរ្ស មានព្រះពស្ត្រដ៏ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ដ៏ល្អ ក្រៃពេក ហាក់ដូចស្ត្រីអប្សរក្នុងឋានត្រៃត្រិង្ស ។ ព្រះរាជបុត្រីបរិបូណ៌ ដោយរបៀបនៃចិញ្ចាញច្នេញល្អក្រៃពេក ហាក់ដូចដើមចេកដែលកើត ក្នុងចិត្តលតាវ័ន ត្រូវខ្យល់បក់បោកហើយ ។ ព្រះរាជបុត្រី មានបបូរ មាត់ដូចផ្លែជ្រៃទុំ និងផ្លែបាសទុំល្អក្រៃពេក ហាក់ដូចបក្សីមានសរីរៈ សព្វគ្រប់ដូចជាសរីរៈនៃមនុស្សមានស្លាបដ៏វិចិត្រហើរឰដ៏អាកាស ។

អាមាត្យ ៦០.០០០ នាក់ បាននាំមកថ្វាយព្រះនាងមទ្រី នូវដំរី ស្រឡាងមួយ ជាសត្វធន់នឹងការប្រហារដោយលំពែងឬសរ មានភ្លុកង

ទន្ទាំ អាចគាស់រំលើងសត្រូវបាន មិនចាស់ពេក ស្អិតស្អាងដោយ អលង្ការទាំងពួង ប្រយោជន៍ដើម្បីជាយានជំនិះរបស់ព្រះនាងមទ្រី ។ ព្រះនាងមទ្រី ឡើងកាន់ដំរីដ៏ប្រសើរ ដែលមិនចាស់ពេក អត់ទ្រាំ លំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុកងទន្ទាំ អាចគាស់រំលើងសត្រូវ បាននោះ ។

## ព្រះបាទសញ្ជ័យត្រាច់ប្រពាតព្រៃ

ក្សត្រិយ៍ទាំងពីរអង្គនោះ បានយាងទៅកាន់បន្ទាយកងទ័ពដោយ មានយសដ៏ធំ ។ ព្រះបាទសញ្ជ័យ ទ្រង់ត្រាច់ប្រពាតភ្នំ ប្រពាតព្រៃអស់ កន្លះខែ ជាមួយនឹងជន ១២ អក្ខោភិណី ។ ដោយតេជះរបស់ព្រះមហា-សត្វ ពុំមានម្រឹគកាច ឬបក្សីណាមួយ បៀតបៀនជនណាម្នាក់ ក្នុងព្រៃ ដ៏សែនធំនោះឡើយ ។ ពួកម្រឹគនិងពួកបស្សីទាំងប៉ុន្មាន ដែលមាននៅ ក្នុងព្រៃទាំងអស់នុ៎ះ មិនបៀតបៀនគ្នានឹងគ្នា ដោយតេជះនៃព្រះបាទ វេស្សន្តរ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ យាងចេញអំពីព្រៃ ពួកម្រឹគនិងពួកបក្សីទាំងប៉ុន្មាន ដែលមាននៅក្នុង ព្រៃទាំងអស់នុ៎ះ បានមកប្រជុំគ្នាក្នុងទីជាមួយគ្នា លែងស្រែកសំឡេង ពីរោះ ។

ព្រះសញ្ជយនរិន្ទ លុះត្រាច់ប្រពាតភ្នំប្រពាតព្រៃកន្លះខែហើយ ទ្រង់បានឲ្យគេទៅអញ្ជើញ នូវលោកសេនាបតីមកសាកសួរថា "នែអ្នក យើងនៅក្នុងព្រៃយូរហើយ តើផ្លូវជាទីទៅរបស់កូនយើង អ្នកតុបតែង លម្អរួចរាល់ហើយឬ" ។ សេនាបតីឆ្លើយថា "ព្រះករុណាថ្លៃវិសេស ព្រះសម្មតិទេព ឥឡូវដល់កាលដែលព្រះអង្គត្រូវយាងទៅហើយ ក្រាបទូល" ។ ព្រះរាជាសញ្ជ័យ ឲ្យគេទៅថ្វាយដំណឹងដល់ព្រះបាទវេស្សន្តររួចនាំសេនាចេញដំណើរទៅ ។ ផ្លូវដើរ ត្រូវបានតុបតែងយ៉ាងស្អាតរាប់ពីជេតុត្តរនគរមក មានចម្ងាយ ៦០ យោជន៍ ព្រះមហាសត្តបានដើរផ្លូវជាមួយនឹងបរិវារជាច្រើន ។ ពួកអាមាត្យបានរៀបចំរាជមាគ៌ា ឲ្យរំលេចធ្មុះធ្មាស់ ត្រៀបត្រា ដោយផ្កា តាំងអំពីទីដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ រហូតដល់ក្រុងជេតុត្តរ ។ លំដាប់នោះ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រ ឲ្យចម្រើន ទ្រង់យាងចេញអំពីព្រៃ ពួកយោធាទាំង ៦០.០០០ ដ៏ល្អមើល ពួកស្រីស្នំផង ពួករាជកុមារផង ពួកអ្នកជំនួញផង ពួកព្រាហ្មណ៍ផង ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ពួកអ្នកជនបទ ពួកអ្នកនិគម ក៏បានមកជួបជុំគ្នាហែហមជុំវិញ ។

ពួកទាហានពាក់មួក ទ្រទ្រង់ខែល កាន់ធ្នូ ចងគ្រឿងក្រោះដ៏ល្អ ដើរហែខាងមុខ ។

ព្រះរាជា យាងផ្លូវ ៦០ យោជន៍ អស់រយៈពេល ២ ខែ ទើបបានដល់ជេតុត្តរនគរ រួចទ្រង់ចូលទៅកាន់នគរដ៏ស្រស់ស្អាត ហើយឡើងកាន់ប្រាសាទ ។ ក្សត្រិយ៍ទាំងនោះ បានយាងចូលទៅកាន់បុរី ជាក្រុងគួរឲ្យត្រេកអរ មានកំពែងនិងទ្វារខាងក្រៅដ៏ច្រើន ប្រកបដោយគ្រឿងស៊ីនិងគ្រឿងផឹក មានទាំងល្បែងពីរយ៉ាង គឺរាំនិងច្រៀង ។ កាលរាជកុមារញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ស្តេចមកដល់ ពួកអ្នកជនបទ និងពួកអ្នកនិគម បានមកជួបជុំគ្នា ត្រេកអរ ។ ពួកមហាជន ក៏នាំគ្នាលើកទង់ជ័យ ទូងនន្ទិភេរី ចូលទៅព្រះនគរ ។ ព្រះបាទវេស្សន្តរ ក៏ទ្រង់ឲ្យឃោសនាដោះលែងសព្វសត្វចាកចំណង ។

## ព្រះវេស្សន្តរច្យុតទៅកើតនៅឋានតុសិត

ក្នុងកាលជិតភ្លឺក្នុងថ្ងៃចូលកាន់ព្រះនគរនោះឯងព្រះបាទវេស្សន្តរគិតថា "នាកាលរាត្រីភ្លឺច្បាស់ ស្មូមទាំងឡាយឮដំណឹងថាអញមកប្រាកដជាពួកគេមកពុំខាន តើអញនឹងឲ្យអ្វីដល់ពួកគេ" ។ រំពេចនោះភពរបស់សក្កទេវរាជ បានបង្ហាញអាការក្តៅធ្លួលឡើង ។ ព្រះអង្គទ្រង់ធ្វើអាវជ្ជនាការទៅ ជ្រាបច្បាស់នូវហេតុការណ៍នោះព្រះអង្គក៏បណ្តាល

ឫទ្ធិធ្វើមេឃស្មើរឡើងជុំអពួ បង្អុរចុះមួយរំពេចនូវភ្លៀងរតនៈ ៧ ប្រការ ខាងមុខឬខាងក្រោយនៃព្រះរាជនិវេសន៍ប្រមាណត្រឹមចង្កេះទូទៅទាំងនគរ ប្រមាណត្រឹមជង្គង់ ។ ព្រឹកឡើង ព្រះមហាសត្វ ប្រកាសថា "ទ្រព្យដែលធ្លាក់ចុះ ក្នុងខាងមុខឬខាងក្រោយត្រកូលណា ចូរជារបស់ត្រកូលនោះចុះ" រួចទ្រង់ឲ្យគេនាំទ្រព្យសេសសល់មកដាក់ក្នុងឃ្លាំង រួមទាំងទ្រព្យ ដែលធ្លាក់ក្នុងរាជដំណាក់របស់ព្រះអង្គ ហើយព្រះអង្គតាំងការឲ្យទានជាធំ ទៅថ្ងៃមុខទៀត ។ ព្រះបាទវេស្សន្តរជាក្សត្រិយ៍ប្រកបដោយប្រាជ្ញា ទ្រង់ឲ្យទាន លុះបែកធ្លាយរាងកាយនោះទៅ ក៏បានស្តេចទៅកើតក្នុងឋានសួគ៌តុសិតបុរីទេវលោក" ។

នគរកណ្ឌវណ្ណនា ចប់ ។

## ព្រះសាស្តាប្រជុំជាតក

*លុះបរិយាយនូវធម្មទេសនាមហាវេស្សន្តរជាតក ប្រដាប់ដោយគាថា ១.០០០ នេះហើយ ទ្រង់បានប្រជុំជាតកថា ៖*

"តទា ជូជកោ ទេវទត្តោ អហោសិ, អមិត្តតាបនា ចិញ្ចមាណវិកា, ចេតបុត្តោ ឆន្នោ, អច្ចុតតាបសោ សារិបុត្តោ, សក្កោ អនុរុទ្ធោ, សញ្ជយនរិន្ទោ សុទ្ធោទនមហារាជា, ផុស្សតី ទេវី សិរិមហាមាយា, មទ្ទី ទេវី រាហុលមាតា, ជាលិកុមារោ រាហុលោ, កណ្ហាជិនា ឧប្បលវណ្ណា, សេសបរិសា ពុទ្ធបរិសា, មហាវេស្សន្តរោ រាជា បន អហមេវ សម្មាសម្ពុទ្ធោ អហោសិំ"។

- *ជូជកគ្រានោះ បានមកជាទេវទត្ត*
- *អមិត្តតាបនា បានមកជាចិញ្ចមាណវិកា*
- *ចេតបុត្រ បានមកជាឆន្នៈ*
- *អច្ចុតតាបស បានមកជាសារិបុត្រ*
- *សក្កទេវរាជ បានមកជាអនុរុទ្ធ*

- ព្រះបាទសញ្ជ័យ បានមកជាសុទ្ធោទនមហារាជ
- ផុស្សតីទេវី បានមកជា សិរិមហាមាយា
- មទ្រីទេវី បានមកជា រាហុលមាតា
- ជាលិកុមារ បានមកជា រាហុល
- កណ្ហាជិនា បានមកជា ឧប្បលវណ្ណា
- បរិស័ទដ៏សេស បានមកជាពុទ្ធបរិស័ទ
- មហាវេស្សន្តរ បានមកជាអញតថាគតសម្មាសម្ពុទ្ធនេះឯង ។

វេស្សន្តរជាតកពិស្តារ ចប់តែប៉ុណ្ណេះ ។



នេះកាលរុក្ខទេវតាកាឡាខ្លួនជាព្រះបាទវេស្សន្តរ
និងនាងមេទ្រីមកថ្នាក់ថ្នមជាលី និងនាងក្រឹស្នា

ISBN 9789996341038

9 789996 341038

PUC Press